សព្វំ រដ្ឋំ សុខំ សេតិ រាជា ចេ ហោតិ ធម្មិកោ ។
មហារុក្ខស្ស ផលិនោ អាមំ ឆិន្ទតិ យោ ផលំ
រសញ្ចស្ស ន ជានាតិ ពីជញ្ចស្ស វិនស្សតិ ។



ព្រោះហេតុតែភ្លៀង បង្អុរចុះផង ទាំងទឹកសន្សើម ក៏ចម្រើនឡើយ ។ ផង ព្រោះដំណាំសន្ទូងទាំងឡាយ ល្អគួរណាស់ល្អ ទាំងផលដែល ក៏ព្រះរាជាទ្រង់គ្រង អស់កាលជាអង្វែងផង ។ កាលពួកគោ ក៏កំពុងឆ្លងទៅ ( កន្លែងណាមួយ ) បើគោធំទៅវៀច កាលបើគោធំ នាំពួកគោទៅវៀច មេគោទាំងអស់នោះក៏ទៅវៀច ។ បណ្ដាពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណាដែលពួកជនសន្មតថា ប្រសើរផុត បើបុគ្គលនោះប្រព្រឹត្តអធម៌ហើយ មិនចាំបាច់និយាយថ្វី ដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ អ្នកដែនទាំងអស់ក៏ដេកជាទុក្ខ ។ កាលពួកគោ ក៏កំពុងឆ្លងទៅ បើគោធំទៅត្រង់ កាលបើគោធំនាំគេទៅត្រង់ មេគោទាំងអស់នោះក៏ទៅត្រង់ ។ ពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណាដែលពួកជនសន្មតថា ប្រសើរផុត ប្រសិនបើ បុគ្គលនោះប្រព្រឹត្តធម៌ មិនចាំបាច់និយាយថ្វី ដល់ប្រជាជនក្រៅនេះ បើព្រះរាជាប្រកបដោយធម៌ អ្នកដែនទាំងអស់ក៏ដេកជាសុខ ។ បុគ្គលណា បេះផ្លែខ្ចី នៃឈើធំដែលមានផ្លែ ( បុគ្គលនោះ ) រមែងមិនដឹងនូវរស នៃផ្លែឈើនោះផង ទាំងពូជ នៃផ្លែឈើនោះ ក៏វិនាសទៅផង ។

មហារុក្ខូបមំ រដ្ឋំ  អធម្មេន(យោ)បសាសតិ
រសញ្ចស្ស ន ជានាតិ  រដ្ឋញ្ចស្ស វិនស្សតិ ។
មហារុក្ខស្ស ផលិនោ  បក្កំ ឆិន្ទតិ យោ ផលំ
រសញ្ចស្ស វិជានាតិ  ពីជញ្ចស្ស ន នស្សតិ ។
មហារុក្ខូបមំ រដ្ឋំ  ធម្មេន យោ បសាសតិ
រសញ្ចស្ស វិជានាតិ  រដ្ឋញ្ចស្ស ន នស្សតិ ។
យោ ច រាជា ជនបទំ  អធម្មេន បសាសតិ
សព្វោសធីហិ សោ រាជា  វិរុទ្ធោ ហោតិ ខត្តិយោ ។
តថេវ នេគមេ ហឹសំ  យេ យុត្តា កយវិក្កយេ
ឱជទានពលីការេ  ស កោសេន វិរុជ្ឈតិ ។
បហារវរខេត្តញ្ញូ  សង្គាមេ កតនិស្សមេ
ឧស្សិតេ ហឹសយំ រាជា  ស ពលេន វិរុជ្ឈតិ ។



ព្រះរាជាណាគ្រប់គ្រងផែនដីដែលប្រៀបដូចដើមឈើធំ ដោយអធម៌ (ព្រះរាជានោះ) ឈ្មោះថា មិនស្គាល់នូវរសរបស់ផែនដីនោះផង ផែនដីរបស់ព្រះរាជានោះក៏វិនាសផង ។ បុគ្គលណាបេះផ្លែឈើទុំពីដើមឈើធំ ដែលមានផ្លែ បុគ្គលនោះរមែងដឹងនូវរសនៃផ្លែឈើនោះផង ពូជរបស់ផ្លែឈើនោះក៏មិនវិនាសផង ។ ព្រះរាជាណាគ្រប់គ្រងផែនដី ដែលប្រៀបដូចជាដើមឈើធំដោយធម៌ (ព្រះរាជានោះ) ឈ្មោះថាបានស្គាល់នូវរសរបស់ផែនដីនោះផង ផែនដីរបស់ព្រះរាជានោះក៏មិនវិនាសផង ។ ព្រះរាជាណាមួយ គ្រប់គ្រងជនបទដោយអធម៌ (ល្មើសច្បាប់) ព្រះរាជាជាក្សត្រិយ៍នោះ ឈ្មោះថា សាបសូន្យចាកដើមឈើ ដែលត្រូវជាឱសថទាំងអស់ ។ មួយវិញទៀត (ព្រះរាជាក្សត្រណា) បៀតបៀនពួកអ្នកនិគម ដែលនៅក្នុងនិគម (ផង) បៀតបៀនពួកពាណិជដែលប្រកបក្នុងការលក់ដូរទំនិញ ជាអ្នកនាំទំនិញថ្វាយពន្ធដារ និងពលិការ (ផង) ព្រះរាជានោះ ឈ្មោះថាសាបសូន្យចាកឃ្លាំង ។ ព្រះរាជាណា បៀតបៀនខ្មាន់ធ្នូ ដែលជាអ្នកដឹងនូវកន្លែងដ៏ប្រសើរ ដែលគួរប្រហារ និងពួកទាហានធំ ដែលជាអ្នកពិចារណាការធ្វើការក្នុងសង្គ្រាម និងមហាមាត្យដែលមានសក្តិ ។ ព្រះរាជានោះ ឈ្មោះថា សាបសូន្យចាកពល ។

ឆាដេវ សំសយោ ហាសំ  សំសារេ ព្រហ្មចារិយេ
អជម្មចារី ទត្តិយោ  សោ សត្ថេ វិរុជ្ឈតិ ។
យោ ច ភជា អធម្មេស្វា  ករិយំ ហត្ថិ អត្តសម្ភំ
លទ្ធិំ បសវតេ ហាធំ  បុត្តហំ ច វិរុជ្ឈតិ ។
ធម្មំ ចរេ ជាចបដេ  ទេគមេសុ ពលេសុ ច
សំសយោ ចន ហាសេយ្យ  បុត្តទារេ សមត្យេ ។
ស តាធិសោ ភូមិបតិ  រដ្ឋបាលោ អកោធនោ
សាមន្តេ សម្បកម្បេតិ  សក្កោ អសុរាធិបោតិ ។

មហាកោដ្ឋិតកំ តតិយំ ។

## តស្សុទ្ទានំ

សង្កេប្បចិត្តេម្បូយនោ  បបមោ
ទុតិយោ បច សន្ទម្ពនថ្ងៃកេ
តតិយោ បច ពោធិសិរិត្ថយនោ
តាប៊តា បច គីណា ជិនេជ សុភា ។

បញ្ហាសន្និបាតំ និដ្ឋិតំ ។





ក្បួនក្រលាប្រព្រឹត្តនូវអធម៌ បៀតបៀនពួកសប្បុរសជ្រើស ប្រព្រឹត្ត
ធម៌ដ៏ប្រសើរ ដូចជាបៀតបៀនខ្លួនពួកអ្នកនិគមម្ចាស់ក្បួនក្រុមនោះ
ឈ្មោះថា សាបសូន្យតាមហេតុ ។ មួយទៀត ព្រះរាជា
ណាមិនបំពេញនូវធម៌ សម្លាប់គុណរបស់ដែលជាអ្នកមិនប្រទូស្ត
ព្រះរាជានោះឈ្មោះថាបានជួបប្រទះនូវហេតុដ៏អាក្រក់ផង ឈ្មោះ
ជាសាបសូន្យតាមខ្លួនទាំងឡាយផង ។ ព្រះរាជាត្រូវតែប្រព្រឹត្តធម៌
ផង មិនត្រូវបៀតបៀនអ្នកដែលបានទីអ្នកនិគមផង ពួកពល
ផង ពួកសេនាផង គប្បីប្រព្រឹត្តស្មោះស្មើចំពោះកូនទីប្រពន្ធផង ។
ព្រះរាជានោះ ទើបឈ្មោះថាជាម្ចាស់នៃផែនដី ឈ្មោះថា អ្នក
គ្រប់គ្រងនូវផែន ឈ្មោះថាជាអ្នកមិនក្រោធ រមែងញុំាងពួកអ្នក
ដែលនៅជាប់ទ្បៀតឲ្យញាប់ញ័រ ដូចព្រះឥន្ទជាធំជាងអសុរ ។

ចប់ មហាកោដ្ឋិតក ទី ៣ ។

## ឧទ្ទាននៃបញ្ហាសន្និបាតនោះគឺ

និទ្ទេសទី ១ ប្រកបដោយនាទីកំពង់ព្រះនាម នទ្យទិកា ១
និទ្ទេសទី ២ ប្រកបដោយសង្ខិការឈ្មោះម្ចាស់ខ្លួនដ៏ប្រសើរ ១
និទ្ទេសទី ៣ ប្រកបដោយគយសមានសេរីឈ្មោះ ពោធិ ១
និទ្ទេសទាំង៣ដ៏ល្អ(នេះ) ព្រះជិនស្រីប្រទានសំដែងទុកមកហើយ ។

ចប់ បញ្ហាសន្និបាត ។

## សត្តិនិបាតេ បឋមំ សោណកជាតកំ

## សត្តិនិបាតជាតកំ

## សោណកជាតកំ

(១)

(៦៦) កស្ស សុត្វា សតំ ទម្មិ សហស្សំ ទិដ្ឋ សោណកំ
កោ មេ សោណកមក្ខាតិ សហាយំ បំសុកីឡិតំ។
អថ ព្រវិ មាណវកោ ទហរោ បញ្ចចូឡកោ
មយ្ហំ សុត្វា សតំ ទេហិ សហស្សំ ទិដ្ឋ សោណកំ
អហំ តេ សោណកមក្ខិស្សំ សហាយំ បំសុកីឡិតំ។

(៦៧) កតរស្មឹ សោ ជនបទេ រដ្ឋេសុ និគមេសុ ច
កត្ថ សោណកមទ្ទក្ខិ(២) តំ មេ អក្ខាហិ បុច្ឆិតោ។

(៦៨) តវេវ ទេវ វិជិតេ តវេវុយ្យានភូមិយា
ឧជុវំសា មហាសាលា នីលោភាសា មនោរមា។
តិដ្ឋន្តិ មេឃសមានា រម្មា អញ្ញោញ្ញនិស្សិតា

១ ម. កស្ស ។ ២ ម. កត្ថ មេ សោណកោ ទិដ្ឋោ ។

## សត្តិនិបាត សោណកជាតក ទី ១

## សត្តិនិបាតជាតក

## សោណកជាតក

(៦៦) (ព្រះរាជាព្រះនាមអរិន្ទមៈ ទ្រង់ត្រាស់ថា) អ្នកណាបានឮ អញនឹងឲ្យទ្រព្យមួយរយ អ្នកណាបានឃើញសោណកៈ អញនឹងឲ្យទ្រព្យមួយពាន់ អ្នកណានឹងប្រាប់អញនូវសោណកៈជាសំឡាញ់ ដែលលេងដីជាមួយគ្នា ។

(អភិសម្ពុទ្ធគាថា) គ្រានោះ មាណពកុមារមានសុក ៥ បានក្រាបបង្គំទូលថា ទូលព្រះបង្គំជាខ្ញុំបានឮ សូមព្រះអង្គប្រទានទ្រព្យមួយរយ ទូលព្រះបង្គំជាខ្ញុំបានឃើញសោណកៈ សូមព្រះអង្គប្រទានទ្រព្យមួយពាន់ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលថ្វាយព្រះអង្គ នូវសោណកៈជាសំឡាញ់ ដែលលេងដីជាមួយគ្នា ។

(៦៧) (ព្រះរាជា...) សោណកៈនោះ នៅក្នុងជនបទណា ក្នុងដែនណា ក្នុងនិគមណា ឯងបានឃើញសោណកៈ ក្នុងទីណា អញសួរហើយ ឯងចូរប្រាប់នូវសោណកៈនោះ ។

(៦៨) (កុមារ...) បពិត្រព្រះសម្មតិទេព ត្រង់ទីឧទ្យានរបស់ព្រះអង្គ ក្នុងដែនរបស់ព្រះអង្គហ្នឹងឯង មានពួកឈើធំ មានដើមត្រង់ មានពន្លឺខៀវ ជាគ្រឿងរីករាយនៃចិត្ត ពួកឈើទាំងនោះ មានពណ៌ដូចពពកមេឃ គួរឲ្យត្រេកអរ ផ្ទុកទាក់ទងគ្នាទៅវិញទៅមក

ទេសំ មូលស្មិំ សោណកោ ឈាយតិ អនុបាទនោ

ឌយ្ហមានេសុ លោកេសុ ឌយ្ហមានេសុ និព្វុតោ ។

(៦៩)តតោ ច រាជា បាយាសិ សេនាយ ចតុរង្គិយា

ការាបេត្វា សមំ មគ្គំ អគមា យេន សោណកោ ។

ឧយ្យានភូមិំ គន្ត្វាន វិចរន្តោ ព្រហាវនេ

អាសីនំ សោណកំ ទក្ខិ ឌយ្ហមានេសុ និព្វុតំ ។

(៧០)កបណោ វតាយំ ភិក្ខុ មុណ្ឌោ សង្ឃាដិបារុតោ

អមាតិកោ អបិតិកោ រុក្ខមូលស្មិំ ឈាយតិ ។

(៧១)ឥមំ វាក្យំ និសាមេត្វា សោណកោ ឯតទព្រវិ

ន រាជ កបណោ ហោតិ ធម្មំ កាយេន ផស្សយំ ។

យោ ច ធម្មំ និរង្កត្វា អធម្មំ អនុវត្តតិ

ស រាជ កបណោ ហោតិ បាបោ បាបបរាយនោ ។



កាលពួកសត្វលោកមានភ្លើងឆេះ កំពុងតែក្តៅក្រហាយនេះ សោណកៈ មិនមានភ្លើងឆេះ ជាបុគ្គលរលត់ហើយ កំពុងចំរើនឈានជិតគល់ឈើពីរនោះ ។

(៦៩) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រះរាជាទ្រង់ប្រើបំរើឲ្យតាក់តែងផ្លូវរាបស្មើ យាងចេញទៅដោយសេនាមានអង្គ៤ សំដៅទៅរកទីកន្លែងដែលព្រះបច្ចេកពុទ្ធព្រះនាមសោណកៈគង់នៅ ។ លុះព្រះរាជាទ្រង់យាងទៅដល់ទីឧទ្យានហើយ ទ្រង់ត្រាច់ទៅក្នុងព្រៃធំ បានទតឃើញព្រះសោណកបច្ចេកពុទ្ធ កាលដែលពួកសត្វលោកកំពុងក្តៅក្រហាយនេះ លោកជាបុគ្គលរលត់ភ្លើងនៅហើយ ។

(៧០) (ព្រះរាជា...) ភិក្ខុត្រងោលដណ្តប់សង្ឃាដិ មិនមានមាតា នេះ កំព្រាណាស់តើ ស្ងួតស្ងប់ជិតគល់ឈើ ។

(៧១) (អភិសម្ពុទ្ធគាថា) ព្រះសោណកបច្ចេកពុទ្ធ ស្តាប់ព្រះបន្ទូលនេះហើយ បានថ្វាយព្រះពរយ៉ាងនេះថា បពិត្រព្រះរាជា បុគ្គលដែលពាល់ត្រូវធម៌ដោយកាយ មិនមែនឈ្មោះថា កំព្រាទេ ។ បុគ្គលណា ក្នុងលោកនេះ លះធម៌ចោលហើយ ប្រព្រឹត្តអធម៌វិញ បពិត្រព្រះរាជា បុគ្គលនោះ ទើបឈ្មោះថា កំព្រា ជាបុគ្គលអាក្រក់ ជាទីពឹងរបស់បុគ្គលអាក្រក់ ។

(៧៦)អក្ខរមោតិ មេ ពាម៉ សាសំកជាតិ ម៉ំ វិត្ត
កាចំ កោតោ សុខសេយ្យា នំខ បត្តស្ស សោណកា ។
(៧៧)សនាបិ អកិញ្ចនស្ស អនាគារស្ស ភិក្ខុនោ
ន តេសំ កោដ្ឋេ ឱបេន្តិ ន កុម្ភេ ន កឡោបិយា
បរនិដ្ឋិតមេសានា តេន យាបេន្តិ សុព្វតា ។
ទុតិយម្បិ អកិញ្ចនស្ស អនាគារស្ស ភិក្ខុនោ
អនវជ្ជបិណ្ឌោ ភោត្តព្វោ ន ច កោចូបរោធតិ ។
តតិយម្បិ អកិញ្ចនស្ស អនាគារស្ស ភិក្ខុនោ
និព្វុតោ បិណ្ឌោ ភោត្តព្វោ ន ច កោចូបរោធតិ ។
ចតុត្ថម្បិ អកិញ្ចនស្ស អនាគារស្ស ភិក្ខុនោ
មុត្តស្ស រដ្ឋេ ចរតោ សង្គោ យស្ស ន វិជ្ជតិ ។
បញ្ចមម្បិ អកិញ្ចនស្ស អនាគារស្ស ភិក្ខុនោ
នគរម្ហិ ឌយ្ហមានម្ហិ នាស្ស កិញ្ចិ អឌយ្ហថ[១]។

១ ម. អឌយ្ហិត្ថ ។



(៧៦) (ព្រះរាជា...) ខ្ញុំឈ្មោះអរិន្ទមៈ អ្នកទាំងឡាយស្គាល់ខ្ញុំថាកាសិករ បពិត្រព្រះសោណកៈ លោកដ៏ចំរើនមកដល់ក្នុងទីនេះស្រួលទេ ជាសុខទេឬ ។

(៧៧) (ព្រះបច្ចេកពុទ្ធ...) សេចក្ដីចំរើន( នៃទាន )ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ សព្វកាល គឺ(ទ្រព្យនិងធញ្ញជាតិទាំងឡាយ) របស់ភិក្ខុទាំងនោះដែលមិនចូលទៅក្នុងជង្រុក ដែលមិនចូលទៅក្នុងឆ្នាំង ដែលមិនចូលទៅក្នុងក្រឡុកប៉ុនៀតហើយ លោកមានវត្តល្អមានការស្វែងរកសម្រេចហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះ ។ សេចក្ដីចំរើនទីពីរ(នៃទាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺបរិភោគនូវបាយ ដែលមិនមានទោស កិលេសណាមួយបៀតបៀនមិនបានទេ ។ សេចក្ដីចំរើនទីបី(នៃទាន)ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺឆាន់នូវបាយដ៏ត្រជាក់ ( មិនជាដែលរបស់តាមជាដើម ) កិលេសណាមួយបៀតបៀនមិនបានទេ ។ សេចក្ដីចំរើនទីបួន( នៃទាន )ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺសេចក្ដីជាប់ជំពាក់ មិនមានដល់ភិក្ខុដែលផុតស្រឡះ(ចាកត្រកូល)ត្រាច់ទៅក្នុងដែន ។ សេចក្ដីចំរើនទីប្រាំ(នៃទាន)ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺកាលបើនគរកំពុងត្រូវភ្លើងឆេះ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះក៏ពុំឆេះទេ ។

ឆដ្ឋមំ ព្រហ្មទត្តស្ស អនាគារស្ស ភិក្ខុនោ
រដ្ឋេ វិលុម្បមានម្ហិ នាស្ស កិញ្ចិ អហារថ[១] ។
សត្តមំ ព្រហ្មទត្តស្ស អនាគារស្ស ភិក្ខុនោ
ចោរេហិ រក្ខិតំ មគ្គំ យេ ចញ្ញេ បរិបន្ថិកា
បត្តចីវរមាទាយ សោត្ថិំ គច្ឆតិ សុព្វតោ ។
អដ្ឋមំ ព្រហ្មទត្តស្ស អនាគារស្ស ភិក្ខុនោ
យំ យំ ទិសំ បក្កមតិ អនបេក្ខោវ គច្ឆតិ ។
(៧៦) ពហូបិ ភទ្រា ឯតេសំ យោ ត្វំ ភិក្ខុ បសំសសិ
អហញ្ច គិទ្ធោ កាមេសុ កថំ កាហាមិ សោណក ។
បិយា មេ មានុសា កាមា អថោ ទិព្យាបិ មេ បិយា
អថ កេន នុ វណ្ណេន ឧភោ លោកេ លភាមសេ ។
(៧៧) កាមេ គិទ្ធា កាមរតា កាមេសុ អធិមុច្ឆិតា
នរា បាបានិ កត្វាន ឧបបជ្ជន្តិ ទុគ្គតិំ ។

១ ឱ. អហីរថ ។ ម. អហារថ ។





សេចក្តីចំរើនទីប្រាំមួយ (តែងមាន) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ កាលបើដែនកំពុងត្រូវគេប្លន់ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះ ឥតវិនាសទេ ។ សេចក្តីចំរើនទីប្រាំពីរ (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យមិនមានផ្ទះ គឺភិក្ខុមានវត្តល្អ កាន់យកបាត្រនិងចីវរ ដើរទៅកាន់ផ្លូវដែលពួកចោរនិងពួកសត្រូវដទៃរក្សា ដោយស្រួល ។ សេចក្តីចំរើនទីប្រាំបី (តែងមាន) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុនោះដើរទៅកាន់ទិសណា ៗ ទៅបានដោយមិនមានអាល័យ ។

(៧៦) (ព្រះរាជា...) បពិត្រភិក្ខុ លោកសរសើរនូវសេចក្តីចំរើនរបស់ភិក្ខុទាំងនោះច្រើនមែន បពិត្រព្រះសោណកៈ តែខ្ញុំជាប់ចិត្តក្នុងកាមទាំងឡាយ តើនឹងធ្វើយ៉ាងណា ។ កាមទាំងឡាយជារបស់មនុស្ស ជាទីស្រឡាញ់របស់ខ្ញុំ មួយទៀត កាមជាទិព្វក៏ជាទីស្រឡាញ់របស់ខ្ញុំ បើដូច្នេះ តើយើងនឹងបាននូវកាមទាំងពីរលោក ដោយហេតុដូចម្តេច ។

(៧៧) (ព្រះបច្ចេកពុទ្ធ...) ពួកជនអ្នកជាប់ចិត្តក្នុងកាម ត្រេកអរក្នុងកាម ជាប់ក្នុងកាម រមែងធ្វើបាបទាំងឡាយ ហើយទៅកាន់ទុគ្គតិ ។

យេ ច កាមេ បហត្វាន | និក្ខន្តា អកុតោភយា
ឯកោទិភាវាធិគតា | ន តេ គច្ឆន្តិ ទុគ្គតឹ ។
ឧបមន្តេ ករិស្សាមិ | តំ សុណោហិ អរិន្ទម
ឧបមាយ មិធេកច្ចេ | អត្ថំ ជានន្តិ បណ្ឌិតា ។
គង្គាយ កុណបំ ទិស្វា | វុយ្ហមានំ មហណ្ណវេ
វាយសោ សមចិន្តេសិ | អប្បបញ្ញោ អចេតសោ ។
យានញ្ច វតិទំ លទ្ធំ | ភក្ខោ ចាយំ អនប្បកោ
តត្ថ រត្តឹ តត្ថ ទិវា | តត្ថេវ និរតោ មនោ ។
ខាទំ នាគស្ស មំសានិ | បិវំ ភាគីរសោទកំ
សម្បស្សំ វនចេត្យានិ | ន បលេត្ថ វិហង្គមោ ។
តញ្ច ឱតរណី គង្គា | បមត្តំ កុណបេ រតំ
សមុទ្ទំ អជ្ឈគាហាសិ | អគតី យត្ថ បក្ខិនំ ។
សោ ច ភក្ខបរិក្ខីណោ | ឧទបត្តា[១] វិហង្គមោ
ន បច្ឆតោ ន បុរតោ | នុត្តរំ នោបិ ទក្ខិណំ ។
ទីបំ សោ នជ្ឈគច្ឆិ | អគតី យត្ថ បក្ខិនំ
សោ ច តត្ថេវ បាបត្ថ | យថា ទុព្ពលកោ តថា ។

---
១ ឧប្បតិត្វាតិ អដ្ឋកថាយំ ទិស្សតិ ។



ចំណែកកុណបដំរីនោះ លះបង់កាយ ហើយបញ្ចេញទៅ មិន មានកម្មអំពីកំលោះណាមួយ ប្រាកដដូចក្អែកជាបុគ្គលឯក ក្អែក ជននោះ មិនទៅកាន់ទុគ្គតិ ។ បពិត្រព្រះអរិន្ទម អាត្មាភាព នឹងធ្វើសេចក្តីឧបមាថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ សេចក្តីឧបមានោះ ព្រោះពួកបណ្ឌិតខ្លះក្នុងលោកនេះ តែងយល់ សេចក្តីដោយសារឧបមា ។ ក្អែកល្ងង់ឥតប្រាជ្ញាឥតសេចក្តីគិតគន់ ឃើញសាកសព(ដំរី)កំពុងអណ្តែតតាមខ្សែទឹកគង្គាទៅក្នុងសមុទ្រ ហើយគិតថា នែយាន ! អញបានយាននេះហើយផង ដំរីនេះនឹង បានជាចំណីអញយ៉ាងច្រើនផង ចិត្តរបស់ក្អែកនោះក៏ត្រេកអរក្នុង ដំរីនោះទាំងថ្ងៃទាំងយប់ ។ ក្អែកចឹកស៊ីសាច់ដំរី ផឹកទឹក ទន្លេគង្គា ឃើញព្រៃដែលគេសន្មតថាចេតិយ ក៏មិនហើរទៅ ។ ទន្លេគង្គាហូរទៅបាននាំក្អែកនោះ ដែលប្រហែសធ្វេសត្រេកអរ ក្នុងសាកសព ទៅកាន់សមុទ្រដែលមិនមែនជាទីទៅនៃបក្សី ។ សត្វហើរនោះអស់ចំណីលើដំរីហើយ ក៏ហើរឡើងទៅទិសខាង លិចមិនរួច ទៅទិសខាងកើតមិនរួច ទៅទិសខាងជើងមិនរួច ទៅទិសខាងត្បូងមិនរួច ។ ក្អែកនោះទៅកាន់សមុទ្រ ដែល មិនមែនជាទីទៅនៃពួកបក្សី ក៏មិនបានឃើញកោះ ធ្លាក់ទៅ ក្នុងសមុទ្រ នោះឯង ដូចជាបុគ្គល មានកំឡាំងខ្សោយ ។

តញ្ច សាមុទ្ទិកា មច្ឆា កុម្ភីលា មករាសុរា

បសយ្ហការា ខាទន្តិ ផន្ទមានំ វិបក្ខិកំ ។

ឯវមេវ តុវំ ចញ្ច យេ ចញ្ញេ កាមភោគិនោ

គិទ្ធា ចេ ន វមិស្សន្តិ កាកបញ្ញាវ តេ វិទូ ។

ឯសា តេ ឧបមា ចញ្ច អត្ថសន្ទស្សនី កតា

ត្វញ្ច បញ្ញាយសេ តេន យទិ កាហសិ វា ន វា ។

(៧៦) ឯកវាចម្បិ ទ្វិវាចំ ភណេយ្យ អនុកម្បកោ

តតុត្តរឹ ន ភាសេយ្យ ទាសោវយ្យស្ស សន្តិកេ ។

(៧៧) ឥទំ វត្វាន បក្កាមិ សោណកោ អមិតពុទ្ធិមា

វេហាសេ អន្តលិក្ខស្មឹ អនុសាសិត្វាន ខត្តិយំ ។

(៧៨) កោ នុមេ រាជកត្តារោ សុតា វេយ្យត្តិមាគតា

រជ្ជំ និយ្យាតយិស្សាមិ នាហំ រជ្ជេន មត្ថិកោ ។



ក្អែកនោះ ត្រី មករ ក្រពើ ដែលកើតក្នុងសមុទ្រ ក៏ហែកស៊ីក្អែកនោះ ដែលមានស្លាបទាល់ហើយ ក៏កំពុងបម្រះ ( យ៉ាងណាមិញ ) ។ បពិត្រព្រះរាជា ព្រះអង្គនិងពួកជនដទៃណាមួយបរិភោគកាមក៏យ៉ាងនោះដែរ បើពួកជនដែលជាប់ចិត្តហើយមិនខ្ជាក់ (កាម) ចោលចេញៗ បណ្ឌិតទាំងឡាយ (ស្គាល់) ពួកជននោះថា មានប្រាជ្ញាស្មើ ដោយប្រាជ្ញារបស់ក្អែក ។ បពិត្រព្រះរាជា ឧបមាជាគ្រឿងបង្ហាញសេចក្ដីនេះ អាត្មាភាពបានធ្វើថ្វាយព្រះអង្គហើយ បើព្រះអង្គធ្វើក្ដីមិនធ្វើ ព្រះអង្គនឹងប្រាកដតាមហេតុនោះ ។

(៧៦) បុគ្គលអ្នកឈឺឆ្អាល គប្បីនិយាយត្រឹមតែមួយម៉ាត់ ឬពីរម៉ាត់ មិនគប្បីនិយាយឲ្យលើសពីនោះទៅ ដូចទាសៈនិយាយក្នុងសំណាក់ម្ចាស់ ។

(៧៧) ( អមិតពុទ្ធិមា ) លុះព្រះសោណកបច្ចេកពុទ្ធ មានប្រាជ្ញារាប់មិនបាន ពោលពាក្យនេះប្រៀនប្រដៅក្សត្រិយ៍ហើយ ហើរចៀសចេញទៅក្នុងអាកាសវេហាស៍ ។

(៧៨) (ព្រះរាជា...) ពួកជនអ្នករៀបចំរាជសម្បត្តិ ដែលស្ទួយល់ច្បាស់ ជាអ្នកបង្កើតប្រយោជន៍នេះ ទាំងឡាយ នៅក្នុងទីណា អាត្មានឹងប្រគល់រាជ្យឲ្យ អាត្មាមិនត្រូវការដោយរាជ្យទេ ។

អជ្ជេវ បុត្តំ បស្សាមិ  កោ ជញ្ញា មរណំ សុវេ

យាហំ ពាលោ ទុម្មេធោ  កាមានំ វសមន្វគា ។

(៧៩) អត្ថិ តេ ទហរោ បុត្តោ  ជាលី រដ្ឋវឌ្ឍនោ

តំ រជ្ជេ អភិសិញ្ចស្សុ  សោ នោ រាជា ភវិស្សតិ ។

(៨០) ខិប្បំ កុមារំ អានេថ  ជាលិំ រដ្ឋវឌ្ឍនំ

តំ រជ្ជេ អភិសិញ្ចិស្សំ  សោ វោ រាជា ភវិស្សតិ ។

(៨១) តតោ កុមារមាទាសុំ  ជាលិំ រដ្ឋវឌ្ឍនំ

តំ ទិស្វា អាលបិ រាជា  ឯកបុត្តំ មនោរមំ ។

សដ្ឋី គាមសហស្សានិ  បរិបុណ្ណានិ សព្វសោ

តេ បុត្ត បដិបជ្ជស្សុ  រជ្ជំ និយ្យាទយាមិ តេ ។

អជ្ជេវ បុត្តំ បស្សាមិ  កោ ជញ្ញា មរណំ សុវេ

យាហំ ពាលោ ទុម្មេធោ  កាមានំ វសមន្វគំ ។





អញនឹងឃើញកូនថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក អញល្ងង់ ក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកគោតហើយ ។

(៧៩) (ពួកអាមាត្យ...) ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមជាលី នៅក្មេង ជាអ្នកញុំាងដែនឱ្យចំរើន សូមព្រះអង្គអភិសេក ព្រះរាជបុត្រនោះក្នុងរាជ្យចុះ ព្រះរាជបុត្រនោះនឹងបានជាព្រះរាជារបស់យើងខ្ញុំ ។

(៨០) (ព្រះរាជា...) អ្នកទាំងឡាយ ចូរនាំយកកុមារឈ្មោះជាលី អ្នកញុំាងដែនឱ្យចំរើនមកឱ្យឆាប់ អញនឹងអភិសេកកុមារនោះក្នុងរាជ្យ កុមារនោះនឹងជាព្រះរាជារបស់អ្នកទាំងឡាយ ។

(៨១) (អភិសម្ពុទ្ធគាថា) លំដាប់នោះ ពួកអាមាត្យក៏បាននាំកុមារឈ្មោះជាលី អ្នកញុំាងដែនឱ្យចំរើនមកថ្វាយ ព្រះរាជាទតឃើញជាលីកុមារនោះ ជាបុត្រតែមួយ ជាទីត្រេកអរពេញព្រះទ័យហើយទ្រង់ត្រាស់ថា នែបុត្រ ស្រុកទាំង ៦០,០០០ បរិបូណ៌ដោយវត្ថុទាំងពួង ចូរចាំថែស្រុកទាំងនោះចុះ អញនឹងប្រគល់រាជ្យដល់បុត្រ ។ អញនឹងឃើញកូនថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក ក៏ឱ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកគោតហើយ ។

សដ្ឋី នាគសហស្សានិ សព្វាលង្ការភូសិតា

សុវណ្ណកច្ឆា មាតង្គា ហេមកប្បនវាសសា ។

អារុឡ្ហា គាមណីយេហិ តោមរង្កុសបាណិភិ

តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។

អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ

មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគុំ ។

សដ្ឋី អស្សសហស្សានិ សព្វាលង្ការភូសិតា

អាជានីយា ច ជាតិយា សិន្ធវា សីឃវាហនា

អារុឡ្ហា គាមណីយេហិ ឥល្លិយាចាបធារិភិ

តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។

អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ

មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគុំ ។

សដ្ឋី រថសហស្សានិ សន្នទ្ធា ឧស្សិតទ្ធជា

ទីបា អថោបិ វេយ្យគ្ឃា សព្វាលង្ការភូសិតា ។

អារុឡ្ហា គាមណីយេហិ ចាបហត្ថេហិ វម្មិភិ[១]

តេ បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។

១ ម. វម្មិហិ ។ ម. វម្មិកិ ។



ដំរី ៦០.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានខ្សែជង្គង់ធ្វើអំពីមាស បិទបាំងដោយគ្រឿងលម្អដែលធ្វើអំពីមាស ជាដំរីកើតក្នុងត្រកូលមាតង្គៈ ។ ដំរីណាដែលពួកហ្មដំរីជាន់ជិះកាន់កង្វេរនិងកន្សែងឡើងជិះ នែបុត្រ អ្នកចូរទទួលពួកដំរីទាំងនោះចុះ អញប្រគល់រាជ្យដល់អ្នក ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាដឹងច្បាស់នូវសេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយដូចជាក្អែកពាលឡើយ ។ សេះ ៦០.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ជាសេះអាជានេយ្យដោយកំណើតជាសេះសិន្ធពៈជាពាហនៈយ៉ាងលឿន ដែលពួកហ្មសេះកាន់ដាវនិងធ្នូជិះ នែបុត្រ ចូរទទួលសេះទាំងនោះចុះ អញប្រគល់រាជ្យដល់ចុះ ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាដឹងច្បាស់នូវសេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកពាលឡើយ ។ រថ ៦០.០០០ ដែលគេចងហើយ លើកទង់ជ័យ ស្រោបដោយស្បែកខ្លាដំបង ស្រោបដោយស្បែកខ្លាធំ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ។ អ្នកបររថ មានដៃកាន់ធ្នូ ស្លៀកក្រោះហើយឡើងជិះ នែបុត្រ ចូរទទួលរថទាំងនោះចុះ អញប្រគល់រាជ្យដល់ចុះ ។

អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។
សដ្ឋី ធេនុសហស្សានិ រោហញ្ញា បុង្គវូសភា
គា បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។
អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។
សោឡសិត្ថិសហស្សានិ សព្វាលង្ការភូសិតា
វិចិត្តវត្ថាភរណា អាមុត្តមណិកុណ្ឌលា
តា បុត្ត បដិបជ្ជស្សុ រជ្ជំ និយ្យាទយាមិ តេ ។
អជ្ជេវ បព្វជិស្សាមិ កោ ជញ្ញា មរណំ សុវេ
មាហំ កាកោវ ទុម្មេធោ កាមានំ វសមន្វគំ ។
(៨៦)ទហរស្សេវ មេ តាត មាតា មតាតិ មេ សុតំ
តយា វិនា អហំ តាត ជីវិតុំ ន ឧស្សហេ ។
យថា អារញ្ញកំ នាគំ បោតោ អន្វេតិ បច្ឆតោ
ជេស្សន្តំ[1] គិរិទុគ្គេសុ សមេសុ វិសមេសុ ច ។

១ ម. ចេស្សន្តំ ។



អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។ មេគោ ៦០ ០០០ ជាមេគោក្រហមប្រផេះ ដោយគោឧសភ (គោបា) នែបុត្រ ចូរទទួលមេគោទាំងនោះចុះ អញប្រគល់រាជ្យដល់ឯង ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថាសេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយដូចជាក្អែកឆោតឡើយ ។ ស្ត្រី ១៦.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាងមានសំពត់និងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលកែវមណី នែបុត្រ ចូរទទួលស្ត្រីទាំងនោះចុះ អញប្រគល់រាជ្យដល់ឯង ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណា គប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។

(៨៦) (ព្រះកន្ទុមារ...) បពិត្រព្រះបិតា កាលដែលខ្ញុំព្រះបង្គំជាកូននៅក្មេងនៅឡើយ ខ្ញុំព្រះបង្គំបានឮថា ព្រះមាតាទ្រង់សោយទិវង្គតទៅហើយ បពិត្រព្រះបិតា ខ្ញុំព្រះបង្គំ ជាខ្ញុំព្រាត់ប្រាសចាកព្រះអង្គហើយ មិនអាចនឹងរស់នៅបានទេ ។ កូនដំរីរមែងដើរតាមក្រោយដំរីដែលនៅក្នុងព្រៃ ដើរទៅក្នុងទីផ្លូវនៃភ្នំទាំងឡាយដែលរាបស្មើ និងមិនរាបស្មើ យ៉ាងណាមិញ ។

ឯវត្តំ អនុគណ្ហាមិ   បុត្តមាទាយ បព្វតោ
សុខកោ តេ ករិស្សាមិ   ជនេ ហេស្សាមិ ទុក្ខកេ ។

(៨៣)យថា សាមុទ្ទិកំ នាវំ   វាណិជានំ ធនេសិនំ
វោហារោ តត្ថ គណ្ហាតិ   វាណិជា ព្យសនី កតា
ឯវមេវាយំ បុត្តកោ   អន្តរាយករោ មម ។

(៨៤) ឥមំ កុមារំ បាបេថ   បាសាទំ រតិវឌ្ឍនំ
កម្ពុកាយូរធរាយោ   យថា សក្កំវ អច្ឆរា
តា នំ តត្ថ រមិស្សន្តិ   តាហិ ចេសោ រមិស្សតិ ។

(៨៥)ឥតោ កុមារំ បាបេសុំ   បាសាទំ រតិវឌ្ឍនំ
តំ ទិស្វា អវចុំ កញ្ញា   ទីឃាវុំ រដ្ឋវឌ្ឍនំ ។
ទេវតា នុសិ គន្ធព្វោ   អាទុ សក្កោ បុរិន្ទទោ
កោ វា ត្វំ កស្ស វា បុត្តោ   កថំ ជានេមុ តំ មយំ ។



ទូលព្រះបង្គំជាខ្ញុំ នាំយកក្តីទៅគាល់ព្រះអង្គ ក៏យ៉ាងនោះដែរ ទូលព្រះបង្គំជាខ្ញុំ ជាបុគ្គលព្រះអង្គចិញ្ចឹមហើយ ក៏រមែងព្រះអង្គ ក៏បានចិញ្ចឹមឡើយ ។

(៨៣) (ព្រះរាជា...) សូមទ្រង់ជាម្ចាស់ចំរើន គប្បីជាប់សំពៅដែលដើរក្នុងសមុទ្រ របស់ពួកពាណិជដែលនៅស្វែងរកទ្រព្យក្នុងសមុទ្រ នោះ ពួកពាណិជត្រូវវិនាស យ៉ាងណាមិញ ឯកូនឈាមក ឯនីនេះ ធ្វើសេចក្តីអន្តរាយ ដល់អញ ក៏យ៉ាងនោះដែរ ។

(៨៤) អ្នកទាំងឡាយ ចូរនាំកុមារនេះឲ្យដល់ប្រាសាទ ដែលញ៉ាំងតម្រេកឲ្យចំរើន ក្នុងប្រាសាទនោះមានពួកស្រីមានដៃស្អិតស្អាង ដោយគ្រឿងអាភរណៈ ធ្វើអំពីមាស ស្រីទាំងនោះនឹងត្រេកអរ ចំពោះកុមារនោះ ក្នុងប្រាសាទនោះ ដូចជាពួកស្រីអប្សរត្រេក អរនឹងសក្កទេវរាជ កុមារនេះនឹងត្រេកអរជាមួយស្រីទាំងនោះ ។

(៨៥) (អភិសម្ពុទ្ធគាថា) លំដាប់អំពីនោះមក ពួកអាមាត្យបាន ញ៉ាំងកុមារឲ្យដល់ប្រាសាទ ដែលញ៉ាំងតម្រេកឲ្យចំរើន ឯពួក នាងកញ្ញា ឃើញទីឃាវុកុមារនោះ ជាអ្នកញ៉ាំងដែនឲ្យចំរើន ហើយ ក៏បាននិយាយថា លោកជាទេវតាឬជាគន្ធព្វ ឬក៏ជា ព្រះឥន្ទ្រឈ្មោះបុរិន្ទទៈ លោកជានរណា ជាបុត្ររបស់អ្នកណា ធ្វើដូច ម្តេច យើងនឹងអាចស្គាល់លោកបាន ។

(៨៦) នាម្ហិ ទេវោ ន គន្ធព្វោ នាបិ សក្កោ បុរិន្ទទោ

កាសិរញ្ញោ អហំ បុត្តោ ទីឃាវុ រដ្ឋវឌ្ឍនោ

មមំ ភរថ ភទ្ទំ វោ(១) អហំ ភត្តា ភវាមិ វោ ។

(៨៧) តំ តត្ថ អវចុំ កញ្ញា ទីឃាវុំ រដ្ឋវឌ្ឍនំ

កុហឹ រាជា អនុប្បត្តោ ឥតោ រាជា កុហឹ គតោ ។

(៨៨) បង្កំ រាជា អតិក្កន្តោ ថលេ រាជា បតិដ្ឋិតោ

អកណ្ដកំ អគហនំ បដិបន្នោ មហាបថំ ។

អហញ្ច បដិបន្នាស្មិ មគ្គំ ទុគ្គតិគាមិនំ

សកណ្ដកំ សគហនំ យេន គច្ឆន្តិ ទុគ្គតឹ ។

(៨៩) តស្ស តេ ស្វាគតំ រាជ សីហស្សេវ គិរិព្ពជំ

អនុសាស មហារាជ ត្វំ នោ សព្វាសមិស្សរោតិ ។

សោណកជាតកំ បឋមំ ។

១ ម. ភរេថ ។



(៨៦) (ព្រះជនកុមារ...) យើងមិនមែនជាទេវតា មិនមែនជាគន្ធព្វ ទាំងមិនមែនជាព្រះឥន្ទ្រឈ្មោះបុរិន្ទទៈទេ យើងជាកូននៃព្រះរាជាក្នុងដែនកាសី ឈ្មោះទីឃាវុ ជាអ្នកញុំាងដែនឲ្យចំរើន នាងទាំងឡាយ ចូរចិញ្ចឹមយើងចុះ សេចក្ដីចំរើនចូរមានដល់ពួកនាងទាំងឡាយ យើងជាភស្ដារបស់ពួកនាង ។

(៨៧) (អភិសម្ពុទ្ធគាថា) ពួកនាងកញ្ញា បានទូលសួរទីឃាវុកុមារនោះដែលញុំាងដែនឲ្យចំរើនក្នុងព្រៃសាលនោះថា ព្រះរាជាស្ដេចយាងទៅក្នុងទីណា ព្រះរាជាស្ដេចចេញអំពីទីនេះទៅក្នុងទីណា ។

(៨៨) (ព្រះជនកុមារ...) ព្រះរាជាទ្រង់បានឆ្លងកន្លងភក់ (កាមកិលេស) ព្រះរាជាទ្រង់បានឋិតនៅលើគោក (ផ្លូវ) ទ្រង់យាងទៅកាន់ផ្លូវធំ (ជាទីទៅកាន់សុគតិនិងព្រះនិព្វាន) ដែលមិនមានបន្លា មិនមានព្រៃញាតស្បាត (កិលេស) ។ ចំណែកយើង ជាអ្នកដើរទៅកាន់ផ្លូវជាទីទៅកាន់ទុគ្គតិ ប្រកបដោយបន្លា ប្រកបដោយព្រៃញាតស្បាត សម្រាប់ទៅកាន់ទុគ្គតិ របស់ពួកសត្វ ។

(៨៩) (ពួកនាងកញ្ញា...) បពិត្រព្រះរាជា ព្រះអង្គនោះយាងមកល្អហើយ ហាក់ដូចជាសីហៈដែលមកកាន់គិរីព្វជៈ (គុហាមាស) បពិត្រមហារាជ សូមព្រះអង្គគប់គ្រងចុះ ព្រះអង្គជាម្ចាស់របស់ពួកខ្ញុំម្ចាស់ទាំងអស់គ្នា ។

ចប់ សោណកជាតក ទី ១ ។

# សត្តុភស្តជាតកំ

(៩០) ទិស្វា និសិន្នំ រាជានំ ព្រហ្មទត្តំ រថេសភំ
អថស្ស បដិវេទេសិ យស្សាសិ អនុកម្បកោ ។
សត្តិក្ខាយំ អនុប្បត្តោ នគរំ សាធុសម្មតោ
ករមាខ្យតោ និយ្យាតិ ចិត្យំ បស្ស មហេសិនំ ។
គតោ ច រាជា ករមាតោ យុត្តមារុយ្ហ សន្ទនំ
មត្តាមគ្គំ បរិក្ខន្តោ អត្តមាសិ រថេសភោ ។
និក្ខិប្ប បញ្ចកកុធានិ កាសីនំ រដ្ឋវឌ្ឍនោ
ភត្យវិជជំ មុញ្ចិត្វា ទត្តំ ជត្តុញ្ចាហនំ ។
ទិស្វា រាជា យាចន្តា ឋបយិត្វា បដិច្ឆនំ
អាសីនំ ទាយបស្សស្មិំ សន្តិក្ខុបសង្កមិ ។
ឧបសង្កមិត្វា សោ រាជា សម្មោទិ ឥសិនា សហ
តំ កថំ វីតិសារេត្វា ឯកមន្តំ ឧបាវិសិ ។
ឯកមន្តំ និសិន្នោវ អថ កាលំ អមញ្ញថ
តតោ បាបានិ កម្មានិ បុច្ឆិតុំ បដិបជ្ជថ ។

# សត្តុភស្តជាតក

(៩០) (អាត់សម្ដែងតាម) (ទម្លាក់ចោលនោះ) ឃើញព្រះរាជាទ្រង់ព្រះនាមព្រហ្មទត្ត ប្រសើរក្នុងរថ ហើយក្រាបទូលព្រះរាជានោះក្នុងគ្រានោះថា ព្រះអង្គជាបុគ្គលឈឺឆ្អាលដល់ឥសីណា ។ ឥសីឈ្មោះសត្តុភស្តៈនេះដែលគេសន្មតថាជាសប្បុរសរបស់ពួកឥសីមកដល់ហើយ សូមព្រះអង្គប្រញាប់ប្រញាល់ យាងចេញទៅជួបនឹងមហាឥសីឲ្យឆាប់ ។ លំដាប់នោះ ព្រះរាជាប្រសើរក្នុងរថ មានម៉ាត្រានឹងអាមាត្យហោហម ទ្រង់ប្រញាប់ឡើងកាន់រថដែលគេទឹមហើយ ទ្រង់យាងទៅ ។ ព្រះរាជាញ៉ាំងដែនដែនក្នុងកាសីឲ្យចំរើន ទ្រង់ដាក់គ្រឿងកកុធៈ ៥ យ៉ាង គឺ ឆ័ត្រកែម សត្វ ១ មកុដ ១ ព្រះខាន់ ១ ស្បែក ១ សុពណ៌ចាមរ ១ ។ លុះព្រះរាជាទ្រង់យាងចុះអំពីយាន ទុកគ្រឿងកកុធៈ ហើយទើបយាងចូលទៅរកសត្តុភស្តឥសី ដែលអង្គុយក្នុងទីទទួលឈ្មោះទាយបស្សៈ ។ ព្រះរាជានោះទ្រង់ត្រាស់សំណេះសំណាលជាមួយនឹងឥសី លុះបញ្ចប់ពាក្យនោះហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ព្រះរាជាគង់ស្ងប់ក្នុងទីសមគួរហើយ ទើបទ្រង់ព្រាបទូលសួរប្រតិបត្តិ ដើម្បីសួរនូវបាបកម្មទាំងឡាយ ក្នុងពេលនោះ ។

ឥសី បុញ្ញាម សន្តិកំ   ឥសីលំ សាធុសម្មតំ
អាសីនំ ទាយបស្សស្មឹ   ឥសិសង្ឃបុរក្ខតំ ។
តំ គតឹ បេច្ច គច្ឆន្តិ   ឯក ធម្មគិចារិនោ
អតិចិរេណ្ណាមយោ ធម្មោ   តំ មេ អក្ខាហិ បុច្ឆិតោ ។
(៤១) ឥសិ អវច សត្តិគុម្ពោ   កាសីនំ រដ្ឋវឌ្ឍនំ
អាសីនំ ទាយបស្សស្មឹ   មហារាជ សុណោហិ មេ ។
ឧប្បជ្ជេន វេជ្ជស្ស   យោ មគ្គមនុសាសតិ
តស្ស ចេ វចនំ ករេយ្យ   នាស្ស មគ្គេយ្យ កណ្ដកោ ។
អធម្មំ បដិបន្នស្ស   យោ ធម្មមនុសាសតិ
តស្ស ចេ វចនំ ករេយ្យ   ន សោ គច្ឆេយ្យ ទុគ្គតឹ ។
(៤២) ធម្មោ បថោ មហារាជ   អធម្មោ បន ឧប្បថោ
អធម្មោ និរយំ នេតិ   ធម្មោ បាបេតិ សុគ្គតឹ ។
អធម្មចារិនោ រាជ   នរា វិសមជីវិនោ
យំ គតឹ បេច្ច គច្ឆន្តិ   និរយេ តេ សុណោហិ មេ ។



យើងខ្ញុំសូមសួរលោកម្ចាស់ឥសី ដែលគេសន្មតថាជាសប្បុរសរបស់ពួកឥសី ដែលពួកឥសីចោមរោមហើយ គង់ក្នុងទាយបស្សប្រទេស ។ ពួកជនអ្នកប្រព្រឹត្តនូវអធម៌ លុះស្លាប់ទៅវិញ ទៅកាន់គតិណា ធម៌ គឺបុរាណកម្ម ខ្ញុំបានប្រព្រឹត្តនូវអធម៌ហើយ ខ្ញុំសួរហើយ សូមលោកប្រាប់សេចក្តីនោះដល់ខ្ញុំ ។

(៤១) សត្តិគុម្ពឥសី បានពោលនឹងព្រះរាជាអ្នកញុំាងដែនកាសីឲ្យចំរើន គង់ក្នុងទាយបស្សប្រទេសថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់អាត្មាភាព ។ អ្នកណាប្រាប់ផ្លូវដល់បុគ្គលអ្នកវង្វេងផ្លូវខុស បើបុគ្គលនោះ ធ្វើតាមពាក្យរបស់អ្នកប្រាប់នោះ បន្លា (គោរ) មិនគប្បីចូលទៅដល់បុគ្គលអ្នកធ្វើតាមនោះទេ ។ អ្នកណាប្រៀនប្រដៅនូវធម៌ដល់បុគ្គលប្រតិបត្តិអធម៌ បើបុគ្គលនោះធ្វើតាមពាក្យរបស់អ្នកប្រដៅនោះ បុគ្គលនោះមិនគប្បីទៅកាន់ទុគ្គតិទេ ។

(៤២) បពិត្រមហារាជ ធម៌ជាផ្លូវត្រូវ ឯអធម៌ជាផ្លូវខុស អធម៌នាំសត្វទៅកាន់នរក ធម៌ញុំាងសត្វឲ្យដល់សុគតិ ។ បពិត្រព្រះរាជា ពួកជនអ្នកមិនប្រព្រឹត្តធម៌ ចិញ្ចឹមជីវិតខុសគន្លងធម៌ លុះស្លាប់ទៅវិញហើយ រមែងទៅកាន់គតិ (នរក)ណា សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យអាត្មាភាព (ដែលសំដែងអំពីនរក) ពីនោះ ។

សញ្ជីវោ កាឡសុត្តញ្ច  សង្ឃាតោ ទ្វេ ច រោរុវា
អថាបរោ មហាវីចិ  តាបនោ ច បតាបនោ ។
ឥច្ចេតេ អដ្ឋ និរយា  អក្ខាតា ទុរតិក្កមា
អាកិណ្ណា លុទ្ទកម្មេហិ  បច្ចេកា សោឡសុស្សទា ។
កទរិយ (១) តាបនា ឃោរា  អច្ចិមន្តោ មហព្ភយា
លោមហំសនរូបា ច  ភេស្មា បដិភយា ទុខា ។
ចតុក្កណ្ណា ចតុទ្វារា  វិភត្តា ភាគសោ មិតា
អយោបាការបរិយន្តា  អយសា បដិកុជ្ជិតា ។
តេសំ អយោមយា ភូមិ  ជលិតា តេជសា យុតា
សមន្តា យោជនសតំ  ផុដា តិដ្ឋន្តិ សព្វទា ។
ឯតេ បតន្តិ និរយេ  ឧទ្ធំបាទា អវំសិរា
ឥសីនំ អតិវត្តារោ  សញ្ញតានំ តបស្សិនំ ។
តេ ភូនហុនោ បច្ចន្តិ  មច្ឆា ពិលកតា យថា
សំវច្ឆរេ អសង្ខេយ្យេ  នរា កិព្ពិសការិនោ ។

---
១ ករិយតាបនាតិ អដ្ឋកថាយំ ។





សញ្ជីវនរក ១ កាឡសុត្តនរក ១ សង្ឃាតនរក ១ រោរុវៈ ២ នរកដទៃទៀត គឺមហាវីចិ ១ តាបនៈ ១ បតាបនៈ ១ ។ នរកទាំង ៨ នុ៎ះដែលអ្នកប្រាជ្ញទាំងឡាយបានសំដែងហើយដោយប្រការដូច្នេះ កន្លងបាន បុគ្គលណាកន្លងទៅលំបាក ពេញដោយពួកសត្វដែលមានកម្មអាក្រក់ពេញដោយមហានរកមួយ ៗ មានឧស្សទនរក ១៦ ៗ ( នរកទាំងនោះ) ជាទីនៅនៃអ្នកកំណាញ់ស្វិតស្វាញ ជានរកដ៏គួរខ្លាច មានអណ្តាតភ្លើង មានភ័យធំ មានសភាពគួរឱ្យព្រឺរោម គួរឱ្យស្បើមបណ្តាលឱ្យរួមរួញ ជាទុក្ខ ។ ( នរកទាំងនោះ ) មានមុំ ៤ មានទ្វារ ៤ ដែលបានចែកចេញជាចំណែក មានកំពែងដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ។ ភូមិរបស់នរកទាំងនោះជាវិការៈនៃដែកឆេះរុងរឿង ប្រកបដោយកំដៅ( នរកទាំងអស់នោះ )ផ្សាយទៅអស់ទី ១០០ យោជន៍ជុំវិញ ឋិតនៅសព្វ ៗ កាល ។ ពួកជនអ្នករំលងរំលោភពួកឥសី ជាអ្នកសង្រួមមានតបៈធម៌ រមែងធ្លាក់ទៅក្នុងនរកមានជើងឡើងលើ មានក្បាលចុះក្រោម ។ ពួកជនអ្នកធ្វើ-ពើអាក្រក់ ជាអ្នកបំផ្លិចបំផ្លាញសត្វដ៏ដទៃនោះ ត្រូវឆេះក្នុងនរកយូរកាលដូចជាពួកត្រីដែលគេបំបែកខ្លួន ( អស់ឆ្នាំ ) រាប់មិនអស់ ។

ឱឡ្ហមានេន កាឡេន ទិដ្ឋិ សន្តាបតោ ហំ

និរយា តាដិតដ្ឋិ ម្ហារំ ចិត្តូមលេសិនោ ។

ឧក្ខិតេន ជាតគ្គិ ឥតោ ជាតគ្គិ បត្ថតោ

ឧទ្ធំ រេបិ ជាតគ្គិ ឥតោ ជាតគ្គិ សត្តុកណ្ណំ

យំ យត្ថ ម្ហារំ គច្ឆតិ ទដ្ឋេវេ ចិចិយ្យរេ ។

ពហូនិ សតសហស្សានិ ៧៦ និរយតាមិនោ

តាហោ បត្តយ្យ កត្តដ្ឋំ បត្វា ឧត្តំ អនប្បកំ ។

អសីវិស្សេ កុប្បតិ គេដសី ឧក្កិត្តមំ

ន សក្កុប្រម អសីវេ សញ្ញាតាន ឱបស្សិនំ ។

អតិតាយោ មហាស្សាសោ អដ្ឋុតោ គេសតាបិតោ

សហស្សាហេ ទក្ខិណ្ឌោ[១] វិសិខាសដ្ឋ គោតមំ ។

អនុំ ធេសា វដ្ឋំ ការំ អត្ថរិយ ឱណ្ណាតិ

តាលោវ មូលតោ ចិន្នោ ស កជា វិកន្តិតោ ។

---

១ ម. អដ្ឋិន្នោ ។



ពួកសត្វនរកមានខ្លួនស្រៀវស្រើបហើយ ក៏ទាញទីកន្លែងក្រៅជាដំបូង ស្បែកខ្លួនទាំងឡាយក៏ត្រូវកំដៅមិនបានខ្លួន ។ ពួកសត្វនរកនោះរត់ទៅទិសខាងកើត ស្បែកក៏ទិសខាងកើតនោះ ទៅទិសខាងលិច ស្បែកទៅទិសខាងជើង ស្បែកក៏ទិសខាងជើង ទៅទិសខាងត្បូង សត្វនរកក៏ដើរនោះទៅដល់ទ្វារណា ៗ ទ្វារនោះ ៗ បិទ គឺបិទជិត ។ ពួកសត្វដែលទៅកាន់នរក ដើរក្រែលក្រើន ដួលដើមដែលត្រូវគេខ្ញាញ ស្បែកនៃឆ្នាំជាច្រើន ។ បុគ្គលមិនអប្បីញ្ញូលទៅរៀនរៀន ខ្លួនពួកសត្វ ដែលមានសេចក្តីសប្បុរស ដូចជាបុគ្គលមិនគួរចូលទៅជិតសត្វកើត ដែលទីមានគេជេរ គេគន្លើលទីបានរលាយព្រោះ (ដែលទីនោះ ជួនក្លាក់ទៅក្នុងនរក រួចហើយរៀនរៀន) ខ្លួនពួកសត្វអ្នកសម្រេចមានតបៈ ។ ព្រោះថាព្រះធម៌ដ៏ប្រសើរ មានពួកគ្រាលជាច្រើន ជាអ្នកចិញ្ចឹមខ្លួនដែលឈ្មោះគោតមៈ ការលើកខ្លួនដែលពួកខ្ញុំ ៨០០ រលាយទៅដោយដើមដៃ ១.០០០ រៀនរៀនសេរីឈ្មោះគោតមៈ ហើយវិនាស ។ ព្រោះថាទណ្ឌកផ្លាចផ្លាកយកខ្លួន (ក្តៅ) លើកលយ ឈ្មោះ គឺសម្ពៈមិនមានខ្លួន (គឺរលាយ) ព្រោះថានោះ ក៏ដល់ខ្លួនសេចក្តីវិនាស ដូចជាដើមត្នោត ដែលគេកាត់ត្រឹមគល់ ។

ឧបហារុ មមំ មេជ្ជោ មាតុក្កស្ស យសស្សិនោ
សសាវកស្ស ពុទ្ធស្ស មេជ្ជា ទេញ្ញា តតោ អហុ ។
ភាវប្ភមិតាយសាសដ្ឋ អសី អព្ភកាវេទុយោ
អញ្ញមញ្ញំ មុសលេ ហត្វា សម្បត្តា យមសាធនំ ។
អជាយំ អសិតា សត្តោ អត្តលាភូចរេ មុរ
តាវេត្តិ បមាំ ចេត្តោ ហិនត្តោ កាលបរិយាយំ ។
តស្មា ហិ ធម្មាកាមេន ចេប្បសំសត្តុ បណ្ឌិតា
អតុដ្ឋចិត្តោ កាសេយ្យ តំ សទ្ធបសត្ថិតំ ។
បធកា ទេ បទុមេន យោ ចរេ មេត្តរេ មុនិ
វិជ្ជាចរណសម្បន្នំ គន្ត្វា សោ ចំរយំ អពោ ។
យេ វុឌ្ឍា បរិកាសត្តិ ជនស្សបញ្ញាមា ជនា
អនបទ្ធា អនាយាតា តាលវត្ថុ គរត្តិ តេ ។
យោ ច បត្វជិតំ ហត្ថិ តតាគិទុំ មហេសិនំ
ស តាធុស្សុត្តេ ចិរយេ ចិរំ វត្តាយ បច្ចតិ ។



ព្រះពុទ្ធព្រះនាម វេស្សភូ ព្រមទាំងបរិស័ទ ញុំាងចិត្តឲ្យជ្រះថ្លា ក្នុងកាលបរិភោគនូវភត្តិឆ្ងាញ់ពិសា មានយស ហើយក៏ដល់នូវសេចក្តីនាស ក្នុងកាលនោះជនឈ្មោះវេស្សភូក៏ទៅជាព្រៃ ។ ក្នុងព្រះពុទ្ធ ជាអាទិត្យវង្សគុតនៅ រៀនៈរៀននូវសីលឈ្មោះគណ្ហាទិបា-មនៈការយកនៅស្រីស្រលាញ់គ្នានឹងគ្នា ហើយក៏ធ្លាក់ទៅក្នុងនរក ។ ព្រះពុទ្ធព្រះនាមៈទក្ខិណេយ្យៈនេះ កាលពីដើមនោះលើកកាសបាន ដល់មកនានីក្រោយ ត្រូវគេបោលសំពៅសាហើយ មានអត្តភាព សាបសូន្យបូលទៅកាន់ផែនដី ដល់នូវសេចក្តីស្លាប់ ព្រោះហេតុនោះ បានជាក្នុងបណ្ឌិតទាំងឡាយសរសើរអ្នក ៤ មានធម្មគុណជាដើមហើយ បុគ្គលមានចិត្តមិនជ្រះថ្លា គប្បីពោលពាក្យប្រកបដោយសច្ចៈ បើនៅតែមានចិត្តជ្រះថ្លាហើយ សំឡុកទៅកាន់អ្នកប្រាជ្ញ ដែលបរិបូណ៌ដោយវិជ្ជានឹងចរណៈ ខណៈនោះនឹងធ្លាក់ទៅក្នុងនរកធានីក្រោម ។ ក្នុងជនណាមានសេចក្តីព្យាយាមមាំក្រៃ លែងប្រ-ទេចក្តុតពាល់ត្រីចក្កបារូ ក្នុងជននោះ (ស្មុះទៅកើតក្នុងភពនីមុខ) គេក្លុងគ្នា គេញ៉ាត់គ្នានូវបណ្តោតកំបុតគល់ ។ ជនណាសម្លាប់បព្វជិតដែលមានគ័ព្ទបើហើយ អ្នកស្វែងរក ខ្វះគុណជាធំ ជននោះរមែងនឹងនៅក្នុងនរកឲ្យសុត្តនៈគស់ការលោយយូរអង្វែង ។

យោ ច រាជា អធម្មដ្ឋោ រដ្ឋវិទ្ធំសនោ មគោ
តាបយិត្វា ជនបទំ តាបនេ បេច្ច បច្ចតិ ។
សោ ច វស្សសហស្សានំ សតំ ទិព្យានិ បច្ចតិ
អច្ចិសង្ឃបរេតោ សោ ទុក្ខំ វេទេតិ វេទនំ ។
តស្ស អគ្គិសិខា កាយា និច្ឆរន្តិ បភស្សរា
តេជោភក្ខស្ស គត្តានិ លោមេហិ ច នខេហិ ច ។
ធូមាយនេ គត្តេន និច្ចំ សន្តាបហីរ
ទុក្ខាភិតុន្នោ នទតិ នាគោ តុត្តដ្ដិតោ យថា[១] ។
យោ លោភា បិតរំ ហន្តិ ទោសា វា បុរិសាធមោ
ស កាលសុត្តេ និរយេ ចិរំ រត្តាយ បច្ចតិ ។

ស តាទិសោ បច្ចតិ លោហកុម្ភិយំ
បក្កញ្ច សត្តីហិ ហនន្តិ និត្តចំ
អន្ធំ ករិត្វា មុត្តករីសភក្ខំ
ខារេ និមុជ្ជន្តិ តថាវិធំ នរំ ។
តត្តំ បក្កុធិតមយោគុឡញ្ច
ទីឃេ ច ផាលេ ចិររត្តតាបិតេ

១ ឱ. តុត្តទ្ទិតោ យថា ។ ម. តុត្តដ្ឋិតោយថា ។



ព្រះរាជាណា មិនតាំងនៅក្នុងធម៌ កំចាត់កំចាយអ្នកដែន ដុតកំ-ដៅអ្នកជនបទ ព្រះរាជានោះលុះច្រើនជីវិតទៅ រមែងឆេះនៅក្នុងតាបននរក ។ ព្រះរាជានោះតែងឆេះអស់មួយសែនឆ្នាំទិព្វ ព្រះរាជានោះត្រូវគំនរអណ្ដាតភ្លើងហ៊ុំព័ទ្ធហើយ ក៏សោយទុក្ខវេទនា ។ អណ្ដាតភ្លើងទាំងឡាយដ៏ភ្លឺស្វាងច្រាលល្អ ផុសចេញអំពីកាយរបស់សត្វនរកនោះ ខ្លួនរបស់សត្វនរកដែលមានភ្លើងជាអាហារ ( មានអណ្ដាតភ្លើងឆេះជាប់ជាមួយគ្នា ) ចេញតាមរោមទាំងឡាយផង ចេញតាមក្រចកទាំងឡាយផង ។ សត្វនរកមានខ្លួនត្រូវភ្លើងឆេះហើយ ចាំទាំងក្នុង ទាំងក្រៅខ្លួន ត្រូវសេចក្ដីទុក្ខចាក់ដោតហើយ ក៏ស្រែកដូចជាដំរី ដែលគេចាក់ដោយកន្ទ្រៀកន្ទុរ ។ បុរសថោកទាប សម្លាប់បិតា ព្រោះតែលោភៈឬព្រោះទោសៈ បុរសថោកទាបនោះ រមែងឆេះនៅក្នុងកាឡសុត្តនរក អស់កាលជាយូរអង្វែង ។ បុរសបែបនោះ រមែងឆេះនៅក្នុងលោហកុម្ភីនរក ពួកនិរយបាល ( នាំចេញ ) ចាក់សម្លាប់ឲ្យខ្ទិច ធ្វើមិនឲ្យមានស្បែក ហើយចាក់ដោយលំពែងទាំងឡាយ ធ្វើឲ្យខ្វាក់ ឲ្យស៊ីនូវមូត្រនិងលាមក ហើយជ្រមុជជនបែបនោះនៅ ក្នុងទឹកខារ ( ទឹកចត់ផែង ) ។ ពួកនិរយបាល ( ញុំាងសត្វនរកឲ្យស៊ីនូវលាមក ) កំពុងពុះ និងដុំដែកដ៏ក្ដៅ ហើយយកបណ្ដាញដែកវែង ដែលគេដុតអស់កាលយូរ

វិក្ខម្ភមានាយ វិកជ្ជ(១) វត្ថុំ
វិវដេ មុខេ សំសវយន្តិ រក្ខសា ។
សាមា ច សោណា សពលា ច គិជ្ឈា
កាកោលសង្ឃា ច ទិជា អយោមុខា
សង្គម្ម ខាទន្តិ វិផន្ទមានំ
ជិវ្ហំ វិភជ្ជ វិឃាសំ សលោហិតំ ។
តំ ទឌ្ឍតាលំ បរិភិន្នគត្តំ
និប្បោថយន្តា អនុវិចរន្តិ រក្ខសា
រតី ហិ នេសំ ទុខិនោ បនីតរេ
ឯតាទិសស្មឹ និរយេ វសន្តិ
យេ កេចិ លោកេ ឥធ បេត្តិឃាតិនោ ។

បុត្តោ ច មាតរំ ហន្ត្វា ឥតោ គន្ត្វា យមក្ខយំ
ភុសមាបជ្ជតេ ទុក្ខំ អត្តកម្មផលូបគោ ។
អមនុស្សា អតិពលា ហន្តារំ ជនយន្តិយា
អយោមយេហិ វាលេហិ បីឡយន្តិ បុនប្បុនំ ។
តំ បស្សវំ សកា គត្តា រុធិរំ អត្តសម្ភវំ
តម្ពលោហវិលីនំវ តត្តំ បាយេន្តិ មត្តិឃំ ។

---
១ ម. វិកន្ត ។



មកបើកមាត់ ( ហើយចាក់សង្កត់ដែក ) ដែលចងនឹង ដោយខ្សែ ( ទាញអណ្តាតចេញហើយចាក់ដុំដែក ) ទៅក្នុងមាត់ ដែលប្រហោះនោះ ៗ ឆ្កែខ្មៅក្រហម ឆ្កែពពាល ក្អែកត្មាត ក្អែកក្អែកនិងពួកសត្វស្លាប ( ឯទៀតច្រើនពួក ) មានចំពុះដែក នាំគ្នាមកដោយពេញចិត្តនាំគ្នាស៊ីនូវអណ្តាត (នៃពួកសត្វនរក) ដែលញាប់ញ័រ (ដូចជាស៊ី) នូវចំណីព្រមទាំងឈាម មានឈាមក្តៅហូរចេញ ៗ ពួកនិរយបាលវាយសំពងសត្វនរកនោះ ដែលក្តៅដក់ក្នុងនេះ មានខ្លួនយេរយោយ ដោយការត្រេកអររបស់ពួកនិរយបាលនោះ ចំណែកខាងសត្វនរកទាំងឡាយក្រៅនេះក៏ដល់នូវសេចក្តីទុក្ខវេទនា ពួកជនណាមួយ ក្នុងលោកនេះ ជាអ្នកសម្លាប់បិតា ពួកជនទាំងនោះតែងទៅកើតក្នុងនរកបែបនុ៎ះ ៗ កូនសម្លាប់មាតា លុះទៅអំពីលោកនេះ ទៅកាន់លំនៅរបស់យមរាជ កាន់យកនូវផលនៃកម្មរបស់ខ្លួន ក៏ដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំង ៗ ពួកអមនុស្ស ( និរយ-បាល ) ក្លាហានក្រៃលែង យកសរសៃដែក ( ខ្សែ ) នូវបុគ្គលអ្នកសម្លាប់មាតា ហើយគាប ( ដោយខ្សែដែក ) រឿយ ៗ ៗ ពួកនិរយបាល ញាំងបុគ្គលអ្នកសម្លាប់មាតានោះ ឲ្យផឹកនូវឈាមដ៏ក្តៅ ដែលហូរចេញអំពីកាយរបស់ខ្លួន ដូចជាទឹកទង់ដែងរលាយ ៗ

ជិគុច្ឆំ កុណបំ បូតី ឧគ្គន្ធំ ទុដ្ឋគន្ធិយំ
បុព្វលោហិតសង្កិណ្ណំ រហោគត្តឃ្ហ(១) និដ្ឋិតំ ។
គម្មេដំ កាមិយោ ធតុ អតិកាយោ អរោមុទា
ជវី កេតាន ទាណខ្និ មតិន្ទា មំសលោហិតេ ។
សោ ច តំ និរយំ បត្តោ និម្មុគ្គោ សតពោរិសំ
បុព្វកំ កុណបំ ភក្ខិ សមន្តា សតយោជនំ ។
ចក្ខុមាបិ ហិ ចក្ខូហិ តេន គន្ធេន ជីយ្យតិ
ឯតាទិសំ ព្រហ្មទត្ត មាតុយោ លភតេ ទុខំ ។
ខុរធារមនុក្កម្ម តិក្ខំ ទុរភិសម្ភវំ
បតន្តិ គព្ភបាតិនិយោ ទុគ្គំ វេត្តរណឹ នទឹ ។
អយោមយា សិម្ពលិយោ សោឡសង្គុលិកណ្ដកា
ឧភតោ អភិលម្ពន្តិ ទុគ្គំ វេត្តរណឹ នទឹ ។
តេ អច្ចិមន្តោ តិដ្ឋន្តិ អគ្គិក្ខន្ធាវ អារកា
អាទិត្តា ជាតវេទេន ឧទ្ធំ យោជនមុគ្គតា ។
ឯតេ បជ្ជន្តិ និរយេ តត្តេ តិខិណកណ្ដកេ
នារិយោ ច អតិចារិនិយោ នរា ច បរទារគូ ។



បុគ្គលអ្នកសម្លាប់មាតានោះ ចុះទៅបិតទៅ ក្នុងរណ្ដៅគួរខ្ពើម ដូចជាអសុភមានក្លិនស្អុយ មានឈាមគ ជាតក់ មានក្លិនអាក្រក់ ប្រហែលគ្នា នឹងខ្ទុះនឹងឈាម ។ ក្នុងនរកនោះមានដង្កូវ ផុត មានខ្លួនធំ មានមាត់ដូចម្ជុលដែក ត្រុគត្រេស ចូលទៅក្នុងសាច់និងឈាមចំណាយទៅស្បែករហូតដល់ឆ្អឹង ហើយស៊ីសត្វនរកនោះ (ជាដីខ្លះក្នុងទីនុ៎ះ) ។ បុគ្គលអ្នកសម្លាប់មាតានោះ ធ្លាក់ទៅក្នុងនរកនោះជ្រៅមួយ(ក្លាស)ចុះទៅ ចំនួនមួយរយជួរប្រុស សាកសពដ៏ស្អុយ ក៏ផ្សាយទៅកាន់ទិសទាំងមួយរយយោជន៍ផងដែរ ។ ព្រោះថា សូម្បីជនមានចក្ខុ ក៏ញាក់ដោយក្លិននោះ ព្រោះតែស្រវឹងចក្ខុ បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសម្លាប់មាតា តែងបានសេចក្ដីទុក្ខបែបនេះ ។ ពួកស្ត្រីល្មួកគត ក្នុងនិន្នាការនៃគេមុខ ដែលគេគ្រងសត្វតេជះដោយក្រ ធ្លាក់ទៅក្នុងស្ទឹងឈ្មោះវេត្តរណី ដែលមិនកបរស្ទើ ។ ដើមរកាកាំមនុស្សដែកពារទៀតដែក មានបន្លាប្រវែងដប់ប្រាំមួយធ្នាប់ ចេញគល់ជ្រុំជ្រើយ ទៅនៃស្ទឹងឈ្មោះវេត្តរណី ដែលមិនកបរស្ទើ ។ ដើមរកាកាំនោះ ក្រហមព្រិលនៃមានអណ្ដាតភ្លើងទៅទៀតទៅរលីង ដូចជាគំនរភ្លើង អំពីឆ្ងាយ ។ ពួកស្រីប្រព្រឹត្តក្បត់ចិត្តប្តី និងពួកប្រុសដែលគប់ភរិយាអ្នកដទៃ ជនទាំងនុ៎ះ រមែងធ្លាក់ទៅក្នុងសិម្ពលិនរក ដែលក្ដៅ មានបន្លាស្រួច

តេ បតន្តិ អធោក្ខន្ធា   វិវត្តា វិហតា បុថុ
ឥសយេន្តិ វិវេជ្ជិត្វា   និយំ ជន្តុ សត្តុណា(១) ។
តតោ រត្យា វិវសនេ   មហាតិ បច្ចុបមំ
លោហកុម្ភី បវជ្ជន្តិ   តត្តំ អគ្គិសមុទកំ ។
ឯវំ ទិវា ច រត្តោ ច   ទុស្សីលា មោហបារុតា
អនុភោន្តិ សកំ កម្មំ   បុព្វេ ទុក្កដមត្តនោ ។
យា ច ភរិយា ធនក្កីតា   សាមិកំ អតិមញ្ញតិ
សស្សុំ វា សសុរំ វាបិ   ជេដ្ឋំ វាបិ ននន្ទនំ
តស្សា វង្កេន ជិវ្ហគ្គំ   និព្វហន្តិ សពន្ធនំ ។
ស ព្យាមមត្តំ កិមិនំ   ជិវ្ហំ បស្សតិ អត្តនោ(២)
វិញ្ញាបេតុំ ន សក្កោតិ   តាបនេ បេច្ច បច្ចតិ ។
ឱរព្ភិកា សូករិកា   មច្ឆិកា មិគពន្ធកា
ចោរា គោឃាតកា លុទ្ទា   អវណ្ណេ វណ្ណការកា ។
សត្តីហិ លោហកូដេហិ   នេត្តិំសេហិ ឧសូហិ ច

---

១ ខ. សាំរែ ។ ២ ទ.ម., អត្តនិ ។



ពួកសត្វនរកទាំងនោះ មានក្បាលចុះក្រោម ត្រូវពួកនិរយបាលចាក់ (ដោយកាំបិត) ត្រឡប់ជើង ក៏លុតធ្លាក់មកវិញ តាមខ្លួនទុះធ្លាយ ពុំមានផុត ពុំមានស្លាប់ អស់កាលជាយូរអង្វែងណាស់ ។ គាថា ៗ (ពួកសត្វនរក ត្រូវពួកនិរយបាលចាប់ផ្ដួលហើយ) ក្នុងនរកឈ្មោះលោហកុម្ភី មានរូបរាងដូចក្អមធំ មានទឹកក្ដៅស្មើនឹងភ្លើងដ៏ក្ដៅ ពុំមានចេះអស់កាលកន្លងទៅនៃត្រើយជាយូរអង្វែង ។ ពួកមនុស្សទ្រុស្តសីល (គប់ប្រពន្ធគេ) ដែលមោហៈគ្របសង្កត់ហើយ ពុំមានដឹងគុណរបស់ខ្លួន ដែលខ្លួនធ្វើបាបក្នុងកាលមុន ទាំងថ្ងៃទាំងយប់ យាំនេះ ៗ ប្រពន្ធណាដែលគេចិញ្ចឹមមកដោយទ្រព្យ មើលងាយប្ដី ម្ដាយក្មេក ឪពុកក្មេក បងប្អូនប្រុស បងប្អូនស្រី ពួកនិរយបាល តែងទាញយកអណ្ដាតព្រមទាំងផល់ របស់នាងនោះព្រមទាំងចំណងដោយសន្ទូច សត្វនរកនោះ ឃើញអណ្ដាតរបស់ខ្លួនប្រមាណមួយព្យាមបញ្ចេញដោយឥតមិនអាចអង្វរ (ពួកនិរ-យបាល) បាន លុះក្រោយមកពុំមានដេកនៅក្នុងនរកបន្តទៀត ។ ពួកអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់ត្រី ចាក់ម្រឹគ ពួកចោរ ពួកអ្នកសម្លាប់គោ ពួកព្រាន ពួកអ្នកធ្វើកុណ្ឌិវាស (អ្នកញុះញង់) ។ ពួកសត្វនរកនោះ ត្រូវពួកនិរយបាលបៀតបៀន ដោយលំពែង ដោយញញួរលោហៈ ដោយសំរែ ដោយព្រួញទាំងឡាយ

ហញ្ញមានា ធារេតិ  បបតន្តិ អវំសិរា ។
សាយំ បាតោ គច្ឆតោរ  អយោគុឡេហិ ហញ្ញតិ
ឥតោ វត្តំ ចុតត្តានំ  បរេសំ ភុញ្ជតេ សទា ។
ខត្វា(១) ហេរណ្ណកាតិជ្ជោ  កាលេ កាលេ ច អយោមុខា
វិច្ឆុមានំ ធាវន្តិ  ខរំ តិក្ខំសតាគតំ ។
យេ មិគេន មិគំ ហន្តិ  បក្ខឹ វា បន បក្ខិនា
អសន្តោ រជសា ឆន្នា  គន្តា តេ និរយុស្សទំ ។
(៩៣) សន្តោ ច ឧទ្ធំ គច្ឆន្តិ  សុចិណ្ណេនិធ កម្មុនា
សុចិណ្ណស្ស ផលំ បស្ស  សឥន្ទា ទេវា សព្រហ្មកា
តំ តំ ព្រូមិ មហារាជ  ធម្មំ រដ្ឋបតី ចរ
តថា តថា រាជ ចរាហិ ធម្មំ
យថា តំ សុចិណ្ណំ នានុតប្បេយ្យ បច្ឆាតិ ។

សត្តិគុម្ពជាតកំ ទុតិយំ ។

---
១ ម. វត្ថា ។



នរកត្រូវសត្វម្ដងៗ ធ្លាក់ទៅក្នុងភ្នំរនារ ។ ពួកនេះក៏ចេញមកវិញ ក្រៅ ពួកនិរយបាល ដេញវាយញញួរដែកកាំទម្លាយចាំងល្ងាចចាំព្រឹក ហើយ ស៊ីរូវកំរួតរបស់ពួកសត្វនរកទាំងនោះ ដែលមានអត្តភាព ត្រូវគេខ្ទេចខ្ទីរជារកាល ។ ពួកខ្លះ បបក ឆ្នាំង ក្រែកក្រែ មាន ចំពុះដែក ពាំត្រាចិតប្រែថ្ងៃ ទុំដង្កួនជើងក្រៅឲ្យត្រូវជាប់ ក្រៅ ។ ពួកជនណាសម្លាប់ម្រឹគ(១) ហើយម្រឹគ សម្លាប់បក្សី(២) ហើយបក្សី ពួកជននោះជាអសប្បុរស ចំរើនដោយខ្ជិល គឺ កាចចិត្តពេល រមែងទៅកាន់នរកខនេក ។

(៩៣) ពួកសប្បុរសក្នុងលោកនេះ មានកម្មសន្សំល្អហើយ តែងទៅកាន់លោកខាងលើ សូមព្រះអង្គទតមើលផលនៃកម្មដែលគេធ្វើល្អ ដូចពួកទេវតាព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រហ្ម បរិវារចេញហើយ សក្ការៈពោលនោះ គឺព្រះអង្គ បរិបូរណ៍ព្រះអង្គបរិបូណ៌នៃ សូមព្រះអង្គប្រព្រឹត្តធម៌ បពិត្រព្រះរាជា អំពើដែលព្រះអង្គប្រព្រឹត្តល្អនោះ មិនគប្បីក្ដៅក្រហាយឡើយ ។ គួរពាល ជាតនិព្រោះយ៉ាងណា ៗ សូមព្រះអង្គប្រព្រឹត្តធម៌យ៉ាងនោះចុះ ។

ចប់ សត្តិគុម្ពជាតក ទី ២ ។

---
១-២- យកម្រឹគ ឬ បក្សីដែលគេធ្លាប់ដាក់ ។

## តស្សុប្បាទំ

ឧជុ សន្ធិបិតាតស្មឹ. សុណោថ មម ភាសិតំ

ជាតការស្សុប្បាទោ ឧបរេ

សោណការអន្តិមស្សុប្បាទោ

តជាវិត្តារថេសកសន្តិទូរភេ ។

សន្ធិនិបាតំ និដ្ឋិតំ ។

---





## ទុក្ខានៃសន្ធិនិបាត

អ្នកទាំងឡាយ ចូរស្តាប់ភាសិតរបស់ខ្ញុំ ក្នុងសន្ធិបាត ចុះចប់

អំពីបញ្ញាសន្ធិបាតនោះនឹង

ទំហាយអំពីឈ្មោះជាតកដ៏ប្រសើរ ដែលនាំមកនូវសោណការករបស់

និងព្រះរាជាទ្រង់ព្រះនាមអន្តិមៈ ។ ព្រះរាជាដ៏ប្រសើរ ក្នុងជ

ដែលយើងពោលហើយដូច្នោះ និងសន្ធិទូតរឿង ។

ចប់ សន្ធិនិបាត ។

---

# សត្តតិនិបាតជាតកំ

## កុសជាតកំ

[៩២] ឥទន្តេ រដ្ឋំ សធនំ សយោគ្គំ
សកាយុរំ សព្វកាមូបបន្នំ
ឥទន្តេ រដ្ឋំ អនុសាស អម្ម
គច្ឆាមហំ យត្ថ បិយា បភាវតី ។

[៩៣] អនុជ្ជុភូតេន ហរំ មហន្តំ
ទិវា ច រត្តោ ច និសីថកាលេ
បដិគច្ឆ ត្វំ ខិប្បំ កុសាវតឹ
និច្ឆាមិ ទុព្វណ្ណមហំ វសន្តំ ។

[៩៤] នាហំ គមិស្សាមិ ឥតោ កុសាវតឹ
បភាវតី វណ្ណបលោភិតោ តវ
រមាមិ មទ្ទស្ស និកេតរម្មេ
ហិត្វាន រដ្ឋំ តវ ទស្សនេ រតោ ។
បភាវតី វណ្ណបលោភិតោ តវ
សម្មូឡ្ហរូបោ វិចរាមិ មេទនឹ
ទិសំ ន ជានាមិ កុតោម្ហិ អាគតោ
តយម្ហិ មត្តោ មិគមន្ទលោចនេ

# សត្តតិនិបាតជាតក

## កុសជាតក

(៩២) ( ព្រះបាទកុសពោធិសត្វ ក្រាបទូលថា ) បពិត្រព្រះមាតា ដែនរបស់ព្រះមាតានេះ ប្រកបដោយទ្រព្យ ប្រកបដោយយាន ប្រកបដោយគ្រឿងសំលៀកបំពាក់ បរិបូណ៌ដោយកាម គ្រប់យ៉ាង សូមព្រះមាតាគ្រប់គ្រងដែន របស់ព្រះមាតានេះចុះ ខ្ញុំនឹងទៅកាន់នគរ ជាទីនៅរបស់នាងបភាវតី ជាទីស្រឡាញ់ ។

(៩៣) ( នាងបភាវតី ពោលថា ) ព្រះអង្គមានព្រះទ័យមិនត្រង់ នាំយកសម្រែកធំ (ទៅវិញ) ទាំងថ្ងៃទាំងយប់ទាំងពេលអធ្រាត្រ សូមព្រះអង្គត្រឡប់ទៅក្រុងកុសាវតីវិញឲ្យឆាប់ ខ្ញុំម្ចាស់មិនចង់ឃើញព្រះអង្គ ដែលមានពណ៌អាក្រក់ មកនៅ ( ក្នុងទីនេះ ) ទេ ។

(៩៤) ( ព្រះពោធិសត្វ... ) ម្នាលនាងបភាវតី អញនឹងមិនទៅអំពីទីនេះ កាន់ក្រុងកុសាវតីទេ ព្រោះអញជាប់ចិត្តនឹងវណ្ណៈរបស់នាង ទើបត្រេកអរក្នុងទីលំនៅជាទីត្រេកអររបស់ព្រះបាទមទ្ទៈ ស៊ូលះបង់ដែន បានត្រេកអរ ក្នុងការឃើញនាង ។ ម្នាលនាងបភាវតី អញជាប់ចិត្តនឹងវណ្ណៈរបស់នាង មានសភាពវង្វេង ត្រាច់ទៅកាន់ផែនដី មិនស្គាល់ទិសថា អញមកអំពីទីណា ម្នាលនាង មានភ្នែកដូចភ្នែកម្រឹគ អញជាមនុស្សវក់ចិត្តក្នុងនាង ។

សោវណ្ណវីរិសារេ   ជាតរូបសុមេធសេ
សុសេដ្ឋិនី នវ តាមាហំ   ហាហំ ផ្ញើន ឥត្ថិយោ ។

(៩៧) អត្ថតិ តស្ស កោ កោចិ   យោ អតិច្ឆន្ត កិច្ចតិ
អកាមំ រាជ កាមេសិ   អកន្តំ កន្តុមិច្ឆសិ(១) ។

(៩៨) អកាមំ វា សកាមំ វា   យោ នរោ លភតេ បិយំ
លាភមេត្ថ បសំសាម   អលាភោ តត្ថ បាបកោ ។

(៩៩) បាសាណសារំ ខណសិ   កណិការស្ស ទារុនា
វាតំ ជាលេន ពាធេសិ   យោ អនិច្ឆន្តមិច្ឆសិ ។

(១០០) បាសាណោ នូន តេ ហទយេ   ឱហិតោ មុទុលក្ខណេ
យោ តេ សាតំ ន វិន្ទាមិ   តិរោជនបទាគតោ ។

១ ម. អកន្តំ កន្តុមិច្ឆសិ ។





ហៃនាងដែលមានទ្រង់ទ្រាយល្អ ដូចជាសរសៃ មាសមានភ្នែកល្អ
ដូចជាកូនមាស ចូរមកក្បែរយើង ជាក់បីប្រាថ្នាសម្បត្តិ
ព្រោះតែសេចក្តីស្រឡាញ់ពីអ្នកនាង ។

(៩៧) (នាងបភាវតី...) បពិត្រព្រះអង្គដ៏បវរ សេចក្តីមិនជាប់ចិត្ត
ដែលមានដល់បុគ្គលដែលស្រឡាញ់ បុគ្គលនោះមិនស្រឡាញ់ (ខ្លួន)
បពិត្រព្រះរាជា ព្រះអង្គមិនជាទីស្រឡាញ់ ចង់បានស្ត្រីជាទី
ស្រឡាញ់ ដែលមិនមានសេចក្តីស្រឡាញ់ ដោយការបង្ខិតបង្ខំ ។

(៩៨) (ព្រះរាជាកុស...) ជនណាបានទទួលនាងជាទីស្រឡាញ់ ទោះ
មិនមានសេចក្តីស្រឡាញ់ក្តី មានសេចក្តីស្រឡាញ់ក្តី យើងសរសើរ
នូវការបានរបស់ជននោះ បណ្តាការបាននិងមិនបាននោះ ឯការ
មិនបាន ទាក់ទាញរបស់លាមក ។

(៩៩) (នាងបភាវតី...) ព្រះអង្គបរិបូណ៌ស្ត្រីដែលមិនចង់បាន
ព្រះអង្គ ដូចជាគេជីកថ្មដោយដើមកណិការ ឬដូចជាគេចាក់
ខ្យល់ដោយសំណាញ់ ។

(១០០) (ព្រះរាជាកុស...) ហៃនាងមានលក្ខណៈទន់ភ្លន់ ឥឡូវនេះ
ក្នុងដួងហឫទ័យនាង មិនបានសេចក្តីស្រួល (ក្នុងសំណាក់) របស់
នាង ហេតុដូចនាងយកថ្មដាក់ទុកក្នុងហឫទ័យ (នៃនាង) ជាយ៉ាងពិត ។

យថា មំ ភាកុដឹ កត្វា  រាជបុត្តិ ឧទិក្ខសិ
អាឡារិកា គតា ហោមិ  រញ្ញោ មនុស្សន្តេបុរេ ។
យថា ឧម្ហយមានា មំ  រាជបុត្តិ ឧទិក្ខសិ
នាឡារិកា គតា ហោមិ  តទា ហោមិ តទា កុសោ ។

(១០១) សចេ ហិ វចនំ សច្ចំ  នេមិត្តានំ ភវិស្សតិ
នេវ មេ ត្វំ បតី អស្ស  កាមំ ឆិន្ទន្តុ សត្តធា ។

(១០២) សចេ ហិ វចនំ សច្ចំ  អញ្ញេសំ យទិ វា មមំ
នេវ តុយ្ហំ បតី អត្ថិ  អញ្ញោ សីហស្សរា កុសា ។

(១០៣) នេត្តំ តីរេ តកាវេស្វំ  ឧត្តា ឧជ្ជំ កុសាវតី
សចេ មំ នាគនាសូរុ  ឱលោកេយ្យ បភាវតី ។
នេត្តំ តីរេ តកាវេស្វំ  បត្តា ឧជ្ជំ កុសាវតី
សចេ មំ នាគនាសូរុ  អាលបេយ្យ បភាវតី ។
នេត្តំ តីរេ តកាវេស្វំ  បត្តា ឧជ្ជំ កុសាវតី
សចេ មំ នាគនាសូរុ  ឧម្ហាយេយ្យ បភាវតី ។



ព្រះរាជបុត្រីធ្វើមុខក្រញូវ ហើយសម្លឹងមើលមកអញ ក្នុងវេលាណា អញក៏ទៅជាជាងបាយពិសេសក្នុងវាំង របស់ព្រះរាជាខាងក្នុង វេលានោះ ។ ព្រះរាជបុត្រី ញញឹមញញែម ក្រឡេកមើលអញ ក្នុងវេលាណា អញមិនទៅជាជាងបាយពិសេស ក្នុងវេលានោះទេ អញទើបជាព្រះរាជាកុសៈក្នុងវេលានោះវិញ ។

(១០១) (នានីបការិ...) ប្រសិនបើពាក្យរបស់ពោរពិតមែន ព្រះអង្គមិនត្រូវបានជាភស្តារបស់ខ្ញុំម្ចាស់ទេ សូមឲ្យគេកាត់ (ខ្ញុំម្ចាស់) ជាប្រាំពីរកំណាត់ចុះ ។

(១០២) (ព្រះរាជិសក...) ប្រសិនបើពាក្យ របស់ពោរផង ឬ របស់អញពិតមែន ភស្តារបស់នាងក្រៅអំពីព្រះរាជាកុសៈ ដែលមានព្រះសូរសៀងដូចសំឡេងសីហៈ ក៏មិនមានទេ ។

(១០៣) ដែលនាងនេះ បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីក្រឡេកមើលអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់តាក់តែង ជាការៈនៃមាសនោះដល់នាង ។ ដែលនាងនេះ បើនាងបភាវតីមានភ្លៅដូចប្រមោយដំរី គប្បីហៅអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់តាក់តែង ជាការៈនៃមាសនោះដល់នាង ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

មហទ្ធនោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

មហព្ពលោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

មហារដ្ឋោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតី

មហារាជោតិ កត្វាន ករស្សុ រុចិរេ បិយំ ។



បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើនូវ ( ក្តីស្នេហ៍ដល់ ព្រះកុសៈនោះ ) មានទ្រព្យច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាង កុំប្រៀបផ្ទឹមនូវព្រះកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើនូវ ( ក្តីស្នេហ៍ដល់ព្រះកុសៈនោះ ) មានកម្លាំងច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើនូវ ( ក្តីស្នេហ៍ដល់ព្រះកុសៈនោះ ) មានដែនធំ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើនូវ ( ក្តីស្នេហ៍ដល់ព្រះកុសៈនោះ ) ជាព្រះរាជាធំ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតិ

សីហស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតិ

វគ្គុស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតិ

ពិន្ទុស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។

មា នំ រូបេន បាមេសិ អារោហេន បភាវតិ

មញ្ជុស្សរោតិ កត្វាន ករស្សុ រុចិរេ បិយំ ។



បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមខ្លួនព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាង សូមធ្វើទុក (ក្នុងហឫទ័យថាព្រះបាទកុសៈនោះ) មានសំឡេងស្មើនឹងសំឡេងនៃសីហៈ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមខ្លួនព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថាព្រះបាទកុសៈនោះ) មានសំឡេងពីរោះ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមខ្លួនព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថាព្រះបាទកុសៈនោះ) មានសំឡេងមូល ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមខ្លួនព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសំឡេងល្អ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

មា នំ រូបេន បាមេសិ   អារោហេន បភាវតិ
មហុស្សក្កោតិ កត្វាន   ករស្សុ រុចិរេ បិយេ ។
មា នំ រូបេន បាមេសិ   អារោហេន បភាវតិ
សព្វសិប្បោតិ កត្វាន   ករស្សុ រុចិរេ បិយេ ។
មា នំ រូបេន បាមេសិ   អារោហេន បភាវតិ
ខត្តិយោតិបិ កត្វាន   ករស្សុ រុចិរេ បិយេ ។
មា នំ រូបេន បាមេសិ   អារោហេន បភាវតិ
កុសរាជាតិ កត្វាន   ករស្សុ រុចិរេ បិយេ ។



បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបធៀបខ្ញុំព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថាព្រះបាទកុសៈនោះ) មានសារស្សុធ ដ៏ផ្ទួមល្អម ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបធៀបខ្ញុំព្រះបាទកុសៈនោះដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសិល្បៈច្រើនហើយ ធ្វើនូវសេចក្តីស្រឡាញ់ចុះ ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបធៀបខ្ញុំព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) ជាក្សត្រិយ៍ (សូរ) ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបធៀប ខ្ញុំព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់បំព្រង ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថាព្រះបាទកុសៈនោះ) ជាព្រះរាជាមាននាមស្មើនឹងស្មៅកុស (ដែលព្រះអង្គប្រទាន) ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

[១០៧]យទា ឆាតា ទុបក្ខា សតេ្ត ខជ្ជិន្តិ វម្មិកា
បុរា មន្តិ ឆាតាវំ អាគតេ បកាតិ ។

(១)
[១០៨]សត្តាហេ សក្កា ទ្វាទស អហមេវំ បការិ
ចត្តារោ បទសោ ហេមំ ហន្ទុំ ធាតកា ។

[១០៩]អជ្ជយា កជបុត្តិ សាមា កោសេយ្យកសិនំ
អសុប្បុណ្ណាហំ ទេវត្តាហំ ឆាសីតណាបុត្តកា ។

[១១០] តំ ទុន ភត្តាបនិសេវិតំ មុទំ
អាពសឆត្តាជបុប្ចវេត្វាតិ
សុកំ សុទេត្តំ វិរជំ អឆគ្គណាំ
ធម្មំ វេទ បស្សតិ ចត្តារោយហំ ។
តេ ទុន មេ អសិតេ វេលិតគ្គេ
កោសេ មុទុ ចង្គសារហិត្តេ
សមាកុលេ សិវជិកាយ បជ្ជេ
តាទេហំ គិជ្ជា បរិកន្តយដ្ឋំ ។

១ សត្តុ ខណ្ឌតិ អដ្ឋកថាយ ទិស្សតិ ។



[១០៧] (កាលណាភ្នំនីទ្បាយ...) ព្រះរាជាព្រះអង្គ ដំរីអស់ទាំង
ឆាព្រះអង្គ កម្ពុជមកហើយ ប្រដាប់ដោយគ្រឿងក្រោះ (សុម
ព្រះអង្គធ្វើព្រះរាជសារកោចា) ខ្ញុំការនីទ្បាយ ចុះទៅព្រះនាង
បភាវតីទាំងមក (បញ្ជូនទៅឲ្យព្រះរាជាទាំងនោះ) កុំឲ្យចំណាយ
កំពង់មុខនាទ ។

[១០៨] (ព្រះរាជា...) អញនឹងធ្វើនាងបភាវតីនុះ ឲ្យជា ៧ កំណាត់
ហើយឲ្យដល់ពួកក្សត្រិយ៍ដែលមកក្នុងទីនេះ ដើម្បីសម្លាប់អញ ។

[១០៩] (អភិសម្ពុទ្ធគាថា)ព្រះរាជបុត្រីមានសម្បុរល្អផ្អែក ទ្រង់ព្រះភូស្ត្រ
ជាវិការៈនៃសូត្រ(ពេលចាដោយមាស) ដែលពួកទាសីកាហាមតាម
ទ្រង់ទាំងពេញដោយព្រះអស្សុជល ចូលទៅកាន់(ពាក់កាសូត) ។

[១១០] (នាងបភាវតី...) បពិត្រព្រះមាតា មុខ (របស់ខ្ញុំ) នោះ
ដាប់លាបប្រហ្មបគ្រឿងលំអិត ខ្ញុំកញ្ចក់មានស្រប ជាវិការៈ
នៃភ្លុក ជាមុខល្អ មានភ្នែកល្អ ឥតមានធូលី គ្រោះពួកក្សត្រិយ៍
លះតាលៈហើយ នឹងកាត់នៅក្នុងព្រៃ ។ ពួកក្អែកនឹងលើករៀនតាំង
ឡាយកកាយខ្លួនសក់ទាំងនោះ របស់ខ្ញុំ ជាសក់ខ្មៅមានចុងដង់
លាបដោយខ្លឹមចន្ទន៍ ឲ្យប្រាប្ដូរច្របល់ ក្នុងកណ្ដាលព្រៃស្មសាន

តា ទ្វេ មេ តម្ពនខា សុលោមា
ពាហា មុទូ ចន្ទនសារលិត្តា
ឆិន្នា វនេ ឧជ្ឈិតា ខត្តិយេហិ
គយ្ហ ធង្ខោ(១) គច្ឆតិ យេន កាមំ ។
តេ នូន តាលបក្កនិភេ អលម្ពេ
និសេវិតេ កាសិកចន្ទនេន
ថនេសុ មេ លម្ពិស្សតិ សិគាលោ
មាតុ ច បុត្តោ តរុណោ តនូជោ ។
តំ នូន សោណឹ បុថុលំ សុកោដ្ដិតំ
និសេវិតំ កញ្ចនមេខលាហិ
ឆិន្នំ វនេ ខត្តិយេហិ អវត្ថំ
សិគាលសង្ឃា បរិកឌ្ឍយន្តិ ។
សោណា ធង្ខា សិគាលា ច យេ ចញ្ញេ សន្តិ ទាឋិនោ
អជរា នូន ហេស្សន្តិ   ភក្ខយិត្វា បភាវតឹ ។
សចេ មំសានិ ហរឹសុ   ខត្តិយា ទូរគាមិនោ
អដ្ឋីនិ អម្ម យាចិត្វា   អនុបន្ថេ ទហាថ នំ ។
ខេត្តានិ អម្ម ការេត្វា   កណិការេសុ រោបយេ

១ ម. ធង្កោ ។



ស្ដួកដៃ របស់ខ្ញុំនោះ ដែលមានក្រចកក្រហម មានរោមល្អ ទន់ លាបដោយខ្លឹមចន្ទន៍ ដាច់ធ្លាក់ឆ្ងាយ ដែលពួកក្សត្រិយ៍ចោលក្នុងព្រៃ ហើយហើរទៅតាមប្រាថ្នា ។ ចចកឃើញស្ដន របស់ខ្ញុំនោះ ស្រដៀងនឹងផ្លែត្នោត មិនយារ លាបដោយខ្លឹមចន្ទន៍ ដ៏ល្អិត ហើយបៀម នូវស្ដន របស់ខ្ញុំនោះ ដូចជាកូនខ្ចីបង្កើត ដែលបៀមនូវស្ដន របស់មាតា ។ ហ្វូងចចក ស៊ីនូវត្រគាក ( របស់ខ្ញុំ ) នោះ ដ៏ស្អាតទូលាយ ដែលគេជិតល្អហើយ ពាក់ដោយ ខ្សែក្រវាត់មាសទាំងឡាយ ដាច់ធ្លាក់ឆ្ងាយ ដែលពួកក្សត្រិយ៍ចោលក្នុងព្រៃ ។ ពួកឆ្កែ ក្អែក ចចក និងសត្វឯទៀត ដែលមានចង្កូម ស៊ីនាងបភាវតី មុខជានឹងមិនចាស់ទ្រុឌទ្រោមដោយពិត ។ ប្រសិនបើពួកក្សត្រិយ៍ដែលទៅឆ្ងាយ នាំយកសាច់ទាំងឡាយ (របស់ខ្ញុំ)ទៅ បពិត្រព្រះមាតាថ្លៃ ព្រះអង្គសូមយកឆ្អឹងទាំងឡាយ ហើយដុតឆ្អឹងនោះក្នុងទីបន្ទាប់ផ្លូវ (ក្នុងទីជាខ្នាតផ្លូវដើរនឹងផ្លូវធំ) ។ បពិត្រព្រះមាតា សូមព្រះ-មាតាប្រើគេធ្វើស្រែចម្ការ ហើយដាំដើមកណិការក្នុងស្រែចម្ការនុ៎ះ

យស្សា តេ បុប្ផិតា អស្សុ   ហោមគ្គាំ ឃរមត្ថុយេ
សរេយ្យាថ មមំ អម្ម   បវណ្ណា ឧការតំ ។
(១១១)ឥស្សា មានា ចុតជ្ជាសំ   ខត្តិយា នេវណ្ណិនី
និស្សា អសិញ្ច សុនញ្ច   ព្រោញ មនុស្សព្ភរុបរេ ។
(១១២)នមិហា ក្នុន អសិតា   សុសញ្ញា តនុមជ្ឈិមា
ជីតាំ មត្ថុ ហត្ថាន   ខត្តិយានំ ឧធស្សរំ(១)
(១១៣)ឯមេ អកាសំ វជេ   អត្តតាមាយ បុត្តិកោ
ស្វាជ្ជិ លោហិតសញ្ជា   គច្ចំ យមសាធនំ ។
បវមាចជ្ជិតំ ពោសោ   ចាមិយញ្ញ ចិតច្ចិត
យោ ចេ ហិតានំ វជេ   ធ គារេតិ អត្តនស្សិ
សទេវ អជ្ជ ចាវេតិ   គាមានំ ចារុនស្សំ
អារុសេន ជាតំ ខត្តិយំ   សុវណ្ណមណិមេខលំ ។
ឬជិតំ ញាតិសង្ឃេហិ   ន គច្ចតំ យមក្ខយំ

---
(១ ឧ.ម. បរស្សំ)



ក្នុងវេលាណាដែលរាជមេឃណាំការពាំងនោះបាននាំ ក្នុងវេលាណានោះទៅ នៃកាលជាទីត្រាក់នៃទឹកសេរ្សជើងក្នុងហោមគ្គម៉ូ បពិត្រព្រះមាតា សូមព្រះមាតា ត្រូវនឹកចាំ នានីបការកើ មានច្បាប់ យ៉ាងនេះ ។

(១១១) (អភិសម្ពុទ្ធគាថា) ក្សត្រិយ៍មានវណ្ណៈដូចវណ្ណៈទៅកាជា មាតារបស់នាងមានបារកើនោះ ព្រោកពាកសមេះទៅកាន់សំណាក់ព្រះពាជៈហើយ បានឃើញជាតិនឹងច្រៀងក្នុងព្រះរាជកំឯព្រះបាទមន្ទៈ ។

(១១២) (ព្រះមាតា...) បពិត្រព្រះបាទមន្ទៈ ព្រះអគ្គនីសម្លាប់ទីការដែលគេបំណាំបានដោយកាយ មានចង្កេះរៀវ ដោយប៉ុំប៉ោនេះ ហើយប្រហារ ឥតពួកក្សត្រិយ៍ដោយពិត ។

(១១៣) វៃហបុត្រ នាងមិនបានធ្វើតាមពាក្យរបស់អញដែលប្រាថ្នាប្រ-យោជន៍ នាងមុខជានឹងពេញការដោយឈាម ហើយទៅកាន់ភពរបស់មច្ចុរាជ ក្នុងថ្ងៃនេះ ។ បើសត្វដែលមិនធ្វើតាមពាក្យរបស់ពួកជនដែលបង្ហាញសេចក្តីចំរើន បង្ហាញប្រយោជន៍ហើយ តែងប៉ះទង្គិចយ៉ាងនេះផង តែងជួបប្រទះនូវសេចក្តីអាក្រក់ជាង(នេះ)ផង ។ បើក្នុងថ្ងៃនេះនាងនឹងបានប្រទះនូវក្រសាស្រស់បំប៉ែប ជាក្សត្រិយ៍ដែលកើតព្រោះព្រះបាទកុសរាជទៀតក៏ជាកែវៈនៃមាសនឹងកែវប-ណ៌ដែលពួកញាតិបូជាហើយ នាងនឹងមិនទៅកាន់សំនៅយមរាជទេ

យត្ថស្សុ ភេរី នទតិ    កុញ្ជរោ ច និកូជតិ
ខត្តិយានំ កុលេ ភន្តេ    កឹ នុ សុខតរំ តតោ ។
អស្សោ ហសិយតិ[1] ទ្វារេ    កុមារោ ឧបរោទតិ
ខត្តិយានំ កុលេ ភន្តេ    កឹ នុ សុខតរំ តតោ ។
មយូរកោញ្ចាភិរុទេ    កោកិលាភិនិកូជិតេ
ខត្តិយានំ កុលេ ភន្តេ    កឹ នុ សុខតរំ តតោ ។

(១០៤) កហំ នុ សោ សត្តុមទ្ទនោ    បររដ្ឋប្បមទ្ទនោ
កុសោ សោឡារបញ្ញាណោ យោ នោ ទុក្ខា បមោចយេ ។

(១០៥) ក្វ នេវ សោ សត្តុមទ្ទនោ    បររដ្ឋប្បមទ្ទនោ
កុសោ សោឡារបញ្ញាណោ យោ នេ សត្តេ វធិស្សតិ ។

(១០៦) ឧម្មត្តិកា នុ ភណសិ    អន្ធពាលា បភាសសិ
កុសោ ចេ អាគតោ អស្ស    កឹ នុ ជានេមុ តំ មយំ ។

---

១ ម. អស្សោ ច សិសតិ ។



ដែលមានដំណើរ ស្គរលាន់ឮក្តី ដំរីស្រែកក្តី ក្នុងខត្តិយត្រកូលណា (នាងឃើញ) អ្វីដែលជាសុខក្រៃលែងជាងខត្តិយត្រកូលនោះ (បានដល់មានមកគង់នៅទីនេះ) ។ សេះក្តៀរប្រចាំប្រៀបទ្វារ កុមារស្រែកយំប្រកែក ក្នុងខត្តិយត្រកូលណា ដែលមានដំណើរ (នាងឃើញ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយត្រកូលនោះ ។ កាលបើក្ងោកនិងក្រៀលយំនិងតាវ៉ៅយំពីរោះហើយនិងកងក្នុងខត្តិយត្រកូលណា ដែលមានដំណើរ (នាងឃើញ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយត្រកូលនោះ ។

(១០៤) ព្រះបាទកុសរាជអ្នកញាំញីនូវសត្រូវ ញាំញីដែនរបស់ព្រះរាជដទៃ មានប្រាជ្ញាធំ សប្បុរសនឹងឲ្យរួចចាកទុក្ខបាន តើនៅក្នុងទីណា ។

(១០៥) (នាងបភាវតី...) ព្រះបាទកុសរាជអ្នកញាំញីនូវសត្រូវ ញាំញីដែនរបស់ព្រះរាជដទៃ មានប្រាជ្ញាធំ សម្លាប់ក្សត្រិយ៍ទាំងអស់នោះ នៅក្នុងទីនេះឯង ។

(១០៦) (ព្រះមាតា...) នាងជាស្រីឆ្កួត ជាស្រីល្ងង់ពាល ពោលតែនិយាយ (ឡប់ឡែកពេក) បើព្រះបាទកុសរាជស្តេចមក ពួកយើងនឹងដឹងច្បាស់ស្គាល់ព្រះបាទកុសរាជនោះបាន ។

(១៥៧) ឯសោ អគ្គិនិកាសោ ហោសោ កុមារីបុរមន្តរេ

ពន្ធុំ ភក្ខាន សំវេល្លំ កុម្ភីនោ តិដ្ឋតោ ។

(១៥៨) វណ្ណំ ត្វមសិ ចណ្ឌាលី អត្តសិ កុលគន្ធិនី

កថំ មទ្ទកុលេ ជាតា ទាសំ កយិរាសិ សាមិកំ ។

(១៥៩) នម្ហិ វណ្ណេន ចណ្ឌាលី ន ចម្ហិ កុលគន្ធិនី

ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។

(១៦០) យោ ព្រាហ្មណសហស្សានិ សទា ភោជេតិ វីសតិ

ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។

យស្ស នាគសហស្សានិ សទា យោជេន្តិ វីសតិ

ឱក្កាកបុត្តោ ភទ្ទន្តេ ត្វំ នុ ទាសោតិ មញ្ញសិ ។



(១៥៧) (នាងបភាវតី...) (ព្រះបាទកុសៈ) គឺបុរសនាយពិសេសនុះ ជាអ្នកយកដំរី ទុកហានផ្លាំង (សូមព្រះមាតាទត) ក្រលំបន្ទោះដំណាក់កុមារ ។

(១៥៨) (ព្រះមាតា...) នាងជាស្រីនៃត្រកូលជាន់ទាប ជាស្រីចណ្ឌាល ឬជាស្រីប្រទូស្តត្រកូលទេឬ នាងកើតក្នុងត្រកូលព្រះបាទមទ្ទៈ ធ្វើអ្វីស្វាមី (របស់ខ្លួន) ឲ្យជាទាសៈ ដូចម្ដេចកើត ។

(១៥៩) (នាងបភាវតី...) ខ្ញុំមិនមែនជាស្រីត្រកូលជាន់ទាប មិនមែនស្រីចណ្ឌាល មិនមែនជាស្រីប្រទូស្តត្រកូលទេ បពិត្រព្រះមាតា (ព្រះបាទកុសៈនោះ) ជាបុត្ររបស់ព្រះបាទឧក្កាកៈ (ចំណែកទាន) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ ។

(១៦០) ព្រះបាទកុសៈណា ញុំាងពួកព្រាហ្មណ៍ពីរម៉ឺននាក់ ឲ្យបរិភោគសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះជាបុត្ររបស់ព្រះបាទឧក្កាកៈ (ចំណែកទាន) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងទឹមដំរីពីរម៉ឺនរបស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្ររបស់ព្រះបាទឧក្កាកៈ (ចំណែកទាន) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ ។ ពួកជន តែងទឹមសេះ ពីរម៉ឺន របស់ព្រះបាទកុសៈណា សព្វកាល

យស្ស អស្សសហស្សានិ សទា យោជេន្តិ វីសតិ

ឱក្កាកបុត្តោ កុសវត្តេ ត្វំ តុ ទាសោតិ មញ្ញសិ ។

យស្ស រថសហស្សានិ សទា យោជេន្តិ វីសតិ

ឱក្កាកបុត្តោ កុសវត្តេ ត្វំ តុ ទាសោតិ មញ្ញសិ ។

យស្ស ធេនុសហស្សានិ សទា ទុហន្តិ វីសតិ

ឱក្កាកបុត្តោ កុសវត្តេ ត្វំ តុ ទាសោតិ មញ្ញសិ ។

(១៦១) កស្ស តេ ទុក្កដំ ពាលេ យំ ខត្តិយំ មហព្វលំ

នាគំ មណ្ឌូកវណ្ណេន ន តំ អក្ខាសិ អាគតំ ។

(១៦២) អបរាធំ មហារាជ ត្វំ នោ ខម រថេសភ

យំ ត្វំ អញ្ញាតវេសេន នាញ្ញាសិម្ហា ឥធាគតំ ។

(១៦៣) មាទិសស្ស ន តំ ឆន្នំ យោហំ អាឡារិកោ ភវេ

ត្វញ្ញេវ មេ បសីទស្សុ នត្ថិ តេ ទេវ ទុក្កដំ ។



បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្ររបស់ព្រះបាទឧក្កាកៈ (ចំណែកនាង) ព្រះមាតាទេវី សំគាល់ថាជាទាសៈទៅវិញ ។ ពួកជន តែងទឹមរថចំនួនម្ភៃពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះជាបុត្ររបស់ព្រះបាទឧក្កាកៈ (ចំណែកនាង) ព្រះមាតាទេវី សំគាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងរឹតទឹកដោះមេគោ ចំនួនម្ភៃពាន់ របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះជាបុត្ររបស់ព្រះបាទឧក្កាកៈ (ចំណែកនាង) ព្រះមាតាទេវី សំគាល់ថាជាទាសៈទៅវិញ ។

(១៦១) (ព្រះកុស...) ម្នាលស្រីពាល ហេតុអ្វីនាងធ្វើខុសដល់ក្សត្រិយ៍ ដែលមានកម្លាំងច្រើន ដូចជាដំរី ដោយភេទនៃកង្កែប នាងមិនបានប្រាប់ក្សត្រិយ៍នោះដែលបានមកហើយ ។

(១៦២) បពិត្រមហារាជ ជាបុគ្គលប្រសើរលើរថ សូមព្រះអង្គទ្រង់អត់កំហុសដល់យើង ព្រោះយើងមិនបានដឹងថា ទ្រង់យាងមក ក្នុងទីនេះ ដោយក្លែងវេសៈ ។

(១៦៣) (ព្រះមហាសត្វ...) បពិត្រព្រះសម្មតិទេព ដំណើរដែលខ្ញុំព្រះបង្គំជាខ្ញុំធ្វើជាតាយពិសេសភាទៈ មិនគប្បីដល់ជនដូចខ្ញុំព្រះបង្គំជាខ្ញុំ សូមព្រះអង្គជ្រះថ្លានឹងខ្ញុំព្រះបង្គំជាខ្ញុំចុះ ទោស របស់ព្រះអង្គមិនមានទេ ។

(១៦៦) គច្ឆ ពាលេ ខមាបេហិ   កុសរាជំ មហព្វលំ

ខមាបិតោ កុសរាជា   សោ តេ ទស្សតិ ជីវិតំ ។

(១៦៧) បិតុស្ស វចនំ សុត្វា   ទេវវណ្ណី បភាវតី

សិរសា អគ្គហី បាទេ   កុសរាជំ មហព្វលំ ។

(១៦៨) យាមា[១] រត្យោ អតិក្កន្តា   តា មា ទេវ តយា វិនា

វន្ទេ តេ សិរសា បាទេ   មា មេ កុជ្ឈ រថេសភ ។

សច្ចំ តេ[២] បដិជានាមិ   មហារាជ សុណោហិ មេ

ន ចាបិ អប្បិយំ តុយ្ហំ   ករេយ្យាមិ អហំ បុន ។

ឯវញ្ចេ យាចមានាយ   វចនំ មេ ន កាហសិ

ឥទានិ មំ តាតោ ហន្ត្វា   ខត្តិយានំ បទស្សតិ ។

---

១ ម. យាមា ។ ២ ម. សច្ចន្តេ ។



(១៦៦) (ព្រះរាជា...) ម្នាលស្រីពាល នាងឯង ចូរទៅសូមខមាទោសនឹងព្រះបាទកុសៈ ដែលមានកម្លាំងច្រើន ព្រះបាទកុសៈនោះ កាលបើនាងសូមខមាទោសហើយ នឹងប្រទានជីវិតដល់នាង ។

(១៦៧) (អភិសម្ពុទ្ធគាថា) នាងបភាវតី មានវណ្ណៈដូចជាវណ្ណៈនៃទេវតា ឮព្រះឱង្ការ របស់ព្រះបិតា (ក៏ក្រាប) ដោយសិរសៈ អោបចាប់ព្រះបាទកុសៈដ៏មានកម្លាំងច្រើន ត្រង់ព្រះបាទាបាន ។

(១៦៨) (នាងបភាវតី...) បពិត្រព្រះសម្មតិទេព ពេលរាត្រីទាំងនោះ វៀរចាកព្រះអង្គកន្លងទៅ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ ខ្ញុំម្ចាស់សូម (ក្រាប) ដោយត្បូង ថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះអង្គ សូមព្រះអង្គកុំក្រោធនឹងខ្ញុំម្ចាស់ ។ បពិត្រមហារាជ ខ្ញុំម្ចាស់សូមប្តេជ្ញាពាក្យពិតចំពោះព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់ខ្ញុំម្ចាស់ ។ ខ្ញុំម្ចាស់នឹងមិនធ្វើនូវការមិនស្រឡាញ់ព្រះអង្គទៀតឡើយ ។ កាលបើខ្ញុំម្ចាស់អង្វរករយ៉ាងនេះហើយ បើព្រះអង្គនឹងមិនធ្វើតាមពាក្យខ្ញុំម្ចាស់ទេ ព្រះរាជបិតាមុខជានឹងសម្លាប់ខ្ញុំម្ចាស់ក្នុងវេលានេះ ហើយប្រទានដល់ពួកក្សត្រិយ៍មិនខាន ។

(១៦៧) ឯវញ្ចេ យាចមានាយ  កិំ ន កាហាមិ តេ វចោ
វិកុទ្ធោ ត្យស្មិ កល្យាណិ  មា ត្វំ ភាយិ បភាវតិ ។
សព្វន្តេ បដិជានាមិ  រាជបុត្តិ សុណោហិ មេ
ន ចាបិ អប្បិយំ តុយ្ហំ  ករេយ្យាមិ អហំ បុន ។
តវ កាមា ហិ សុស្សោណិ  បហុ ទុក្ខំ តិតិក្ខិសំ
ពហុំ មទ្ទកុលំ ហន្ត្វា  នយិតុំ តំ បភាវតិ ។

(១៦៨) យោជយន្តុ រថេ អស្សេ  នានាចិត្តេ សមាហិតេ
អថ ទក្ខថ មេ វេគំ  វិធមន្តស្ស សត្តវោ ។
តញ្ច តត្ថ ឧទិក្ខិំសុ  រញ្ញោ មទ្ទស្សន្តេបុរេ
វិជម្ភមានំ សីហំវ  ផោដេន្តំ ទិគុណំ ភុជំ ។

(១៦៩) ហត្ថិក្ខន្ធញ្ច អារុយ្ហ  អារោបេត្វា បភាវតិំ
សង្គាមំ ឱតរិត្វាន  សីហនាទំ នទី កុសោ ។



(១៦៧) (ព្រះមហាសត្វ...) កាលបើនាងអង្វរយ៉ាងនេះហើយ យើងនឹងមិនធ្វើតាមពាក្យរបស់នាងឯណាបាន ម្នាលនាងបភាវតី ម្នាលនាងកល្យាណី បងលែងខឹងនឹងនាងហើយ នាងកុំភ័យឡើយ ។ ម្នាលនាងរាជបុត្រី យើងសូមប្ដេជ្ញាពាក្យពិតចំពោះនាង ១ ចូរស្ដាប់ពាក្យរបស់យើង ។ លែងធ្វើនូវសេចក្ដីមិនជាទីស្រឡាញ់នាងទៀត ។ ម្នាលនាងបភាវតី ជាស្រីមានចង្កេះរៀវ យើងអត់ទ្រាំសេចក្ដីទុក្ខច្រើនដង ព្រោះតែចង់បាននាង យើងហ៊ានសម្លាប់ត្រកូលរបស់ព្រះបាទមទ្ទៈជាច្រើន ហើយនាំយកនាងទៅបាន ។

(១៦៨) ពួកជនទាំងឡាយ ចូរទឹមសេះនឹងរថ ដោយគ្រឿងប្រដាប់ផ្សេងៗ ជាសត្វរៀបរយគួរ កាលបើទឹមហើយ អ្នកទាំងឡាយមុខជានឹងឃើញកម្លាំង របស់ខ្ញុំដែលកំចាត់ពួកខ្មាំងបាន ។ (អភិសម្ពុទ្ធគាថា) ពួកស្រីក្នុងព្រះរាជវាំង របស់ព្រះបាទមទ្ទៈ (នាំគ្នាបើកបង្អួច) អោកមើលព្រះបាទកុសៈនោះដែលកំពុងម៉ត តក់កំពុងទង្គិចដើមដៃទាំងពីរតាង ដូចជាសីហៈក្នុងទីនោះ ។

(១៦៩) ព្រះបាទកុសៈ លើកព្រះនាងបភាវតី ឡើងកាន់កដំរី លុកលុយចូល ទៅក្នុងសង្គ្រាម ហើយក៏បន្លឺសីហនាទ ។

តស្ស តំ វចនំ សុត្វា សីហស្សេវិតរេ មិគា
ទន្តិយោ វិបលាយឹសុ កុសសទ្ទភយដ្ដិតា ។
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
អញ្ញមញ្ញស្ស ឆិន្ទន្តិ កុសសទ្ទភយដ្ដិតា ។
តស្មឹ សង្គាមសីសស្មឹ បស្សិត្វា ហដ្ឋមានសោ
កុសស្ស រញ្ញោ ទេវិន្ទោ អទា វេរោចនំ មណឹ ។
សោ តំ វិជិត្វា សង្គាមំ លទ្ធា វេរោចនំ មណឹ
ហត្ថិក្ខន្ធគតោ រាជា បាវេក្ខិ នគរំ បុរំ ។
ជីវគ្គាហំ គហេត្វាន ពន្ធិត្វា សត្ត ខត្តិយេ
សសុរស្សុបនាមេសិ ឥមេ តេ ទេវ សត្តវោ ។
សព្វេវ តេ វសំ គតា អមិត្តា វិហតា តវ
កាមំ ករោហិ តេ តយា មុញ្ច វា តេ ហនស្សុ វា ។



ពួកក្សត្រិយ៍ឮព្រះបាទកុសៈទ្រង់បន្លឺសីហនាទនោះ ត្រូវភ័យគំរាមសំឡេងគំរាម នៃព្រះបាទកុសៈបៀតបៀនហើយ ក៏នាំគ្នារត់បែកខ្ញែកដូចជាពួកម្រឹគដទៃ (ដែលភ័យនឹងសំរែក) នៃសីហៈ ។ ពួកពលហស្ដី ពលសេះ ពលរថ ពលថ្មើរជើង ត្រូវភ័យគំរាមសំឡេងនៃព្រះបាទកុសៈបៀតបៀនហើយ ក៏កាប់ចាក់គ្នាទៅវិញទៅមក ។ ទេវិន្ទជាធំជាងទេវតាបានឃើញហើយក៏មានព្រះហឫទ័យរីករាយ បានប្រទានកែវមណីឈ្មោះវេរោចនៈ ដល់ព្រះបាទកុសៈក្នុងប្រធានទីនៃសង្គ្រាមនោះ ។ ព្រះរាជានោះលុះឈ្នះសង្គ្រាមនោះ បានកែវមណីឈ្មោះវេរោចនៈ ហើយគង់លើកដំរីក៏យាងចូលទៅកាន់បុរី ។ ព្រះបាទកុសៈ បានចាប់យកក្សត្រិយ៍ទាំង ៧ អង្គទាំងរស់ ចងនាំមកថ្វាយ ដល់ព្រះបិតាក្មេកថា បពិត្រព្រះសម្មតិទេព ក្សត្រិយ៍ទាំង ៧ នេះហើយជាសត្រូវរបស់ព្រះអង្គ ។ ពួកក្សត្រិយ៍ជាសត្រូវទាំងអស់ ជាអ្នកបៀតបៀនព្រះអង្គ លុះក្នុងអំណាច របស់ព្រះអង្គហើយ សូមព្រះអង្គធ្វើតាមបំណង របស់ព្រះអង្គចុះ ទោះព្រះអង្គលែងក្សត្រិយ៍ទាំងនោះ ឬសម្លាប់នូវក្សត្រិយ៍ទាំងនោះចុះ ។

(១៣០) តុយ្ហេវ សត្តុកេ ឯតេ ន ហេតេ មយ្ហ សត្តុកេ
ត្វញ្ញេវ នោ មហារាជ មុញ្ច វា តេ ហនស្សុ វា ។

(១៣១) ឥមា តេ ធីតរោ សត្ត ទេវកញ្ញូបមា សុភា
ទទាហិ នេសំ ឯកេកំ ហោន្តុ ជាមាតរោ តវ ។

(១៣២) អម្ហាកញ្ចេវ តាសញ្ច ត្វំ នោ សព្វេសមិស្សរោ
ត្វញ្ញេវ នោ មហារាជ ទេហិ នេសំ យទិច្ឆសិ ។

(១៣៣) ឯកមេកស្ស ឯកេកំ អទា សីហស្សរោ កុសោ
ខត្តិយានំ តទា តេសំ ភរិយា មទ្ទស្ស ធីតរោ ។
បីណិតា តេន លាភេន តុដ្ឋា សីហស្សរេ កុសេ
សករដ្ឋានិ បាយឹសុ ខត្តិយា សត្ត តាវទេ ។



(១៣០) (ព្រះរាជា...) បពិត្រមហារាជ ព្រះរាជាទាំងនុ៎ះ ជាសត្រូវ របស់ព្រះអង្គ ព្រះរាជាទាំងនោះ មិនមែនជាសត្រូវ របស់ខ្ញុំទេ ព្រះអង្គ(ជាម្ចាស់) របស់ពួកយើងស្រាប់ហើយ ទោះលែងក្សត្រិយ៍ទាំងនោះ ឬសម្លាប់ពួកក្សត្រិយ៍ទាំងនោះចុះ ។

(១៣១) (ព្រះមហាសត្វ...) ធីតាទាំងឡាយរបស់ព្រះអង្គទាំង ៧ នេះ ល្អមានឧបមាដោយទេវកញ្ញា សូមព្រះអង្គប្រទានធីតាមួយអង្គ ៗ ដល់ព្រះរាជាទាំងនោះ ៗ ចូរជាកូនប្រសា របស់ព្រះអង្គចុះ ។

(១៣២) (ព្រះបាទមទ្ទៈ...) បពិត្រមហារាជ ព្រះអង្គជាម្ចាស់ របស់ពួកយើងទាំងអស់គ្នា គឺ (ព្រះរាជាទាំង ៧ នេះផង) ខ្ញុំផង ធីតាទាំងនោះផង ព្រះអង្គប្រាថ្នានឹង (ប្រទាន) ធីតាណា (ដល់ព្រះរាជាណា) សូមប្រទាន (ធីតានោះ) ដល់ព្រះរាជានោះចុះ ។

(១៣៣) (អភិសម្ពុទ្ធគាថា) ព្រះបាទកុសៈមានព្រះសូរសៀងស្មើនឹងសំឡេងសីហៈ បានប្រទានពួកធីតារបស់ព្រះបាទមទ្ទៈមួយអង្គ ៗ ដល់ក្សត្រិយ៍ទាំងនោះមួយអង្គ ៗ ។ ពួកក្សត្រិយ៍ទាំង ៧ អង្គ មានព្រះហឫទ័យស្កប់ស្កល់ ដោយលាភនោះហើយ ក៏ត្រេកអរ ចំពោះព្រះបាទកុសៈ ដែលមានព្រះសូរសៀងស្មើនឹងសំឡេងសីហៈ បានទៅកាន់ដែនទាំងឡាយរៀងខ្លួនក្នុងលំដាប់នោះឯង ។

ឧបការិកា អាសាយ   មណី វេរោចនំ សុភំ
កុសាវតី កុសោ រាជា   វេគមាសំ ឧបាគមេ ។
តស្ស ឯការេ យន្តា   បវិសន្តា កុសាវតិ
សមាគេ វណ្ណរូបេន   អញ្ញមញ្ញានុកេចិតំ ។
មាតា បុត្តេន សង្គញ្ឆិ   ឧភយោ ច ជយម្បតី
សមគ្គា តេ តទា អាសុំ   ផីតំ ធរណិមាវសុន្តិ ។

កុសជាតកំ បឋមំ ។

## សោណនន្ទជាតកំ

(១៣៦) ទេវតា នុសិ គន្ធព្វោ   អាទុ សក្កោ បុរិន្ទទោ
មនុស្សភូតោ ឥទ្ធិមា   កថំ ជានេមុ តំ មយំ ។
(១៣៧) នាម្ហិ ទេវោ ន គន្ធព្វោ   នាម្ហិ សក្កោ បុរិន្ទទោ
មនុស្សភូតោ ឥទ្ធិមា   ឯវំ ជានាហិ ភារធ ។



ចំណែកឯព្រះបាទកុសៈមានកម្លាំងច្រើន បានគាំយកនាងបភាវតី ដែលបានមណី ឈ្មោះវេរោចនៈដ៏ល្អ ហើយទ្រង់ស្តេចយាងត្រឡប់ទៅកាន់ក្រុងកុសាវតីវិញ ។ ក្សត្រិយ៍ទាំងនោះគង់លើរថជាមួយគ្នា ហោះហើរចូលទៅកាន់ក្រុងកុសាវតី ស្មើគ្នាដោយវណ្ណៈនឹងរូប មិនត្រូវឡើងជាងគ្នាប៉ុន្មានទេ ។ ព្រះមាតាបានជួបជុំដោយបុត្រ ចំណែកឯអគ្គមហេសីនិងព្រះរាជស្វាមីទាំងពីរព្រះអង្គនោះ បានព្រមព្រៀងគ្នា នៅគ្រប់គ្រងផែនដីដ៏សម្បូណ៌សប្បាយក្នុងកាលនោះ ។

ចប់ កុសជាតក ទី ១ ។

## សោណនន្ទជាតក

(១៣៦) (ព្រះរាជាព្រះនាម មនោជៈ ត្រាស់សួរថា) លោកជាទេវតាឬជាគន្ធព្វ ជាសក្កបុរិន្ទទៈ ឬជាមនុស្សមានឫទ្ធិ យើងដូចម្តេច យើងនឹងស្គាល់លោកបាន ។

(១៣៧) (តាបសឈ្មោះនន្ទបណ្ឌិតពោលថា) អាត្មាភាពមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ អាត្មាភាពជាមនុស្សមានឫទ្ធិ បពិត្រព្រះរាជាជាធំក្នុងភារៈ(ដែន) សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។

(១៣៦) តាតស្សុបមិដ្ឋំ កោ តេ　វេយ្យាវច្ចំ អនប្បកំ

ទេវម្ហិ វស្សមានម្ហិ　អនោវស្សំ ភវំ អគា ។

ឧណ្ហេ ច អាតបេ ឃោរេ　សីតច្ឆាយំ ភវំ អគា

គតោ អមិត្តមជ្ឈេសុ　សរតាណំ ភវំ អគា ។

គតោ ជីតាជំ រដ្ឋាជំ　វសិតោ តេ ភវំ អគា

គតោ បញ្ចសតំ ទទេ្យ　អនុយន្តេ ភវំ អគា ។

បតិតាសស្ស មយំ កោ តេ វរំ កុញ្ជមិច្ឆសិ

ហត្ថិយានំ អស្សរថំ　នារិយោ ច អលង្កតា

និវេសនានិ រម្មានិ　មយំ កោ តេ ទទាមសេ ។

អជវត្ថេ ភ មគធេ　មយំ កោ តេ ទទាមសេ

អជភ អស្សកាវន្តី　សុមនា ធម្មនេ មយំ ។

ឧបឌ្ឍំ ភវំ រដ្ឋស្ស　មយំ កោ តេ ទទាមសេ

សាចេ តេ អត្ថោ រជ្ជេន　អនុសាស យទិច្ឆសិ ។



(៩៣៦) (ព្រះបាទមហេរាជ...) ការខ្វល់ខ្វាយបំរើ មានគាថាដែល
លោកដ៏ចំរើនធ្វើហើយ នេះជាការមិនមែនតិច កាលដែល
ភ្លៀងកំពុងធ្លាក់ចុះ លោកដ៏ចំរើនតាមធ្វើមិនឲ្យមានភ្លៀងបាន ។
កាលក្ដៅមក លោកដ៏ចំរើនតាមធ្វើឲ្យម្លប់ត្រជាក់បាន ក្នុងទីមាន
ខ្យល់និងកំដៅថ្ងៃខ្លាំង កាលបានមក លោកដ៏ចំរើន តាមធ្វើ
គ្រឿងការពារគ្រប់ញ ក្នុងកណ្ដាលនៃសត្រូវទាំងឡាយបាន ។
កាលបានមក លោកដ៏ចំរើនតាមធ្វើដែនទាំងឡាយជាសម្បូណ៌(ដី)
ម្នាក់ដែនទាំងនោះឲ្យល្អក្នុងដែនពាក (របស់យើងខ្ញុំ) កាលបានមក
លោកដ៏ចំរើនតាមធ្វើក្រោយ ១០០ ឲ្យជាចំណុះ(នៃយើងខ្ញុំបាន) ។
យើងខ្ញុំត្រេកអរនឹងលោកដ៏ចំរើន លោកចង់បានវត្ថុ ( ណា )
ចូរទទួលយកវត្ថុនោះចុះ យើងខ្ញុំប្រគេនយានដំរី រថសេះ គួរ
នារីនាដែលប្រដាប់ស្រេច ទាំងលំនៅដ្ឋានឲ្យត្រេកអរទាំងឡាយ
ដល់លោកដ៏ចំរើន ។ មួយទៀត យើងខ្ញុំប្រគេនដែនអង្គៈ ឬ
មគធៈ ដល់លោកដ៏ចំរើន មួយទៀត យើងខ្ញុំសប្បាយចិត្ត
ប្រគេនដែនអស្សកៈ ឬដែនអវន្តីដល់លោក ។ យើងខ្ញុំប្រគេន
កន្លះពាក់កណ្ដាល ដល់លោកដ៏ចំរើន បើលោកត្រូវការដោយ
កន្លះ លោកចង់បានរបស់ណា សូមត្រូវប្រាប់របស់នោះចុះ ។

(១៣៧) ន មេ អត្ថោ ហិរញ្ញេន គាមេន នគរេន វា

អថោបិ ជនបទេន អត្ថោ មយ្ហំ ន វិជ្ជតិ ។

(១៣៨) តវេវ រដ្ឋេ វិជិតេ អរញ្ញេ អត្ថិ អស្សមោ

បិតា មយ្ហំ ជនេត្តី ច ឧភោ សម្មន្តិ អស្សមេ ។

តេសាហំ បុព្វាចរិយេសុ បុញ្ញំ ន លភាមិ កាតវេ

ភវន្តំ អជ្ឈាវរំ កត្វា សោណំ យាចេមុ សំវរំ ។

(១៣៩) ការោមិ តេ តំ វចនំ យំ មំ ភណសិ ព្រាហ្មណ

ឯតញ្ច ខោ នោ អក្ខាហិ កីវន្តោ ហោន្តុ យាចកា ។

(១៤០) បរោសតំ ជានបទា មហាសាលា ច ព្រាហ្មណា

ឥមេ ច ខត្តិយា សព្វេ អភិជាតា យសស្សិនោ

ភវញ្ច រាជា មនោជោ អលំ ហេស្សន្តិ យាចកា ។

(១៤១) ហត្ថី អស្សេ ច យោជេន្តុ រថំ សន្នយ្ហ សារថិ



(១៣៧) (ខ្ញុំបពិត្រតាបស...) អាត្មាភាព មិនត្រូវការដោយប្រាក់
ដោយស្រុក ឬដោយក្រុង ទាំងមិនត្រូវការដោយជនបទទេ ។
(១៣៨) ក្នុងព្រៃក្នុងដែនជាអាណាខេត្តរបស់ព្រះអង្គដ៏ចំរើន មាន
អាស្រមមួយ បិតាមាតារបស់អាត្មាភាពទាំងពីរនាក់ នៅក្នុង
អាស្រមនោះ ។ អាត្មាភាពមិនបានធ្វើបុណ្យចំពោះបុព្វាចារ្យ
ទាំងនោះ យើងធ្វើព្រះអង្គដ៏ចំរើនឲ្យប្រសើរលើសលុប ឲ្យសូម
នូវការប្រជុំជាមួយនឹងសោណបណ្ឌិតតាបស ។
(១៣៩) (ព្រះរាជា...) បពិត្រព្រាហ្មណ៍ ខ្ញុំធ្វើតាមពាក្យរបស់លោក
ដែលលោកពោលនឹងខ្ញុំ សូមលោកប្រាប់ហេតុនោះ ដល់យើង
ខ្ញុំ ត្រូវឲ្យពួកជនប៉ុន្មាននាក់ ជាអ្នកជួយអង្វរ ។
(១៤០) (ខ្ញុំបពិត្រតាបស...) ពួកគហបតីមហាសាលជាងមួយ
រយ ពួកព្រាហ្មណ៍មហាសាលជាងមួយរយ និងពួកក្សត្រិយ៍ទាំង
អស់ ដែលមានជាតិខ្ពង់ខ្ពស់ មានយសទាំងនេះ ទាំងព្រះបាទមនោជៈ
ដ៏ចំរើន ទើបល្មមជាអ្នកជួយអង្វរ ។
(១៤១) (ព្រះរាជា...) ពួកអ្នករក្សាដំរី ពួកអ្នករក្សាសេះ ចូរនាំ
គ្នា តាក់តែងនូវពួកដំរីពួកសេះ ម្នាលសារថី អ្នកចូរប្រដាប់រថ

អាតប្បនាចិ គច្ឆាមិ   ហានាសុស្សូសយេច្ចវេ
អស្សមន្តំ គមិស្សាមិ   យត្ថ សម្មតិ កោសិយោ ។

(១៦២)តតោ ចក្កជាតាយកំ   សេនាយ ចតុរង្គិនី
អគមាសិ អស្សមំ រម្មំ   យត្ថ សម្មតិ កោសិយោ ។

(១៦៣)កស្ស កាទម្ពយោ កាជោ   វេហាសំ ចតុរង្គុលំ
អំសំ អសំផុសំ ឯតិ   ឧទហារស្ស គច្ឆតោ ។

(១៦៤)អហំ សោណោ មហារាជ   តាបសោ សហិតព្វតោ
ភរាមិ មាតាបិតរោ   រត្តិន្ទិវមតន្ទិតោ ។
វនេ ផលញ្ច មូលញ្ច   អាហរិត្វា ទិសម្បតិ
បោសេមិ មាតាបិតរោ   បុព្វេកតមនុស្សរំ ។

(១៦៥)ឥច្ឆាម អស្សមំ គន្តុំ   យត្ថ សម្មតិ កោសិយោ
មគ្គំ នោ សោណ អក្ខាហិ   យេន គច្ឆេមុ អស្សមំ ។



អ្នកទាំងឡាយ ចូរយកគ្រឿងប្រដាប់សម្រាប់ចង (ឯដំរីសេះរថ) ជនទាំងឡាយ ចូរលើកទង់ជ័យ ត្រង់ដើមទង់ជ័យដែលដាក់លើរថ អញនឹងទៅកាន់អាស្រមជាទីនៅនៃកោសិយគោត្ត ។

(១៦២) (អភិសម្ពុទ្ធគាថា) លំដាប់នោះមក ព្រះរាជាចុះយាន ទៅដោយសេនាប្រកបដោយអង្គ ៤ ទ្រង់ស្តេចទៅកាន់អាស្រម ជាទីរីករាយ ជាទីនៅនៃកោសិយគោត្ត ។

(១៦៣) (ព្រះបាទមនោជៈ...) ដងរែក ជាវិការៈនៃឈើកទម្ពរបស់អ្នកណា ដែលទៅផងទឹក ហើយមិនប៉ះពាល់ស្មា ទៅលើអាកាសប្រមាណ ៤ ធ្នាប់ ។

(១៦៤) (ព្រះមហាសត្វ...) បពិត្រមហារាជ អាត្មាភាពជាតាបស ឈ្មោះសោណៈ ប្រកបដោយវត្ត មិនខ្ជិលច្រអូស ចិញ្ចឹមមាតាបិតា ទាំងយប់ទាំងថ្ងៃ ។ បពិត្រព្រះអង្គជាម្ចាស់នៃទិស អាត្មាភាព រលឹកឃើញឧបការៈដែលមាតាបិតាធ្វើក្នុងកាលមុន ហើយក៏យកផ្លែឈើនិងមើមឈើក្នុងព្រៃ មកចិញ្ចឹមមាតាបិតា ។

(១៦៥) (ព្រះរាជា...) យើងនឹងចង់ទៅកាន់អាស្រម ជាទីនៅរបស់កោសិយគោត្ត បពិត្រព្រះសោណៈ សូមលោកប្រាប់ផ្លូវដល់យើង យើងនឹងទៅកាន់អាស្រម ។

(១៤៦)អយំ ឯកបទី រាជ យេនេតំ មេឃសន្និភំ
កោវិឡារេហិ សញ្ឆន្នំ ឯត្ថ សម្មតិ កោសិយោ ។

(១៤៧)ឥតិ វត្វាន បក្កាមិ តរមានោ មហាឥសិ
វេទេហោ អន្តលិក្ខស្មិំ អនុសាសេត្វាន ខត្តិយេ ។
អស្សមំ បរិមជ្ជិត្វា បញ្ញាបេត្វាន អាសនំ
បណ្ណសាលំ បវិសិត្វា បិតរំ បដិពោធយិ ។
ឥមេ អាយន្តិ រាជានោ អភិជាតា យសស្សិនោ
អស្សមា និក្ខមិត្វាន និសីទ ត្វំ មហាឥសេ ។
តស្ស តំ វចនំ សុត្វា តរមានោ មហាឥសិ
អស្សមា និក្ខមិត្វាន សទ្វារម្ហិ(១) ឧបាវិសិ ។

(១៤៨)តញ្ច ទិស្វាន អាយន្តំ ជលន្តំរិវ តេជសា
ខត្តសង្ឃបរិព្យូឡ្ហំ កោសិយោ ឯតទព្រវិ ។
កស្ស ភេរី មុទិង្គា ច សង្ខា បណវទិន្ទិមា
បុរតោ បដិបន្នានិ ហាសយន្តា រថេសភំ ។

១ ម. បទ្វារម្ហិ ។



(១៤៦) (ព្រះមហាសត្វ...) បពិត្រព្រះរាជា ផ្លូវដើរទោលនេះ ទៅ
នេះ មានទៅត្រង់ឈើមានព័ណ៌ដូចពពកមេឃ ដ៏ដេរដាសដោយដើម
ល្ហុសផ្ទីង ជាទីនៅរបស់កោសិយគោត្រ ។

(១៤៧) (អភិសម្ពុទ្ធគាថា) លុះមហាឥសីពោលពាក្យនេះទូលប្រាប់
ក្សត្រិយ៍ហើយ ប្រញាប់ប្រញាល់ទៀសចេញទៅ (កាន់ស្រះ
អនោតត្ត) តាមអាកាសវេហាស៍ មហាឥសី ក៏បោសសំអាត
អាស្រម រៀបចំអាសនៈ ចូលទៅកាន់បណ្ណសាលាហើយដាស់
បិតាឲ្យក្រោកថា បពិត្រមហាឥសី ព្រះរាជាទាំងនេះ មាន
ជាតិខ្ពស់ មានយស យាងមក សូមព្រះបិតាចេញអំពីអាស្រម
មកគង់ទាំងខ្លួន ។ មហាឥសីឮពាក្យនោះរបស់កូននោះហើយ
ក៏ប្រញាប់ប្រញាល់ ចេញអំពីអាស្រម មកគង់ជិតទ្វារ ។

(១៤៨) កោសិយគោត្រតាបស បានឃើញស្តេចនោះ ដូចជារុងរឿង
ដោយតេជះ មានពួកក្សត្រិយ៍ហែហម ក៏ពុទ្ធបានមក ហើយពុន
ពោលពាក្យនេះថា ស្គរ សង្ខ ស័ព្ទ ស្គរតូចនិងបណ្ឌឹតរបស់
អ្នកណាទាំងនេះស្តេចជាបុគ្គលប្រសើរលើរថ ឲ្យរីករាយទៅខាងមុខ ។

កស្ស កញ្ចនបដ្ដេន បុថុនា វិជ្ជុវណ្ណិនា
យុវា កលាបសន្នទ្ធោ កោ ឯតិ សិរិយា ជលំ ។
ឧក្កាមុខបហដ្ឋំវ ខទិរង្គារសន្និភំ
មុខញ្ច រុចិរា ភាតិ កោ ឯតិ សិរិយា ជលំ ។
កស្ស បគ្គហិតំ ឆត្តំ សសលាកំ មនោរមំ
អាទិច្ចរំសាវរណំ កោ ឯតិ សិរិយា ជលំ ។
កស្ស អង្គំ បរិគ្គយ្ហ វាលវីជនិមុត្តមំ
ចរន្តិ វរបុញ្ញស្ស ហត្ថិក្ខន្ធេន អាយតោ ។
កស្ស សេតានិ ឆត្តានិ អាជានីយា ច វម្មិតា
សមន្តា បរិកិរន្តិ កោ ឯតិ សិរិយា ជលំ ។
កស្ស ឯកសតំ ខត្យា អនុយន្តា យសស្សិនោ
សមន្តានុបរិយន្តិ កោ ឯតិ សិរិយា ជលំ ។
ហត្ថិអស្សរថបត្តិ សេនា ច ចតុរង្គិនី
សមន្តានុបរិយន្តិ កោ ឯតិ សិរិយា ជលំ ។



(ទីបផ្ទុកដាស) នៃអ្នកណា (ប៉ែងប៉ុន) ដោយបន្ទះមាសផង មានពណ៌ដូចជាផ្លេកបន្ទោរ ប្រុសកំលោះណា សៀតបំពង់ព្រួញ ទ្រើងរឿងដោយសិរី ហើយដើរមក ។ អ្នកណាមានមុខទ្រើងរឿងភ្លឺចាំង ដូចជាមាសក្លំវិញ្ញាចេញចាកមាត់ជាង ប្រហៀងនឹងរងើកភ្លើងនៃខ្លឹមគគីរ ទ្រើងរឿងដោយសិរី ហើយដើរមក ។ អ្នកណា ចាំងឆត្រព្រមទាំងឆ្អឹង ជាទីគាប់នៃចិត្ត ការពាររស្មីព្រះអាទិត្យ អ្នកណាទ្រើងរឿងដោយសិរី ហើយដើរមក ។ ពួកជនប៉ែងបាំងផ្លិតវិជនី នៃអ្នកណា ដែលមានបុណ្យដ៏ប្រសើរ ក៏ពួនជិះលើកនៃដំរី ដោយចំកៀមសងខាង ហើយដើរទៅ ។ ពួកឆត្រសទាំងពួកសេះអាជានេយ្យប្រដាប់ដោយក្រោះខ្ទាស់ខ្ទាប់ជុំវិញនៃអ្នកណា អ្នកណាទ្រើងរឿងដោយសិរីហើយដើរមក ។ ពួកក្សត្រិយ៍មួយរយមួយ សុទ្ធតែមានយសជាស្តេចចំណុះ ដើរហែហមជុំវិញនៃអ្នកណា អ្នកណាទ្រើងរឿងដោយសិរី ដើរមក ។ ពួកសេនាប្រកបដោយអង្គ ៤ គឺដំរី១ សេះ១ រថ១ ពលថ្មើរជើង១ ដើរហែហមជុំវិញ (នៃអ្នកណា) អ្នកណាទ្រើងរឿងដោយសិរី ដើរមក ។

កស្សេសា មហតី សេនា បិដ្ឋិតោ អនុវត្តតិ

អក្ខោភិណី អបរិយន្តា សាគរស្សេវ ឧម្មិយោ ។

(១៤៩)រាជាភិរាជា មនោជោ ឥន្ទោវ ជយតំ បតិ

នន្ទស្សជ្ឈាវរំ ឯតិ អស្សមំ ព្រហ្មចារិនំ ។

កស្សេសា មហតី សេនា បិដ្ឋិតោ អនុវត្តតិ

អក្ខោភិណី អបរិយន្តា សាគរស្សេវ ឧម្មិយោ ។

(១៥០)អនុលិត្តា ចន្ទនេន កាសិកុត្តមធារិនោ

សព្វេ បញ្ជលិកា ហុត្វា ឥសីនំ អជ្ឈុបាគមុំ ។

(១៥១)កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ

កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។

កច្ចិ ឌំសា មកសា ច អប្បមេវ សរីសបា



សេនាដ៏ធំនេះ មិនមានអ្នកណាមួយឲ្យកម្រើកបាន មិនមានទីបំផុត ដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃអ្នកណា ។

(១៤៩) (ព្រះមហាសត្ត...) ព្រះបាទមនោជៈ ជាព្រះរាជាប្រសើរ ជាងពួកព្រះរាជា ដូចជាព្រះឥន្ទ្រជាធំជាងពួកទេវតា ក្នុងឋានត្រៃត្រិង្ស ដែលមានជ័យជំនះ បានស្តេចចូលមកកាន់អាស្រមនៃនន្ទ-តាបស មកកាន់អាស្រមនៃពួកព្រហ្មចារីបុគ្គល(ដើម្បីខមាទោសនឹងយើង) ។ សេនាដ៏ធំនេះ មិនមានអ្នកណាមួយ ឲ្យកម្រើកបាន មិនមានទីបំផុតដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃព្រះបាទមនោជៈនោះ ។

(១៥០) (អនុលិត្តា...) ពួកព្រះរាជាទាំងអស់ លាបស្រឡាប ដោយខ្លឹមចន្ទន៍ ទ្រង់កាសិកពស្ត្រដ៏ឧត្តម បានផ្គងអញ្ជលីចូលទៅរកពួកឥសី ។

(១៥១) (ព្រះបាទមនោជៈ...) លោកដ៏ចំរើន មានសេចក្តីសុខស្រួលទេឬ លោកដ៏ចំរើន មានអនាម័យទេឬ លោកទាំងឡាយ ចិញ្ចឹមជីវិត ដោយការស្វែងរកឬ មើមឈើនិងផ្លែឈើ មានច្រើនដែរឬ ។ ពួករបោម មូស គស់ មានតិចតួចដែរឬ

វនេ វាឡមិគាកិណ្ណេ កច្ចិ ហិំសា ន វិជ្ជតិ ។
(១៩២)កុសលញ្ចេវ នោ រាជ អថោ រាជ អនាមយំ
អថោ ឧញ្ឆេន យាបេម អថោ មូលផលា ពហូ ។
អថោ ដំសា មកសា ច អប្បមេវ សរីសបា
វនេ វាឡមិគាកិណ្ណេ ហិំសា មយ្ហំ ន វិជ្ជតិ ។
ពហូនិ វស្សបូគានិ អស្សមេ សម្មតំ វនេ
នាភិជានាមិ ឧប្បន្នំ អាពាធំ អមនោរមំ ។
ស្វាគតំ តេ មហារាជ អថោ តេ អទុរាគតំ
ឥស្សរោសិ អនុប្បត្តោ យំ ឥធត្ថិ បវេទយ ។
តិន្ទុកានិ បិយាលានិ មធុកេ កាសុមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ រាជ វរំ វរំ ។
ឥទម្បិ បានីយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហារាជ សចេ ត្វំ អភិកង្ខសិ ។



ក្នុងព្រៃដែលដាសដោយម្រឹគសាហាវ មិនបៀតបៀនទេឬ ។

(១៩២) (កោសិយគោត្ត...) បពិត្រព្រះរាជា ពួកខ្ញុំព្រះអង្គ មានសេចក្ដីស្រួលទេ បពិត្រព្រះរាជា មួយទៀត ពួកខ្ញុំព្រះអង្គ មិនមានសេចក្ដីឈឺចាប់ទេ ពួកខ្ញុំព្រះអង្គ ចិញ្ចឹមជីវិតដោយការស្វែងរក (ផលាផល) ស្រួលទេ ទាំងមើមឈើទាំងផ្លែឈើក៏មានច្រើន ។ មួយទៀត ពួករបោម មូស ពស់ ក៏មានតិចតួចទេ ក្នុងព្រៃដែលដាសដោយម្រឹគសាហាវ ក៏មិនបៀតបៀនខ្ញុំព្រះអង្គទេ ។ ខ្ញុំព្រះអង្គ មកនៅក្នុងព្រៃសមរម្យនេះ អស់ប៉ុន្មានឆ្នាំជាច្រើន មិនដែលស្គាល់អាពាធ មិនជាទីត្រេកអរនៃចិត្ត កើតឡើងទេ ។ បពិត្រមហារាជ ព្រះអង្គយាងមកល្អហើយ មួយទៀត ព្រះអង្គមិនមែនយាងមកអាក្រក់ទេ ព្រះអង្គជាឥស្សរៈ យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមព្រះអង្គមានព្រះបន្ទូល ។ បពិត្រព្រះរាជា សូមព្រះអង្គសោយផ្លែទន្លាប់ ផ្លែព្រីង ផ្លែស្រគំ ផ្លែមាក់ម៉ាក មានរសឆ្ងាញ់ពិសា ដូចជាទឹកឃ្មុំ ។ ទឹកត្រជាក់នេះ ខ្ញុំព្រះអង្គ ដងយកមក អំពីជ្រោះភ្នំ បពិត្រមហារាជ សូមព្រះអង្គសោយទឹកនោះចុះ ប្រសិនបើទ្រង់ត្រូវការ ។

(១៨៥)បដិគ្គហិតំ យំ ទិន្នំ សព្វស្ស អគ្ឃិយំ កតំ
នន្ទស្សាបិ និសាមេថ វចនំ សោ បវក្ខតិ ។
អជ្ឈាវរម្ហា នន្ទស្ស ភោតោ សន្តិកមាគតា
សុណាតុ មេ ភវំ វចនំ នន្ទស្ស បរិសាយ ច ។

(១៨៦)បរោសតំ ជានបទា មហាសាលា ច ព្រាហ្មណា
ឥមេ ច ខត្តិយា សព្វេ អភិជាតា យសស្សិនោ
ភវញ្ច រាជា មនោជោ អនុមញ្ញន្តុ មេ វចោ ។
យេ ច សន្តិ សមីតារោ យក្ខានិ ឥធ មស្សមេ
អរញ្ញេ ភូតភព្យានិ សុណន្តុ វចនំ មម ។
នមោ កត្វាន ភូតានំ ឥសី វក្ខាមិ សុព្វតំ
សោ ត្យាហំ ទក្ខិណា បាហុ តវ កោសិយ សម្មតោ ។



(១៨៥) (ព្រះរាជា...) របស់ណាដែលលោកឲ្យហើយ (របស់នោះ) ឈ្មោះថា យើងខ្ញុំទទួលហើយ ការទទួលធ្វើឲ្យជាទីគួរដល់ជនទាំងពួង លោកក៏បានធ្វើហើយ សូមស្ដាប់ពាក្យនន្ទបណ្ឌិតតាបស លោកនឹងនិយាយនូវពាក្យនេះ ពួកយើងជាបរិស័ទនៃនន្ទបណ្ឌិត-តាបស បានមកកាន់សំណាក់នៃលោកដ៏ចំរើន សោណបណ្ឌិតដ៏ចំរើន សូមស្ដាប់ពាក្យ នៃខ្ញុំផង នៃបរិស័ទរបស់នន្ទបណ្ឌិត-តាបសផង ។

(១៨៦) (នន្ទបណ្ឌិតតាបស...) ពួកជនបទមហាសាលជាច្រើនរយ ពួកព្រាហ្មណមហាសាលជាច្រើនរយ និងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចំរើន សូមព្រមតាមសំដីរបស់អាត្មាភាពចុះ ។ ពួកជនដែលមកជួបជុំគ្នា ពួកយក្ស ពួកភូតនិងទេវតា ក្នុងទីអាស្រមក្នុងព្រៃនេះ សូមស្ដាប់នូវពាក្យរបស់អាត្មា ។ អាត្មាធ្វើនមស្ការដល់ពួកភូតហើយ នឹងនិយាយចំពោះឥសី (ឈ្មោះសោណបណ្ឌិត) ដែលមានវត្តល្អថា ខ្ញុំនោះហើយដែលកោ-សិយគោត្តសន្មតថាជាដៃស្ដាំ របស់លោក ។

បិតរំ មេ ជនេត្តិ ច ភត្តការស្ស មេ សតោ
វរំ បុញ្ញមិតំ ហនំ មា មំ កោសិយ វារយ ។
សត្តិហតំ ខុបញ្ញាតំ មមេតំ ខុបធិស្សតិ
ឧដ្ឋានចារិយាយេ ជីយន្តំ តយា កតំ
មាតាបិតុសុ បុញ្ញានិ មម លោកគតោ កតំ ។
ការេយំ សន្តិ មនុជា ធម្មេ ធម្មបតិ វិទូ
មគ្គោ សគ្គស្ស លោកស្ស យថា ជានាសិ ត្វំ ឥសេ ។
ឧដ្ឋានចារិយាយេ មាតាបិតុសុខាវហំ
តំ មំ បុញ្ញា និវារេតិ អរិយមគ្គាវរោ នរោ ។
(១៥៥)សុណន្តុ ភោន្តោ វចនំ ភាតុរដ្ឋាភិ មម
កុលវំសំ មហារាជ ពោរាណំ បរិហាបយំ ។
អធម្មចារី ជេដ្ឋេសុ និរយំ សោ ឧបបជ្ជតិ ។



បពិត្រអ្នកមានព្យាយាម ការទំនុកបម្រើមាតាបិតានេះ ជាបុណ្យរបស់ខ្ញុំដែលជាគ្រឿងគ្រាច់ចិញ្ចឹមបិតាមាតារបស់ខ្ញុំ បពិត្រព្រះកោសិយៈ សូមលោកកុំឃាត់ខ្ញុំឡើយ ។ ការទំនុកបម្រុងមាតាបិតានុ៎ះ ពួកសប្បុរសបានដឹងហើយ សូមលោកលះនូវការទំនុកបម្រើមាតាបិតានេះឲ្យដល់ខ្ញុំ លោកបានធ្វើ (កុសល) ដោយការខ្នះខ្នែងនឹងការបម្រើយូរយារណាស់មកហើយ (សព្វថ្ងៃនេះ ខ្ញុំចង់ធ្វើ) បុណ្យទាំងឡាយដល់មាតានិងបិតា សូមលោកប្រគល់ស្ម័គរទៅលោកដល់ខ្ញុំ ។ បពិត្រឥសី លោកដឹងផ្លូវទៅកាន់សួគ៌ទៅលោកយ៉ាងណា ពួកមនុស្សក៏ដឹងចំណែកធម៌ ក្នុងធម៌ក៏យ៉ាងនោះដែរ គឺបោរាណិកបុរសបានក្តីសុខដល់មាតាបិតា ដោយការខ្នះខ្នែងការបំរើ សព្វថ្ងៃនេះ ផង (សោណបណ្ឌិត) ហាមឃាត់ខ្ញុំនោះ ជាគបុណ្យ ឈ្មោះថាជាអ្នកកាត់ផ្លូវថ្កើងប្រសើរ (បានសួគ៌) ។

(១៥៥) (ព្រះមហាសត្វ...) លោកដ៏ចំរើនទាំងឡាយ ដែលជាបរិស័ទនៃប្អូនរបស់ខ្ញុំ សូមស្តាប់ពាក្យរបស់ខ្ញុំ បពិត្រមហារាជ អ្នកណា មិនប្រព្រឹត្តធម៌ ចំពោះបុគ្គលជាច្បងទាំងឡាយ ញ៉ាំងប្រវេណីពីបុរាណឲ្យសាបសូន្យ អ្នកនោះរមែងទៅកើតក្នុងនរក ។

យេន ធម្មស្ស កុសលា ពោរាណស្ស ទិសំបតិ
ចារិត្តេន ច សម្បន្នា ន តេ គច្ឆន្តិ ទុគ្គតិំ ។
មាតា បិតា ច ភាតា ច ភគិនី ញាតិពន្ធវា
សព្វេ ជេដ្ឋស្ស តេ ភារា ឯវំ ជានាហិ ភារថ ។
អាទិយិត្វា គរុំ ភារំ នាវិកោ វិយ ឧស្សហេ
ធម្មញ្ច នប្បមជ្ជាមិ ជេដ្ឋោ ចស្មិ រថេសភ ។
(១៨៦)អធិគន្តា(១) តមេ ញាណំ ជាលំវ ជាតវេទតោ
ឯវមេវ នោ ភវំ ធម្មំ កោសិយោ បវិទំសយិ ។
យថា ឧទយមាទិច្ចោ វាសុទេវោ បភង្ករោ
បាណីនំ បវិទំសេតិ រូបំ កល្យាណបាបកំ
ឯវមេវ នោ ភវំ ធម្មំ កោសិយោ បវិទំសយិ ។
(១៨៧)ឯវំ មេ យាចមានស្ស អញ្ជលី នាវពុជ្ឈថ
តវ បទ្ធចរោ ហេស្សំ វុដ្ឋិតោ បរិចារកោ ។

---

១ ឱ. អធិគន្តា ។ ម. អធិគមា ។



បពិត្រព្រះអង្គជាម្ចាស់នៃទិស ពួកជនណាឈ្លាសវៃក្នុងធម៌(ផ្លូវ-បុរាណធម៌) ជាប្រព្រឹត្តតាំងពីបុរាណ ព្រមទាំងបរិបូណ៌ដោយសណ្ដាប់ធ្នាប់ ពួកជននោះរមែងមិនទៅកាន់ទុគ្គតិទេ ។ បពិត្រព្រះអង្គជាអ្នកទ្រទ្រង់នូវរថ (ផែន) សូមព្រះអង្គទ្រាបយ៉ាងនេះថា មាតាបិតា បងប្អូនប្រុសស្រី ញាតិនិងផៅពង្សទាំងអស់នោះជាភារៈរបស់ខ្ញុំបាទ ។ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ អាត្មាភាពស៊ូទ្រាំនាយសំពៅកាន់យកនូវភារៈធ្ងន់ អាត្មាភាពពុំប្រមាទនូវផ្លូវបុរាណធម៌ទេ ព្រោះអាត្មាភាពជាច្បង ។

(១៨៦) ( ព្រះកជាពីឥឡូវ... ) ពួកយើងបានញាណដូចបុគ្គលបានអណ្ដាតភ្លើងអំពីភ្លើង ក្នុងទីងងឹត លោកកោសិយតាបសដ៏ចំរើនបានធ្វើសម្ដែងនូវធម៌ដល់ពួកយើង យ៉ាងនេះឯង ។ ព្រះអាទិត្យដែលបំភ្លឺនូវទ្រព្យ ធ្វើពន្លឺកាលរះឡើង តែងសម្ដែងនូវរូបល្អអាក្រក់ ដល់សត្វទាំងឡាយយ៉ាងណា លោកកោសិយៈដ៏ចំរើន បានធ្វើសម្ដែងនូវធម៌ដល់ពួកយើង ក៏យ៉ាងនោះដែរ ។

(១៨៧) (ឧទ្ទុបល្ខិតតាបស...) កាលបើខ្ញុំអង្វរយ៉ាងនេះហើយ លោកនៅតែមិនទទួលអញ្ជលី ខ្ញុំនឹងជាអ្នកប្រព្រឹត្តតាមពាក្យ ជាអ្នកប្រើបំរើលោក ។

(១៥៨)អច្ឆរា ទេវ វីជាហសិ សព្វង្គំ សព្វាភេសិតំ
អភិយា អភិយសមាបាទេ ពាន្យ ត្វំ មម ព្រូសិ ។
កាវត្តំ វជាមិ កោតិញ្ញ សុណោម វចនំ មម
ទាយំ កាកេ ការមន្តោ អហុ មយ្ហំ កុណាចធំ ។
តំ មំ ឧបដ្ឋិតំ សន្តំ មាតាបិតុសុទាវហំ
ទេវោ អជ្ឈាវរំ កត្វា ឧបដ្ឋានាយ យាចតិ ។
យោ ចេ វន្ទតិ កាមេន សក្កាចំ ព្រហ្មចារិនំ
ធម្មំ ចរំ វរជ បរោក្ខ តំ ទេវោ ឧបតិដ្ឋតុ ។
(១៥៩)តយោ កាលេ អនុញ្ញាតា សោណាតំ ជិតស្មិតា មយំ
ឧបយាតុំ សកេ ធម្មំ ឧបដ្ឋិ ព្រហ្មចារិនំ ។
(១៦០)អស្សត្ថស្សេវ តរុណំ បវាលំ មាលុតេរិតំ
ចិរស្សំ ធម្មំ វិស្សាន ហានយំ មេ បវេធតិ ។
យថា សុត្តាបិ សុព្យគ្គ ធម្មំ បស្សាមិ អាគតំ
ឧជគ្គា សុមនា ហោមិ ទេវោ នោ អាគតោ អយំ ។



(១៥៨) ( ព្រះមហាសត្វ... ) ម្នាលនាង អ្នកស្គាល់ច្បាស់នូវព្រះសទ្ធម្មដែលពួកសប្បុរស សំដែងហើយមែន អ្នកជាមនុស្សល្អមានឫកពាល្អ ត្រូវចិត្តយើងហើយ ។ ខ្ញុំសូមនិយាយនឹងបិតានឹងបីតែង នឹងមាតាដ៏បីតែង សូមលោកទាំងឡាយស្ដាប់ពាក្យរបស់ខ្ញុំ ការនេះមិនមែនគ្រាន់តែជាការៈរបស់ខ្ញុំក្នុងកាលម្ដង ។ ទេ ។ ខ្លួនម៉ឺយខ្ញុំដែលជាអ្នកបំរើ នាំមកនូវសេចក្ដីសុខដល់មាតានឹងបិតានោះ ឲ្យជាធំ ហើយសូមដើម្បីការបំរើផង ។ បណ្ដា (មាតានឹងបិតា) ជាព្រហ្មចារី បើលោកណាម្នាក់ចង់បាន សូមលោកទទួលយកនាង: តាមប្រាថ្នាចុះ គេឲ្យនាង:ចំពោះលោកណា ។

(១៥៩)(មាតា...)នែសោណៈកូន យើងតស្រ័យនឹងអ្នក អ្នកអនុញ្ញាតហើយ គួរបានដើម្បីចូលទៅបំរើក្បាលនាង: ជាព្រហ្មចារី ។

(១៦០) ជុំដីហាក់យរបស់ម្ដាយនៅដ៏ល ព្រោះតែឃើញនាង:អស់កាលយូរហើយ ដូចជាស្លឹកខ្ចីរបស់អស្សត្ថព្រឹក្ស ដែលត្រូវខ្យល់បក់ ។ វេលាណា ម្ដាយដេកលក់ យល់សប្តាឃើញនាង:មក ក៏មានចិត្តត្រេកអរមានចិត្តរីករាយ (ដោយគិតថា) នាង:របស់យើងនេះមកហើយ ។

យថា ច បតិតុជ្ឈិត្វា ធង្កំ បស្សាមិ ធាតកំ
កិំ យោ អាកិសតិ សោ កោ ទោមនស្សញ្ចខេមកំ ។
សាហំ អជ្ជ ចិរស្សំបិ ធង្កំ បស្សាមិ អាគតំ
ឥត្ថុ ច មយ្ហកុំ បិយោ ធន្ទោ ពោធាវិសី យវំ ។
បិតុ ច ធន្ទោ សុបិយោ យំ ធន្ទោ ធប្បវេសេ យវំ
លាភតុ តាត ធន្ទោ តំ មំ ធន្ទោ ខុបតិដ្ឋតុ ។

(១៦០) អនុកម្បកា បតិដ្ឋា ច បុព្វេ រសទទី ច នោ
មគ្គោ សគ្គស្ស លោកស្ស មាតា តំ វរតេ ឥសេ ។
បុព្វេ រសទទី គោត្តី មាតា បុញ្ញូបសញ្ហិតា
មគ្គោ សគ្គស្ស លោកស្ស មាតា តំ វរតេ ឥសេ ។

(១៦២) អាកង្ខមានា បុត្តផលំ ទេវតាយ នមស្សតិ
នក្ខត្តានិ ច បុច្ឆតិ ឧតុសំវច្ឆរានិ ច ។
តស្សា ឧតុសិ ន្ហាតាយ ហោតិ គព្ភស្ស វោក្កមោ
តេន ទោហឡិនី ហោតិ សុហទា តេន វុច្ចតិ ។
សំវច្ឆរំ វា ឩនំ វា បរិហរិត្វា វិជាយតិ



វេលាណាម្តាយក្អាក់ឡើង មិនឃើញធង្កៈមកទេ សេចក្តីសោក កើតមានដល់ម្តាយច្រើន តើទៅតបណ្តាលឡើង ។ យូរណាស់ ហើយ ស្រាប់តែឃើញថ្ងៃនេះ ម្តាយបានឃើញធង្កៈមកដល់ ធង្កៈជាទីស្រឡាញ់នៃស្វាមីរបស់ម្តាយនេះ នៃម្តាយនេះ បានចូលមកកាន់ផ្ទះរបស់ពួកយើង ។ ធង្កៈជាទីស្រឡាញ់ក្រៃលែងរបស់បិតា កុំឲ្យធង្កៈទៅប្រាសចេញអំពីផ្ទះ នៃកូន ឯធង្កៈ (ចង់បានអ្វីណា) ចូរបានអ្នកនោះចុះ ធង្កៈចូរបំរើខ្ញុំវិញចុះ ។

(១៦១) (ព្រះមហាសត្វ...) ម្នាលឥសី មាតាជាអ្នកឈឺឆ្អាល ជាទីពឹង ជាអ្នកឲ្យរស (ទឹកដោះ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ទេវលោក បងចង់បានអ្នក ។ មាតាជាអ្នកឲ្យរសជាមុន ជាអ្នកគ្រប់គ្រង ដែលយើងចូលទៅតាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ទេវ-លោក ម្នាលឥសី មាតាបងចង់បានអ្នក ។

(១៦២) មាតាកាលប្រាថ្នាចង់បានផ្លែគឺកូន រមែងនមស្ការទៅកាន់ទេវតា សួរនូវផ្កាយឫក្ស រដូវនិងឆ្នាំទាំងឡាយផង ។ កាលមាតានោះ មានរដូវលាងស្អាតហើយ សត្វក៏ចុះមកកាន់គភ៌សិប មាតាជាស្ត្រីមានសេចក្តីពាញ់ផ្សេងៗ ព្រោះហេតុនេះ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា សុហទា (មានផ្លូវចិត្តល្អ) ។ មាតារក្សា(ផ្ទៃ)អស់មួយឆ្នាំ ឬថយក៏មួយឆ្នាំ ហើយប្រសូតបុត្រមក

តេន សា ជនយន្តីតិ ជនេត្តី តេន វុច្ចតិ ។

ថនក្ខីរេន គីតេន អង្គបាវុរណេន ច

រោទន្តំ បុត្តំ តោសេតិ តោសេន្តី តេន វុច្ចតិ ។

តតោ វាតាតបេ ឃោរេ មមំ កត្វា ឧទិក្ខតិ

ទារកំ អប្បជានន្តំ បោសេន្តី តេន វុច្ចតិ ។

យញ្ច មាតុ ធនំ ហោតិ យញ្ច ហោតិ បិតុទ្ធនំ

ឧភយម្បេតស្ស គោបេតិ អបិ បុត្តស្ស នោ សិយា ។

ឯវំ បុត្ត អទុំ បុត្ត ឥតិ មាតា វិហញ្ញតិ

បមត្តំ បរទារេសុ និសីថេ បត្តយោព្វនេ

សាយំ បុត្តំ អនាយន្តំ ឥតិ មាតា វិហញ្ញតិ ។

ឯវំ កិច្ឆាភតោ បោសោ មាតុ អបរិចារកោ



ព្រោះហេតុនោះ បានជាបណ្ឌិតហៅមាតានោះថា ជនយន្តី ផង ជនេត្តីផង (អ្នកបង្កើតកូន) ។ មាតាញ៉ាំងកូន ដែលកំពុងយំឲ្យត្រេកអរ ដោយទឹកដោះផង ដោយការបំពេរផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា តោសេន្តី (អ្នកញ៉ាំងកូនឲ្យត្រេកអរ) ។ តពីនោះមក មាតារក្សានូវសេចក្តីស្រឡាញ់រាប់អាន ហើយក្រឡេកមើលទារក ដែលនៅក្នុងទន់ដ៏ក្តៅ ក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា បោសេន្តី (អ្នកចិញ្ចឹមកូន) ។ ទ្រព្យណារបស់មាតាផង ទ្រព្យណារបស់បិតាផង មាតាក៏គ្រប់គ្រងទ្រព្យទាំងពីរនោះទុកដើម្បីកូននោះ (ដោយបំណងថា ទ្រព្យនេះ) គួរតែមានដល់កូនរបស់យើង ។ មាតាតែងនឹងលំបាកដោយការបង្ហាត់បង្រៀនកូនថា ម្នាលកូន (ឯងចូរកុំប្រមាថក្នុងរាជត្រកូលជាដើម) យ៉ាងនេះ ម្នាលកូន (ឯងចូរធ្វើការ) ឯណោះ ។ កាលបើកូនមានវ័យចំរើនឡើងហើយ មាតា(បានដឹង)កូននោះប្រមាថក្នុងប្រពន្ធរបស់អ្នកដទៃក្នុងពេលអធ្រាត្រ ហើយមិនមកក្នុងវេលាល្ងាច ក៏តែងនឹងលំបាកចិត្តដូច្នេះ ។ សត្វដែលមាតាចិញ្ចឹមដោយក្រដោយក្រលំបាកយ៉ាងនេះ ហើយមិនបំរើមាតា

មាតរំ មិច្ឆាចរិត្វាន និរយំ សោ ឧបបជ្ជតិ ។
ឃរំ ភិក្ខាគតោ ហោសោ មិត្ត អបរាបរោ
បិតរំ មិច្ឆាចរិត្វាន និរយំ សោ ឧបបជ្ជតិ ។
ធនម្បិ ធនកាមានំ នស្សតិ ឥតិ មេ សុតំ
មាតរំ អបរិចរិត្វាន កិច្ឆំ វា សោ និគច្ឆតិ ។
ធនម្បិ ធនកាមានំ នស្សតិ ឥតិ មេ សុតំ
បិតរំ អបរិចរិត្វាន កិច្ឆំ វា សោ និគច្ឆតិ ។
អានន្ទោ ច បមោទោ ច សទា ហសិតកីឡិតំ
មាតរំ បរិចរិត្វាន លព្ភមេតំ វិជានតោ ។
អានន្ទោ ច បមោទោ ច សទា ហសិតកីឡិតំ
បិតរំ បរិចរិត្វាន លព្ភមេតំ វិជានតោ ។
ទានញ្ច បិយវាចញ្ច អត្ថចរិយា ច យា ឥធ
សមានត្តតា ច ធម្មេសុ តត្ថ តត្ថ យថារហំ ។
ឯតេ ខោ សង្គហា លោកេ រថស្សាណីវ យាយតោ
ឯតេ ច សង្គហា នាស្សុ ន មាតា បុត្តការណា
លភេថ មានំ បូជំ វា បិតា វា បុត្តការណា ។



ប្រព្រឹត្តខុសក្នុងមាតា នោះរមែងទៅកើតក្នុងនរក ។ សត្វដែលបំពា ចចិត្តមាតាយ៉ាងក្រោយបង្អស់យ៉ាងនេះ ហើយមិនបំរើបិតាប្រព្រឹត្ត ខុសក្នុងបិតានោះ តែងទៅកើតក្នុងនរក ។ បើមានទ្រព្យមកជា សូម្បីតែទ្រព្យរបស់ពួកអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ បុគ្គល នោះរមែងដល់ក្រលំបាកព្រោះមិនបំរើមាតា ។ បើមានទ្រព្យមកជា សូម្បីតែទ្រព្យរបស់ពួកអ្នកចង់បានទ្រព្យតែងវិនាសទៅវិញ បុគ្គល នោះរមែងដល់ក្រលំបាកព្រោះមិនបំរើបិតា ។ បណ្ឌិតបំរើមាតា សប្បុរស បាននូវសុខទុំ គឺសេចក្តីត្រេកអរក្រៃកយ ការសើចលេងសប្បាយ ។ គាល ។ បណ្ឌិតបំរើបិតា សប្បុរសបាននូវសុខទុំ គឺសេចក្តីត្រេកអរ ក្រៃកយ ការសើចលេងសប្បាយគាល ។ ទាន ១ ពាក្យជាទីស្រឡាញ់ ១ ការប្រព្រឹត្តប្រយោជន៍ក្នុងលោកនេះ ១ ភាពនៃបុគ្គលមានខ្លួន ប្រព្រឹត្តស្មើក្នុងធម៌ផ្សេងៗតាមសមគួរ ១ សង្គហធម៌ទាំង ៤ នុ៎ះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាស្លាក់នៃកង់ រថដែលវិលទៅ បើសង្គហធម៌ទាំងនុ៎ះមិនមានទេ មាតាមិនគួរបាន នូវសេចក្តីរាប់អាននិងការបូជា ព្រោះហេតុនៃកូន ចាំងបិតា ក៏មិន គួរបាននូវសេចក្តីរាប់អាននិងការបូជា ព្រោះហេតុនៃកូន ។

យស្មា ច សត្តិហា ឯតេ សមវេក្ខិត្វា បណ្ឌិតា
តស្មា មហន្តំ បប្បោន្តិ បាសំសា ច ភវន្តិ តេ ។
ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា ។
តស្មា ហិ តេ នមស្សេយ្យ សក្ករេយ្យ ច បណ្ឌិតោ
អន្នេន អថ បានេន វត្ថេន សយនេន ច
ឧច្ឆាទនេន ន្ហាបនេន បាទានំ ធោវនេន ច ។
តាយ នំ បារិចរិយាយ មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតីតិ ។

សោណនន្ទជាតកំ ទុតិយំ ។

### តស្សុទ្ទានំ

អថ សត្តតិមម្ហិ និបាតវរេ
សភាវន្តុ កុសាវតិរាជវរោ
អថ សោណសុនន្ទវរោ ច បុន
អភិវាសិតសត្តតិមម្ហិ សុតេ ។

សត្តតិនិបាតំ និដ្ឋិតំ ។

---



ក្នុងបណ្ឌិត រមែងសរសើញដោយល្អនូវសេចក្តីបរមធម៌ទាំងនុ៎ះ ព្រោះហេតុនោះ បណ្ឌិតទាំងនោះ រមែងដល់នូវភាពធំ ទាំងជាអ្នកគួរសរសើរ ។ មាតាបិតា ជាអ្នកអនុគ្រោះដល់ពួកសត្វជាបុត្រ បណ្ឌិតហៅថា ព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យៈផង របស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូតទឹកការលាងជើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបំរើ ចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។

ចប់ សោណនន្ទជាតក ទី ២ ។

### ឧទ្ទាននៃសត្តតិនិបាតនោះ គឺ

រឿងព្រះរាជាប្រសើរក្នុងក្រុងកុសាវតី ក្នុងនិបាតដ៏ប្រសើរគំរប់ចិតសិប ១ និងរឿងសោណតាបសនិងនន្ទតាបសដ៏ប្រសើរក្នុងសូត្រគំរប់ចិតសិប ។

ចប់ សត្តតិនិបាត ។

## អសីតិនិបាតជាតកំ

## ចុល្លហំសជាតកំ

(១៦៣) សុមុខ អនុបចិនន្តា បក្កមន្តិ វិហង្គមា
គច្ឆ តុវំបិ មា កង្ខិ នត្ថិ ពទ្ធេ សហាយតា ។

(១៦៤) គច្ឆេ វាហំ ន វា គច្ឆេ ន តេន អមរោ សិយំ
សុខិតំ តំ ឧបាសិត្វា ទុក្ខិតំ តំ កថំ ជហេ ។
មរណំ វា តយា សទ្ធិំ ជីវិតំ វា តយា វិនា
តទេវ មរណំ សេយ្យោ យញ្ចេ ជីវេ តយា វិនា ។
នេស ធម្មោ មហារាជ យំ តំ ឯវំ គតំ ជហេ
យា គតិ តុយ្ហំ សា មយ្ហំ រុច្ចតេ វិហគាធិប ។

## អសីតិនិបាតជាតក

## ចុល្លហំសជាតក

(១៦៣) (ករហង្សឈ្មោះធតរដ្ឋៈពោលថា) ម្នាលហង្សឈ្មោះសុមុខៈ ពួកបក្សីកាលមិនគយគន់មើល ហើយចេញទៅ អ្នកចូរទៅចុះ កុំប្រាថ្នា (នៅក្នុងទីនេះទៀត ព្រោះថា) ភាពនៃអ្នកជាសំឡាញ់ នឹងយើងដែលជាប់ចំណង មិនមានទេ ។

(១៦៤) (ហង្សសេនាបតីឈ្មោះសុមុខៈ ក្រាបបង្គំទូលថា) ខ្ញុំព្រះបង្គំជាខ្ញុំ ទៅក្តី មិនទៅក្តី ខ្ញុំព្រះបង្គំជាខ្ញុំមិនមែនមិនស្លាប់ ដោយការទៅ ឬការមិនទៅនោះទេ ខ្ញុំព្រះបង្គំជាខ្ញុំចូលទៅរកព្រះអង្គដែលដល់នូវសេចក្តីសុខហើយ នឹងលះព្រះអង្គដែលដល់នូវសេចក្តីទុក្ខដូចម្តេចកើត ។ សេចក្តីស្លាប់ជាមួយនឹងព្រះអង្គក្តី ការរស់នៅវៀរចាកព្រះអង្គក្តី សេចក្តីស្លាប់នោះប្រសើរជាង ខ្ញុំព្រះបង្គំជាខ្ញុំ តែវៀរចាកព្រះអង្គហើយ រស់នៅមិនប្រសើរសោះឡើយ ។ បពិត្រមហារាជ ខ្ញុំព្រះបង្គំជាខ្ញុំលះបង់ព្រះអង្គដែលដល់ (នូវសេចក្តីទុក្ខ) យ៉ាងនេះ ដោយសភាវៈណា សភាវៈនោះមិនមែនជាធម៌ទេ បពិត្រព្រះអង្គជាធំលើបក្សី ដំណើរណា របស់ព្រះអង្គ ដំណើរនោះខ្ញុំព្រះបង្គំជាខ្ញុំ ក៏គាប់ចិត្តដែរ ។

(១៦៥)ការានុការោ សេដ្ឋកម្មស្ស កតំ អញ្ញា ឧបាសកា

សា កាតំ បេតយោនស្ស មុត្តស្ស តវ វុត្តិ ។

តំ ភាតុ បស្សសេ អត្ថំ មម កុណ្ឌញ្ញ បត្តិម

ញាតីនំ ករសិ ផាសុំ ទុក្ខិតំ ជីវិតក្ខយេ ។

យន្តំ ការណឧទ្ទិស្ស អាទិច្ច តមសា កតំ

តាតិសេ សញ្ញំ ធារេសិ ការិមគ្គមរំ ជោតយេ ។

(១៦៦)ការំ ចុ បតតំ សេដ្ឋ ធម្មំ អត្ថំ ន ពុជ្ឈសិ

ធម្មោ អបចិតោ សន្តោ អត្ថំ ទស្សេតិ ធាណិនំ ។

សោភាគំ ធម្មំ អបេក្ខាតោ ធម្មា ធម្មំ សមុដ្ឋិតំ

កតិញ្ចុ កយា សមស្សំ ជាតកាត្ថុម ជីវិតំ ។



(១៦៥) (ភវហារ...) ដំណើរដូចម្ដេចរបស់ខ្ញុំ ដែលជាប់អន្ទាក់ ហើយ ដោយអំណាចកម្ម ដំណើរនោះ នៅជាពេញចិត្តដល់អ្នក ដែលមានប្រាជ្ញា ជាអ្នកដោះអំពីអន្ទាក់ដូចម្ដេច ។ ម្នាលអ្នកជាបក្សី កាលបើយើងទាំងពីរនាក់រស់នៅហើយ អ្នកឃើញនូវប្រយោជន៍ដូចម្ដេច របស់ខ្ញុំផង របស់អ្នកផង របស់ពួកញាតិមិត្រសម្លាញ់ផង ។ ម្នាលអ្នកមានសម្បុរទាំងពីរដូចជាមាស កាលនេះបាននូវជីវិតរបស់អ្នកណា កាលនេះបាននូវជីវិតរបស់អ្នកនោះហាក់ដូចជាចិត្តខ្ញុំទីទឹកដោយសេចក្តីរីករាយ អ្នកកាលបានបាននូវជីវិត ព្រោះគុណដែលមិនជាក់ច្បាស់ដូច្នោះ តើព្រោះទុះឃើញនូវប្រយោជន៍អ្វី ។

(១៦៦) (ហង្សរាជា...) បពិត្រព្រះអង្គដ៏ប្រសើរបំផុត ព្រះអង្គមិនជ្រាបនូវប្រយោជន៍ដែលធ្លាក់ចុះ ក្នុងធម៌ដូចម្ដេច ដ្បិតធម៌ដែលពួកសត្វគោរពហើយ រមែងបង្ហាញនូវសេចក្តីចំរើន ដល់សត្វទាំងឡាយ ។ ទូលព្រះបង្គំជាខ្ញុំនោះ កាលឃើញនូវធម៌ផង នូវប្រយោជន៍ដែលកើតអំពីធម៌ផង ពិចារណាឃើញនូវសេចក្តីស្រឡាញ់ចំពោះព្រះអង្គផង បានជាមិនប្រាថ្នាជីវិតទេ ។

អទ្ធា ឯសោ សតំ ធម្មោ យោ មិត្តោ មិត្តមាបទេ

ន ចជេ ជីវិតស្សាបិ ហេតុ ធម្មមនុស្សរំ ។

(១៦៧)ស្វាយំ ធម្មោ ច តេ ចិណ្ណោ ភត្តិ ច វិទិតា មយិ

កាមំ ករស្សុ មយ្ហេតំ គច្ឆេវេតោ មយា ។

អបិ ត្វេវំ គតេ កាលេ យំ ខណ្ឌំ ញាតិនំ មយា

តយា តំ ពុទ្ធិសម្បន្ន អស្ស បរមសំវុតំ ។

(១៦៨)ឥច្ចេវំ មន្តយន្តានំ អរិយានំ អរិយវុត្តិនំ

បច្ចទិស្សថ នេសាទោ អាតុរានមិវន្តកោ ។

តេ សត្តុមភិសញ្ចិក្ខ ទីឃរត្តំ ហិតា ទិជា

តុណ្ហី មាសិត្ថ ឧភយោ ន សញ្ចលេសុមាសនា ។



មិត្តណា កាលគ្រោះភ័យកើតមាន ហើយមិនលះបង់មិត្រក្នុងកាល ដែលមានសេចក្តីអន្តរាយ ព្រោះហេតុនៃជីវិត ធម៌របស់មិត្រនោះ ឈ្មោះថាជាធម៌របស់សប្បុរសទាំងឡាយដោយពិត ។

(១៦៧) (កវិហង្ស...) ធម៌នោះអ្នកបានសន្សំហើយ ទាំងសេចក្តីស្រឡាញ់ចំពោះយើង ក៏ប្រាកដដល់យើងហើយ អ្នកចូរធ្វើតាមសេចក្តីប្រាថ្នារបស់យើងចុះ អ្នកដែលយើងបានអនុញ្ញាតហើយ ចូរទៅចុះ ។ ម្នាលអ្នកបរិបូណ៌ដោយប្រាជ្ញា មួយទៀត ការបែកចាកនៃពួកញាតិណា ដែលយើងបានបំពេញហើយ ក្នុងកាលដែលប្រព្រឹត្តទៅយ៉ាងនេះ ការបែកចាកនៃពួកញាតិនោះ អ្នកគប្បីបិទបាំងទុកឲ្យល្អចុះ ។

(១៦៨) (អភិសម្ពុទ្ធគាថា) កាលដែលអរិយហង្សទាំងឡាយ ជាសត្វមានការប្រព្រឹត្តដ៏ប្រសើរ កំពុងតែប្រឹក្សាគ្នាយ៉ាងនេះ ស្រាប់តែនាយនេសាទ មកប្រាកដដូចជាសេចក្តីស្លាប់ ដែលប្រាកដដល់បុគ្គលឈឺ ។ ហង្សទាំងពីរនោះ មានប្រយោជន៍ (ដល់គ្នានឹងគ្នា ) យូរអង្វែងហើយ បានឃើញច្បាស់នូវសត្រូវ ក៏នៅស្ងៀមទាំងពីរនាក់ មិនកម្រើក ចាកទ្រនំឡើយ ។

ជនេន្ទ ច និស្សាយ សមុទ្ទន្តេ ឋិតោ ឋិតោ

អភិក្កមថ វេគេន ទិជសត្តុ · ទិជាធិបេ ។

សោ ច វេគេនភិក្កម្ម អាសជ្ជ បរមេ ទិជេ

បច្ចាមិត្តស្ស ហេសាតោ គន្ធា អតិ វិចិន្តយំ ។

ឯកញ្ច ពន្ធមាសីនំ អពន្ធញ្ច បុនាបរំ

អាសជ្ជ ពន្ធមាសីនំ បេក្ខមានមជីវំ ។

តតោ សោ វិមតោយេវ បណ្ឌរេ អជ្ឈភាសថ

បវទ្ធកាយេ អាសីនេ ទិជសង្ឃគណាធិបេ

យន្នុ បាសេន មហតា ពទ្ធោ ន កុរុតេ ទិសំ

អថ កស្មា អពទ្ធោ ត្វំ ពលី បក្ខី ន គច្ឆសិ ។

កិំ នុ ត្យាយំ ទិជោ ហោតិ មុត្តោ ពទ្ធំ ឧបាសសិ

ឱហាយ សកុណា យន្តិ កិំ ឯកោ អវហីយសិ ។

(១៦៨) រាជា មេ សោ ទិជាមិត្ត សខា បាណសមោ ច មេ



ក្រោយព្រានជាសត្រូវនៃសត្វស្លាប ចុះឃើញហង្សឈ្មោះសុមុខៈ ទឹកផុតហង្សឈ្មោះធតរដ្ឋៈជាស្ដេចនៃបក្សីកាលទំតចូលមកកេន្ទ: អំពីវិនោះ ។ កំពុងដើរដោយប្រញាប់ៗ លុះនាយនេសាទនោះ ស្ទុះដោយប្រញាប់ទៅពីរកពួកបក្សីប្រសើរហើយ ក៏គិតថា សត្វហង្សពីរនេះជាប់ហើយ ញាប់ញ័រក៏នាយនេសាទចុះឃើញ សត្វហង្សមួយ ជាប់អន្ទាក់ហើយទំនៅ នឹងសត្វហង្សមួយទៀត ដែលមិនជាប់អន្ទាក់ ចូលមកកេសត្វហង្សដែលជាប់អន្ទាក់ហើយ ទំនៅ សំឡឹងមើលខ្លួនហង្សដែលមានទោស ។ លំដាប់អំពីនោះទៅ នាយនេសាទនោះមានសេចក្ដីសង្ស័យ ក៏ចូលសួរនូវសត្វហង្សមានពណ៌ស មានកាយធំ ជាអធិបតីលើពួកនៃបក្សីថា សត្វហង្សដែលជាប់អន្ទាក់ដ៏ធំល្មម មិនហើរទៅវិញ (ដើម្បីហើរទៅ) ដោយហេតុណា (ហេតុនោះគួរហើយ) ម្នាលសត្វស្លាប ចុះអ្នកមិនជាប់អន្ទាក់ៗ ជាសត្វមានកំឡាំង ហេតុអ្វីក៏មិនហើរទៅ ។ សត្វបក្សីនេះត្រូវជាអ្វីនឹងអ្នក អ្នករួច (អំពីអន្ទាក់ហើយ) ចូលមកកេបក្សីដែលជាប់អន្ទាក់វិញ បក្សីទាំងឡាយនាំគ្នាហើរចោលទៅអស់ហើយ ចុះអ្នកត្រូវនៅតែម្នាក់ឯង ។

(១៦៨)(ហង្សសេនាបតី...) បពិត្រនាយនេសាទជាសត្រូវនៃសត្វបក្សី ហង្សនេះជាព្រះរាជានៃខ្ញុំផង ជាសំឡាញ់ស្មើដោយជីវិតនៃខ្ញុំផង

(១)

ទេវ ធំ វិជហិស្សាមិ យាវ កាលបរិយាយំ ។

(១៧០) ភរិយំ បតយំ វិហង្គោ ជាតុស្ស តាស មោទតំ

បនំ ហោតិ មហន្តាមំ ពោធុមរហាទ្ធិ អាបតិ ។

(១៧១) យថា បកកកំ ហោតិ តោសេក ជីវិតសន្ទេយេ

អជ ជាលញ្ច តាសញ្ច អាសជ្ជាបិ ន វុជ្ឈតិ ។

(១៧២) អបិ ត្វេវ អហោបញ្ញ ជាសា ពហុវិធា ភាគា

កុល្លមាសន្នំ ពជ្ឈន្តិ អជេវំ ជីវិតក្ខយេ ។

(១៧៣) អបិ ជាយំ តយា សន្ធឹ សំកសស្ស សុខុន្ទ្រយោ

អបិ នោ អនុមញ្ញាសិ អបិ នោ ជីវិតំ ទទេ ។

(១៧៤) ន ចេវ មេ ត្វំ ពទ្ធាសិ នបិ ឥច្ឆាមិ តេ វធំ

កាមំ ខិប្បមិតោ គន្ត្វា ជីវ ត្វំ អនីឃោ ចិរំ ។

១. យាវ កាលស្ស បរិយាយំ ។



ខ្ញុំនឹងមិនលះបង់នូវហង្សនោះ ដរាបដល់សេចក្តីស្លាប់មកដល់ ។

(១៧០) (នាយនេសាទ...) ចុះហង្សក្តី ហង្សនេះ ក៏មិនឃើញនូវអន្ទាក់ដែលនេះជាប់ហើយ ដើរហើរនេះហើយ ដែលជាដំណើរសម្រាប់ពួកសត្វធំ ៗ ពួកសត្វធំ ៗ ឬមើលនូវសេចក្តីអន្តរាយ ។

(១៧១) (ហង្សសេនាបតី...) កាលណា ដែលសត្វជាអ្នកមានសេចក្តីវិនាស គឺកាលជាទីអស់ទៅនៃជីវិត កាលនោះ សត្វនោះ សូម្បីចូលមកជិតដល់សំណាញ់នៃអន្ទាក់ ក៏នៅតែមិនដឹងឡើយ ។

(១៧២) (នាយនេសាទ...) ម្នាលសត្វមានប្រាជ្ញាច្រើន តែនេះហើយ អន្ទាក់ពាំនឡូយ យើងបានដាក់ហើយជាច្រើន កាលបើសត្វមានជីវិតរស់នៅយ៉ាងនេះ សត្វស្លាបពាំនឡូយ តែនចូលមកជាប់នឹងអន្ទាក់ដ៏កំបាំង ។

(១៧៣) (ហង្សសេនាបតី...) សូមឲ្យការនៅរួមជាមួយនឹងអ្នកនេះមានសុខជាកម្រៃ សូមអ្នកអនុញ្ញាតយើងទាំង សូមអ្នកឲ្យជីវិតដល់យើងទាំង ។

(១៧៤) (នាយនេសាទ...) ឯងមិនជាប់ (អន្ទាក់)អញទេ ទាំងអញទៀតសោត ក៏មិនប្រាថ្នាសម្លាប់ឯងដែរ ចូរឯងទៅអំពីទីនេះតាមប្រាថ្នាយ៉ាងឆាប់ ហើយរស់នៅមិនមានទុក្ខ អស់កាលជាអង្វែងចុះ ។

(១៨៥) ឯកាហមេកមិច្ឆាមិ អញ្ញត្រេកស្ស ជីវិតា
បេចេ ឋានោ ច ទុច្ចោសិ មុញ្ចេតំ មញ្ញ ភក្ខយ ។
អារោហបរិណាហេន តុល្យស្មា វយសា ឧភោ
ន តេ លាភេន ជីវត្ថិ ឯតេន និមិនា តុវំ ។
តទិង្ឃ សមបេក្ខស្សុ ហោតុ គិទ្ធិ តវស្មាសុ[1]
មំ បុព្វេ ពន្ធ បាសេន បច្ឆា មុញ្ច ទិជាធិបំ ។
តាវទេវ ច តេ លាភោ កតាស្ស យាចនាយ ច
មិត្តិ ច ធតរដ្ឋេហិ យាវជីវាយ តេ សិយា ។

(១៨៦) បស្សន្តុ នោ មហាសង្ឃា តយា មុត្តំ ឥតោ គតំ
មិត្តាមច្ចា ច ភច្ចា ច បុត្តទារា ច ពន្ធវា ។
ន ច តេ តាទិសា មិត្តា ពហូនំ ឥធ វិជ្ជរេ[2]
យថា តុវំ ធតរដ្ឋស្ស បាណសាធារណោ សខា ។

---
១ ម. តវម្ហាសុ ។ ២ ឱ,ម. វិជ្ជតិ ។



(១៨៥) (ហង្សសេនាបតី...) ខ្ញុំប្រាថ្នាតែជីវិតនៃបក្សីនោះហើយ មិនប្រាថ្នាជីវិតទេ ។ បើអ្នកត្រេកអរដោយហង្សមួយ ចូរអ្នកលែងនូវហង្សនេះទៅ ចូរបរិភោគខ្លួនខ្ញុំវិញចុះ ។ យើងទាំងពីរនាក់នោះ មានកំពស់ ទំហំនឹងវ័យស្មើៗគ្នា អ្នកមិនមែនសាបសូន្យលាភលោកទេ សូមអ្នកប្តូរយកខ្ញុំដោយហង្សនេះ ។ ចូរអ្នកសង្កេតមើលដំណើរនេះចុះ សេចក្តីជាប់ចិត្តរបស់អ្នកចំពោះយើងទាំងពីរឡាយ សូមលើកទុកសិន ចូរអ្នកយកអន្ទាក់ចងខ្ញុំមុនសិនចុះ រួចសឹមលែងស្តេចបក្សីជាខាងក្រោយ ។ លាភរបស់អ្នកក៏នៅដដែលផង សេចក្តីអង្វរនេះកើតឈ្មោះថា អ្នកបានទៀតកាមផង សេចក្តីរាប់អានដោយការបានហង្សឈ្មោះធតរដ្ឋៈ នឹងមានដល់អ្នក ជាប់ដល់អស់ជីវិតផង ។

(១៨៦) (នាយនេសាទ...) ពួកសត្វបក្សីជាច្រើន ដែលជាមិត្រ អាមាត្យក្តី មាតាបិតាក្តី កូនប្រពន្ធក្តី ជាទៅញាតិក្តី ចូរចូលមកជួបនូវហង្សនេះ ដែលរួចហើយ ព្រោះអ្នកហើរទៅអំពីទីនេះ ។ ពួកមិត្រ របស់ពួកសត្វដទៃជាច្រើន ដែលប្រហែលគ្នានឹងមិត្ររបស់អ្នក ដូចអ្នកជាសំឡាញ់ស្មើជីវិត នឹងរកហង្សឈ្មោះធតរដ្ឋៈនេះ មិនមានក្នុងទីនេះទេ ។

ឯសោ តេ សហាយំ មុញ្ចាមិ ហោតុ រាជា តវានុគោ

កាមំ ខិប្បមិតោ គន្ត្វា ញាតិមជ្ឈេ វិរោចតុ ។

(១៧៧)សោ បតីតោ បមុត្តេន ភត្តុនា ភត្តុគារវោ

អជ្ឈភាសថ វក្កង្គោ វាចំ កណ្ណសុខំ ភណំ

ឯវំ លុទ្ទក នន្ទស្សុ សហ សព្វេហិ ញាតិភិ

យថាហមជ្ជ នន្ទាមិ មុត្តំ ទិស្វា ទិជាធិបំ ។

(១៧៨)ឯហិ តំ អនុសិក្ខាមិ យថា ត្វមបិ លច្ឆសេ

លាភំ តវាយំ[១] ធតរដ្ឋោ បាបំ កិញ្ចិ ន ទក្ខិតិ ។

ខិប្បមន្តេបុរំ នេត្វា រញ្ញោ ទស្សេហិ នោ ឧភោ

អពទ្ធេ បកតិភូតេ កាជេ ឧភយតោ ឋិតេ ។

ធតរដ្ឋា មហារាជ ហំសាធិបតិនោ ឥមេ

អយំ ហិ រាជា ហំសានំ អយំ សេនាបតីតរោ ។

---

១ ឱ. យសាយំ ។



ខ្ញុំនោះបានលែងនូវកំពូលហង្សជាសំឡាញ់របស់អ្នក ព្រះរាជារបស់អ្នកចូរទៅតាមអ្នកចុះ អ្នកចូរចេញឆ្ងាយ ចូរហើរទៅអំពីទីនេះដោយក្រឡាំងឆាប់ ហើយរុងរឿងក្នុងកណ្តាលពួកញាតិចុះ ។

(១៧៧) (អភិសម្ពុទ្ធគាថា) ហង្សឈ្មោះសុមុខៈនោះ មានចិត្តត្រេកអរ ព្រោះម្ចាស់ផុតចាកបណ្តាញ ជាសត្វគោរពម្ចាស់ កាលពោលនូវវាចាដ៏ស្រួលដល់ត្រចៀក ទើបពោលថា បពិត្រនាយនេសាទ យើងត្រេកអរព្រោះបានឃើញនូវស្តេចបក្សី ដែលរួចចាកអន្ទាក់ក្នុងថ្ងៃនេះ យ៉ាងណា លោកចូរត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះចុះ ។

(១៧៨) លោកចូរមកនេះ ខ្ញុំប្រៀនប្រដៅលោកឲ្យបានលាភ ស្តេចហង្សឈ្មោះធតរដ្ឋៈនេះ នឹងមិនឃើញសេចក្តីអាក្រក់ របស់លោកតិចតួចទេ ។ លោកចូរ(នាំយើងទាំង)ទៅក្នុងរាជបុរីជាឆាប់ ហើយបង្ហាញចំពោះព្រះរាជា នូវយើងទាំងពីរនាក់ដែលមិនជាប់ចំណង មានសភាពជាប្រក្រតី ដែលទៅលើអម្រែកទាំងពីរខាង ។ (លោកក្រាបទូលថា) បពិត្រមហារាជ ហង្សទាំងពីរនេះ កើតក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ឯហង្សនេះ ជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះជាសេនាបតី ។

អសំសយំ ឥមំ ទិស្វា ហំសរាជំ ឆកចំហោ
បតីតោ សុមនោ វិត្តោ ពហុំ ទស្សតិ តេ ធនំ ។

(១៧៩) តស្ស តំ វចនំ សុត្វា កម្មុនា ឧបបាទយិ
ខិប្បមេត្ថ បុរំ គន្ត្វា រញ្ញោ ហំសេ អទស្សយិ
អពទ្ធេ បកតិភូតេ កាជេ ឧភយតោ ឋិតេ ។
ធតរដ្ឋា មហារាជ ហំសាធិបតិនោ ឥមេ
អយំ ហិ រាជា ហំសានំ អយំ សេនាបតីតរោ ។

(១៨០) កថំ បនិមេ វិហង្គា តវ ហត្ថត្តមាគតា
កថំ លុទ្ទោ មហន្តានំ ឥស្សរេ ឥធ អជ្ឈគា ។

(១៨១) វិហិតា សន្តិមេ បាសា បល្លលេសុ ជនាធិប
យំ យទាយតនំ មញ្ញេ ទិជានំ បាណរោធនំ ។





ព្រះរាជាជាធំបតីលើពួកជន ទ្រង់បានទតឃើញរាជហង្សនេះហើយ មុខជាទ្រង់មានព្រះរាជហឫទ័យត្រេកអរពេកណាស់ នឹងប្រទានទ្រព្យច្រើនដល់អ្នក ឥតសង្ស័យ ។

(១៧៩) នាយនេសាទ លុះបានស្ដាប់ពាក្យហង្សឈ្មោះសុមុខៈនោះហើយ ក៏បង្កើយតបថា រួច (នាំហង្សទាំងពីរ) ទៅកាន់ក្នុងបុរីហាំងដាប់ ហើយបង្ហាញចំពោះព្រះរាជានូវហង្សទាំងពីរ ដែលមិនជាប់អន្ទាក់ មានសភាពតាមប្រក្រតី ឋិតនៅលើស្រែកទាំងពីរខាងថា បពិត្រមហារាជ ហង្សទាំងពីរនេះ កើតក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ឯហង្សនេះជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះ ជាសេនាបតី ។

(១៨០) (ព្រះរាជា...) ហង្សទាំងនេះ មកឋិតនៅក្នុងកណ្ដាប់ដៃរបស់អ្នក តើដោយហេតុដូចម្ដេច អ្នកជានាយព្រាន បានដល់នូវភាពជាម្ចាស់ជាន់សត្វហង្សធំ ៗ ទាំងឡាយក្នុងទីនេះ ដោយហេតុដូចម្ដេច ។

(១៨១) (ព្រានព្រៃ...) បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះបង្គំជាខ្ញុំស្គាល់នូវកន្លែងជាទីប្រជុំនៃពួកសត្វស្លាបណា ៗ ជាទីដើរទ្រុសទៅនៃជើង នៃពួកសត្វស្លាប ខ្ញុំព្រះបង្គំបានដាក់អន្ទាក់ទាំងនេះលើគល់ទាំងឡាយ (ក្នុងកន្លែងនោះ ៗ) ។

តាទិសំ ទាសមាសជ្ជ ហំសរាជា អចិន្តយិ
ទំ អតេត្វា ទុតាសីនោ មមាយំ អជ្ឈភាសថ ។
សុទុត្តរំ អចរិយាហំ ឧបាតេ កាមមុត្តមំ
កត្វានេត្ថ បរក្កន្តោ ឧឡ្ហយុត្តោ វិហង្គមោ ។
អត្តហេយំ ចជិត្វាន ជីវិតំ ជីវិតារហោ
អនុត្ថុនន្តោ អាសីនោ ភត្តុ យាចិត្ថ ជីវិតំ ។
តស្ស តំ វចនំ សុត្វា បសាទមហមជ្ឈគា
តតោ នំ ចាមុចិ ទាសោ អនុញ្ញាសិ សុខេន ច ។
សោ បតីតោ បមុត្តេន ភត្តុនា ភត្តុគារវោ
អជ្ឈភាសថ វក្កង្គោ គិរំ កណ្ណសុខំ ភណំ ។
ឯវំ លុទ្ទក នន្ទស្សុ សហ សព្វេហិ ញាតិភិ
យថាហមជ្ជ នន្ទាមិ មុត្តំ ទិស្វា ទិជាធិបំ ។
ឯហិ តំ អនុសិក្ខាមិ យថា ត្វមបិ លច្ឆសេ
លាភំ តវាយំ ធតរដ្ឋោ បាបំ កិញ្ចិ ន ទស្សតិ ។



ពេលហង្សបានមកជាប់អន្ទាក់ព្រានដង្ហោះហើយ ចំណែកហង្សជាសេនា-បតីនេះ មិនជាប់អន្ទាក់ទេ តែហើរទៅចាំពិតនឹងហង្សនោះ ហើយបាននិយាយនឹងខ្លួនព្រានមន្ត្រីជាច្រើន ។ ហង្សជាសេនាបតីនេះ (បានធ្វើ) នូវអំពើដែលគួរជនមិនមែនជាអរិយៈធ្វើបានដោយក្រ ជាសត្វប្រកបដោយធម៌ សន្តិភក្តិប្រយោជន៍ របស់ម្ចាស់ បានប្រកាសនូវគតិនៃខ្លួនជាសត្វដ៏ឧត្តម ។ ហង្សជាសេនាបតីនេះ ជាសត្វគួរទីន័រសៀត តែស៊ូលះបង់នូវជីវិតនៃខ្លួន កាលសរសើរ(នូវគុណនៃម្ចាស់)ហើយទំនៅ បានសុំនូវជីវិតម្ចាស់ ។ ខ្លួនព្រានមន្ត្រីជាទីវបានស្ដាប់ពាក្យនោះ របស់ហង្សសេនាបតីនោះ ហើយ ទើបដល់នូវសេចក្តីជ្រះថ្លា លំដាប់នោះ ខ្លួនព្រានមន្ត្រីបានដោះពរាហង្សនោះពាក់អន្ទាក់ ទាំងបានអនុញ្ញាតឱ្យទៅដោយស្រួល ។ ហង្សជាសេនាបតីនោះ ក៏មានចិត្តរីករាយ ព្រោះម្ចាស់បានរួចហើយ ជាសត្វគោរពម្ចាស់ កាលនឹងពោលពាក្យស្រួលដល់ត្រចៀក បានពោលយ៉ាងនេះថា បពិត្រព្រានព្រៃ ថ្ងៃនេះខ្ញុំរីករាយ ព្រោះបានឃើញស្ដេចបក្សីដែលរួចហើយយ៉ាងណា សូមឱ្យលោករីករាយ ជាមួយនឹងពួកញាតិទាំងអស់យ៉ាងនោះ ។ លោកចូរមកនេះ ខ្ញុំនឹងប្រៀនប្រដៅឱ្យបាននូវលាភ ពរាហង្សឈ្មោះធតរដ្ឋៈនេះ នឹងឥតឃើញសេចក្ដីអាក្រក់តិចតួចរបស់លោកទេ ។

ចិរប្បមេណ្ឌបុរំ គន្ត្វា    វេឡោ ឧស្សេហិ ហោ ទុរោ
អតន្ទេ បតរតិក្ខេ    កាលេ ទុក្ខយតោ បិតេ ។
ឧតន្ទោ មហាករ    ហំសាធិបតិនោ តវេ
អយញ្ហិ រាជា ហំសានំ    អយំ សេនាបតីតរេ ។
អសំសយំ តវំ ធិស្វា    ហំសរាជំ ឧតធិតោ
បតិតោ សុមុខោ វត្តា    ពហុំ ឧស្សូតិ តេ ធនំ ។
ឯវមេតស្ស វចនា    អាធីតាមេ ទុរោ មយា
ឯវំ ហិ តវេ អស្សុ    ទុរោ អនុមតា មយោ ។
សោយំ ឯវត្តតោ បត្តោ    ធិតោ បរមធម្មិកោ
មាតិសស្ស ហិ សុទ្ធស្ស    ជនយេយ្យាថ មន្តំ ។
ទុបយាងញ្ញ តេ តេវ    ញាតញ្ញំ បស្សាមិ បធិសំ
សព្វសកុណាភាតាមេ    តំ បស្ស មនុជាធិប ។





លោកបាននាំយើងខ្ញុំទៅក្នុងបុរីជាលំដាប់ ហើយបង្ហាញព្រះរាជានូវយើងខ្ញុំទាំងពីរនាក់ ដែលមិនជាប់ចំណង មានសភាពជាប្រក្រតី មិនទៅណាទៀតម្នាក់ពីរនាក់ ។ ( លោកក្រាបទូលថា ) បពិត្រមហារាជ ហង្សពីរនេះ កើតទៅក្នុងត្រកូលធតរដ្ឋៈជាអធិបតីលើពួកហង្ស ឯហង្សនេះជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះជាសេនាបតី ។ ព្រះរាជាជាធំលើពួកដទៃបានទតឃើញពងហង្សនេះហើយ មុខជានឹងមានព្រះទ័យត្រេកអរសោមនស្សរីករាយ នឹងព្រះរាជទានទ្រព្យដ៏ច្រើន ដល់លោកជាយពិត ។ ទូលព្រះបង្គំជាខ្ញុំ បាននាំហង្សទាំងពីរនេះមក តាមពាក្យហង្សជាសេនាបតីនេះយ៉ាងនេះ ព្រោះថា ទូលព្រះបង្គំជាខ្ញុំបានលើកលែងហង្សទាំងពីរនេះ ក្នុងវាលនោះរួចទៅហើយ ។ សកុណបក្សីនោះជាវិជាត មានជំណើរយ៉ាងនេះ ប្រកបដោយធម៌ដ៏ក្រៃលែង ព្រោះថា សកុណបក្សីនោះបានញុំាងចិត្តដ៏ទន់ឲ្យកើតដល់ព្រានព្រៃក្រុកដូចជាទូលព្រះបង្គំជាខ្ញុំ ។ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ មិនឃើញតង្វាយដទៃ ក្នុងស្រុកនៃព្រានបក្សីដ៏សមគួរដល់ព្រះអង្គឡើយ បពិត្រព្រះអង្គជាធំជាងពួកមនុស្ស សូមព្រះអង្គទតមើលនូវតង្វាយនោះ ។

(១៨២)ទិស្វា និសិន្នំ រាជានំ បីឋេ សោវណ្ណមយេ សុភេ

អជ្ឈភាសថ វក្កង្គោ វាចំ កណ្ណសុខំ ភណំ ។

កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ

កច្ចិ រដ្ឋមិទំ ផីតំ ធម្មេន មនុសាសសិ ។ (១)

(១៨៣)កុសលញ្ចេវ មេ ហំស អថោ ហំស អនាមយំ

អថោ រដ្ឋមិទំ ផីតំ ធម្មេន អនុសាសហំ ។

(១៨៤)កច្ចិ នុ ភោ អមច្ចេសុ ទោសោ កោចិ ន វិជ្ជតិ

កច្ចិ ច តេ តវត្ថេសុ នាវកង្ខន្តិ ជីវិតំ ។

(១៨៥)អថោបិ មេ អមច្ចេសុ ទោសោ កោចិ ន វិជ្ជតិ

អថោបិ តេ មមត្ថេសុ នាវកង្ខន្តិ ជីវិតំ ។

(១៨៦)កច្ចិ តេ សាទិសី ភរិយា អស្សវា បិយភាណិនី

បុត្តរូបយសូបេតា តវ ឆន្ទវសានុគា

---

១ ឱ. មនុសាសតិ ។



(១៨២) កាលហង្សធ្ងន់ឃើញព្រះរាជា ប្រថាប់គង់នៅលើតាំងដ៏វិការៈនៃមាសដ៏ល្អ កាលនឹងពោលនូវវាចាឲ្យស្រួលដល់ត្រចៀក បានពោលថា ព្រះអង្គបានសេចក្តីសុខស្រួលទេឬ ព្រះអង្គមិនមានជម្ងឺអ្វីទេឬ មួយទៀត ព្រះអង្គគ្រប់គ្រង ដែនដីដ៏ធំទូលាយនេះ តាមធម៌ដែរឬ ។

(១៨៣) (ព្រះរាជា...) ម្នាលហង្ស យើងមានសេចក្តីសុខស្រួលទេ ម្នាលហង្ស យើងមិនមានជម្ងឺអ្វីទេ ម្យ៉ាងទៀត យើងគ្រប់គ្រងនូវដែនដីដ៏ធំទូលាយនេះ តាមធម៌ហើយ ។

(១៨៤) (ហង្ស...) កំហុសបន្តិចបន្តួចរបស់ព្រះអង្គមិនមានក្នុងពួកអាមាត្យទេឬ ពួកអាមាត្យទាំងនោះ មិនអាល័យជីវិតព្រោះប្រយោជន៍ទាំងឡាយរបស់ព្រះអង្គទេឬ ។

(១៨៥) (ព្រះរាជា...) កំហុសបន្តិចបន្តួចរបស់យើង មិនមានក្នុងអាមាត្យទេ អាមាត្យទាំងនោះ មិនអាល័យជីវិតព្រោះប្រយោជន៍ទាំងឡាយរបស់យើងទេ ។

(១៨៦) (ហង្ស...) អគ្គមហេសីរបស់ព្រះអង្គដែលមានជាតិស្មើគ្នា ជាស្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្រ រូប និងយស លុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គដែរឬ ។

(១៨៧)អជោ មេសា ពិសី កាយា អស្សរ មិយការណិរ

មុត្តរូបយេ សុរេ ពតា មម ជន្តសាធុតា ។

(១៨៨)កវច្ឆ[1] កាច្ចិ ធុមហា- សត្តុហត្ថុក តតោ

ធុត្តមាបដ្ឋ វិបុលំ តស្មិំ បឋមមាបទេ ។

កាច្ចិ យញ្ញាបតិត្តាន ធនេណ្ឌ សមតោចយេ

បរំមេតសំ ជម្ពុ ធាតិតំ កវតិ តាវទេ ។

(១៨៩)ទេមមាសិ មហាកជ បរិមាបរិយាសតិ

ន ចាយំ កិញ្ចិរស្មាស សត្តុំ សមពជ្ជិ ។

បច្ចាមិត្តំ ទេសានោ មុត្តេ អជ្ជាភាសជ

តតាយំ សុមុខោ យេ បណ្ឌិតោ បច្ចាភាសជ ។

តស្ស តំ វេចនំ សុត្វា បសាទមយភជ្ជតា

តតោ មំ ធាមុចិ ធាសា អនុញ្ញាសិ សុខេន ច ។

វនច្ច សុមុខេនេវ បតគន្តាយ ចិន្តិតំ

ហោតោ សត្តាសេអាតមមំ ប្រតស្ស ធនមិច្ចតា ។

---

១ ឱ. កវច្ឆ ។ ម. កវច្ឆំ ។



(១៨៧) (ព្រះពុទ្ធ...) នេះជាហេតុរបស់យើងដែលមានជាតិស្មើ
គ្នា ជាស្រីស្ដាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ ប្រកប
ដោយប្រយោជន៍ ... [illegible] សុំអំណាចសេចក្ដីប្រាថ្នារបស់យើង ។
(១៨៨) អ្នកដ៏ចំរើន លុះតែឃើញកណ្ដាប់ដៃសត្រូវដ៏ធំ ដល់នូវសេចក្ដី
ទុក្ខដ៏ធំ គឺអន្តរាយទាំងមួយនោះដែរ ។ ព្រានព្រៃបានសួរ
ថាលោកសំគាល់អ្នកដោយដម្បូងដែរ ថ្ងៃកំណើតយ៉ាងនេះ តែង
មានជាបច្ចាមិត្ត ដល់ពួកអ្នកធ្វើអំពើអាក្រក់ ក្នុងខណៈនោះ ។
(១៨៩) (កវចហ្ស...) បពិត្រមហាកជ ខ្លួនព្រះបន្ទំជាទីទុកដាក់សេចក្ដី
ស្នេហាក្នុងខ្លួន កាលបើមានហេតុយ៉ាងនេះ ព្រានព្រៃនេះ មិន
ដល់ (នូវកាតាំងខ្លួន) ដូចជាសត្រូវចំពោះខ្លួនព្រះបន្ទំជាទីទុក
ក្នុងឡើយ ។ ព្រានព្រៃនេះ ថយបន្តិច ។ កំពុងសាកសួរ
ខ្លួនព្រះបន្ទំជាមុន គ្រានោះ ហង្សឈ្មោះសុមុខៈ ជាបណ្ឌិត
បានឆ្លើយតបវិញ ។ ព្រានព្រៃបានស្ដាប់ពាក្យហង្សឈ្មោះ
សុមុខៈនោះហើយ ក៏បានដល់នូវសេចក្ដីជ្រះថ្លា លំដាប់នោះ
ព្រានព្រៃបានដោះខ្លួនព្រះបន្ទំជាទីទុកដាក់ ទាំងបានអនុញ្ញាត
ឲ្យទៅដោយស្រួលផង ។ ដំណើរមកក្នុងសំណាក់នៃព្រះអង្គនេះ
គឺហង្សឈ្មោះសុមុខៈនេះបានប្រាថ្នាដល់ព្រានព្រៃនុ៎ះ បានគិត
ហើយដើម្បីប្រយោជន៍ដល់ព្រានព្រៃនុ៎ះ ។

(១៨០)ស្វាគតញ្ចេវិទំ ភវតំ បតីតោ ចស្មិ ទស្សនា

ឯសោ ចាបិ ពហុំវិត្តំ លភតំ យាវទិច្ឆតិ ។

(១៨១)សន្តប្បយិត្វា នេសាទំ ភោគេហិ មនុជាធិបោ

អជ្ឈភាសថ វក្កង្គំ កណ្ណសុខំ ភណំ

(១៨២)យំ ខលុ ធម្មមាធីនំ វសោ វត្តតិ កិញ្ចនំ

សព្វត្ថិស្សរិយំ ភវតំ បសាសថ យទិច្ឆថ ។

ទានត្ថំ ឧបភោត្តុំ វា យញ្ចញ្ញំ ឧបកប្បតិ

ឯតំ ទទាមិ វោ វិត្តំ ឥស្សរិយំ វិស្សជាមិ វោ ។

(១៨៣)យថា ច ម្យាយំ សុមុខោ អជ្ឈភាសេយ្យ បណ្ឌិតោ

កាមសា ពុទ្ធិសម្បន្នោ តម្យស្ស បរមប្បិយំ ។

(១៨៤)អហំ ខលុ មហារាជ នាគនាសូរូបមំ

បដិវត្តុំ ន សក្កោមិ ន មេ សោ វិនយោ សិយា ។



(១៨០) (ព្រះរាជា...) ដំណើរមករបស់អ្នកដ៏ចំរើនទាំងពីរឡាយ ជាការស្រួលណាស់ហើយ យើងមានចិត្តត្រេកអរព្រោះការបានឃើញអ្នក ឯព្រានព្រៃនេះ ចូរបានទ្រព្យដ៏ច្រើនដរាបទាល់សល់ចំណង់ចុះ ។

(១៨១) (អភិសម្ពុទ្ធគាថា) ព្រះរាជាជាធំជាងមនុស្ស បានញុំាងនាយនេសាទឲ្យឆ្អែតស្កប់ស្កល់ដោយភោគៈតាមដំណើរដែលសមគួរហើយទ្រង់យាយនូវពាក្យដ៏សុខស្រួលដល់ត្រចៀក បានពោលហើយ ។

(១៨២)(ព្រះរាជា...)អំណាច (របស់យើង) ប្រព្រឹត្តទៅអស់ទីជាទីទ្រង់ទុកនូវធម៌ (ច្បាប់) ណា អ្នកដ៏ចំរើនចូរជាធំក្នុងទីទាំងអស់នោះ សូមប្រើកិច្ចការ ចូរគ្រប់គ្រងនូវទីជាទីប្រាថ្នាចុះ ។ ម្យ៉ាងទៀត ទ្រព្យណាដទៃគាប់សមគួរដើម្បីនឹងឲ្យទាន ឬជាគ្រឿងប្រើប្រាស់ យើងឲ្យនូវទ្រព្យនោះដល់អ្នក យើងនឹងលះនូវភាពជាធំដល់អ្នក ។

(១៨៣) ប្រសិនបើហង្សឈ្មោះសុមុខៈ ជាបណ្ឌិតបរិបូណ៌ដោយប្រាជ្ញានេះ ពោលនូវពាក្យដល់យើងតាមសេចក្ដីប្រាថ្នា ពាក្យនោះជាទីស្រឡាញ់របស់យើងក្រៃពេក ។

(១៨៤) ( ហង្សសេនាបតី... ) បពិត្រព្រះមហារាជ ខ្ញុំព្រះបង្គំជាខ្ញុំ ដូចជានាគរាជ ( ចូលទៅ ) កាន់ចន្លោះ ( ខ្ញុំ ) មិនអាចនឹងក្រាបទូលតបបានទេ ព្រោះការក្រាបទូលតបនោះ មិនមែនជាច្បាប់ សម្រាប់ខ្ញុំព្រះបង្គំ ជាខ្ញុំឡើយ ។

អញ្ញាតកញ្ញោ សោ សេដ្ឋោ  ភូតា ឧត្តមសត្តកេ

ភូមិបាលោ មនុស្សិន្ទោ  បូជា ពហូហិ ហេតុភិ ។

តេសំ ទុភិន្នំ គណាតំ  វត្តមានេ វិនិច្ឆយេ

នន្តរំ បដិវត្តព្ពំ  បេស្សេន មនុជាធិប ។

(១៩៥) ធម្មេន ការេ នេសាទោ  បណ្ឌិតោ អណ្ឌជោ ឥតិ

ឆ ហេវ អញ្ញគត្តស្ស  ឥតោ បភាតិ សោ សិយា ។

ឯវំ អត្តបករិយា  ឯវំ ឧត្តមសត្តកេ

យាវតត្ថិ មយា ទិដ្ឋា  នាញ្ញំ បស្សាមិ ឯទិសំ ។

តុដ្ឋាស្មិ វោ បកតិយា  វាក្យេន មធុរេន ច

ឯសោ ចាបិ មមច្ឆន្ទោ  ចិរំ បស្សេយ្យ វោ ឧភោ ។

(១)

(១៩៦) យំ កិច្ចំ បរមេ មិត្តេ  កតមស្មាសុ តំ តយា

បត្តា និស្សំសយំ ត្យម្ហា  ភត្តិរស្មាសុ យា តវ ។

---

១ ឱ. យំ កិច្ចំ ។



កាចហាន្សប្រសើរបំផុតជាទីពួកខ្ញុំព្រះបង្គំជាខ្ញុំនោះផង ព្រះអង្គ

ជាសត្វដ៏ឧត្តមក្រៃលែងដ៏ជាធំជាងមនុស្សផង ខ្ញុំព្រះបង្គំជាខ្ញុំ

បូជាដោយហេតុដ៏ច្រើន ៗ បពិត្រព្រះអង្គជាធំជាងមនុស្ស កាល

ដែលការវិនិច្ឆ័យ កំពុងប្រព្រឹត្តទៅតាមពាក្យជាអ្នកបំរើមិនគប្បីក្រោម

ខ្ញុំព្រះបង្គំបញ្ចាំងព្រះអង្គទាំងពីរកំពុងមានព្រះបន្ទូលពោលនឿយៗ

(១៩៥) (ព្រះរាជា...) បានឮថា នាយព្រាន បានសរសើរអ្នក

ដោយពិត អ្នកជាបក្សីបណ្ឌិត ព្រានដែលបានមិនគប្បីមាន

ដល់សត្វដែលមានអត្តភាពមិនទាន់សម្រេច ។ អ្នកមានប្រាជ្ញា

ដ៏ប្រសើរយ៉ាងនេះ ជាសត្វដ៏ខ្ពស់យ៉ាងនេះ សត្វទាំងឡាយ

ទាំងប៉ុន្មានដែលយើងបានឃើញហើយ យើងមិនដែលឃើញនូវ

សត្វដទៃដូចនេះ ។ យើងត្រេកអរដោយបានឃើញអ្នកទាំងពីរ

ជាមិត្តថ្មីផង ដោយពាក្យដ៏ពីរោះផង ទាំងជាសេចក្តីពេញចិត្តរបស់

យើង យើងគប្បីចួបនូវអ្នកទាំងពីរ អស់កាលជាអង្វែង ។

(១៩៦) (កាចហាន្ស...) អំពើណាដែលត្រូវធ្វើចំពោះមិត្តដ៏ប្រសើរ អំពើ

នោះព្រះអង្គបានធ្វើហើយចំពោះខ្ញុំព្រះបង្គំទាំងពីរ សេចក្តី

ភក្តីភាពណា របស់ព្រះអង្គ ចំពោះខ្ញុំព្រះបង្គំទាំងពីរ ខ្ញុំ

ព្រះបង្គំទាំងពីរយល់ហើយចំពោះព្រះអង្គ ដោយឥតសង្ស័យ ។

អទ្ធា នូន សុមុខោ- ញាតិសង្ឃស្ស មន្តិនំ
អគស្សវេន អស្មាកំ ទត្វាំ ពហុសុ បក្ខិសុ ។
តេសំ សោកវិឃាតាយ តយា អនុមតា មយំ
តំ បជត្វិណោ តាតា ញាតី បស្សេមុរិន្ទម ។
អញ្ញាយំ វិបុលំ បីតី ភវតំ វិភ្ហមំ ពស្សោ
ឃរេភ ភិបំ មហាអត្ថោ ញាតិវិស្សាសមាសិយោ ។

[១៩៧] វិធំ វត្វា ធតរដ្ឋោ ហំសរាជា ឧកធិបំ
ឧត្តមំ ជវមជ្ឈាយ ញាតិសង្ឃមុបាគមុំ ។
តេ អរោគេ អនុប្បត្តេ ទិស្វាន បរមេ ទិជេ
កោកាតិមគ្គុំ ហំសា បុថុសទ្ទោ អជាយថ ។
តេ បតីតា បមុត្តេន ភត្តុនា ភត្តុគារវា
សមន្តា បរិការីសុ អណ្ឌជា លទ្ធបច្ចយា ។





សេចក្តីទុក្ខឯណោះ បានរក៏តរៀនហើយគ្រនឹបក្សីជាច្រើន ព្រោះមិនឃើញនូវមុលព្រះបន្តីជាទុំទាំងពីរ ក្នុងបន្ទោះនៃពួកញាតិជាច្រើន ដោយពិត ។ ឃើនាំងពីរដែលព្រះអង្គអនុញ្ញាតហើយ ដើម្បីកំចាត់បន្ទ់នូវសេចក្តីសោក របស់បក្សីទាំងនោះ បពិត្រព្រះអង្គជាអ្នកទូន្មានខ្មាំងសត្រូវ ទូលព្រះបង្គំជាខ្ញុំទាំងពីរ សូមថ្វាយបង្គំលាព្រះអង្គ ហើយទៅឃើញនូវពួកញាតិ ។ ទូលព្រះបង្គំជាខ្ញុំ បាននូវសេចក្តីត្រេកអរដ៏ទូលាយ ព្រោះបានជួបព្រះអង្គដោយពិត មួយទៀត ប្រយោជន៍នេះ កើតមានព្រោះតែសេចក្តីស្និទ្ធស្នាលចំពោះញាតិ ។

[១៩៨] (អភិសម្ពុទ្ធគាថា) លុះព្រះយជម្ពស្សរឈ្មោះធតរដ្ឋ: (និងហង្សឈ្មោះសុមុខ:) បានពោលពាក្យនេះចំពោះព្រះរាជាជាធំលើផែនដីហើយ ក៏ហើរស៊ំដៅទៅរកពួកញាតិ ហោះហើរយនូវសន្ទុះដ៏ឧត្តម ។ សត្វហង្សទាំងឡាយ បានឃើញនូវហង្សដ៏ឧត្តមទាំងពីរនោះមិនមានរោគមកដល់ហើយ ក៏បានធ្វើនូវសម្លេងថា កេកា ៗ ស្រស់ស្រៀនយ៉ាងខ្លាំង ក៏កើតមានឡើង ។ បក្សីទាំងនោះ មានសេចក្តីត្រេកអរ ព្រោះម្ចាស់រួចហើយ ជាសត្វគោរពចំពោះម្ចាស់ ជាសត្វបាននូវទីពឹង ហើយហើរព្រៀបជុំវិញ ។

(១៩៨) ឯវំ មិត្តវតំ អត្ថា សព្វេ ហោន្តិ បទក្ខិណា
ហំសា យថា ធតរដ្ឋា ញាតិសង្ឃមុបាគមុន្តិ ។

ចុល្លហំសជាតកំ បឋមំ ។

## មហាហំសជាតកំ

(១៩៩) ឯតេ ហំសា បក្កមន្តិ វក្កង្គា ភយមេរិតា
ហរិត្តច ហេមវណ្ណ កាមំ សុមុខ បក្កម ។
ឱហាយ មំ ញាតិគណា ឯកំ បាសវសំ គតំ
អនបេក្ខមានា គច្ឆន្តិ កឹ ឯកោ អវហីយសិ ។
បតេវ បតតំ សេដ្ឋ នត្ថិ ពទ្ធេ សហាយតា
មា អនីឃាយ ហាបេសិ កាមំ សុមុខ បក្កម ។
(២០០) នាហំ ទុក្ខបរេតោបិ ធតរដ្ឋ តុវំ ជហេ
ជីវិតំ មរណំ វា មេ តយា សទ្ធឹ ភវិស្សតិ ។
នាហំ ទុក្ខបរេតោបិ ធតរដ្ឋ តុវំ ជហេ
ន មំ អនរិយសំយុត្តេ កម្មេ យោជេតុមរហសិ ។



(១៩៨) ប្រយោជន៍ទាំងអស់ របស់ពួកជនអ្នកមានមិត្ត រមែងសម្រេចសេចក្ដីសុខយ៉ាងនេះ ដូចជាហង្សឈ្មោះធតរដ្ឋៈនឹងហង្សឈ្មោះសុមុខៈ បានទៅដល់ពួកញាតិដូច្នោះ ។

ចប់ ចុល្លហង្សជាតក ទី ១ ។

## មហាហង្សជាតក

(១៩៩) (ពស់ហង្សពោលថា) ហង្សទាំងឡាយនេះ ត្រូវភ័យគំរាមហើយ ទាំងកោងហើរទៅ ម្នាលសុមុខៈ អ្នកមានស្បែកដូចមាស មានសម្បុរដូចមាស អ្នកចូរហើរទៅតាមប្រាថ្នាចុះ ។ ពួកបក្សីជាញាតិ បានលះចោលយើង ដែលលុះអំណាចនៃអន្ទាក់តែម្នាក់ឯង មិនអាល័យហើរទៅ អ្នកក្រាញនៅតែម្នាក់ឯងដូចម្ដេច ។ ម្នាលអ្នកដ៏ប្រសើរជាងពួកបក្សី អ្នកចូរហើរទៅចុះ ព្រោះជាភាពជាសំឡាញ់នឹងយើងដែលជាប់ចំណង មិនមានទេ អ្នកកុំធ្វើខុសឲ្យសាបសូន្យចាកសេចក្ដីសុខឡើយ ម្នាលសុមុខៈ អ្នកចូរហើរទៅតាមប្រាថ្នាចុះ ។
(២០០) (ហង្សសេនាបតីឈ្មោះសុមុខៈពោលថា) បពិត្រព្រះបាទធតរដ្ឋៈ ខ្លួនព្រះបង្គំជាខ្ញុំ សូម្បីសេចក្ដីទុក្ខគ្របសង្កត់ហើយ ក៏មិនលះបង់ចោលព្រះអង្គ ជីវិតឬសេចក្ដីស្លាប់របស់ខ្លួនព្រះបង្គំជាខ្ញុំនឹងមានជាមួយព្រះអង្គ ។ បពិត្រព្រះបាទធតរដ្ឋៈ ខ្លួនព្រះបង្គំជាខ្ញុំ សូម្បីសេចក្ដីទុក្ខគ្របសង្កត់ហើយ ក៏មិនលះបង់ចោលព្រះអង្គ ទាំងព្រះអង្គក៏មិនគួរប្រកបខ្លួនព្រះបង្គំជាខ្ញុំ ក្នុងអំពើមិនប្រសើរទេ ។

សាមច្ចកេ សខា ត្យម្ហិ សចិត្តេ វសេ ឋិតោ ។
ញាតោ សេនាបតិ ត្យាហំ ហំសានំ បវរុត្តម
កថំ អហំ វិកត្ថិស្សំ ញាតិមជ្ឈេ ឥតោ គតោ
តំ ហិត្វា បតតំ សេដ្ឋ កិន្តេ វក្ខាមិតោ គតោ
ឥធ បាណំ ចជិស្សាមិ នានរិយំ កត្តុមុស្សហេ ។

(២០១) ឯសោ ហិ ធម្មោ សុមុខ យំ ត្វំ អរិយបថេ ឋិតោ
យោ ភត្តារំ សខារំ មំ ន បរិច្ចត្តុមុស្សហេ ។
តញ្ហិ មេ បេក្ខមានស្ស ភយំ ត្វេវ ន ជាយតិ
អធិគច្ឆសិ ត្វំ មយ្ហំ បរិក្ខតស្ស ជីវិតំ ។

(២០២) ឥច្ចេវំ មន្តយន្តានំ អរិយានំ អរិយវុត្តិនំ
ទណ្ឌមាទាយ នេសាទោ អាបតី តុរិតោ ភុសំ ។



ខ្ញុំព្រះបង្គំជាខ្ញុំ ជាកូនអាមាត្យ ជាសំឡាញ់នៃព្រះអង្គ ជាមិត្តនៅក្នុងអំណាចចិត្ត របស់ព្រះអង្គ ដែលជាមិត្តប្រព្រឹត្តទៅដោយប្រពៃ បពិត្រព្រះអង្គដ៏ប្រសើរខ្ពង់ខ្ពស់ ជាធំក្នុងពួកហង្ស ខ្ញុំព្រះបង្គំជាខ្ញុំ ត្រូវជាសេនាបតីរបស់ព្រះអង្គ លុះខ្ញុំព្រះបង្គំជាខ្ញុំ ទៅអំពីទីនេះ នឹងថ្លែងសេចក្តីក្នុងកណ្តាលញាតិ ដោយប្រការដូចម្តេច បពិត្រព្រះអង្គដ៏ប្រសើរ ជាធំក្នុងពួកបក្សី ខ្ញុំព្រះបង្គំលះបង់ព្រះអង្គ ហើយទៅអំពីទីនេះ នឹងប្រាប់ (ដំណឹង) របស់ព្រះអង្គដូចម្តេច ខ្ញុំព្រះបង្គំនឹងលះបង់ជីវិតក្នុងទីនេះ មិនអាចនឹងធ្វើនូវអំពើ មិនប្រសើរទេ ។

[២០១] (ពួកហង្ស..) ម្នាលសុមុខៈ នុ៎ះជាធម៌ (របស់បុគ្គលអ្នកបណ្ឌិតទាំងឡាយ) ព្រោះថា អ្នកឋិតនៅក្នុងអរិយមគ្គរបស់ជនដ៏ប្រសើរ មិនអាចលះបង់នូវយើងដែលជាម្ចាស់ផង ជាសំឡាញ់ផង ។ ម្យ៉ាងទៀត កាលយើងសំឡឹងមើលអ្នក សេចក្តីភ័យក៏មិនកើតឡើងសោះឡើយ អ្នកបាននាំនូវជីវិតយើងដែលមានសេចក្តីលំបាកយ៉ាងនេះ ឲ្យបានទូលំទូលាយ ។

[២០២] (អភិសម្ពុទ្ធគាថា) កាលដែលហង្ស ដ៏ប្រសើរ (ពីរ) មានការប្រព្រឹត្ត ដ៏ប្រសើរ កំពុងប្រឹក្សាគ្នា យ៉ាងនេះ ដូច្នេះ នាយនេសាទកាន់ដំបង ប្រញាប់មក ដល់ភ្លាម ។

តមាយន្តំ និស្វាន សុមុខោ អតិព្រូហយិ[១]
អដ្ឋាសិ បុរតោ រញ្ញោ ហំសោ វិស្សាសយំ ព្យថំ។
មា ភាយិ បតតំ សេដ្ឋ ន ហិ ភាយន្តិ តាទិសា
អហំ យោគំ បយុញ្ជិស្សំ យុត្តំ ធម្មូបសញ្ហិតំ
តេន បរិយាបទានេន ខិប្បំ បាសា បមោក្ខសិ ។
(៦០៣) តស្ស តំ វចនំ សុត្វា សុមុខស្ស សុភាសិតំ
បហដ្ឋលោមោ នេសាទោ អញ្ជលិស្ស បណាមយិ ។
ន មេ សុតំ វា ទិដ្ឋំ វា ភាសន្តោ មានុសិំ ទិជោ
អរិយំ ព្រុវានោ វក្កង្គោ ចជន្តោ មានុសិំ គិរំ ។
កិន្នុ តាយំ ទិជោ ហោតិ មុត្តោ ពទ្ធំ ឧបាសសិ
ឱហាយ សកុណា យន្តិ កឹ ឯកោ អវហីយសិ ។
(៦០៤) រាជា មេ សោ ទិជាមិត្ត សេនាបច្ចស្ស ការយិំ
តមាបទេ បរិច្ចត្តុំ នុស្សហេ វិហាតវេ ។

១ ម. អតិព្រូហយិ ។



ហង្សឈ្មោះសុមុខៈ លុះឮឃើញនាយនេសាទនោះ មកដល់ ក៏ឋិតនៅខាងមុខរាជហង្ស ហើយលួងលោមរាជហង្សដែលកំពុងភ័យ ព្រួយបារម្ភផង បពិត្រព្រះអង្គដ៏ប្រសើរ ជាងសត្វស្លាប ព្រះអង្គកុំភ័យឡើយ ព្រោះថាបក្សីពិសេសដូចជាព្រះអង្គ រមែងមិនភ័យទេ ខ្ញុំព្រះបង្គំនឹងប្រកបសេចក្តីព្យាយាម ដ៏សមគួរ ដែលអាស្រ័យនូវធម៌ ព្រះអង្គនឹងរួចចាកអន្ទាក់ ជាឆាប់ ដោយសេចក្តីព្យាយាមនោះមិនខាន ។

(៦០៣) នាយនេសាទ បានឮសុភាសិត របស់ហង្សឈ្មោះសុមុខៈនោះហើយ ក៏ត្រេកអរ បង្អោនខ្លួនអញ្ជលី ចំពោះហង្សឈ្មោះសុមុខៈនោះថា អ្នកជាបក្សីពោលនូវភាសា របស់មនុស្ស ពោលពាក្យដ៏ប្រសើរ បញ្ចេញនូវវាចារបស់មនុស្សដែលអញមិនធ្លាប់ឮ មិនធ្លាប់ឃើញ ។ បក្សីនេះត្រូវជាអ្វីនឹងអ្នក អ្នកជាសត្វរួចហើយ ចូលមកកេសត្វជាប់ ពួកបក្សីហើរទៅលះបង់ទៅហើយ ម្តេចក៏អ្នកក្រាញនៅតែម្នាក់ឯង ។

(៦០៤) (ហង្សសេនាបតី ..) ម្នាលនាយព្រានជាសម្លាញ់នៃបក្សី រាជហង្សនោះជាព្រះរាជារបស់ខ្ញុំ ខ្ញុំជាសេនាបតីរបស់រាជហង្សនោះ ខ្ញុំមិនអាចលះបង់ស្តេចបក្សីនោះ ក្នុងកាលមានសេចក្តីអន្តរាយទេ ។

មហាគណាយំ ភត្តា មេ មា ឯកោ ព្យសនំ អគា
យថា តំ សម្មោទមានា ភត្តារំ អនុកម្បរេ ។

(២០៥) អរិយវត្តសិ វក្កង្គ យោ បិណ្ឌមបចាយសិ
ចជាមិ តេ តំ ភត្តារំ គច្ឆតូភោ យថាសុខំ ។

(២០៦) ស ចេ អត្តប្បយោគេន ឱហិតោ ហំសបក្ខិនំ
បដិគ្គណ្ហាម តេ សម្ម ឯតំ អភយទក្ខិណំ ។
នោ ចេ អត្តប្បយោគេន ឱហិតោ ហំសបក្ខិនំ
អនិស្សរោ មុញ្ចមម្ហេ ថេយ្យំ កយិរាសិ លុទ្ទក ។

(២០៧) យស្ស ត្វំ ភតកោ រញ្ញោ កាមំ តស្សេវ បាបយ
តត្ថ សំយមនោ រាជា យថាភិញ្ញំ ករិស្សតិ ។



ព្រះរាជារបស់ខ្ញុំនេះ ជាម្ចាស់នៃពួកហង្សដ៏ច្រើន កុំដល់នូវសេចក្ដីវិនាសតែម្នាក់ឯងឡើយ បពិត្រនាយនេសាទដ៏សំឡាញ់ ព្រោះថា កងហង្សនេះជាម្ចាស់ ខ្ញុំតែងត្រេកអរក្រៃពេក (គួរនៅសំណាក់កងហង្សនោះ) ។

(២០៥) (ព្រះនៃព្រ...) ម្នាលសត្វហង្ស អ្នកណា បូជាគោរពចំពោះអាហារ (ដែលបានអំពីម្ចាស់) អ្នកនោះឈ្មោះថា ប្រព្រឹត្តធម៌ដ៏ប្រសើរ យើងនឹងលែងនូវម្ចាស់របស់អ្នកនោះ អ្នកទាំងពីរចូរទៅតាមស្រួលចុះ ។

(២០៦) (ហង្សសេនាបតី...) នែសំឡាញ់ បើលោកដាក់អន្ទាក់ពួកហង្សនឹងបក្សីដ៏សេស ដោយសេចក្ដីព្យាយាមរបស់ខ្លួន យើងខ្ញុំនឹងទទួលនូវអភយទាននេះ របស់លោក បើលោកមិនដាក់អន្ទាក់ពួកហង្ស នឹងបក្សីដ៏សេស ដោយសេចក្ដីព្យាយាមរបស់ខ្លួនទេ បពិត្រនាយនេសាទ លោកមិនមែនជាធំ ការដែលទុកយើងខ្ញុំ ឈ្មោះថា ធ្វើនូវការលួច ។

(២០៧) លោកជាបុគ្គលស៊ីឈ្នួល របស់ព្រះរាជាណា លោកចូរនាំយើងខ្ញុំឡើងដល់ទៅព្រះរាជានោះតាមប្រាថ្នាចុះ ព្រះរាជាព្រះនាមសំយមៈ នឹងធ្វើតាមគាប់ព្រះទ័យ ក្នុងព្រះរាជនិវេសន៍នោះ ។

(២០៨) ឯវំ វុត្តោ នេសាទោ ហេមវណ្ណេ ហំសាធិបេ

ឧភោ ហត្ថេហិ បគ្គយ្ហ[១] បញ្ជរេ អជ្ឈវោទហិ ។

តេ បញ្ជរគតេ បក្ខី ឧភោ ភស្សរវណ្ណិនេ

សុមុខំ ធតរដ្ឋញ្ច លុទ្ទោ អាទាយ បក្កមិ ។

(២០៩) ហរីយមានោ ធតរដ្ឋោ សុមុខំ ឯតទព្រវិ

ពាឡ្ហំ ភាយាមិ សុមុខ សាមាយ លក្ខណូរុយា

អស្មាកំ វធមញ្ញាយ អថត្តានំ វធិស្សតិ ។

បាកហំសា ច សុមុខ សុហេមា ហេមសុត្តចា

កោញ្ចី សមុទ្ទតីរេវ កបណា នូន រុច្ឆតិ ។

(២១០) ឯវំ មហន្តោ លោកស្ស អប្បមេយ្យោ មហាគណី

ឯកិត្ថិមនុសោចេយ្យ នយិទំ បញ្ញវតាមិវ ។

១ ម. សំវដ្ឋ ។



(៦០៨) (អភិសម្ពុទ្ធគាថា) លុះហង្សឈ្មោះសុមុខៈ និយាយយ៉ាងនេះហើយ នាយនេសាទ ក៏យកដៃស្ទួយនូវហង្សទាំងពីរ ដែលមានសម្បុរនៃស្បែកដូចមាស ហើយដាក់ទៅក្នុងទ្រុង ។ ព្រានព្រៃបាននាំយកបក្សីឈ្មោះសុមុខៈ ១ ឈ្មោះធតរដ្ឋៈ ១ ទាំងពីរ មានសម្បុរដ៏ភ្លឺផ្លេក នាំទៅក្នុងទ្រុងនោះហើយចៀសចេញទៅ ។

(៦០៩) កាលហង្សឈ្មោះធតរដ្ឋៈ ដែលព្រានព្រៃកំពុងនាំទៅ បានពោលពាក្យនេះនឹងហង្សឈ្មោះសុមុខៈថា ម្នាលសុមុខៈ ខ្ញុំខ្លាច (សេចក្តីស្លាប់) នៃនាងបក្សីឈ្មោះសុហេមា ដែលមានសម្បុរដូចមាស មានភ្លៅប្រកបដោយលក្ខណៈល្អណាស់ នៃនាងសុហេមាបានដឹងថាគេសម្លាប់នូវយើងទាំងពីរហើយ មុខជានឹងសម្លាប់ខ្លួនឯងដែរ ។ ម្នាលសុមុខៈ នាងបក្សីឈ្មោះសុហេមាជាភរិយា នៃពួកហង្ស ដែលមានស្បែកល្អដូចមាស ជាសត្វក្រោមខ្ញុំ ដោយពិត ដូចជាក្រៀលញី ខ្ញុំយំប្រែបនៃសមុទ្រដូច្នោះ ។

(៦១០) (ហង្សសេនាបតី...) ព្រះអង្គជាធំជាងហង្ស មានគុណប្រមាណមិនបាន ជាម្ចាស់នៃពួកហង្ស ជាច្រើនយ៉ាងនេះ ហើយសោកស្តាយ នូវមេហង្សមួយ ការយ៉ាងនេះ ហាក់ដូចជាមិនសមគួរ ដល់ព្រះអង្គ ដែលមានប្រាជ្ញាឡើយ ។

វាតោវ គន្ធមាទេតិ ឧភយំ ឆេកបាបកំ

ពាលោ អាមកបក្កំវ លោលោ អច្ចោវ អាមិសំ ។

អវិនិច្ឆយញ្ញូ អត្ថេសុ អច្ចោវ បដិកាសិ យំ

កិច្ចាកិច្ចំ ន ជានាសិ សម្បត្តោ កាលបរិយាយំ ។

អឌ្ឍុម្មត្តោ ឧទីរេសិ យោ សេយ្យោ មញ្ញសិត្ថិយោ

ពហុសាធារណា ហេតា សោណ្ឌានំវ សុរាឃរំ ។

មាយា ចេតា មរីចី ច សោកោ រោគោ ចុបទ្ទវោ

ខរា ច ពន្ធនា ចេតា មច្ចុបាសា គុហាសយា ។

តាសុ យោ វិស្សសេ បោសោ សោ នរេសុ នរាធមោ ។



ព្រះអង្គសោកស្តាយ ព្រោះតែស្ត្រីទាំងឡាយ ព្រោះស្ត្រីទាំងឡាយដូចជាខ្យល់ហួចយក នូវក្លិនល្អទាំងអាក្រក់ទាំងពីរ ឬដូចជាក្មេងល្ងង់ ចាប់យកផ្លែឈើទាំងឆ្អិនទាំងខ្ចី ព្រះអង្គសោកដូចមនុស្សម្នាក់ ជាអ្នកស្រេកឃ្លាន ចង់យកសាច់ស៊ី ( ទាំងល្អទាំងអាក្រក់ ) ។ ព្រះអង្គមិនដឹងនូវការកិច្ចឬអកិច្ចប្រយោជន៍ទាំងឡាយ ដូចជាមនុស្សល្ងង់ខ្លៅ ដល់នូវព្រះបត្តិ លុះដល់កាលជាទីស្លាប់ទៅតែមិនដឹងអំពើដែលគួរធ្វើនិងមិនគួរធ្វើឡើយ ។ ព្រះអង្គជាបុគ្គលឆ្កួតពាក់កណ្តាល និយាយផ្តេសផ្តាស ព្រោះថាព្រះអង្គសំគាល់នូវស្ត្រីទាំងឡាយថាប្រសើរបំផុត ព្រោះថាស្ត្រីទាំងនេះជាសាធារណៈដល់ជនច្រើន ដូចជាកន្លែងស្រាជាសាធារណៈដល់ពួកអ្នកលេង ។ មួយទៀត ស្ត្រីទាំងនេះ ជាមាយាដូចជាថ្ងៃបណ្តាក្តៅ ជាទីសោយសោក ជាទីកើតនៃរោគ ជាទីឧបទ្រព ស្ត្រីទាំងនេះមានទុក្ខព្រួយដ៏ខ្លាំង ជាចំណងសម្រាប់ចង ជាអន្ទាក់នៃសេចក្តីស្លាប់ ជាគុហាសម្រាប់នៅ (របស់មច្ចុរាជ) បុរសណា ទុកចិត្តនូវស្ត្រីទាំងនោះ បណ្តាបុរសទាំងឡាយ បុរសនោះឈ្មោះថា បុរសថោកទាប ។

(២១១) យំ វុឡ្ហមាហុ ឧទញ្ញាតំ តោ តំ ជិណ្ណម្បរមាតំ
មកោ កុន្តិត្ថិយោ ជាម   លោកស្មឹ ឧបបជ្ជិសុំ ។
ចិន្នា បណ៌ហិតា តាសុ(១)   រតិ តាសុ(២) បតិដ្ឋិតា
វីជានិ តាសុ(៣) វហន្តិ   យន្តំ សត្តា បជាយរេ
តាសុ តោ ចិត្តិជេ ហោសោ   ជាលមាសជ្ជ តាលសិតំ ។
ខុមេវ ជាញ្ញោ សុមុខ   ជីវំ អត្ថស្ស យុញ្ញសិ
តស្ស ត្យជ្ជ ភយេ ជាតេ   ភីតេន ជាយតេ មតិ ។
សព្វោ ហិ សំសយំ បត្តោ   ភយំ ភីរុ តិតិក្ខតិ
បណ្ឌិតា ហិ មហត្តាទោ   អត្ថេ យុញ្ជន្តិ ទុយ្យុជេ ។
ឯតទត្ថាយ រាជានោ   សូរមិច្ឆន្តិ មន្តិនំ
បដិពាហតិ យំ សូរោ   អាបទំ អត្តបរិយាយំ ។

១–២ ឱ. ម. ត្យាសុ ។ ៣ ម. តីជានិ ត្យាសុ ។





(៤៩១) (ពេលនោះ...) (ពួកស្ត្រី) ណា ដែលពួកជនអ្នកចំរើន ពោលថាប្រាជ្ញាប្រាកដហើយ បុគ្គលណា ស្គាល់នូវពួកស្ត្រីនោះបាន ពួកស្ត្រីទាំងឡាយ មានគុណច្រើន ហើយកើតឡើងក្នុងលោក (មុខគេ) ។ ល្បែងរីករាយក្តី ក្នុងស្ត្រីទាំងនោះ សេចក្តីត្រេកអរកើតមានក្នុងស្ត្រីទាំងនោះដែរ ពូជទាំងឡាយរមែងលូតលាស់ឡើងក្នុងស្ត្រីទាំងនោះ ពួកសត្វទាំងអស់ តែងកើត (ព្រោះអាស្រ័យស្ត្រីទាំងនោះ) បុរសដូចម្តេច ឬដឹងតែដោយចិត្តហើយ គប្បីខ្ជិលណាយក្នុងស្ត្រីទាំងនោះ ។ ម្នាលសុមុខៈ អ្នកឯងវិញនុ៎ះហើយ មិនមែនជាអ្នកដទៃ រមែងប្រកបក្នុងប្រយោជន៍ចំពោះពួកស្ត្រី ក៏យកើតឡើងដល់អ្នកក្នុងថ្ងៃនេះ គំនិតរបស់អ្នកក៏កើតឡើងដោយសេចក្តីភ័យ ។ ជនទាំងអស់ដល់នូវសេចក្តីសង្ស័យ ក្នុងជីវិតហើយជាអ្នកខ្លាច ប្រឹងអត់ទ្រាំនូវសេចក្តីខ្លាច ចំណែកពួកបណ្ឌិត ជាអ្នកខិតខំក្នុងទីដ៏ប្រសើរ តែងប្រកបក្នុងប្រយោជន៍ដែលគេប្រកបបានដោយក្រ ។ ព្រះរាជាទាំងឡាយ តែងប្រាថ្នានូវមន្ត្រី ដែលមានសេចក្តីក្លៀវក្លា ដើម្បីប្រយោជន៍ការពារ នូវអន្តរាយនេះ ព្រោះមន្ត្រីដែលក្លៀវក្លា រមែងហាត់ នូវសេចក្តីអន្តរាយ នឹងការពារ នូវខ្លួនបាន ។

ពា ពោ អត្ថំ វិកាតព្ពំសុ   រញ្ញោ សុទាមហាបោស
តាហាហំ វិញ្ញាបន្តាមំ   ផលំ វេឡុំវ តំ វធិ ។
មុត្តោបិ នេច្ឆសិ ឧទ្ទេតុំ   សយំ ពន្ធំ ឧបាគមិ
សោបជ្ជ សំសយំ បត្តោ   អត្ថំ គណ្ហាហិ មាមុខំ ។

(២១២) សោតុំ យោគំ បយុញ្ជស្សុ   យុត្តំ ធម្មូបសញ្ហិតំ
ត្វំ បរិយាបញ្ញាណេន   មម ទាសោសមំ ចរ ។

(២១៣) មា ការបិ បត្តំ សេដ្ឋ   ជហិ កាយន្តិ ភាសសា
អហំ យោគំ បយុញ្ជស្សំ   យុត្តំ ធម្មូបសញ្ហិតំ
មម បរិយាបញ្ញាណេន   ចិប្បំ ទាសា បមោក្ខសិ ។

(២១៤) សោ លុទ្ទោ ហំសកាជេន   រាជទ្វារំ ឧបាគមិ
បដិវេទេថ មំ រញ្ញោ   ធតរដ្ឋាយមាគតោ ។



ពួកពិសេសរបស់ព្រះរាជាក៏វេះខ្លួនយ៉ាងវិសេសក្រែងខ្ញុំជានេះ យ៉ាងណា (អ្នកខ្លាក់) យ៉ាងនោះចុះ ដូចសម្បុកស្វាបសម្លាប់អ្នក(ឯង) ហើយ ដូចផ្លែឫស្សីសម្លាប់នូវដើមឫស្សី ។ អ្នកក្ដៅ (ជាមួយនឹងហើយ) ហើយមិនចង់ហើរទៅ ចូលមករកចំណងដោយខ្លួនឯងវិញ ថ្ងៃនេះ អ្នកនោះដល់នូវសេចក្ដីសង្ស័យ (ក្ដីជីវិត) អ្នកចូរកាន់យកនូវប្រយោជន៍ចុះ កុំបានតែមាត់ឡើយ ។

(២១២) អ្នកនោះ ចូរប្រកបព្យាយាមដ៏សមគួរ ប្រកបដោយធម៌ ប្រព្រឹត្តនូវការស្វែងរកនូវជីវិត ឲ្យដល់យើង ដោយព្យាយាមរបស់អ្នកចុះ ។

(២១៣) (ហង្សសេនាបតី...) បពិត្រព្រះអង្គដ៏ប្រសើរជាងសត្វស្លាប ព្រះអង្គកុំខ្លាចឡើយ ដូចសត្វទាំងឡាយ ប្រហែលព្រះអង្គ រមែងមិនខ្លាច ខ្ញុំព្រះបង្គំជាខ្ញុំនឹងប្រកបនូវព្យាយាមដ៏សមគួរប្រកបដោយធម៌ ព្រះអង្គនឹងរួចចាកសង្គ្រាម យ៉ាងឆាប់ ដោយព្យាយាម របស់ខ្ញុំព្រះបង្គំជាខ្ញុំ ។

(២១៤) (គង់សម្លុតគាត់)ព្រានព្រៃនោះ បានចូលទៅកាន់ទ្វារព្រះរាជវាំងទាំងនឹងស្រែក ហង្ស ( ពោលថា ) អ្នកទាំងឡាយ ចូរក្រាបទូលព្រះរាជាថា ខ្ញុំនាំរាជហង្សឈ្មោះធតរដ្ឋៈ នេះមកហើយ ។

(៦១៥) តេ ទិស្វា បុញ្ញសង្កាសេ ឧភោ លក្ខណសម្មតេ

ខលុ សញ្ញមនោ រាជា អមច្ចេ អជ្ឈភាសថ ។

ទេថ លុទ្ទស្ស វត្ថានិ អន្នំ បានញ្ច ភោជនំ

កាមំ ករោ ហិរញ្ញស្ស យាវន្តោ ឯស ឥច្ឆតិ ។

(៦១៦) ទិស្វា លុទ្ទំ បសន្នត្តំ កាសិរាជា តទព្រវិ

យទាយំ សម្ម ខេមក បុណ្ណា ហំសេហិ តិដ្ឋតិ ។

កថំ រុចិមជ្ឈគតំ បាសហត្ថោ ឧបាគមិ

ឱកិណ្ណំ ញាតិសង្ឃេហិ និម្មជ្ឈិមំ កថំ គហិ ។

(៦១៧) អជ្ជ មេ សត្តមា រត្តិ អាទានានិ ឧបាសតោ

បទមេតស្ស អន្វេសំ អប្បមត្តាយ ឃាសតោ ។

អថស្ស បទមទ្ទក្ខឹ ចរតោ អាទនេសនំ

តត្ថាហំ ឱទហឹ បាសំ ឯវេតំ ទិជមគ្គហឹ ។



(៦១៥) ព្រះរាជា ព្រះនាមសំយមៈ ទតឃើញហង្សទាំងពីរនោះ ប្រាកដស្មើដោយបុណ្យ ដែលសន្មតថា មានលក្ខណៈល្អ ទ្រង់ត្រាស់ទៅ នឹងពួកអាមាត្យថា អ្នកទាំងឡាយ ចូរឲ្យសំពត់ បាយ ទឹក និងភោជន ដល់នាយព្រាន ចូរបំពេញសេចក្តីប្រាថ្នា ដោយប្រាក់ដែលព្រាននេះប្រាថ្នាចុះ ។

(៦១៦) ព្រះរាជាក្នុងដែនកាសី ទ្រង់ទតឃើញព្រានព្រៃមានចិត្ត រីករាយ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលខេមកៈជាសំឡាញ់ បើ ស្រះបោក្ខរណីពេញដាសដោយពួកហង្ស ។ អ្នកមានដៃកាន់ អន្ទាក់ចូលទៅរកហង្ស ដែលឋិតនៅក្នុងកណ្តាលនៃពួកហង្សដ៏ច្រើន ដោយប្រការដូចម្តេច អ្នកចាប់ហង្សដ៏ឧត្តមដែលនៅលាយ ឡំដោយពួកហង្សជាញាតិ ដោយប្រការដូចម្តេច ។

(៦១៧) (ព្រានព្រៃ...) កាលខ្ញុំព្រះបង្គំជាខ្ញុំ ចូលទៅកាន់ទីជាទី កាន់យកនូវចំណី (របស់ហង្ស) ថ្ងៃនេះ ជាគម្រប់ ៧ ខ្ញុំ ព្រះបង្គំជាខ្ញុំ ស្វែងរកនូវស្នាមជើងនៃហង្សនោះ ដែលមានសេចក្តី ប្រយ័ត្ន កាលស្វែងរកនៅក្នុងទីកាន ។ លុះខ្ញុំព្រះបង្គំជាខ្ញុំ បានឃើញស្នាមជើងនៃហង្សនោះ ត្រាច់ស្វែងរកទីជាទីកាន់ យកចំណីហើយ ទើបខ្ញុំព្រះបង្គំជាខ្ញុំបានដាក់អន្ទាក់ក្នុងទីនោះ រួចចាប់យកហង្សនោះ ដោយឧបាយយ៉ាងនេះ ។

(២០៨) លុទ្ទកេ ទ្វេ មេ សាកុណា ឯវ បតោន្ត ភាសសិ

ចិត្តំ នុ តេ វិបរិយត្តំ អាទុ កិន្នុ ជិគីសសិ ។

(២០៩) យស្ស លោហិតកា តាលា តបនេយ្យនិភា សុភា

ឧរំ សំហច្ច តិដ្ឋន្តិ សោ មេ ពន្ធំ ឧបាគមិ ។

អថាយំ ភស្សរោ បក្ខី អពទ្ធោ ពទ្ធមាតុរំ

អរិយំ ព្រូហានោ(១) អដ្ឋាសិ ចជន្តោ មានុសឹ គិរំ ។

(២១០) កច្ចន្នុ ទានិ សុមុខ ហនុំ សំហច្ច តិដ្ឋសិ

អាទុ មេ បរិសំ បត្តោ ភយា ភីតោ ន ភាសសិ ។

(២១១) នាហំ កាសិបតិ ភីតោ ឱគ្គយ្ហ បរិសំ តវ

នាហំ ភយា ន ភាសិស្សំ វាក្យំ អត្ថស្មិ តាទិសេ ។

---

១ ម. ព្រុវានោ ។



(២០៨) (ព្រះរាជា...) ម្នាលនាយព្រាន បក្សីនេះ ចុះហេតុអ្វីក៏បានជាអ្នកពោលថា បក្សីមួយ ចិត្តរបស់អ្នកប្រែប្រួលឬ មួយអ្នកប្រាថ្នា ដូចម្ដេចវិញ ។

(២០៩) (ព្រានព្រៃ...) ឆ្នូតក្រហមល្អក្ដី រុងរឿង ប៉ះទៅជាប់ នឹងទ្រូងនៃហង្សណា ហង្សនោះ បានចូលមកជាប់អន្ទាក់ របស់ខ្ញុំព្រះបង្គំជាខ្ញុំ ចំណែកបក្សីដែលភ្លឺផ្លេកនេះ មិនបានជាប់អន្ទាក់ទេ ចាំនូវនូវអរិយធម៌ បានឈរនិយាយពាក្យជារបស់មនុស្ស នឹងបក្សីដែលជាប់ចំណងក៏ត្រូវនៃក្ដៅក្រហាយ (ដោយទុក្ខ) ។

(២១០) (ព្រះរាជា...) ម្នាលសុមុខៈ ឥឡូវនេះ អ្នកឈរទល់ចង្កា (បិទមាត់) តើព្រោះហេតុអ្វី ឬក៏អ្នកមកកណ្ដាលបរិស័ទរបស់យើងហើយ មានសេចក្ដីភ័យខ្លាច ទើបមិនពោល ។

(២១១) (ហង្សសុមុខ...) បពិត្រព្រះអង្គ ជាធំក្នុងដែនកាសី ខ្ញុំព្រះបង្គំជាខ្ញុំ មិនមែនខ្លាច ព្រោះតែចូលមកកាន់បរិស័ទរបស់ព្រះអង្គទេ ខ្ញុំព្រះបង្គំជាខ្ញុំ មិនមែនជានឹងមិននិយាយ ព្រោះខ្លាចទេ កាលបើមានហេតុត្រូវការដូច្នោះហើយ ខ្ញុំព្រះបង្គំជាខ្ញុំមុខជានឹង (បញ្ចេញ) ទូលថា ។

(៦៦៦) នតេ អភិស្សរំ បស្សេ   ន រថេ នបិ បត្តិកេ
នាស្ស ចម្មំ វ កីដំ វា   វម្មិតេ ច ធនុគ្គហេ ។
ន ហិរញ្ញំ សុវណ្ណំ វា   ធនំ វា សុមាបិតំ
ទឡ្ហំ ឥណ្ណាបរិក្ខំ ទុគ្គំ   ទឡ្ហមដ្ដាលកោដ្ឋកំ
យត្ថ បវិដ្ឋា សុមុខ   ភាយិតព្វំ ន ការយេ ។

(៦៦៧) នមេ អភិស្សរេ ចក្ខុ   ចក្ខុរេ ធនេន វា
អបរេន បនំ យាម   អត្តនិទ្ធំ ធនំ មយំ ។
សុតា ច បណ្ឌិតា ត្យម្ហា   ពិទុណា ចត្តចិត្តកា
ការេមន្តោតិ ភវំ   សព្វេ ចសម្បត្តិ ខ្ញីតោ ។
ទីឃា ត្យុយំ អសប្បុស្ស   អចរិយស្ស ការិស្សតិ
មុសាវាទិស្ស លុទ្ទស្ស   គណិតំបិ សុភាសិតំ ។



(៦៦៦) (ព្រះរាជា...) យើងមិនឃើញកុមារ មិនឃើញពលរថ មិនឃើញពលថ្មើរជើង មិនឃើញខែល មិនឃើញដំរីអ្នកកាន់កាំភ្លើង មិនឃើញដំរីអ្នកចាក់កាំព្រួញ មិនឃើញអ្នកកាន់ធ្នូរបស់អ្នកទាំងឡាយ ។ ក្រុងសុមុខៈ យើងមិនឃើញប្រាក់ ឬមាស ឬខែល ដែលគេសាងល្អហើយ ជាខែលមានក្តីដ៏រឹងមាំ មិនដឹងយកទៅមកបាន ជាខែលមានបែបដ៏រឹងមាំ ... ជាកន្លែងដែលអ្នកចូលទៅហើយ មិនខ្លាចខ្មាំងហេតុដែលគេស្លៀកទូច ។

(៦៦៧) (ពាក្យសេនាបតី...) ខ្ញុំព្រះអង្គជាខ្ញុំ មិនត្រូវការដោយកាមាន ដោយខែល ឬដោយទ្រព្យទេ ពួកខ្ញុំព្រះអង្គជាខ្ញុំតែងទៅកាន់ផ្លូវតាមផ្លូវ មិនមែនជាផ្លូវដែលព្រះអង្គទៅបានទេ ខ្ញុំព្រះអង្គជាខ្ញុំប្រាថ់នាឲ្យជីកកាស ។ ព្រះអង្គបានទ្រង់ព្រួយហើយ ជា ពួកខ្ញុំព្រះអង្គជាខ្ញុំ ជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវសេចក្តីប្រាថ្នា បើព្រះអង្គប្រតិស្ឋានក្នុងសច្ចៈ ពួកខ្ញុំព្រះអង្គជាខ្ញុំនឹងពោលនូវពាក្យដែលមានប្រយោជន៍ ។ ឯពាក្យសុភាសិត ដែលព្រះអង្គមិនមានសច្ចៈជាបុគ្គលមិនប្រសើរបានពោលដល់ព្រាហ្មណ៍ ជាអ្នកលោភនិយាយកុហកដែរ មិនធ្វើឲ្យបានមួយ ។

(៦៦៦) តំ ព្រាហ្មណានំ វចោ   នមំ ខេមមការយិ
អភយញ្ច តយា ឃុដ្ឋំ   ឥមាយោ ទសធា ទិសា ។
ឱគ្គយ្ហ តេ បោក្ខរណឹ   វិប្បសន្នោទកំ សុចឹ
បហូតំ ចាទនំ តត្ថ   អហឹសា ចេត្ថ បក្ខិនំ ។
ឥទំ សុត្វាន និគ្ឃោសំ   អាគតម្ហា តវន្តិកេ
តេ តេ ពទ្ធស្មា បាសេន   ឯតន្តេ ភាសិតំ មុសា ។
មុសាវាទំ បុរក្ខត្វា   ឥច្ឆាលោភញ្ច បាបកំ
ឧភោ សន្ធឹ អតិក្កម្ម   អសាតំ ឧបបជ្ជតិ ។

(៦៦៧) នាបរជ្ឈាម សុមុខ   នបិ លោភាវ មគ្គមា
សុតា ច បណ្ឌិតាត្យត្ថ   និបុណា អត្ថចិន្តកា ។
អប្បេវត្ថវតឹ គិរំ   ព្យាហរេយ្យុំ ឥធាគតា
តថា តំ សម្មនេសាទោ   វុត្តោ សុមុខ មគ្គហា ។



(៦៦៦) ព្រះអង្គបានឲ្យគេធ្វើស្រះបោក្ខរណីឈ្មោះខេមានោះ តាមសំដីនៃពួកព្រាហ្មណ៍ ម្យ៉ាងទៀតព្រះអង្គឲ្យគេឃោសនានូវអភ័យគ្រប់ទិសទាំង ១០ នេះ ។ ដោយហេតុឲ្យសត្វបក្សីចុះកាន់ស្រះបោក្ខរណីដែលមានទឹកថ្លាស្អាតបុះ ផ្សិតខាងក្នុងសម្រាប់ទំពាស៊ីក្នុងស្រះនោះជាច្រើន ទាំងមិនមានការបៀតបៀនដល់ពួកសត្វបក្សីក្នុងស្រះនោះទេ ។ ពួកខ្ញុំព្រះបង្គំជាខ្ញុំបានឮនូវអភ័យនេះ ដែលព្រះអង្គឲ្យឃោសនាហើយ បានជាមកក្នុងសំណាក់នៃព្រះអង្គ ខ្ញុំព្រះបង្គំជាខ្ញុំទាំងនោះ ជាប់ដោយអន្ទាក់របស់ព្រះអង្គ នេះហើយជាសំដីកុហករបស់ព្រះអង្គ ។ បុគ្គលធ្វើនូវមុសាវាទទុកនូវសេចក្តីលោភនិងសេចក្តីប្រាថ្នាដ៏លាមកជាទី ឲ្យជាប្រធាន រមែងកន្លងនូវបដិសន្ធិក្នុងលោកទាំងពីរ ហើយចូលទៅកាន់ទីមិនមានសេចក្តីត្រេកអរ (នរក) ។

(៦៦៧) (ព្រះរាជា...) ម្នាលសុមុខៈ យើងមិនមែនប្រទូស្តអ្នកទេ យើងមិនមែនចាប់អ្នក ព្រោះសេចក្តីលោភទេ យើងបានឮថា អ្នកទាំងឡាយ ជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវការថកំប៉ាំង ។ ធ្វើម្ដេចហ្ន៎ ហង្សទាំងឡាយបានមកក្នុងទីនេះ ពោលនូវវាចាមានប្រយោជន៍ ម្នាលសុមុខៈជាសំឡាញ់ ព្រោះហេតុនោះ បានជាយើងប្រាប់នាយនេសាទនេះ ឲ្យចាប់ (អ្នក) ។

(១)

(២២៦) នេវ វុឌ្ឍា កាសិបតិ ឧបនីតស្មិំ ជីវិតេ
កាសេមន្តេតិ កិច្ចំ សម្បត្តា កាលបរិយាយំ ។
យោ មិគេន មិគំ ហន្តិ បក្ខឹ វា បន បក្ខិនា
សុតេន វា សុតំ កិណ្យា កឹ អនរិយតរំ តតោ ។
យោ ចារិយរុទំ កាមេ អនរិយធម្មវស្សិតោ
ឧភោ សោ ធំសតេ លោកា ឥធ ចេវ បរត្ថ ច ។
ន មជ្ជេយ យសំ បត្តោ ន ព្យាធេ បត្តសំសយំ
វាយមេថេវ កិច្ចេសុ សំវរេ វិវរេ ច ។
យេ វុឌ្ឍា អព្ភតិក្កន្តា សម្បត្តា កាលបរិយាយំ
ឥធ ធម្មំ ចរិត្វាន យន្តិ តេ តិទិវង្គតា ។

១ ម. កិរ ។



(២២៦) (ហង្សរាជាថា...) បពិត្រព្រះអង្គជាធំ ក្នុងដែនកាសី យើងទាំងឡាយ ជាចាស់ កាលបើមិនចូលទៅកាន់ (សេចក្ដីស្លាប់) ហើយដល់នូវកាលកំណត់ដែលត្រូវស្លាប់ហើយ ពោលនូវពាក្យដែលមានប្រយោជន៍មិនបានទេ ។ បុគ្គលណា សម្លាប់ម្រឹគដោយម្រឹគ ឬបក្សីដោយបក្សី ម្យ៉ាងទៀត បៀតបៀននូវបុគ្គលដែលមានឈ្មោះល្បី ដោយរបស់ដែលមានឈ្មោះល្បី អំពើអ្វីដែលអាក្រក់ជាងអំពើ របស់បុគ្គលនោះទៅទៀត ។ បុគ្គលណា និយាយសរសើរធម៌ប្រសើរ ប៉ុន្តែជាបុគ្គលមិនប្រព្រឹត្តធម៌ប្រសើរ បុគ្គលនោះ រមែងឃ្លាតចាកលោកទាំងពីរ គឺលោកនេះនឹងលោកខាងមុខ ។ បុគ្គលដែលបាននូវយស មិនគួរស្រវឹង ដល់នូវការសង្ស័យ ក្នុងជីវិត មិនគួរទុក្ខលំបាកឡើយ គួរព្យាយាមក្នុងកិច្ចទាំងឡាយផង គួរបិទនូវប្រហោងគឺ (ទោស) ទាំងឡាយផង ។ ពួកបុគ្គលណា ចាស់ដោយគុណ ដល់កាលកំណត់ដែលត្រូវស្លាប់ បានឃើញធម៌ ទាំងបានប្រព្រឹត្តធម៌ក្នុងលោកនេះ ពួកបុគ្គលនោះ រមែងទៅកើតក្នុងត្រៃត្រឹង្សយ៉ាងនេះ ។

ឥទំ សុត្វា កាសិបតិ ជម្ពុមត្តំ ចាលយ
ជនរដ្ឋញ្ច មុញ្ចាហិ ហំសរាជំ បវុត្តមំ ។

(៦២៧) អាហារត្ថូបគាំ បដ្ឋំ អាសនញ្ច មហារហំ
បញ្ជរតោ បមោក្ខាមិ ជនរដ្ឋំ យសស្សិនំ ។
តញ្ច សេនាបតិំ ធីរំ និបុណំ អត្ថចិន្តកំ
យោ សុខេ សុខិតោ រញ្ញោ ទុក្ខិតេ ហោតិ ទុក្ខិតោ ។
ឯទិសោ ខោ អរហតិ បិណ្ឌមស្នាតុ ភត្តុនោ
យថាយំ សុមុខោ រញ្ញោ ហំសាធិបតិនោ សខា ។

(៦២៨) បីឋញ្ច សព្វសោវណ្ណំ អដ្ឋបាទំ មនោរមំ
មដ្ឋំ កាសិកបច្ឆន្នំ[១] ធតរដ្ឋោ ឧបាវិសិ ។

១ ម. កាសិកមត្ថតំ ។



បពិត្រព្រះអង្គជាធំក្នុងដែនកាសី ព្រះអង្គទ្រង់ព្រះសណ្ដាប់នូវពាក្យនេះហើយ សូមក្រុងខ្ញុំទទួលព្រះអង្គនុះ ម្យ៉ាងទៀត សូមព្រះអង្គទ្រង់ដោះលែងនូវពួកហង្សឈ្មោះធតរដ្ឋៈ ដ៏ប្រសើរលើសជាងពួកហង្ស ។

(៦២៧) (ព្រះរាជា...) ពួកអ្នកបំរើ នាំមកនូវទឹក (សម្រាប់លាងជើង) ផង នូវប្រេងសម្រាប់លាបជើងផង នូវអាសនៈដែលមានថ្លៃច្រើនផង ដើម្បីទំនុកបំរុងនូវហង្សឈ្មោះធតរដ្ឋៈដ៏មានយស ចេញអំពីទ្រុង ។ ម្យ៉ាងទៀត ហង្សណា កាលបើព្រះរាជា មានសេចក្ដីសុខ ខ្លួនក៏មានសេចក្ដីសុខដែរ ព្រះរាជាមានសេចក្ដីទុក្ខ ខ្លួនក៏មានសេចក្ដីទុក្ខដែរ ដើម្បីនឹងលែងនូវហង្សនោះ ជាសេនាបតី ជាអ្នកប្រាជ្ញ មានប្រាជ្ញាល្អិត អ្នកគិតនូវប្រយោជន៍ ។ បុគ្គលបែបនេះ ទើបគួរបរិភោគដុំបាយរបស់ម្ចាស់បាន ដូចជាហង្សសេនាបតីឈ្មោះសុមុខៈនេះជាសំឡាញ់របស់ស្ដេចហង្ស ។

(៦២៨) (អភិសម្ពុទ្ធគាថា) ឯហង្សឈ្មោះធតរដ្ឋៈ បានគង់លើតាំង ជាវិការៈនៃមាសសុទ្ធ មានជើង៨ ជាទីត្រេកអរនៃចិត្ត ជាតាំងដ៏រលីង ក្រាលដោយសំពត់កើតក្នុងដែនកាសី ។

កោច្ឆញ្ច សព្វសោវណ្ណំ វេយ្យគ្ឃបរិសិព្វិតំ
សុមុខោ អជ្ឈភាសេត្វា ឧតរដ្ឋស្សុឧត្តក ។
តេសំ កញ្ចនបត្តេហិ បុដ្ឋា អាទាយ កាសិយោ
ហំសានំ អភិហារេសុំ អគ្គរញ្ញោ បរន្តប ។
(៦២៩) ទិស្វា អភិហដំ អគ្គំ កាសិរាជេន បេសិតំ
កុសលោ ខត្តធម្មានំ តតោ បុច្ឆិ អនន្តរា
កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ
កច្ចិ រដ្ឋមិទំ ផីតំ ធម្មេន មនុសាសសិ ។
(៦៣០) កុសលញ្ចេវ មេ ហំស អថោ ហំស អនាមយំ
អថោ រដ្ឋមិទំ ផីតំ ធម្មេន មនុសាសហំ ។
(៦៣១) កច្ចិ ភោតោ អមច្ចេសុ ទោសោ កោចិ ន វិជ្ជតិ
កច្ចិ ច តេ តវត្ថេសុ នាវកង្ខន្តិ ជីវិតំ ។



ចំណែកហង្សសេនាបតី ឈ្មោះសុមុខៈ បានឲ្យចូលទៅទំលើកៅអី ជាវិការៈនៃមាសសុទ្ធ ដែលពាសដោយស្បែកខ្លាក្នុងទីជាលំដាប់ នៃពួកហង្សឈ្មោះធតរដ្ឋៈ ។ ពួកអ្នកដែនកាសីជាច្រើន បាននាំយកនូវភោជនាហារសព្វប្រសើរ ដែលគេបញ្ជូនទៅថ្វាយព្រះរាជា ដោយភាជនជាវិការៈនៃមាសទាំងឡាយ ហើយក៏បញ្ជូនទៅដល់ហង្សទាំងនោះ ។

(៦២៩) កាលហង្សឈ្លាសវៃ ក្នុងខត្តិយធម៌ លុះបានឃើញចំណីភោជនដ៏ប្រសើរ ដែលគេនាំមក ដែលព្រះរាជាក្នុងដែនកាសីទ្រង់បញ្ជូនមកហើយ ក្នុងកាលជាលំដាប់នោះជា ព្រះអង្គទ្រង់បានសេចក្ដីសុខស្រួលដែរឬ ព្រះអង្គមិនមានជម្ងឺថ្កាត់ទេឬ ព្រះអង្គគ្រប់គ្រងដែនដ៏ធំទូលាយនេះ ដោយធម៌ដែរឬ ។

(៦៣០) (ព្រះរាជា...) ម្នាលហង្ស យើងមានសេចក្ដីសុខស្រួលដែរ ម្នាលហង្ស យើងមិនមានជម្ងឺថ្កាត់ទេ យើងគ្រប់គ្រងដែនដ៏ធំទូលាយនេះត្រឹមត្រូវ ដោយធម៌ហើយ ។

(៦៣១) (ហង្ស...) ទោសណាមួយ របស់ព្រះអង្គមិនមានក្នុងពួកអាមាត្យទេឬ អាមាត្យទាំងនោះ មិនអាល័យក្នុងជីវិតចំពោះប្រយោជន៍ទាំងឡាយ របស់ព្រះអង្គទេឬ ។

(២៣២) អថោបិ មេ អមច្ចេសុ  ទោសោ កោចិ ន វិជ្ជតិ
អថោបិ តេ មមត្ថេសុ  នាវកង្ខន្តិ ជីវិតំ ។

(២៣៣) កច្ចិ តេ សាទិសី ភរិយា  អស្សវា បិយភាណិនី
បុត្តរូបយសូបេតា  តវ ឆន្ទវសានុគា ។

(២៣៤) អថោ មេ សាទិសី ភរិយា  អស្សវា បិយភាណិនី
បុត្តរូបយសូបេតា  មម ឆន្ទវសានុគា ។

(២៣៥) កច្ចិ រដ្ឋំ អនុប្បីឡំ  អកុតោចិ ឧបទ្ទវំ
អសាហសេន ធម្មេន  សមេន អនុសាសសិ ។

(២៣៦) អថោ រដ្ឋំ អនុប្បីឡំ  អកុតោចិ ឧបទ្ទវំ
អសាហសេន ធម្មេន  សមេន អនុសាសហំ ។

(២៣៧) កច្ចិ សន្តោ អបចិតា  អសន្តោ បរិវជ្ជិតា
នោ ច ធម្មំ និរំកត្វា  អធម្មមនុវត្តសិ ។



(២៣២) (ព្រះរាជា...) ទោសណាមួយ របស់យើងមិនមានក្នុងពួកអាមាត្យទេ ពួកអាមាត្យទាំងនោះ មិនអាល័យក្នុងជីវិតចំពោះប្រយោជន៍ទាំងឡាយ របស់យើងទេ ។

(២៣៣) (ហង្សរាជ...) អគ្គមហេសីដែលមានជាតិស្មើនឹងព្រះអង្គ ជាស្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត រូបនិងយស ជាស្រីលុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គទេឬ ។

(២៣៤) (ព្រះរាជា...) អគ្គមហេសីដែលមានជាតិស្មើនឹងយើង ជាស្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ បានប្រកបដោយបុត្ត រូបនិងយស ជាស្រីលុះអំណាចសេចក្តីប្រាថ្នារបស់យើង ។

(២៣៥) (ហង្សរាជ...) ព្រះអង្គមិនបៀតបៀនអ្នកដែន ដែលមិនមានឧបទ្រពអំពីទីណា គ្រប់គ្រងដោយការ មិនប្រកាន់តាមធម៌ដ៏ស្មើទេឬ ។

(២៣៦) (ព្រះរាជា..) យើងមិនបានបៀតបៀនអ្នកដែនដែលមិនមានឧបទ្រពអំពីទីណា គ្រប់គ្រងដោយការមិនប្រកាន់តាមធម៌ដ៏ស្មើ ។

(២៣៧) (ហង្សរាជ...) ព្រះអង្គប្រទិតបានគោរពពួកសប្បុរសវៀរបង់ពួកអសប្បុរស មិនលះបង់នូវធម៌ ហើយប្រព្រឹត្តនូវអធម៌ទេឬ ។

(៦៣៨) សន្តោ ច មេ អបចិតា   អសន្តោ បរិវជ្ជិតា
ធម្មមេវានុវត្តាមិ   អធម្មោ មេ វិវជ្ជិតោ ។

(៦៣៩) តាទិ អនាគតំ (១) ភយំ   សមវេក្ខិសំ ខត្តិយ
តាទិ មត្តា មនធីយេ   បរលោកា ន សន្តសិំ ។

(៦៤០) អហំ អនាគតំ ភយំ   សមវេក្ខាមិ ខត្តិយ
ឋិតោ ទសសុ ធម្មេសុ   បរលោកា ន សន្តសេ ។ (២)
ទានំ សីលំ បរិច្ចាគំ   អជ្ជវំ មទ្ទវំ តបំ
អក្កោធំ អវិហឹសញ្ច   ខន្តិញ្ច អវិរោធនំ ។
ឥច្ចេតេ កុសលេ ធម្មេ   ឋិតេ បស្សាមិ អត្តនិ
តតោ មេ ជាយតេ បីតិ   សោមនស្សញ្ចនប្បកំ ។
សុមុខោ ច អចិន្តេត្វា   វិសជ្ជិ ផរុសំ គិរំ
ភាវទោសមនញ្ញាយ   អស្មាកាយំ វិហង្គមោ ។

---

១ ម. កទ្ធិ តាគតំ ។ ២ ម. ឥ. សព្វេ ។



(៦៣៨) (ក្រាបទូល...) យើងខ្ញុំបានគោរពនូវពួកសប្បុរស វៀរចេញ នូវពួកអសប្បុរស យើងខ្ញុំលះបង់នូវអធម៌ ហើយប្រព្រឹត្តតាម ធម៌នៃយើងខ្ញុំ ។

(៦៣៩) (បពិត្រក្ស...) បពិត្រក្សត្រ ព្រោះតែខ្ញុំព្រះអង្គឃើញ នូវភ័យជាអនាគតដ៏វែងឆ្ងាយ ព្រោះតែខ្ញុំស្រឡាញ់ ក្នុងអារម្មណ៍ ជាទីតាំងនៃសេចក្តីស្រឡាញ់ហើយ មិនតក់ស្លុតនឹងបរលោកទេ ។

(៦៤០) (ក្រាបទូល...) ម្នាលបក្សី យើងនឹងប្រមើលមើលនូវភ័យអនាគតដ៏វែង យើងឋិតនៅ ក្នុងធម៌ ១០ ប្រការ មិនតក់ស្លុតនឹងបរលោកឡើយ ។ (ធម៌ ១០ ប្រការគឺ) ទាន ១ សីល ១ បរិច្ចាគៈ ១ ការនៃចិត្តត្រង់ ១ ការនៃចិត្តទន់ ១ តបៈគឺកំដៅបាបធម៌-សីល ១ ការមិនក្រោធ ១ ការមិនបៀតបៀន ១ ខន្តិ ១ កិរិយាមិនទាស់ ១ ។ យើងឃើញនូវកុសលធម៌ទាំងនេះ ឋិតនៅក្នុងខ្លួន លំដាប់នោះ បីតិនឹងសោមនស្សដ៏ក្រៃលែង កើតឡើងដល់យើង ដោយប្រការដូច្នេះ ។ ឯបក្សី ឈ្មោះសុមុខៈ មិនបានគិត ហើយបញ្ចេញ នូវពាក្យគ្រោតគ្រាត ព្រោះតែមិនបានដឹងច្បាស់ នូវការប្រទូស្ត ក្នុងចិត្ត របស់យើង ។ បក្សីនោះ

សោ ទុក្ខោ ផុស្សំ ភវំ ឧជ្ឈាវេសិ អយោនិសោ
យានស្មាសុ ន វិជ្ជតិ ឆយិតំ បញ្ញវតាមិវ ។

(៦៦១) អត្ថិ មេ តំ អតិសារំ វេគេន មនុជាធិប
ធតរដ្ឋេ ច ពទ្ធស្មឹ ទុក្ខំ មេ វិបុលំ អហុ ។

ត្វំ នោ បិតាវ បុត្តានំ ភូតានំ ធរណីរិវ
អស្មាកំ អធិបន្នានំ ត្វមស្សុ រាជកុញ្ជរ ។

(៦៦២) ឯវន្តេ អនុមោទាម យំ ការំ ច ឥច្ឆសិ
ទិលំ បរិច្ចសិ បក្ខិ ឧជ្ជុំ កោសិ វិហង្គម ។

(៦៦៣) យត្ថិញ្ចិ រតនំ អត្ថិ កាសិរាជនិវេសនេ
រជតំ ជាតរូបញ្ច មុត្តា វេឡុរិយា ពហូ ។



ល្មះទទឹរហើយ គឺបក្សីញនូវចំណាប់វេទនា ដោយអំណាចទឹក (ពោល) នូវពាក្យនាំទៀតឲ្យណែលមិនមានគុណប្រយោជន៍ ពាក្យនេះមិនមែនដូចពាក្យនៃបុគ្គលមានប្រាជ្ញ (ពោលហើយ) ទេ ។

(៦៦១) (ពាក្យប្រាសាទតី...) បពិត្រព្រះអង្គជាធំជាងពួកមនុស្ស ទូលព្រះបង្គំជាខ្ញុំ មានសេចក្ដីក្ដៅក្រហាយ ព្រោះពាក្យដោយរួសរាន់ពេក ដូចកាលដែលរាជហង្សឈ្មោះធតរដ្ឋៈ ជាប់អន្ទាក់ ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីទុក្ខដ៏ធំ ។ បពិត្រព្រះអង្គជាកន្ទក្ខរ ព្រះអង្គ (ជាទីពឹង) នៃពួកទូលព្រះបង្គំជាខ្ញុំ ដូចជាបិតា (ជាទីពឹង) នៃកូន ឬដូចធរណី (ជាទីពឹង) នៃពួកសត្វ សូមព្រះអង្គអត់ទោស ដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ដែលត្រូវសេចក្ដីទុក្ខគ្របសង្កត់ ។

(៦៦២) (ព្រះរាជា...) យើងត្រេកអរចំពោះអ្នកយ៉ាងនេះ ព្រោះថាអ្នកមិនលាក់នូវភាពនៃចិត្តដ៏កំបាំងរបស់ខ្លួន ម្នាលបក្សី អ្នកបានទំលាយនូវចិត្តដ៏រឹងរូស ម្នាលបក្សី អ្នកជាសត្វមានចិត្តត្រង់ ។

(៦៦៣) វត្ថុណាមួយ គឺប្រាក់ មាស កែវមុក្តា កែវពៃទូរ្យ ជាច្រើន មាននៅ ក្នុងព្រះរាជនិវេសន៍ ក្នុងដែនកាសី ។

មណយោ សង្ខមុត្តា ច វត្ថកំ ហរិចន្ទនំ

អជិនំ ទន្តភណ្ឌញ្ច លោហំ កាឡាយសំ ពហុំ

ឯតំ ទទាមិ តេ វិត្តំ សព្វំ វិស្សជាមិ តេ ។

(៦៤៤) អទ្ធា អបចិតា ត្យម្ហា សក្កតា ច រថេសភ

ធម្មេសុ វត្តមានានំ ត្វំ នោ អាចរិយោ ភវ ។

អាចរិយ សមនុញ្ញាតា តយា អនុមតា មយំ

តំ បទក្ខិណតោ កត្វា ញាតី បស្សេមុរិន្ទម ។

(៦៤៥) សព្វរត្តិំ ចិន្តយិត្វា មន្តយិត្វា យថាតថំ

កាសិរាជា អនុញ្ញាសិ ហំសានំ បវរុត្តមំ ។

(៦៤៦) តតោ រត្យា វិវសានេ សុរិយុគ្គមនំ បតិ

បេក្ខតោ កាសិរាជស្ស ភវនា តេ វិគាហិសុំ ។



មួយទៀត កែវមណី ស័ង្ខ(ជាទក្ខិណាវដ្ដ)កែវមុក្តា(មានសណ្ឋាន មូលដូចផ្លែកន្ទួតព្រៃ) សំពត់ខ្លឹមចន្ទន៍ក្រហម ស្បែកខ្លាឃ្មុំ ភណ្ឌៈជាវិការៈនៃភ្លុក លោហៈក្រហម និងលោហៈខ្មៅដ៏ច្រើន យើងឲ្យទ្រព្យទាំងនេះដល់អ្នក យើងនឹងលះបង់នូវគ្រឿងទាំងអស់ដល់អ្នក ។

(៦៤៤) (អទ្ធា...) បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ព្រះអង្គបានគោរព ធ្វើសក្ការៈ (ដល់យើងទាំងឡាយ) ដោយពិត សូមព្រះអង្គជាអាចារ្យរបស់យើង ដែលជាអ្នកប្រព្រឹត្ត ក្នុងធម៌ទាំងឡាយ ។ បពិត្រព្រះអង្គជាអាចារ្យ ព្រះអង្គបានអនុញ្ញាត បើកយើងទាំងឡាយឲ្យទៅដោយស្រួលហើយ បពិត្រព្រះអង្គជាអ្នកទូន្មាននូវសត្រូវ យើងទាំងឡាយ សូមធ្វើប្រទក្សិណនូវព្រះអង្គ ហើយទៅជួបនឹងពួកញាតិ ។

(៦៤៥) (សព្វរត្តិំ) ព្រះរាជាក្នុងដែនកាសី ទ្រង់បានគិត បានប្រឹក្សា នូវហេតុដ៏គួរតាមពិត ពេញមួយរាត្រី ហើយទ្រង់អនុញ្ញាតឲ្យរាជហង្សដ៏ប្រសើរខ្ពង់ខ្ពស់ជាងពួកហង្ស ហើរទៅ ។

(៦៤៦) លំដាប់នោះ កាលដែលរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង កាលព្រះរាជា ក្នុងដែនកាសី ទ្រង់កំពុងទតមើល សត្វហង្សទាំងពីរ ក៏ហើរចេញទៅ អំពីវិមានរបស់ព្រះរាជា ។

[៦៦៧] តេ អរោគេ អនុប្បត្តេ ទិស្វាន បតិមាគតេ
កេកាតិ មករុំ ហំសា បុថុសទ្ទោ អជាយថ ។
តេ បតីតា បមុទិតា ភត្តារំ បរិវារយុំ
សមន្តា បរិកិរិំសុ អណ្ឌជា លទ្ធបច្ចយា ។
[៦៦៨] ឯវំ មិត្តវតំ អត្ថា សព្វេ ហោន្តិ បទក្ខិណា
ហំសា យថា ធតរដ្ឋា ញាតិសង្ឃមុបាគមុំ ។

មហាហំសជាតកំ ទុតិយំ ។

## សុធាភោជនជាតកំ

[៦៦៩] នេវ កិណាមិ ន វិក្កិណាមិ
ន ចាបិ មេ សន្និចយោ ច អត្ថិ(១)
សុកិច្ឆរូបំ វតិទំ បរិត្តំ
បត្ថោទនោ នាលមយំ ទុវិន្នំ ។
[៦៧០] អប្បម្ហា អប្បកំ ទជ្ជា អនុមជ្ឈតោ មជ្ឈកំ
ពហុម្ហា ពហុកំ ទជ្ជា អទានំ នុបបជ្ជតិ ។

១ ឱ.ម. ច អត្ថិ ។



[៦៦៧] ហង្សទាំងឡាយ លុះបានឃើញហង្សធតរដ្ឋដ៏ប្រសើរ ទាំងពីរនោះ មិនមានរោគ មកដល់ហើយ ក៏ស្រែកសូរសម្លេងថាកេកា ។ ដូច្នេះ សូរសព្ទកងរំពងក៏កើតឡើង ។ ហង្សទាំងឡាយជាអណ្ឌជាតិ ទាំងនោះ មានចិត្តរីករាយ ត្រេកអរហើយ ជាសត្វគោរពម្ចាស់ ជាសត្វបានខ្លួនទីពឹង ក៏ហែហមម្ចាស់ដោយជុំវិញ ។
[៦៦៨] ប្រយោជន៍គ្រប់យ៉ាង របស់ពួកជនអ្នកមានមិត្រល្អ រមែងជាប្រយោជន៍ត្រូវចំពោះ ដូចហង្សឈ្មោះធតរដ្ឋៈនឹងហង្សឈ្មោះសុមុខៈ បានចូលទៅជួបនឹងពួកញាតិ ។

ចប់ មហាហង្សជាតក ទី ២ ។

## សុធាភោជនជាតក

[៦៦៩] (កោសិយសេដ្ឋី ពោលថា) ខ្ញុំមិនមែនទិញ មិនមែនលក់ទេ មួយទៀត ការសន្សំរបស់ខ្ញុំ ក៏មិនមានក្នុងទីនេះដែរ របស់នេះ មានប្រមាណតិច មានសេចក្ដីក្រណាស់ បាយចំនួនអង្ករមួយនាឡិនេះ មិនល្មមដល់ជនពីរនាក់ទេ ។
[៦៧០] (សក្កទេវរាជ ពោលថា) បុគ្គលគប្បីឲ្យវត្ថុតិច អំពីវត្ថុតិច គួរឲ្យវត្ថុពាក់កណ្ដាល អំពីវត្ថុពាក់កណ្ដាល គួរឲ្យវត្ថុច្រើន អំពីវត្ថុច្រើន ការមិនឲ្យ មិនគួរទេ ។

តំ តំ វទាមិ កោសិយ   ទេហិ ទានានិ ភុញ្ជ ច
អរិយមគ្គំ សមារុហ   នេកាសី លភតេ សុខំ ។

(៤៨៣) មោឃញ្ចស្ស ហុតំ ហោតិ   មោឃញ្ចាបិ សមីហិតំ
អតិថិស្មឹ យោ និសិន្នស្មឹ   ឯកោ ភុញ្ជតិ ភោជនំ ។
តំ តំ វទាមិ កោសិយ   ទេហិ ទានានិ ភុញ្ជ ច
អរិយមគ្គំ សមារុហ   នេកាសី លភតេ សុខំ ។

(៤៨៦) សច្ចញ្ចស្ស ហុតំ ហោតិ   សច្ចញ្ចាបិ សមីហិតំ
អតិថិស្មឹ យោ និសិន្នស្មឹ   នេកោ ភុញ្ជតិ ភោជនំ ។
តំ តំ វទាមិ កោសិយ   ទេហិ ទានានិ ភុញ្ជ ច
អរិយមគ្គំ សមារុហ   នេកាសី លភតេ សុខំ ។



ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យនូវទានផង ចូរបរិភោគផង អ្នកចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

(៤៨១) (ចន្ទទៅបុគ្គ...) បុគ្គលណា កាលបើភ្ញៀវអង្គុយហើយ បរិភោគនូវភោជនម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការឥតផលទេ ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យ (របស់បុគ្គលនោះ) ក៏ឥតផលដែរ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

(៤៨៦) (ស្រីយទៅបុគ្គ...) បុគ្គលណា កាលបើភ្ញៀវអង្គុយហើយ មិនបរិភោគនូវភោជនម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការពិតប្រាកដមែន ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យ(របស់បុគ្គលនោះ)ក៏ជាការព្យាយាមពិតមែន ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

(២៨៣)សច្ចញ្ជុហតិ ពោសោ ពហុកាយ គយាយ ច

ទោណេ តិម្ពរុតិត្ថស្មឹ សីឃសោតេ មហាវហេ

អត្រ ចស្ស ហុតំ ហោតិ អត្រ ចស្ស សមិជ្ឈតិ

អតិថិស្មឹ យោ និសិន្នស្មឹ ឯកោ ភុញ្ជតិ ភោជនំ ។

តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច

អរិយមគ្គំ សមារូហ នេកាសី លភតេ សុខំ ។

(២៨៤)ពលិសំ ហិ សោ និគិលតិ ទីឃសុត្តំ សពន្ធនំ

អតិថិស្មឹ យោ និសិន្នស្មឹ ឯកោ ភុញ្ជតិ ភោជនំ ។

តំ តំ វទាមិ កោសិយ ទេហិ ទានានិ ភុញ្ជ ច

អរិយមគ្គំ សមារូហ នេកាសី លភតេ សុខំ ។



(២៨៣) (ម្ចាស់ទៅបុគ្គល...) បុរសបូជាស្រះក្ដី បូជាទន្លេឈ្មោះពហុកា ឬស្រះបោក្ខរណីឈ្មោះគយាក្ដី កំពង់ឈ្មោះទោណៈ ឬកំពង់ឈ្មោះតិម្ពរុក្ខ ទន្លេដ៏មានខ្សែទឹកដ៏លឿនក្ដី ។ ការបូជារបស់បុរសនោះក្នុងទីនោះ រមែងមាន (ផល) ពិធីការក្រោយមក ហេតុឲ្យកើតច្រើនរបស់បុរសនោះ ក្នុងទីនោះ ក៏មានផលដែរ ព្រោះថា បុរសនោះ កាលបើភ្ញៀវអង្គុយនៅហើយ មិនគួរបរិភោគភោជនម្នាក់ឯងទេ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង បរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគភោជនម្នាក់ឯង មិនបានសេចក្ដីសុខទេ ។

(២៨៤)(បញ្ញសិក្ខទៅបុគ្គល...)បុគ្គលណា កាលបើភ្ញៀវអង្គុយនៅហើយ បរិភោគភោជនម្នាក់ឯង បុគ្គលនោះឈ្មោះថាលេបសន្ទូចដែលមានខ្សែវែងព្រមទាំងចំណង ។ ម្នាលកោសិយៈព្រោះហេតុនោះ យើងនិយាយនឹងអ្នកចូរអ្នកឲ្យទានផងចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសុខទេ ។

(២៤៥) ឧឡារវណ្ណា វត ព្រាហ្មណា ឥមេ
អយញ្ច វោ សុនខោ កិស្ស ហេតុ
ឧច្ចាវចំ វណ្ណនិភំ វិកុព្វតិ
អក្ខាថ នោ ព្រាហ្មណា កេ នុ តុម្ហេ ។

(២៤៦) ចន្ទោ ច សុរិយោ ច ឧភោ ឥធាគតា
អយំ បន មាតលិ ទេវសារថិ
សក្កោហមស្មិ តិទសានមិន្ទោ
ឯសោ ច ខោ បញ្ចសិខោតិ វុច្ចតិ ។

(២៤៧) បាណិស្សរា មុទិង្គា ច មុរជាលម្ពរានិ ច
សុត្តមេនំ បពោធេន្តិ បដិពុទ្ធោ ច នន្ទតិ ។

(២៤៨) យេ កេចិមេ មច្ឆរិនោ កទរិយា
បរិភាសកា សមណព្រាហ្មណានំ
ឥធេវ និក្ខិប្ប សរីរទេហំ
កាយស្ស ភេទា និរយំ វជន្តិ ។
យេ កេចិមេ សុគតិមាសីសមានា
ធម្មេ ឋិតា សំយមេ សំវិភាគេ
ឥធេវ និក្ខិប្ប សរីរទេហំ
កាយស្ស ភេទា សុគតិំ វជន្តិ ។



(២៤៥) (កោសិយសេដ្ឋី...) ម្នាលព្រាហ្មណ៍ទាំងនេះ ពេញជាមានសម្បុរល្អលើសលុប ចុះឆ្កែនេះ របស់ពួកអ្នក ធ្វើខ្លួនឲ្យមានពណ៌ខ្ពស់ទាបផ្សេងៗ ព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយចូរប្រាប់យើង អ្នកទាំងឡាយជាអ្វី

(២៤៦) (ព្រះឥន្ទ្រ...) ព្រាហ្មណ៍ទាំងពីរនាក់ដែលមកក្នុងទីនេះ គឺចន្ទទេវបុត្ត និងសុរិយទេវបុត្ត ចំណែកព្រាហ្មណ៍នេះ គឺមាតលិទេវបុត្ត ដែលជាទេវសារថី និងយើងជាសក្កៈ ជាធំជាងពួកទេវតាក្នុងឋានតាវត្តិង្ស ឯព្រាហ្មណ៍នេះគេហៅថាបញ្ចសិខៈ ។

(២៤៧) សូរទះដៃក្តី ស្គរសំភោរក្តី ស្គរតូចនិងស្គរធំក្តី តែងញ៉ាំងបញ្ចសិខទេវបុត្តនេះ ដែលដេកលក់ឲ្យភ្ញាក់ឡើងបាន លុះបញ្ចសិខទេវបុត្តនោះ ភ្ញាក់ឡើងហើយ រមែងត្រេកអរ ។

(២៤៨) ពួកជនណានីមួយ មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកប្រទេចផ្តាសាចំពោះសមណព្រាហ្មណ៍ ពួកជននោះ ដាក់ចុះនូវរាងកាយគឺសរីរៈក្នុងលោកនេះ លុះបែកធ្លាយនៃកាយហើយ រមែងទៅកើតក្នុងនរក ។ ពួកជនណានីមួយ កាលប្រាថ្នានូវសុគតិ ឋិតនៅក្នុងធម៌ គឺការសង្រួមនិងការចែករំលែកឲ្យទាន ពួកជននោះ ដាក់ចុះនូវរាងកាយគឺសរីរៈក្នុងលោកនេះ លុះបែកធ្លាយនៃរាងកាយ រមែងទៅកាន់សុគតិ ។

(២៥៩) ត្វំ នោ ញាតិ បុរមាសុ ជាតិសុ
សោ មច្ឆរី កោសិយោ បាបធម្មោ
តវេវ អត្ថាយ ឥធាគតម្ហា
មា បាបធម្មោ និរយំ អបត្ថ ។

(២៦០) អទ្ធា ហិ មេ តេ ហិតកាមា យំ មំ សមនុសាសថ
សោហំ តថា ករិស្សាមិ សព្វំ វុត្តំ ហិតេសិភិ
ឯសាហមជ្ជេវ ឧបារមាមិ
ន ចាបិហំ កិញ្ចិ ករេយ្យ បាបំ
ន ចាបិ មេ កិញ្ចិ អទេយ្យមត្ថិ
ន ចាបិទត្វា ឧទកំ បិវាមិ ។
ឯវញ្ច មេ ទទតោ សព្វកាលំ
ភោគាបិ មេ វាសវ ខីយិស្សន្តិ
តតោ អហំ បព្វជិស្សាមិ សក្ក
ហិត្វាន កាមានិ យថោធិកានិ ។

(២៦១) នគុត្តមេ គិរិវរេ គន្ធមាទនេ
មោទន្តិ តា ទេវវរាភិបាលិតា



(២៥៩) អ្នកជាញាតិរបស់យើងក្នុងជាតិមុន អ្នកនោះឈ្មោះកោសិយៈ ជាបុគ្គលកំណាញ់ មានធម៌ដ៏លាមក យើងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់អ្នកតែម្យ៉ាងគឺថា ញាតិរបស់យើងដែលមានធម៌ដ៏លាមក កុំទៅកាន់នរកឡើយ ។

(២៦០) (កោសិយសេដ្ឋី...) អ្នកទាំងឡាយនោះ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំដោយពិត ព្រោះថា អ្នកទាំងឡាយបានប្រៀនប្រដៅខ្ញុំដោយល្អ ខ្ញុំនោះនឹងធ្វើតាមពាក្យទាំងអស់ ដែលអ្នកទាំងឡាយជាអ្នកស្វែងរកប្រយោជន៍ បានពោលហើយដូច្នោះ ។ ខ្ញុំនោះវៀរចាកសេចក្តីកំណាញ់ ក្នុងថ្ងៃនេះឯង ខ្ញុំមិនធ្វើអំពើអាក្រក់តិចតួច ខ្ញុំមិនមែនជាមិនឲ្យវត្ថុតិចតួចទេ បើខ្ញុំមិនទាន់បានឲ្យទានទឹក មិនផឹកនូវទឹកទេ ។ បពិត្រព្រះវាសវៈ កាលខ្ញុំឲ្យទានសព្វកាលយ៉ាងនេះ ភោគៈទាំងឡាយរបស់ខ្ញុំ មុខជានឹងអស់ទៅ បពិត្រសក្កៈ តអំពីនេះទៅ ខ្ញុំនឹងលះបង់កាមទាំងឡាយតាមទីកំណត់ហើយបួស ។

(២៦១) (អភិសម្ពុទ្ធគាថា) ពួកទេវធីតានោះ ដែលទេវរាជរក្សាហើយរីករាយ លើភ្នំគន្ធមាទន៍ដ៏ប្រសើរ ដែលជាភ្នំខ្ពង់ខ្ពស់

អជ្ឈាគមា នំ សិវកេ សព្វលោកគុ
សុបុប្ផិតំ ធុមវរសាខមាទិយ ។
សុចិំ សុគន្ធំ តិទសេហិ សក្កតំ
បុប្ផុត្តមំ អមរេហិ សេវិតំ
អលទ្ធមច្ចេហិ វ ទានវេហិ
អញ្ញត្រ ទេវេហិ តទារហំ ហិតំ ។
តតោ ចតស្សោ កនកត្តចូបមា
ឧដ្ឋាយ នារិយោ បមទាធិបា មុនិំ
អាសា ច សទ្ធា ច សិរី តតោ ហិរី
ឥច្ចព្រវុំ នារទំ ទេវព្រាហ្មណំ ។
សចេ អនុទ្ទិដ្ឋំ តយា មហាមុនិ
បុប្ផំ ឥទំ បារិច្ឆត្តស្ស ព្រហ្មេ
ទទាហិ នោ សព្វា គតិ តេ ឥជ្ឈតុ
តុវម្បិ នោ ហោហិ យថេវ វាសវោ ។
តំ យាចមានា អភិសមេក្ខ នារទោ
ឥច្ចព្រវី សំកលហំ ឧទីរយិ
ន មយ្ហមត្ថត្ថិ ឥមេហិ កោចិ នំ
យាយេវ វោ សេយ្យសិ សា បិឡន្ធតុ(*) ។

* ម. បិឡន្ធយតំ ។ ឧ. បិឡន្ធនំ ។



ព្រោះនោះ ឥសីដ៏ប្រសើរ ដ៏អ្នកអាចទៅកាន់លោកទាំងអស់ បានកាន់យក ទងផ្កាឈើដ៏ប្រសើរ ដែលរីកស្គុះស្គាយ នាំមក ។ ផ្កានោះ ជាផ្កាស្អាត មានក្លិនក្រអូប ដែលពួកទេវតាក្នុងជាន់ត្រៃត្រិង្ស ធ្វើសក្ការៈហើយ ជាផ្កាដ៏ឧត្តម ដែលពួកទេវតាដ៏ប្រសើរសេពហើយ ពួកមនុស្សដទៃក្តី ពួកអសុរក្តី វៀរលែងតែពួកទេវតាមិនដែលបានឡើយ ព្រោះថា ផ្កានោះ ជាប្រយោជន៍ដ៏សមគួរដល់ ( ពួកទេវតាទាំងនោះ ) ។ លំដាប់នោះ នារីទាំងបួន ដែលជាធំលើសអស់ពួកស្រី មានស្បែកដូចមាស ឈ្មោះអាសា ១ សទ្ធា ១ សិរី ១ ហិរី ១ បានក្រោកឡើង ហើយនិយាយនឹងនារទតាបស ជាអ្នកប្រាជ្ញ ទាំងជាព្រាហ្មណ៍ដ៏ប្រសើរដូច្នេះថា បពិត្រមហាមុនីដ៏ប្រសើរ បើផ្កាបារិច្ឆត្រនេះ លោកមិនឧទ្ទិស (អ្នកណាទេ) សូមលោកឲ្យដល់ពួកយើងផង ( នៃខ្ញុំ ) គតិទាំងពួង សូមសម្រេចដល់លោក ចំពោះលោកក៏សូម (ឲ្យមានមេត្តា) ចំពោះពួកយើង ដូចជាព្រះវាសវៈ ។ នារទតាបស បានឃើញពួកនាងមកសូមផ្កានោះ ក៏ពោលថា នាងនិយាយនូវពាក្យនាំឲ្យបង្កើតកលហៈ ប្រយោជន៍ក្នុងដោយផ្កាឈើទាំងនេះ មិនមានដល់យើងទេ នាងណា ដែលចម្រើនជាងនាងទាំងឡាយ នាងនោះ ចូរប្រដាប់ផ្កានេះចុះ ។

(៦៦៦) ត្វំ នោជ្ឈមេវាភិសមេក្ខ(១) នារទ
យស្សិច្ឆសិ តស្ស បវេច្ឆ បុប្ផំ
យស្សា ហិ នោ នារទ ត្វំ បទស្សសិ
សាយេវ នោ ហោហិតិ សេដ្ឋសម្មតា ។

(៦៦៧) អសយ្ហមេតំ វចនំ សុគត្តេ
កោ ព្រាហ្មណោ វោ កលហំ ឧទីរយេ
គន្ត្វាន ភូតាធិបមេវ បុច្ឆថ
សចេ ន ជានាថ ឥធុត្តមាធមំ ។

(៦៦៨) តា នារទេន បរមប្បកោបិតា
ឧទីរិតា វណ្ណមទេន មត្តា
សកាសំ គន្ត្វាន សហស្សចក្ខុនោ
បុច្ឆឹសុ ភូតាធិបំ កា នុ សេយ្យសី ។

(៦៦៩) តា ទិស្វា អាយត្តមនា បុរិន្ទទោ
ឥច្ចព្រវី ទេវវរោ កតញ្ជលី

១ ម. នោត្តមេវាភិសមេក្ខ ។



(៦៦៦) (ពួកទេវធីតា...) បពិត្រនារទតាបសដ៏ឧត្តម សូមលោក រមិលមើលនូវពួកយើងចុះ បើលោកប្រាថ្នានឹងឲ្យផ្កាដល់នាងណា សូមលោកបោះផ្កានោះសំដៅទៅនាងនោះ បពិត្រនារទតាបស ព្រោះថាបណ្តាពួកយើង បើលោកឲ្យផ្កាដល់នាងណា នាងនោះនឹងយើងសន្មតថា ប្រសើរបំផុតជាងគេ ។

(៦៦៧) (នារទតាបស...) នែនាងទាំងឡាយមានខ្លួនដ៏ល្អ សំដីនេះមិនគួរទេ បុគ្គលដូចម្តេច ដែលហៅថាព្រាហ្មណ៍ បុគ្គលដូចម្តេច គួរពោលពាក្យដែលនាំមកនូវជំលោះ បើនាងទាំងឡាយមិនដឹងដ៏ថោកទាប និងដ៏ខ្ពង់ខ្ពស់ ក្នុងលោកនេះទេ ចូរទៅសួរព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាចុះ ។

(៦៦៨) ពួកទេវធីតាទាំងនោះ ដែលនារទតាបស បានពោលយ៉ាងនេះហើយ ក៏មានចិត្តក្រៅក្រោធយ៉ាងក្រៃលែង ជាស្រីស្រវឹងដោយសេចក្តីស្រវឹងនឹងសម្បុរ ហើយបានទៅកាន់សំណាក់ព្រះឥន្ទ្រ ជាសហស្សនេត្រ រួចសួរព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាថា (បណ្តាពួកយើង) នាងណាប្រសើរជាងគេ ។

(៦៦៩) ព្រះឥន្ទ្រ ដ៏ប្រសើរជាងពួកទេវតា ដែលពួកទេវតា ទ្រង់ប្រណម្យអញ្ជលី លុះបានឃើញនូវពួកទេវធីតាទាំងនោះ មានចិត្តខ្វល់ខ្វាយ ក៏បានពោលតប ដូច្នេះថា

សញ្ញាវ ហេ ហោថ សុភត្តេ(១) សារាសំ
គោចេវ កន្តេ គតេសុ ចុតិយំ ។

(២៦៦) យោ សត្តលោកញ្ញុតោ មហាមុនិ
ឆន្ទេ ឋិតោ ធាតេ(២) សច្ចនិក្កមោ
សោ ទោ ព្រាហ្មី តិរិយ ភក្ខមានលេ
ភក្ខាន ក្ខាជិបមេវ មុដ្ឋ
សទេ ច ជាយាថ វិទុក្ខមធម្មំ ។

(២៦៧) អស្ស ព្រហ្មារញ្ញជកេ មហាមុនិ
ជាលក្ខា កន្តំ វិគន្ធេ កុញ្ញតិ
វិចេយ្យ ធាតាតិ ចលាតិ គោសិយោ
យស្មា ហិ សោ ឧស្សុតិ សាវ សេយ្យសិ ។

(២៦៨) អស្ស ហិ សោ សម្មតិ ឧត្តិណំ តិសំ
គន្ធាយ គិរ ហិមវន្តបស្សតិ(៣)
ស គោសិយោ ធុព្ភគាទនកាជលោ
ពស្ស សុចិ តាបស ទេវសាធេ ។

(២៦៩) សោ មាតលី ទេវវរេន បេសិតោ

១ ឱ. ម. សុភត្តេ ។ ២ ឱ. ម. ធារកោ ។ ៣ ឱ.ម. ហិមវន្តបស្សតិ ។



ដែលខានមានសេចក្ដី ខាន់ចាំងអស់ប្រហែល ១ គ្នា ម្នាលនាង
ទាំង៤ ចុះប្ដូរណាហ៊ុំ បានពោលពាក្យ ដែលខាំបន្តិចណោះ ។

(២៦៦) (ពួកទេវតា...) តាបសណា ជាមហាមុនីអាចក្រោកទៅ
ក្នុងលោកទាំងអស់បាន ឋិតនៅក្នុងធម៌ មានព្យាយាមដ៏ទៀង
ពាក់ តាបសនោះ បានពោលនូវពួកយើងលើក្តីដ៏ប្រសើរ
ឈ្មោះនន្ទមានចិត្ត បើខានចាំងឡាយ មិនដឹងខ្លួនមិនដឹងក្តីអង្គ
លោកនេះ ចូរទៅសួរព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាចុះ ។

(២៦៧) (ព្រះឥន្ទ្រ...) ម្នាលនាងមានខ្លួនដ៏ប្រសើរ តាបសឯណោះ
ជាមហាមុនី ជាអ្នកគ្រាប់ទៅក្នុងព្រៃធំ បើមិនបានឲ្យទាន មិន
បរិភោគនូវភក្តនៃ កាលបើតាបសនោះ ពិចារណាហើយ ទើប
ឲ្យនូវទានទាំងឡាយ ព្រោះថា តាបសនោះ នឹងឲ្យផ្លូវដល់នាង
ណា នាងនោះឯង គេញ្ញាថាប្រសើរជាងគេ ។

(២៦៨) តាបសឯណានោះ រស់នៅក្នុងទិសខាងត្បូងនៃភ្នំហិមវន្ត
ប្របមាត់ទន្លេគង្គា កាលបើតាបសនោះ បានទឹកនិងភោជន
ដោយក្រៃ ម្នាលមាតលិទេវបុត្ត ចូរទៅសួរថា អ្នកចូរនាំទឹក
សុធាភោជន ឲ្យសម្រេចដល់កោសិយតាបសចុះ ។

(២៦៩) មាតលិទេវបុត្តនោះ លុះព្រះឥន្ទ្រប្រសើរជាងទេវតាប្រើហើយ

សហស្សយុត្តំ អភិរុយ្ហ សន្ទនំ
សុខិប្បមេវ ឧបគម្ម អស្សមំ
អទិស្សមានោ មុនិនោ សុធំ អទា(១) ។

(២៧០) ឧទគ្គិហុត្តំ ឧបតិដ្ឋតោ ហិ មេ
បភង្ករំ លោកតមោនុទុត្តមំ
សព្វានិ ភូតានិ អធិច្ច វាសវោ
កោ នេវ មេ បាណិសុ កិំ សុធោទហិ ។
សង្ខូបមំ សេតមតុល្យទស្សនំ
សុចិំ សុគន្ធំ បិយរូបមព្ភុតំ
អទិដ្ឋបុព្វំ មម ជាតុចក្ខុភិ
កា ទេវតា បាណិសុ កិំ សុធោទហិ ។

(២៧១) អហំ មហិន្ទេន មហេសិ បេសិតោ
សុធាភិហាសិំ តុរិតោ មហាមុនិ
ជានាសិ មំ មាតលិ ទេវសារថិ
ភុញ្ជស្សុ ភត្តុត្តម មាភិវារយិ(២) ។
ភុត្តា ច សា ទ្វាទស ហន្តិ បាបកេ
ខុទ្ទំ បិបាសំ អរតិំ ទរថំ កិលំ(៣)

១ ឱ. អទាតិ ។ ម. អទស៍ ។ ២ ឱ. មាភិវារយិ ។ ៣ ឱ. ទរក្លមំ ។ ម. ទរថក្លមំ ។



គ្រឿងទឹមនិងរថ ដែលទឹមដោយសេះមួយពាន់ ហើយចូលទៅកាន់អាស្រមយ៉ាងរហ័ស មិនបង្ហាញកាយឲ្យឃើញ ក្រាបថ្វាយប្រគេននូវសុធាភោជន ដល់តាបសជាអ្នកប្រាជ្ញ ។

(២៧០) (កោសិយតាបស...) កាលដែលអាត្មាអញបំរើនូវការបូជាភ្លើងទីទីព្រះអាទិត្យដ៏ឧត្តម ដែលបន្ទោបង់នូវងងឹតក្នុងលោក អ្នកណាហ្ន៎ ដូចព្រះឥន្ទ្រ គង្វាល់ពួកទេវតាទាំងអស់ ដាក់សុធាភោជន លើផ្ទៃដៃរបស់អាត្មាអញ ។ សុធាភោជននោះមិនសដូចជាស័ង្ខ គួរមើលមើល រកអ្វីប្រៀបគ្មាន ជាភោជនស្អាត មានក្លិនក្រអូប មានសភាពគួរពេញចិត្តយ៉ាងចំឡែក ដែលរបស់អញមិនធ្លាប់ពីកំណើតមក មិនដែលឃើញសោះឡើយ ទេវតាណាហ្ន៎ ដាក់នូវសុធាភោជន លើផ្ទៃដៃរបស់អាត្មាអញ ។

(២៧១) (មាតលិទេវបុត្ត...) បពិត្រលោក ជាមហាមុនី អ្នកវិសេស ខ្ញុំនេះជាទេវតា ខ្ញុំដែលព្រះឥន្ទ្រជាធំបានបញ្ជូនមក ខ្ញុំក៏បាននាំសុធាភោជនយ៉ាងរហ័ស លោកបានស្គាល់ខ្ញុំជាឈ្មោះមាត-លិទេវបុត្ត ជាទេវសារថី សូមលោកឆាន់នូវភត្តដ៏ឧត្តម លោកកុំប្រកែកឃាត់ឡើយ ។ ឯសុធាភោជននោះ បើលោកបរិភោគហើយ រមែងកំចាត់បង់នូវបាបធម៌ ១២ យ៉ាងបានគឺ សេចក្តីឃ្លាន ១ ការស្រេក ១ សេចក្តីអផ្សុក ១ ក្រវល់ក្រវាយកាយ ១ លំបាកកាយ ១

គោធម្មបជាមាតុ វិកេទបេតុំហំ
សីតុណ្ហគន្ធិតុ សេវុត្តមំ ឥតំ ។

(៤៧២) ន តាបេតិ ធាតលិ មយ្ហ កុញ្ចិតុំ
បុព្វេ អនត្ថ ឥតិ មេ វត្តុត្តមំ
ន ចាបិ បកាសនមរិយធម្មជិតំ
អសេវិតាតិ ច សុចំ ន វិន្ទតិ ។

(៤៧៣) ជីយាតតា យេ កោចិមេ បរតាតា
មិត្តទ្រោហោ យេ ច សបន្តិ សត្រុតេ
សរេត្វា តេ មច្ចិបញ្ញមានហា
តម្ហា អនត្ថ ទុនតាមប្បំ ចាសិយេ ។
សោ ហិតតិយា កំ បុរិសស្ស កំ បន
ធតរដ្ឋមំ ញាណំ វិនុសមប្បវណ្ណិតំ
សន្តា វនញ្ញា ឥឝ វិគមច្ចា
គាវិត្តិ ហោតេ សុចិសច្ចសម្មតា ។

(៤៧៤) អតោ មតា តេវីរេន បេសិតា
កញ្ញា ចតស្សោ ការតន្តធុបមា
អាសា ច សទ្ធា ច សិរី តតោ ហិរី



ក្រោធ១ ចរិសេចក្តីក្រោធគ្នាចិត្ត១ ឈ្លោះប្រកែក១ ញុះញង់១
ក្រេវក១ ក្កេវ១ ខ្ជិល១ ដូច្នេះការដ៏ឥមខះ មានសេចក្តីខ្ពស់ ។

(៤៧២) (ពោធិយ...) ម្នាលព្រាហ្មណ៍ឈ្មោះមាតលិ ការដែលគេញ
មិនបានឲ្យបានជាមុនសិនហើយបារគោរ មិនគួរទេ ព្រោះថាគួរនេះ
ជាវត្តុត្តមរបស់គេញ ឯការប្រកាសនូវធម៌ដ៏ឯទ ជាអំពើដែល
ព្រះអរិយៈ មិនបូជាឡើយ មួយទៀត បុគ្គលអ្នកមិនបានដែរ
វិសេក ក៏មិនបានខ្សោយសេចក្តីស្មោះទេ ។

(៤៧៣) ពួកជនណាមួយ ជាអ្នកសម្លាប់ស្ត្រី ជាអ្នកប្រព្រឹត្តបរទារិក-
កម្ម ឬក៏ពួកជនណា ជាអ្នកប្រទូស្តមិត្ត គេប្រាប់ចក្ខុបុគ្គល
អ្នកមានវេទ្ទ ជនទាំងអស់នោះ សូវតែមានសេចក្តីកំណាញ់
ដាំជាតកាលជាតំបង់ព្រៃ ព្រោះហេតុនោះ គេញយើមិនបានឲ្យ
សូមរ៉ូទ្ធវ៉ែក គឺមិនបោះភេគទេ ។ មួយទៀត គេញនោះគ្រប់តែឲ្យ
បានដែលអ្នកប្រាជ្ញសរសើរហើយ ដល់ស្ត្រីឬបុរស ដូចបុគ្គល
អ្នកមានសក្ខា អ្នកដ៏នឹងនៅពាក្យសួម ប្រាសចាកសេចក្តីកំណាញ់
ទាំងនេះ លោកសន្មតជាជាអ្នកមានសច្ចៈដ៏ស្អាត គឺលោកនេះ ។

(៤៧៤) (អភិសម្ពុទ្ធគាថា) លំដាប់នោះនាងកញ្ញាទាំង ៤ នាក់ ដែល
មានស្បែកដូចជាមាសឈ្មោះ អាសា១ សទ្ធា១ សិរី១ ហិរី១
ដែលព្រះឥន្ទ្របញ្ជូនឲ្យទៅជាង ... បានយល់ព្រមគ្រប់ទៅហើយ

តំ អស្សមំ អាគម្ម យត្ថ កោសិយោ ។
តា ទិស្វា សព្វា បរមប្បមោទិតា
សុភេន វណ្ណេន សិខារិវគ្គិយោ
កញ្ញា ចតស្សោ ចតុរោ ចតុទ្ទិសា
ឥច្ចាព្រវី មាតលិនោ សម្មុខា ។
បុរិមំ ទិសំ កា ត្វំ បភាសិ ទេវតេ
អលង្កតា តារវរា ឱសធី
បុច្ឆាមិ តំ កញ្ចនវេល្លិវិគ្គហេ
អាចិក្ខ មេ ត្វំ កតមាសិ ទេវតា(១) ។
(៤៧៨) សិរីហា ទេវី មនុជេសុ បូជិតា
អបាបសត្តូបនិសេវិនី សទា
សុធាវិវាទេន តវន្តិមាគតា
តំ មំ សុធាយ វរបញ្ញ ភាជយ ។
យស្សាហមិច្ឆាមិ សុធំ មហាមុនិ
សោ សព្វកាមេហិ នរោ បមោទតិ
សិរីតិ មំ ជានាហិ ជុហតុត្តម
តំ មំ សុធាយ វរបញ្ញ ភាជយ ។

១ ម. ទេវតេ ។



នាងក៏មកកាន់អាស្រមជាទីនៅនៃកោសិយតាបសនោះ ។ កោសិយតាបស បានឃើញនាងកញ្ញាទាំង ៤ នោះ ដែលមានចិត្តត្រេកអរយ៉ាងលើសលុបទាំងអស់គ្នា មានវណ្ណៈដ៏ល្អដូចអណ្ដាតភ្លើង ឋិតនៅក្នុងទិសទាំងបួន ហើយបានពោលដូច្នេះក្នុងទីចំពោះមុខនៃមាតលិទេវបុត្តថា ម្នាលទេវតា នាងជាអ្វី មានកាយប្រដាប់ហើយ បានភ្លឺក្នុងទិសខាងកើតឡើង ដូចជាផ្កាយព្រឹកដ៏ប្រសើរ ម្នាលនាងមានកាយដូចជារូបបៀប ជាវិការៈនៃមាស អាត្មាសូមសួរនាង ចូរនាងប្រាប់អាត្មា នាងជាទេវតាឈ្មោះអ្វី ។
(៤៧៨) (នាងសិរី...) ខ្ញុំជាទេវតាឈ្មោះសិរី ដែលគេបូជាក្នុងពួកមនុស្ស មិនចូលទៅគប់រកនូវសត្វមានបាបគ្រប់កាល មកកាន់សំណាក់លោក ព្រោះតែសេចក្ដីវិវាទនឹងគ្នាអំពីសុធាភោជន បពិត្រលោកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជនដល់ខ្ញុំ ។ បពិត្រលោកជាមហាមុនី ខ្ញុំប្រាថ្នាសុធាភោជនរបស់ជនណា ជននោះឯងរមែងរីករាយ ដោយកាមគ្រប់យ៉ាង បពិត្រលោកដ៏ខ្ពង់ខ្ពស់ជាងពួកជនអ្នកបូជាភ្លើង សូមលោកដឹងនូវខ្ញុំថា ជាទេវតាឈ្មោះសិរី បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជន ដល់ខ្ញុំ ។

(៦៧៦) សំបេឡន វិជ្ជាចរណេន គុត្តិយា
ឆក ទុបេតា បត្តុសា សកម្មុនា
ឧយា វិហីឆា ច លកត្តិ តាតុំ មំ
ហយិ ចំ ច កភត្ត យធិណ៌ ឥយា ភត្តំ ។
បសម្ពមិ តោសំ អលសំ មហគ្ឃសំ
សុត្តក្កលីធំបំ អតុបិទ ជរ
ឥយា ទុត្តោ្ត សរំ ជាតិមាមបិ
បេះសត់ ឆាសំ វិយ កោតក សុទិ ។
កត្តំ អសទ្ធំ អកិតញ្ញុ សេរិធំ
ជាហាម៉ មុត្តំ វិតុកទុតាតិខំ
ឧ តាធិសំ អហាតិ កសឧតំ
ត្បោក សុតា កចូ ឧ បព្ពុរ រុច្ចសំ ។
(៦៧៧) តា សុត្តេតាហ បធិមុត្តកណ្ហាលា
ចិត្តទ្ធិឆា តាម្ហុមទ្ទតាវិធំ
ទិសាតុ្តវណ្ណិ បរិធេ្ឃ សោតកំ
ឆតុសក្ខិត្តំ អបិឡ្យុ មញ្ជុំ ។
មិតិ កញ្ជា សរោចបោវោ
វិកធិតា មន្ទមិរ ទុធិក្តុសំ



(៦៧៦) (សោ.ម.យ...) ក្នុងកាលដែលព្រះបាទជាមួយសិស្សបរិបូណ៌ដោយចរណៈ និងប្រាជ្ញា ជាអ្នកប្រាជ្ញាញ ដោយអំពើរបស់ខ្លួន ត្រឡប់ជាទៅកាន់អបាយវិញ មិនមានរយៈកម្មសេចក្ដីសុខនោះទេបុគ្គលសោះឡើយ អំពើណា ដែលខ្លួនធ្វើហើយ អំពើនោះមិនប្រែកទេ ។ ភក្ដាធ្វើយើញខ្លួនជនទូលព្រះអង្គ យ៉ាងច្រើន ជាអ្នកមានត្រកូលដ៏ថោកទាប មានរូបអាក្រក់ ប្រុសនោះ ដែលខ្លួនឆ្លងកន្លងហើយ គឺបានទៅជាអ្នកមានសេរី ភាពប្រេះខ្ទែង ដែលមានជាតិខ្ពស់ ដូចជាអ្នកមានគោត្រ មានសេចក្ដីសុខ ប្រើខ្លួនថ្មីផង ។ ព្រោះហេតុនោះ យើងឃើញនាងជាស្រីមួយ មានសម្បុរ ល្អក្រអូប ជាស្រីល្អដែលជិតនឹងអ្នកប្រាជ្ញ ស្រីប្រពៃពលដូចនាង មិនគួរទទួលយកនូវជីវិតទេ សូមកោតដទឹកមានភ័ណ្ឌ នាងចុះទៅចុះ ភក្ដាមិនពេញចិត្តនឹងនាងទេ ។

(៦៧៧) នាងជាស្រី មានឧត្តមស ជាកុលបុត្រ មាននៅត្រៀមប្រដាប់ដោយកែវមណី ក្រវិលត្រចៀកប្រដាប់កាយនៃនាងក្នុង ស្នៀតនល្អ សំពត់មានពណ៌ដូចទៅនៃទឹកដែលនាងស្រាតចុះ សៀតក្រអូបល្អ មានពណ៌ក្រហមដូចផ្កាចេរ ល្អ ។ នាងដូចមេម្រឹក ដែលព្រានព្រៃបាញ់ហើយ កំពុងតែដើរក្រឡេកមើលទៅ ។

កោ តេ ទុតិយោ នត្ថិ មនុស្សលោកេ
ន ភាយសិ ឯកិកា កាននេ វនេ ។

[៤៣៨] ន មេ ទុតិយោ ឥធមត្ថិ កោសិយ
មសក្កសារប្បភវម្ហិ ទេវតា
អាសា សុធាសាយ តវន្តិមាគតា
តំ មំ សុធាយ វរបញ្ញ ភាជយ ។

[៤៣៩] អាសាយ យន្តិ វាណិជា ធនេសិនោ
នាវំ សមារុយ្ហ បរេន្តិ អណ្ណវេ
តេ តត្ថ សីទន្តិ អថោបិ ឯកទា
ជីនាធនា ឯន្តិ វិនដ្ឋបាភតា ។
អាសាយ ខេត្តានិ កសន្តិ កស្សកា
វបន្តិ ពីជានិ ករោន្តុបាយសោ
ឦតីនិបាតេន អវុដ្ឋិតាយ វា
ន កិញ្ចិ វិន្ទន្តិ តតោ ផលាគមំ ។
អថត្តការានិ ករោន្តិ ភត្តុសុ
អាសំ បុរក្ខត្វា នរា សុខេសិនោ
តេ ភត្តុរត្តា អតិគាឡិតា(១) បុន
ទិសា បនស្សន្តិ(២) អលទ្ធ កិញ្ចនំ ។

---
១ ម. អតិគាឡ្ហិតា ។ ២ ម. បលាយន្តិ ។



ដូច្នោះ ម្នាលនាងមានខ្លួនស្រស់ បុគ្គលណាជាអ្នកបំរើនៃនាង ក្នុងវេលានេះ នាងតែម្នាក់ឯង នៅក្នុងព្រៃ មិនខ្លាចទេឬ ។

(៤៣៨) (នាងអាសា...) បពិត្រកោសិយមហាបស ក្នុងវេលានេះ មិនមានបុគ្គលជាអ្នកបំរើខ្ញុំទេ ខ្ញុំជាទេវតាឈ្មោះអាសា កើតក្នុងភពភ្នំត្រីកូដ មកកាន់សំណាក់លោកដោយ (សេចក្ដីចង់បាន) នូវសុធាភោជន បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជន ដល់ខ្ញុំ ។

(៤៣៩) (អាសាយ...) ពួកពាណិជអ្នកស្វែងរកទ្រព្យ នាំគ្នាឡើងសំពៅទៅក្នុងសមុទ្រ ព្រោះសេចក្ដីប្រាថ្នា ពាណិជទាំងនោះ ជួនកាល លិចចុះក្នុងសមុទ្រនោះ ជួនកាល សាបសូន្យចាកទ្រព្យ ចុះទាំងដើមទុន ។ ពួកកសិករភ្ជួរស្រែទាំងឡាយ ព្រោះ (សេចក្ដីប្រាថ្នា) សាបព្រោះនូវពូជទាំងឡាយ ធ្វើ (កិច្ចនោះៗ) ដោយឧបាយ ក៏មិនបាននូវផលកើតផលបន្តិចបន្តួចអំពីសន្ទូងនោះ ដោយសេចក្ដីអន្តរាយផ្សេងៗ ឬគ្មានភ្លៀង ព្រោះតែសេចក្ដីប្រាថ្នា ។ ពួកជនអ្នកស្វែងរកសេចក្ដីសុខ បាននូវសេចក្ដីប្រាថ្នាជាប្រធាន ហើយធ្វើនូវសេចក្ដីព្យាយាមក្នុងទីយុទ្ធភូមិ ដើម្បីម្ចាស់ ជនទាំងនោះរមែងធ្វើប្រយោជន៍ដល់ម្ចាស់ ត្រូវគេបង្ខាត់ បៀតបៀនយ៉ាងខ្លាំង មិនបាននូវទ្រព្យអ្វីបន្តិចបន្តួច ក៏រត់ទៅកាន់ទិសទាំងឡាយ ។

ហិត្វាន ធញ្ញញ្ច ធនញ្ច ញាតកេ
អាសាយ សគ្គាធិមនា សុខេសិនោ
តបន្តិ លូខម្បិ តបំ ចិរន្តរំ
កុម្មគ្គមារុយ្ហ បរេន្តិ ទុគ្គតិំ ។
អាសា វិសំវាទិកសម្មតា ឥមេ
អាសេ សុធាយ វិនយស្សុ អត្តនោ
ន តាទិសី អរហតិ អាសភោជនំ
តស្មា សុធា គច្ឆ ន មយ្ហ រុច្ចសិ ។

(៦៨០) ទទ្ទល្លមានា យសសា យសស្សិនី
ជិឃញ្ញនាមវ្ហយនំ ទិសំបតិ
បុច្ឆាមិ តំ កញ្ចនវេល្លិវិគ្គហេ
អាចិក្ខ មេ ត្វំ កតមាសិ ទេវតា ។

(៦៨១) សទ្ធាហ ទេវី មនុជេសុ បូជិតា
អបាបសត្តូបនិសេវិនី សទា
សុធាវិវាទេន តវន្តិមាគតា
តំ មំ សុធាយ វរបញ្ញ ភាជយ ។



ពួកជនអ្នកបួសទៅកាន់ឋានសួគ៌ ដែលជាសេចក្តីសុខ ក៏លះបង់នូវស្រូវទ្រព្យនិងពួកញាតិ ហើយធ្វើកំដៅនូវតបៈដ៏សៅហ្មងអស់កាលយូរអង្វែង តែបែរជាឡើងកាន់ផ្លូវខុស ត្រឡប់ទៅកាន់ទុគ្គតិ ព្រោះតែសេចក្តីប្រាថ្នា ។ នែនាងអាសា នាងឯងដែលគេឈ្មោះថាអាសា គេសន្មតថាជាស្រីបោកប្រាស់នូវជនទាំងនេះ (ពោលគឺនោះ) នាងចូរបន្ទាបង់នូវសុធាភោជនចំពោះខ្លួនឯងចុះ ស្រីប្រហែលនាងមិនគួរទទួលភោជនៈទិព្វទេ សុធាភោជនមិនមានដល់អ្នកណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ ។

(៦៨០) នាងជាស្រីមានយស រុងរឿងដោយយស ជាទិសវិសេស គេហៅដោយឈ្មោះថា បច្ឆិម ម្នាលនាងមានសរីរៈដូចរបៀបវល្លិមាស អាត្មាសួរនាង នាងចូរប្រាប់ដល់អាត្មា នាងជាទេវតាឈ្មោះអ្វី ។

(៦៨១) (នាងសទ្ធា...) ខ្ញុំជាទេវតាឈ្មោះសទ្ធា ដែលគេបូជាក្នុងពួកមនុស្ស មិនសេពគប់នូវសត្វដ៏លាមកសព្វកាល៖ មកកាន់សំណាក់លោកដោយការឈ្លោះប្រកែក ព្រោះសុធាភោជន បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែករំលែក នូវសុធាភោជន ដល់ខ្ញុំ ។

[២៨៦] ឆាតំ ឥមំ ជាតមេជោបិ សំយមំ
អកាយ សទ្ធាយ ការេន្តិ ហេតុនា
ជេយ្យំ មុសា កុឌមហោបិ បេសុណំ
ការេន្តិ ហោតោ មុន វិទុតា គយោ ។
កាយាសុ រោសោ សតិសីសុ មេត្តាក
សីលូបបន្នាសុ បតិព្វតាសុបិ
វិនេត្វា ធម្មំ កុលិត្ថិយាសុបិ
ការេតិ សង្ខំ មុន ក្រុម្ភធាសិយា ។
ទុមេដ សទ្ទេ បរទារសេវិធី
ហាបំ ការេសី ក្រុសលំ និរត្តសំ
ន ការិសី អរហាតិ អាសន្នកំ
ក្រុតោ សុតា គច្ឆ ន មយ្ហ រុច្ចសិ ។
[២៨៧] ជិយព្ញាត្តិ អរុណាស្មិមាគេ
យា និស្សតិ ទុគ្គមរូបវណ្ណិនី
គច្ឆបមា មំ បដិភាសិ នេត្តេ
អាចិក្ខ មេ ត្វំ កតមាសិ អច្ឆរា ។



(២៨៦) (គោតមៈ...) ជួនកាល មនុស្សទាំងឡាយពិសផ្ញើកស សុរា ហើយធ្វើនូវទាន នូវការប្រព្រឹត្តខុសក្រែង នូវការបរិហារនិន ការបង្រ្ទើមក៏មាន មនុស្សពួកខ្លះ ដែលឃ្លានផឹកនានី (សុរា) វិញ ក៏ធ្វើនូវការលួច កុហក ចង្អៀតញ្ញៀកក៏មាន ។ បុរស អ្នកប្រព្រឹត្តកន្លងកាយនានីឡាយ ដែលមានគុណសម្បត្តិល្អិតៗ ជា ស្រីបរិបូណ៌ដោយសីល មានវត្តរវាពារខ្លួន តែលតែងធ្វើនូវសេចក្តី ប្រព្រឹត្តកន្លងស្រីដែលមានត្រកូលល្អ ហើយធ្វើនូវការលើមហារ កុម្ភកាសីញ្ញក៏មាន ។ ម្នាលនាងសុតា នាងបានដឹងបេះពល់ប្រាកដ របស់វានដល់ ហើយធ្វើនូវការកើតរោមក ល្បះទាលនូវកុសល ប្រើ ប្រហែលនាង មិនគួរទទួលនូវអាសនៈទីទាំងនេះ សុតសោមនាង មានគតិណា នាងចូរទៅចុះ យើងមិនពេញចិត្តនឹងនាងទេ ។

(២៨៧) ទិសនានាំកើត ឯណា ទាំងសម្បូរបែប ដ៏ឧត្តម ព្រោតផ ច្បាស់ ក្តីនៅណាអរុណរះឡើង ក្តីទីបំផុតនៃពន្លឺ ម្នាលនាង ទេវតា នាងប្រាកដច្បាស់ ដល់យើង ដូចជាទិសនាង កើតដោយដែរ នាងចូរប្រាប់យើង នាងជាស្រីអ្វីរបស់ ។

កាឡា មិគាយេវ អគ្គិជាវ
អធិសេវិតា លោហិតបត្តមាលិនី
កា តិដ្ឋសិ មន្ទមិតា លោកាយំ
កាសេសមាតា ទេវ ន មុញ្ចសិ ។

[៤៨៦] ហរិតា ទេវី មនុជេសុ បូជិតា
អហាបសត្តុបធិសេវិធី សុធា
សុនាវិកេន កវត្ថិមាគតា
សហំ ន សក្កោមិ សុធំបិ យាចិតុំ
កោបិនរូបា វិយ យាចនិត្ថិយា ។

[៤៨៧] ជម្ពោន ញាយេន សុខេត្ត លទ្ធសិ
បរេសោ ហិ ជម្ពោ ន ហិ យាចនា សុធា
តំ តំ អយាចន្តិមហំ និមន្តយេ
សុធំ យំ យទិច្ឆសិ តំបិ ធម្មំ ទេ ។
សា ត្វំ មយា អជ្ជ សកម្ហិ អស្សមេ
និមន្តិតា កញ្ចនវេល្លិវិគ្គហេ
តុវញ្ហិ មេ សព្វរសេហិ បូជិតា
តំ បូជយិត្វាន សុធំបិ អស្មិយេ ។



នារីឈ្មោះអ្វី ដូចជាវល្លិប្រេង ដែលត្រូវរុំព័ទ្ធមានពេលាវៀលនស្លឹក ដ៏ក្រហមក្នុងខែកាយជេដ្ឋ ឬដូចជាអណ្ដាតភ្លើង កុំនោះសោក ដូចម្រឹគស្មោះ ការស្រែកស្ររេកមើលនារីហាក់ដូចជាមានប្រាថ្នានឹង និយាយ តែមិនបញ្ចេញនូវពាក្យទៅវិញ ។

[៤៨៦] (នារីហរី...) ខ្ញុំជានារីទេវីឈ្មោះហរី ដែលគេបូជាក្នុង ពួកមនុស្ស ជាស្រីមិនលោភលន់នូវសត្វដើរលើមេឃក្នុងកាល មក កាន់សំណាក់លោកដោយការឈ្មោះប្រើគេ ព្រោះសុធាភោជន តែខ្ញុំនាមិនអាចនឹងសុំនូវសុធាភោជននោះ ដូចជាការសុំនៃស្រី ដូចជាការបើកបង្ហាញកេរ្តិ៍ក្នុង ។

[៤៨៧] (គោសិយ...) ម្នាលនារីមានរាងកាយល្អ នាងនឹងបាន (នូវសុធាភោជន) តាមសេចក្ដីគួរ នេះកើតជាធម៌ហើយ ដ្បិតជាសុធាភោជន គេមិនបានព្រោះការសុំទេ ព្រោះហេតុនោះ អាត្មានឹងអញ្ជើញនាងដែលមិនសុំ នាងប្រាថ្នានូវសុធាភោជន ណា ៗ អាត្មានឹងឲ្យនូវសុធាភោជនៈនោះៗ ដល់នាង ។ ម្នាល នាងមានរាងកាយដូចរូបរៀបជាមាសនៃមាស នាងនោះអាត្មា នឹងអញ្ជើញទៅក្នុងអាស្រមរបស់អាត្មាក្នុងថ្ងៃនេះ នាងជាស្រីគួរ អាត្មាបូជាដោយវត្ថុមានរសគ្រប់យ៉ាង អាត្មាលុះបូជានាងហើយ ទើបនឹងបរិភោគនូវសុធាភោជននោះ ។

[៤៨៦] សា កោសិយេនានុមតា ជុតិមតា
អទ្ធា ហិរី រម្មំ បាវិសិ យស្សមំ
ឧទកវន្តំ ផលមរិយបូជិតំ
អបាបសត្តូបនិសេវិតំ(១) សទា ។
រុក្ខគ្គហានា ពហុកេត្ថ បុប្ផិតា
អម្ពា បិយាលា បនសា ច កឹសុកា
សោភញ្ជនា លោទ្ទមថោបិ បទ្មកា
កេកា ច ភង្គា តិលកា ច បុប្ផិតា ។
សាលា ករេរី ពហុកេត្ថ ជម្ពុយោ
អស្សត្ថនិគ្រោធមធុកា ច វេតសា
ឧទ្ទាលកា បាដលិ សិន្ទុវារិតា
មនុញ្ញគន្ធា មុចលិន្ទកេតកា ។
ហរេណុកា វេឡុកា វេណុតិន្ទុកា
សាមាកនីវារមថោបិ ចីនកា
មោចា កទលី ពហុកេត្ថ សាលិយោ
បវីហយោ អាភុជិនោ ច តណ្ឌុលា ។

១ ម. អបាបសត្តូ បរិសេវិតំ ។



[៤៨៦] (អភិសម្ពុទ្ធគាថា) នាងហិរីនោះ ជាស្រីមិនសេពគប់នូវសត្វលាមកសព្វកាល ដែលកោសិយតាបសមានអានុភាពដ៏រុងរឿងអនុញ្ញាតហើយ ក៏ចូលទៅកាន់អាស្រមជាទីរីករាយ ជាអាស្រមមានទឹក មានផ្លែឈើ ដែលពួកអរិយជនបូជាហើយ ។ ជិតអាស្រមនោះ មានព្រៃឈើស៊ុបទ្រុមធំច្រើន មានផ្ការីកហើយ ដើមស្វាយ ដើមព្រីង ដើមខ្នុរ ដើមចារ ដើមម្រុម ដើមលោធ ដើមក្ទាតង្គៀប ដើមសំរោង ដើមចន្ទន៍ ដើមត្រមូង មានផ្ការីកហើយ ។ ជិតអាស្រមនោះ មានដើមឈើច្រើន គឺដើមកង ដើមថ្នាំ ដើមក្រឹង ដើមពោធិ៍ព្រាយ ដើមជ្រៃ ដើមស្រគំ មានមែកទោរទន់ចុះ គឺដើមកន្ទ្រើស ដើមច្រាខៀង ដើមព្រឡា ដើមកន្ទុំ និងដើមសំរោង មានក្លិនផ្សព្វផ្សាយក្រអូបគាប់ចិត្ត ។ ជិតអាស្រមនោះ មានអបរណ្ណជាតិ គឺពោតខ្ញី សណ្ដែកព្រៃ ដើមខ្ចាប់ ស្រូវទ្រ និងដែលលក សណ្ដែកផងតាល ចេកមានក្រាប់ និងស្រូវសំរូប ស្រូវក្រហមជាច្រើន ដែលចេញជាអង្ករស្អាតឥតកន្ទក ។

តស្សា ច ឧត្តរបស្សេន ជាតា ពោក្ខរណី សិវា
អកក្កសា អបព្ភារា សាទុ អប្បដិគន្ធិកា ។
តត្ថ មច្ឆា សន្និរតា ខេមិនោ ពហុភោជនា
សិង្គូ សវង្កា សកុលា សតវង្កា ច រោហិតា
អាលិគគ្គរកាកិណ្ណា បាឋីនា កាកមច្ឆកា ។
តត្ថ បក្ខី សន្និរតា ខេមិនោ ពហុភោជនា
ហំសា កោញ្ចា មយូរា ច ចក្កវាកា ច កុក្កុហា
កុណាលកា ពហូ ចិត្រា សិខណ្ឌី ជីវជីវកា ។
តត្ថ បានាយ មាយន្តិ នានា មិគគណា ពហូ
សីហា ព្យគ្ឃា វរាហា ច អច្ឆកោកតរច្ឆយោ
បលសាទា ច គវជា មហិសា រោហិតា រុរូ
ឯណេយ្យា ច វរាហា ច គណិនោ នីកសូករា ។
កទលិមិគា ពហុកេត្ថ ពិឡារា សសកណ្ណិកា
ឆមាគិរី បុប្ផវិចិត្រសន្ថតា
ទិជាភិឃុដ្ឋា ទិជសង្ឃសេវិតា ។



នៅខាងជើង នៃទីតាស្រះនោះ មានជាតស្រះបោក្ខរណីដ៏ក្សេម មិនមានខ្ទះក្រក់ មានកំពង់មិនចោត ជាស្រះដ៏ល្អប្រកបដោយទឹកមានខ្លិនមិនគួរខ្ពើម ។ ក្នុងស្រះនោះ មានពួកត្រីត្រេកត្រអាល ជាសត្វមានសេចក្តីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺ ត្រីផ្ទក់ ត្រីខ្ជឹង ត្រីក្រាយ បន្ទន ត្រីឆ្ពិន ត្រីស្លាក និងត្រីក្អក គឺពាហ៊ាលេះទាយគាដោយស ។ ក្នុងស្រះនោះ មានពួកសត្វស្លាបត្រេកត្រអាល ជាសត្វមានសេចក្តីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺហង្ស ក្រៀល ក្ងោក ចាក្រពាក អកកាលើ ក្ងោកមាស ខោម ព្រហ៊ក ដ៏ច្រើន ។ មានពួកសត្វតិរច្ឆាននៃម្រឹគផ្សេងៗ ជាច្រើន គឺសីហៈ ខ្លាធំ ខ្លាឃ្មុំ ជ្រូកព្រៃ ខ្លារខិន ចោស គោព្រៃ ក្របី រមាំង ប្រើស ព្រាយ ជ្រូកព្រៃ ក្ដាន់ និងជ្រូកស្រុក មកប្រជុំគ្នាក្បែរស្រះនោះ ។ មានពួកសត្វ ឆ្មា ទន្សាយនិងទន្សងជាច្រើន ដែលនៅទីនោះ ពេញពាសដោយផ្កាដ៏វិចិត្រ គិរីកើតដោយសម្លេងនៃសត្វបក្សី មានហ្វូងបក្សីគប់រកជានិច្ច ក្បែរស្រះនោះ ។

(៦៨៧) សា សុត្តចា នីលទុមាភិលម្ពិតា
វិជ្ជុមហាមេឃរិវានុបជ្ជថ
តស្សា សុសម្ពន្ធសិរំ កុសាមយំ
សុចឹ សុគន្ធំ អជិនូបសេវិតំ
អត្រិច្ឆកោច្ចំ ហិរិមេតទព្រវិ
និសីទ កល្យាណិ សុខយិទមាសនំ ។
តស្សា តទា កោច្ឆគតាយ កោសិយោ
យទិច្ឆមានាយ ជដាជិនន្ធរោ
នវេហិ បត្តេហិ សយំ សហូទកំ
សុធាភិហាសី តុរិតោ មហាមុនិ ។
សា តំ បដិគ្គយ្ហ ឧភោហិ បាណិភិ
ឥច្ចព្រវិ អត្តមនា ជដាធរំ
ហន្ទាហំ ឯតរហិ បូជិតា តយា
ចរេយ្យំ ព្រហ្មេ តិទិវំ ជិតាវិនី ។



(៦៨៧) នាងហិរីនោះ មានស្បែកដ៏ល្អ តោងដើមឈើមានពណ៌ខៀវ បានចូលទៅ ( កាន់អាស្រម ) ហាក់ដូចជាផ្លេកបន្ទោររបស់មហាមេឃ កោសិយតាបសបានរៀបចំកៅអី ដែលមានបណ្តាញប្រទាក់គ្នាដ៏ល្អ ជាវិការៈនៃស្បូវភ្លាំងដ៏ស្អាត មានក្លិនដ៏ល្អ ក្រាលដោយស្បែកខ្លាឃ្មុំ បម្រុងនាងហិរីនោះ បានពោលពាក្យនេះនឹងនាងហិរីថា ម្នាលនាងមានលំអ នាងចូរអង្គុយឱ្យស្រួលចុះ នេះអាសនៈ ។ កាលដែលនាងហិរីនោះ ឋិតនៅលើកៅអី ប្រាថ្នានូវសុធាភោជនណា គ្រានោះ កោសិយ-តាបស អ្នកទ្រទ្រង់នូវផ្នួងសក់ដ៏រុងរឿង ជាមហាមុនី ប្រញាប់ប្រញាល់ បាននាំមកនូវសុធាភោជននោះ ព្រមទាំងទឹកដោយស្លឹកឈូកថ្មី ៗ ដោយខ្លួនឯង ។ នាងហិរីនោះ មានចិត្តត្រេកអរ បានទទួលនូវសុធាភោជននោះ ដោយដៃទាំងពីរ ហើយពោលនឹងកោសិយតាបស អ្នកទ្រទ្រង់នូវផ្នួងសក់នោះថា បពិត្រព្រហ្ម ឥឡូវនេះ ខ្ញុំដែលលោកបូជាហើយ ជាបុគ្គលមានជ័យជំនះ សូមទៅ កាន់ឋានត្រៃត្រឹង្សវិញ ។

ឥធ កោសិយេ ធាតុមតា ជុតីមតា
ឧឡារា[1] វណ្ណោមេ ពេន មត្តា
សណ្ហិសេ កញ្ចន សហស្សនេត្តោ
អយំ សុធា កោសិយ ទេហិ មេ ជយំ ។
ឥមេធំ សណ្ហោមិ គតា អម្ពុជយិ
សហិន្ទទេវេ សុរកញ្ញមុត្តមំ
សា បញ្ចលី ទេវមនុស្សបូជិតា
នាម្ហិ កោធម្ហិ យេតា ឧទានសិ ។

(២៨៨) ឥមេវ អសំសី បុនទេវ មាតលី
សហស្សនេត្តោ តិទសានមិន្ទោ
កញ្ញាន កញ្ញ មម ព្រូហិ កោសិយំ
អាសាយ សទ្ធាយ សិរិយា ច កោសិយ
ហិរី សុធំ ភោជនមលត្ថ ហោតុតា ។

(២៨៩) តំ សុប្បវត្តំ ឧទតារយី រថំ
ឧទ្ទព្យមានំ ឧបការិយសាទិសំ
ជម្ពោនទីសំ តបនេយ្យសន្និភំ
អលង្កតំ កញ្ចនចិត្តសន្និភំ ។

១ ម. ឧទិយិ ។



នាងទេវតានោះ ដែលកោសិយតាបសមានតេជានុភាពដ៏ធំរុងរឿង ប្រុង
អនុញ្ញាតហើយ ជាស្រីស្រស់បំព្រងដោយការស្រស់បំព្រងនៃវណ្ណៈ កំពុង
ក្នុងសំណាក់ព្រះអង្គជាសហស្សនេត្រ ក្រាបទូលថា បពិត្រព្រះ
កោសិយៈ នេះជាសុធាភោជន សូមព្រះអង្គទ្រង់ប្រទានឲ្យដល់
ខ្ញុំ ។ នាងទេវតានោះ ដែលពួកទេវតានិងមនុស្សទាំងអស់បូជាហើយ
កំពុងលើកអញ្ជលីលើកសំពត់ចូលជិតកោសិយ ព្រះអង្គក្រោមនាំទៀត
ទៀត កំពុងនាងទេវតានោះ ជានាងទេវតាដ៏ខ្ពង់ខ្ពស់ទាំងនោះ ។

(២៨៨) សហស្សនេត្រ ជាធំជាងពួកទេវតាជាន់ត្រៃត្រិង្ស ទ្រង់បានត្រាស់
នឹងមាតលិទេវបុត្តនោះម្តងទៀតថា អ្នកចូរទៅសួរកោសិយតាបស
តាមពាក្យរបស់យើងថា បពិត្រកោសិយៈ នាងអាសា នាងសទ្ធា នាង
សិរី និងនាងហិរី បានឲ្យសុធាភោជនដល់អ្នកដោយហេតុអ្វី ។

(២៨៩) មាតលិទេវបុត្ត បានឡើងជិះរថនោះ ដែលស្លាបដោយស្រះសីរី
ស្រស់ត្រចះត្រចង់ចរទៅប្រែប្រួលទាំងអស់ មានពន្លឺដូចភ្លើងដែលឆេះ
ដូចមាសជម្ពូនទ ដូចមាសចម្រាញ់ ដែលប្រដាប់ប្រដាស្រស់ស្អាត
ប្រកបដោយការប្រកាសដោយការងារនៃមាស ដ៏ត្រចះត្រចង់ដោយប្រការ ។

សុវណ្ណចន្ទេត្ថ ពហូ និបាតិតា
ហត្ថី គវស្សា កិម្បុរិសព្យគ្ឃទីបិយោ
បដេយ្យកា សព្វមយេត្ថ បក្ខិនោ
មិគេត្ថ វេឡុរិយមយា យុធាយុតា ៗ
អស្សរាជហរិយោ អយោជយុំ
ទសសតានិ សុសុនាគសាទិសេ
អលង្កតេ កញ្ចនជាលុរច្ឆទេ
អាវេឡិនេ សទ្ទគមេ អសង្គិតេ ៗ
តំ យានសេដ្ឋំ អភិរុយ្ហ មាតលិ
ទស ទិសា ឥមា អភិនាទយិត្ថ
នភញ្ច សេលញ្ច វនប្បតិញ្ច
សសាគរំ បកម្បយិត្ថ មេទនិំ ៗ
ស ខិប្បមេវ ឧបគម្ម អស្សមំ
បាវារមេកំសកតោ កតញ្ជលី
ពហុស្សុតំ វុទ្ធំ វិនីតវន្តំ
ឥច្ចព្រវិ មាតលិ ទេវព្រាហ្មណំ ៗ



ក្នុងរថនុ៎ះ មានរូបព្រះចន្ទជាវិការៈនៃមាស របស់គោ សេះ កិន្នរ ខ្លាធំ ខ្លា
ដំរីរាយជាច្រើនក្នុងរថនោះ មានរូបបក្សីជាវិការៈនៃកែវផ្សេង ៗ
ក្នុងរថនោះ មានទាំងស្បែកម្រឹគប្រុសប្រដាប់ដោយហ្វូងជាវិការៈនៃកែវពិទូរ្យ
ក្នុងរថនោះ ៗ គូគោទាំងបួនទឹមនូវស្តេចសេះ មានសម្បុរលឿង
មួយពាន់ក្នុងរថនោះ ជាសេះមានសម្បុរដូចមាស ប្រហែលនឹងជ័រ
ស្វា ប្រដាប់ដោយគ្រឿងអលង្ការ មានគ្រឿងប្រដាប់ខ្លួនជាវិការៈ
នៃបណ្តាញមាស មានគ្រឿងប្រដាប់ពាក់ត្រចៀក ស្អាតដោយ
គ្រាន់តែឮសម្លេង ជាសេះមានសន្ទុះលឿន ៗ មាតលីទេវបុត្ត
បានឡើងជិះរថនោះ ជាយានដ៏ប្រសើរ ហើយញ៉ាំងទិសទាំង ១០
នេះ ឲ្យគឹកកងទាំងញ៉ាំងអាកាស ភ្នំ ឈើ ព្រមព្រៃ សាគរនឹង
ផែនដីឲ្យរំភើបញាប់ញ័រ ៗ មាតលីទេវបុត្តនោះ ចូលទៅកាន់
អាស្រមជាឆាប់ បានាំសំពត់ទិព្វជាស្រេច រួច[illegible]ពោល
ទៅនឹងកោសិយតាបស ជាទេវព្រាហ្មណ៍ ដែលជាពហុស្សូត
ជាអ្នកចំរើនដោយគុណ មានគាថាយ៉ាងនេះហើយ ដូច្នេះថា

ឥន្ទស្ស ភត្តុំ បំសភមេហំ កោសិយ
ទូតោ អហំ បុច្ឆតិ តំ បុរិន្ទទោ
អាសាយ សទ្ធាយ សិរិយា ច កោសិយ
ហិរី សុធំ កេនមលត្ថ ហេតុនា ។

(៦៩០) អន្ធា សិរី មំ បដិភាតិ មាតលិ
សទ្ធា អនិច្ចា បន ទេវសារថិ
អាសា វិសំវាទិកសម្មតា ហិ មេ
ហិរី ច អរិយម្ហិ គុណេ បតិដ្ឋិតា ។

(៦៩១) កុមារិយោ យាចិមា គោត្តរក្ខិតា
ជិណ្ណា ច យា ច សភត្តុវត្តិយោ
តា ឆន្ទរាគំ បុរិសេសុ ឧគ្គតំ
ហិរិយា និវារេន្តិ សចិត្តមត្តនោ ។
សង្គាមសីសេ សរសត្តិសំយុតេ
បរាជិតានំ បតតំ បលាយិនំ
ហិរិយា និវត្តន្តិ ជហិត្វាន ជីវិតំ
តេ សម្បដិច្ឆន្តិ បុន ហិរីមនា ។
វេលា យថា សាគរវេគវារិណី
អយំ ហិរី បាបជនំ និវារិណី



បពិត្រកោសិយៈ សូមលោកស្ដាប់ពាក្យព្រះឥន្ទ្រ ខ្ញុំឯងជាទូតព្រះឥន្ទ្រ សូមសួរលោកថា បពិត្រកោសិយៈ ព្រោះនាងហិរីវៀរតែពីនាងអាសា នាងសទ្ធា នឹងនាងសិរី ហើយបានទទួលសុធាភោជនដោយហេតុអ្វី ។

(៦៩០) (កោសិយៈ...) ម្នាលមាតលិ ជាទេវសារថី នាងសិរីប្រាកដច្បាស់ដល់អាត្មា ថាជាស្ត្រីស្អុកស្អុសស្រអាប់ហើយ ចំណែកនាងសទ្ធា ប្រាកដដល់អាត្មា ថាជាស្ត្រីមិនទៀង នាងអាសា ក៏ប្រាកដដល់អាត្មា ថាជាស្ត្រីដែលលោកសន្មត ថាជាស្រីបោកប្រាស់ ឯនាងហិរី តាំងនៅស៊ប់ក្នុងគុណដ៏ប្រសើរ ។

(៦៩១) ពួកនាងកុមារីណា ដែលត្រកូលរក្សា ហើយក្ដី ពួកស្ត្រីចាស់ៗ (ស្ត្រីមេម៉ាយ) ណាក្ដី ពួកស្ត្រីណា ដែលមានប្ដីក្ដី ស្ត្រីទាំងនោះ ( ដ៏ខ្ពស់ ) នូវឆន្ទរាគៈដែលកើតឡើង ក្នុងពួកបុរស ហើយរក្សានូវចិត្តរបស់ខ្លួនដោយហិរី ។ កាលជនទាំងឡាយបរាជ័យក្នុងប្រធាននៃសង្គ្រាម ដែលប្រកបដោយព្រួញ និងលំពែង ស្ទុះរត់ទៅ ជនទាំងនោះ បានលះបង់នូវជីវិត ក៏ត្រឡប់វិលវិញដោយហិរី មានចិត្តប្រកបដោយហិរី ទទួលយក(ម្ចាស់)វិញ ។ ច្រាំងជាគ្រឿងឃាត់នូវកំលាំង នៃរលកទឹក ក្នុងសមុទ្រយ៉ាងណា ហិរីនេះ ក៏ឃាត់នូវជនពាលបាប យ៉ាងនោះដែរ

តំ សព្វលោកេ ហិតមត្ថយុត្តំ
ឥន្ទស្ស តំ វេទយ ទេវសារថិ ។

(៤៩២) កោ តេ ឥមំ កោសិយ ទិដ្ឋិមោទហិ
ព្រហ្មា មហិន្ទោ អថវា បជាបតិ
ហីនាយ ទេវេសុបិ សេដ្ឋសម្មតា
ឥតា មហិន្ទស្ស មហេសិ ជាយថ ។

(៤៩៣) ហន្ទហិនាម តិតិរំ អបក្កម
រថំ សមារុយ្ហ មមាយិតំ ឥទំ
អញ្ញោ ច តំ ឥន្ទសលោកា កាម្ហិតំ
អញ្ញេវ តុំ ឥន្ទសហព្យតំ វជ ។

(៤៩៤) យំ រំ វិសុទ្ធិ អតាបកម្មិនោ
អតោ សុចិណ្ណស្ស ផលំ ឆ ចស្សតិ
យេកេចិ អត្តាំ សុជាកោជំ
សព្វេវ តេ ឥន្ទសហាព្យតំ គតាតិ ។

(៤៩៥) ហិរី ទុព្បលវណ្ណាសិ កោសិយោ ជានបតិកិច្ច
អក្ខរេញ្ញា បត្តាសិតោ អានព្ភោ អសិ មាតលិ
សុរិយោ កាសប្បតោ កិច្ច មោគល្លានោសិ ចន្ទិមា



ម្នាលទេវសារថី ព្រោះហេតុនោះ អ្នកចូរក្រាបទូលព្រះឥន្ទ្រថា
ហិរីនោះ ក្រៅអំពីយើង ប្រាថ្នាហើយ គឺលោកតាំងក្នុង ។

(៤៩២) (មាតលីទេវបុត្ត...) បពិត្រកោសិយៈ បុគ្គលណាជាព្រហ្ម
ឬព្រះឥន្ទ្រ ឬបជាបតិ ប្រកាន់អារម្មណ៍យល់របស់លោកនេះ
ថា នីតារបស់ព្រះឥន្ទ្រ ជាស្រីស្មើនឹងកន្លងគុណធំប្រសើរ ដែល
ទេវតាទាំងឡាយសន្មតថាជាស្រីប្រសើរបំផុតក្នុងពួកទេវតា ព្រោះតែហិរី ។

(៤៩៣) បើដូច្នោះ ទេវធីតានេះ សូមលោកយក សូមលោកទៅកាន់
ឋានត្រៃត្រិង្ស សូមលោកឡើងរថ ដែលជាទីគាប់ចិត្តនេះ
បពិត្រលោកអ្នកមានតេជះស្មើដោយព្រះឥន្ទ្រ ព្រះឥន្ទ្រទ្រង់នឹង
ពេញចិត្ត សូមលោកទៅនៅរួមជាមួយនឹងព្រះឥន្ទ្រក្នុងទីនោះ ។

(៤៩៤) (អកិត្តិតាបស) ពួកសត្វអ្នកមិនធ្វើអំពើបាប រមែង
បរិសុទ្ធយ៉ាងនេះ មួយទៀត ផលនៃកុសល ដែលបុគ្គលបាន
សន្សំល្អហើយ រមែងមិនសាបសូន្យទេ ពួកសត្វណាមួយ បាន
ឃើញនូវសុតសោមជន (ក្នុងកាលនោះ) សត្វទាំងអស់នោះឯង
រមែងដល់នូវការនៅរួមជាមួយនឹងព្រះឥន្ទ្រ ។

(៤៩៥) នាងហិរីទេវធីតា គឺនាងឧប្បលវណ្ណាភិក្ខុនី កោសិយតាបសគឺ
កិច្ចជាម្ចាស់ទាន បញ្ចសិខទេវបុត្ត គឺអនុរុទ្ធភិក្ខុ មាតលីទេវបុត្ត
គឺអានន្ទ សុរិយទេវបុត្ត គឺកស្សបភិក្ខុ ចន្ទទេវបុត្ត គឺមោគ្គល្លាន

ជាតកោ សារីបុត្តោសិ   សម្ពុទ្ធោ អសិ ភិក្ខវេតិ ។

សុត្តកោសជាតកំ តតិយំ ។

# កុណាលជាតកំ

(៤៨២) ឯវមក្ខាយតិ ឯវមនុស្សុយ្យតិ សព្វោស-ធធរណីតលេ នានាបុប្ផមាលវិតតេ គជគវយមហឹ-សរុរុចាមរបសភខគ្គគោកណ្ណសីហព្យគ្ឃទីបិអច្ឆកោកត-រច្ឆឧទ្ទារកទលិមិគពិឡារសសកណ្ណិកានុចរិតេ អា-កិណ្ណនេលកសណ្ឌមហាវរាហនាគកុលករេណុ-សង្ឃាធិវុត្ថេ ឥស្សមិគសាខមិគសរភមិគឯណីមិគ-វាតមិគបសទមិគបុរិសាលុកិម្បុរិសយក្ខរក្ខសនិសេវិតេ អមជ្ជវមញ្ជរីធរបហដ្ឋបុប្ផផុសិតគ្គានេកបាទបគណវិ-តតេ កុររចកោរវារណមយូរបរភុតជីវញ្ជីវកចេលា-វកភិង្ការករវីកមត្តវិហង្គគណសតតសម្បឃុដ្ឋេ អញ្ជន-



ជាតកនោះ គឺសារីបុត្ត ឯព្រះពុទ្ធនោះគឺតថាគត ជាព្រះសម្ពុទ្ធ ។

ចប់ សុត្តកោសជាតក ទី ៣ ។

# កុណាលជាតក

(៤៨២) តាមដំណើរប្រវត្តិ ដែលគេតែងនិយាយហើយនោះ ដែលឮហើយនោះ មានសេចក្តីដំណាលថា បក្សីកុណាល (តាវ៉) មានសម្បុរដ៏វិចិត្រក្រៃលែង មានស្លាបជាគ្រឿងប្រទាប់ដ៏វិចិត្រក្រៃលែង តែងទៅកាន់ព្រៃហិមវន្តដ៏ត្រជាក់ទីកែកាយ មានសេចក្តីយ៉ាងនេះ ជាប្រទេសប្រទេសដ៏ខ្ពង់ខ្ពស់ណា ប្រកបដោយឱសថ គ្រប់យ៉ាង រាយរាប់ដោយបុប្ផជាតិដ៏ច្រើន ជាប្រទេសដាំវល្លិតៗមកហើយ ។ ដែលដំរី គោ ក្របីស្ទើរសាស តោស៊ី ក្តាន់ ទោស រមាំង ស៊ីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លៃព្រៃ ខ្លារខិន កែ ឈ្លូស ខ្លាត្រី ទន្សាយ ទោន្ស ជាទីកាន់ព្រៃយារទៅនៃហ្វូងដំរីធំ ៗ ដំរីញី និងរមាំងកើតមានច្រើនក្រុង ដំរីជាពាស ជាទីកាន់ព្រៃយានៅនៃខ្លាឃ្មុំ ស្វាសោខៈ ម្រឹគព្រាយ ក្តាន់ប៉ុរិសាទ (យក្ខិនីមានមុខដូចសេះ) កិន្នរ យក្ស រាក្សស ដាំព្រៃដ៏ដេរដាសដោយពួកឈើជាច្រើនយ៉ាង គឺឈើមានផ្កាក្រពុំ ឈើមានត្រួយលាស់ទៅទាំងសំដីសំឡេងរាយដោយហ្វូងបក្សីជាច្រើន គឺសត្វអក លលកព្រៃ ហក្ខលិង្គ ក្ងោក ទំនុយ ទោណេសាក តាប កុកព្រៃ សម្បុកត្រចៀក គវៀក

នោសិលាហរិតាលហិង្គុលកហេមរជតកនកានេក-
ធាតុសតវិនទ្ធបដិមណ្ឌិតប្បទេសេ ឯវរូបេ ខលុ
ភោ រម្មេ វនសណ្ឌេ កុណាលោ នាម សកុណោ
បដិវសតិ អតិវិយ ចិត្តោ អតិវិយ ចិត្តបត្តច្ឆទនោ ។
តស្សេវ ខលុ ភោ កុណាលស្ស សកុណស្ស អឌ្ឍុ-
ឌ្ឍានិ ឥត្ថីសហស្សានិ បរិចារិកា ទិជកញ្ញាយោ ។
អថ ខលុ ភោ ទ្វេ ទិជកញ្ញាយោ កដ្ឋំ មុខេន
ឌំសិត្វា តំ កុណាលំ សកុណំ មជ្ឈេ និសីទាបេត្វា
ឧឌ្ឌេន្តិ មា នំ កុណាលំ សកុណំ អទ្ធានបរិយាយបថេ
កិលមថោ ឧព្ពាហេថាតិ ។ បញ្ញាស ទិជកញ្ញាយោ
ហេដ្ឋតោ ហេដ្ឋតោ ឧឌ្ឌេន្តិ សចាយំ កុណាលោ សកុ-
ណោ អាសនា បរិបតិស្សតិ មយំ តំ បក្ខេហិ បដិគ្គ-
ហេស្សាមាតិ ។ បញ្ញាស ទិជកញ្ញាយោ ឧបរូបរិ ឧឌ្ឌេន្តិ
មា នំ កុណាលំ សកុណំ អាតបោ បរិតាបេសីតិ ។
បញ្ញាស បញ្ញាស ទិជកញ្ញាយោ ឧភតោ បស្សេន
ឧឌ្ឌេន្តិ មា នំ កុណាលំ សកុណំ សីតំ វា ឧណ្ហំ វា
តិណំ វា រជោ វា វាតោ វា ឧស្សាវោ វា ឧបប្ផុសីតិ ។



ជាប្រទេសដ៏ប្រដាប់ដោយវត្ថុ ជាទីកើតរ៉ែច្រើនយ៉ាង គឺថ្មមនោសិលា
មានពណ៌ខៀវ ដូចផ្កាអញ្ចាញ ជាហិង្គុល មាស ប្រាក់ មាសស្រួយ
និងលោហធាតុជាច្រើនយ៉ាង ។ បក្សីតាកើរនោះឯង មានបក្សីញីចំនួន
៣.៥០០ សុទ្ធតែបក្សីដែលជាបរិវារ ។ មានសេចក្តីដំណាលថា គ្រានោះ
បក្សីញីទាំងពីរ ពាំមែកឈើ ដោយចំពុះ ឲ្យបក្សីតាកើរឈ្មោលនោះ
ទំនៅកណ្តាលមែកឈើ ហើយហើរទៅដោយគិតថា សូមកុំឲ្យមានសេចក្តី
លំបាកក្នុងផ្លូវឆ្ងាយ បៀតបៀនបក្សីតាកើរឈ្មោលនោះឡើយ ។ ពួក
បក្សីកញ្ញាចំនួន ៥០ ក៏ហើរពីខាងក្រោមៗ ដោយគិតថា បើបក្សីតាកើរ
នេះធ្លាក់ពីបល្ល័ង្ក យើងនឹងទទួលបក្សីតាកើរឈ្មោលនោះដោយស្លាបទាំងឡាយ ។
ពួកបក្សីកញ្ញាចំនួន ៥០ ហើរពីខាងលើៗ ដោយគិតថា សូមកុំឲ្យ
កំដៅក្តៅដល់បក្សីតាកើរឈ្មោលនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ៗ
នាក់ៗ ហើរតាមពីខាងទាំងពីរ ដោយគិតថា សូមកុំឲ្យត្រជាក់ ក្តៅ
ស្មៅ ធូលី ខ្យល់ ឬទឹកសន្សើមប៉ះពាល់ត្រូវបក្សីតាកើរឈ្មោលនោះឡើយ ។

បញ្ចសតា ទិជកញ្ញាយោ បុរតោ បុរតោ ធេន្តិ មា នំ កុណាលំ សកុណំ គោបាលកា វា បសុបាលកា វា តិណហារកា វា កដ្ឋហារកា វា វនកម្មិកា វា កដ្ឋេន វា កឋលាយ វា បាណិនា វា (បាសាណេន) វា លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា សក្ខរាហិ វា បហារំ អទំសុ មាយំ កុណាលោ សកុណោ គច្ឆេហិ វា លតាហិ វា រុក្ខេហិ វា សាខាហិ វា ថម្ភេហិ វា បាសាណេហិ វា ពលវន្តេហិ វា បក្ខីហិ សង្គាមេសីតិ ។ បញ្ចសតា ទិជកញ្ញាយោ បច្ឆតោ បច្ឆតោ ធេន្តិ សណ្ហាហិ សខិលាហិ មញ្ជូហិ មធុរាហិ វាចាហិ សមុទាចរន្តិយោ មាយំ កុណាលោ សកុណោ អាសនេ បរិយុក្កណ្ឋីតិ ។ បញ្ចសតា ទិជកញ្ញាយោ ឧភតោបស្សំ ធេន្តិ អនេក-រុក្ខវិដបិកផលមាហារន្តិយោ មាយំ កុណាលោ សកុណោ ខុទ្ទាយ បរិកិលមិត្ថាតិ ។ អថ ខលុ តា តា ទិជកញ្ញាយោ តំ កុណាលំ សកុណំ អារា-មេន អារាមំ ឧយ្យានេន ឧយ្យានំ នទីតិត្ថេន នទីតិត្ថំ បព្វតសិខរេន បព្វតសិខរំ អម្ពវនេន អម្ពវនំ ជម្ពុវនេន ជម្ពុវនំ លពុជវនេន លពុជវនំ



ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅអំពីខាងមុខ ៗ ដោយគិតថា សូមកុំឲ្យគង្វាលគោ គង្វាលសត្វចិញ្ចឹម អ្នកនាំស្មៅ អ្នកនាំឧស អ្នកធ្វើការក្នុងព្រៃ ប្រហារនូវបក្សីកុណាលនោះ ដោយកំណាត់ឈើ ដោយអំបែង ដោយដៃ (ដោយដុំថ្ម) ដោយដុំដី ដោយដំបង ដោយសស្ត្រាវុធ ឬដោយដុំក្រួសទាំងឡាយឡើយ សូមកុំឲ្យបក្សីកុណាលនោះ ប៉ះទង្គិចនឹងគុម្ពឈើ វល្លិ ដើមឈើ មែកឈើ សសរ ថ្ម ឬពួកបក្សីមានកម្លាំងឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរមកអំពីខាងក្រោយ ៗ និយាយទន់ភ្លន់ ដោយពាក្យស្រទន់ផ្អែមពីរោះផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យបក្សីកុណាលនោះ អផ្សុកនៅលើអាសនៈឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅគ្រប់ចំហៀង នាំយកផ្លែឈើផ្សេង ៗ ពីព្រៃជាច្រើនដោយគិតថា សូមកុំឲ្យបក្សីកុណាលនោះ លំបាកដោយការស្រេកឃ្លានឡើយ ។ គ្រានោះ ពួកបក្សីកញ្ញាទាំងនោះ ហើរនាំបក្សីកុណាលនោះអំពីសួនច្បារទៅកាន់សួនច្បារ អំពីឧទ្យាន ទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹងទៅកាន់កំពង់ស្ទឹង អំពីកំពូលភ្នំទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយទៅកាន់ព្រៃស្វាយ អំពីព្រៃព្រីងទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្លទៅកាន់ព្រៃខ្នុរសម្ល

នាឡិកេរសញ្ចារិយេនេវ នាឡិកេរសញ្ចារិយំ ខិប្បមេវ អភិសម្ភោន្តិ រតត្ថាយ ។ អថ ខលុ ភោ កុណាលោ សកុណោ តាហិ ទិជកញ្ញាហិ ទិវសំ បរិព្យូឡ្ហោ ឯវំ អបសាទេតិ នស្សថ តុម្ហេ វសលិយោ វិនស្សថ តុម្ហេ វសលិយោ ចោរិយោ ធុត្តិយោ អសតិយោ លហុចិត្តាយោ កតស្ស អប្បដិការិកាយោ អនិលោ វិយ យេនកាមង្គមាយោតិ ។

(៤៨៧) តស្សេវ ខលុ ភោ ហិមវតោ បព្វតរាជស្ស បុរត្ថិមេ ទិសាភាគេ សុសុខុមសុនិបុណាគិរិប្បភវា ហរិតុបយន្តិយោ ។ ឧប្បលបទុមកុមុទនឡិនសតបត្តសោគន្ធិកមន្ទាលកសម្បតិតិរុចិគន្ធមនុញ្ញមាវកប្បទេសេ កុរវកមុចលិន្ទកេតកវេទិសវញ្ជុលបុន្នាគពកុលតិលកបិយកហសនសាលសឡលចម្បកអសោកនាគរុក្ខតិរីដិភុជបលាសលោទ្ទចន្ទនោឃវនេ កាឡាគរុបទុមបិយង្គុទេវទារុកចោចគហនេ



ពីកៀនព្រៃដូងទៅកាន់ព្រៃដូង ដើម្បីសេចក្តីសប្បាយរីករាយ រហ័សទាន់ហើយ ។ គ្រានោះឯង បក្សីកុណាលនោះ ដែលពួកបក្សីកញ្ញាចាំរោមរោមហើយ ពេញមួយថ្ងៃ ក៏បណ្តេញយ៉ាងនេះថា នែមេចង្រៃ ហានឯងទាំងឡាយ ចូរវិនាសទៅ នែមេចង្រៃ ជាចោរ ជាស្រីអ្នកលេង ជាមនុស្សពាល មានចិត្តស្រាល មិនធ្វើតបចំពោះឧបការគុណដែលគេធ្វើហើយ ជាអ្នកហើរទៅ តាមតែដូចជាខ្យល់ ហានឯងទាំងឡាយ ចូរវិនាសទៅ ។

(៤៨៧) មានសេចក្តីដំណាលថា ក្នុងភាគទិសខាងកើត នៃស្តេចភ្នំហិមវន្តនោះឯង មានស្ទឹងហូរនាំយកទឹកហូរចុះមកពីភ្នំ ដ៏ល្អិតដែលមានទឹកដ៏ល្អសុខុមល្អិតល្អន់ៗ មានសេចក្តីដំណាលថា ភាគ-សាឈ្មោះបុណ្ឌមុខៈ មានសម្បុរដ៏ពីរោះក្រអូប មានផ្កាក្រៀវខ្យង ផ្កាផ្កាឈូកស្រាវីង កើតក្រវ៉ាលទៅក្នុងដងព្រៃ ជាទីសប្បាយរីករាយ មានសត្វគយ៉ាន់ឈ្មោះ គឺប្រទេសជាទីពេញចិត្តរីករាយ ដោយផ្កាឧប្បល ឈូកក្រហម កុមុទ ឈូកសឈូកខាងស្រអាប់ជាច្រើន ចន្ទ្រប្បល័យមានក្លិនក្រអូបល្អឈ្ងុយ ហើយនឹងផុះឡើងដើមជាព្រៃដោយផ្កាសសៈ ដោយក្រវែលព្រឹក្សព័ន្ធនឹងដើមព្រឹក្សរវៀស-ព្រឹក្ស ដើមព្រៃ ដើមបុន្នាគ ពកុល ទ្រមូង ទ្រមូង ក្រម ចន្ទក្រឹត ស្រឡៅ ចម្បក អសោកព្រឹក្ស ខ្វឹត ស្នាច់ លោទ្ធ និងចន្ទន៍ក្រហមជាព្រៃញាតស្បាត ដោយដើមឈើខ្មៅ ប៉ិយង្គុ មានគណ៍ក្រហម ទេវទារុ ចេកតាន់ -

កាកុធកុដជអង្កោលកច្ឆិការណិការកណ្ណិការកោ-
រណ្ឌកកោវិឡារកឹសុកយោធិការវនមល្លិកមនង្គណអន-
វជ្ជភណ្ឌិសុរុចិរគិរិមាលមល្លិកេ ជាតិសុមនមធុគន្ធិ-
កចទុមញ្ញាវិតាលិសមកតរខុរសីរកោរណ្ឌកគុជ្ជវិតតេ អនិ-
មុត្តិកសអតសុមិកលកាវេឡុបនមណ្ឌិតបព្ពតេសេ ហំ-
សបិលវកោចនម្ពកាកណ្ណាកិកាមិតេ វិជ្ជារសិន្ទុសម-
ណាតាបសតណាទិវុត្ថេ ធរណេធរយុគន្ធរសាធរវេលន្ធ-
កាន្ទរមហោធកានុចិណ្ណបព្ពតេសេ បតិវសតិ កុណាលោ រម្ម-
វេសល្លោ បុណ្ណមុខោ នាម ផុស្សកោកិលោ បដិវសតិ
អតិវិយ មធុរគិរោ វិលាសិតនយនមត្តក្ខោ ។ តស្សេវ
កុណាលោ បុណ្ណមុខស្ស ផុស្សកោកិលស្ស អឌ្ឍតេយ្យេហិ
វគ្គុសតានិ បរិចារិកា ទិជកញ្ញាយោ ។ អថ កុណាលោ
ទ្វេ ទិជកញ្ញាយោ កដ្ឋំ មុខេន ឌំសិត្វា តំ បុណ្ណមុខំ
ផុស្សកោកិលំ មជ្ឈេ និសីទាបេត្វា ឧឌ្ឌេន្តិ មា នំ បុណ្ណ-
មុខំ ផុស្សកោកិលំ អទ្ធានបរិយាយបថេ កិលមថោ
ឧព្ពាហេថាតិ ។ បញ្ញាស ទិជកញ្ញាយោ ហេដ្ឋតោ ហេដ្ឋ-
តោ ឧឌ្ឌេន្តិ សចាយំ បុណ្ណមុខោ ផុស្សកោកិលោ អាស-
នាប រិបតិស្សតិ មយំ តំ បក្ខេហិ បដិគ្គហេស្សាមាតិ ។



ជាព្រៃប្រទាំង ខ្ទៅដើមចាម វល្លិកន់ ព្រលស រំដេង កណ្ណិការ
ដើមច្បា ដើមប្រហោយដី ដើមល្ហុសម្ពុង ដើមតាវ ដើមយុគ្គុ
ទំនប់ក្លិមផ្កាម្លិះព្រៃ ក្លាំងភ្នំ ចម្បា ចម្បី ខ្ទុំស្រី ជាព្រៃដ៏ស្រស់
ដោយម្លិះរួត សេកសេស ប្រទៀង ដើមព្រាំង ក្រសា ស្នាំង និងកុម្ភ
ឈើជាច្រើន ។ ជាប្រទេស ដ៏ប្រដាប់ដោយដើមឈើដ៏ស្រស់ គឺដើម
វល្លិ៍ដែលនៅល្អមានផ្កាដ៏ល្អ ជាព្រៃក្នុងលោកប្រាសាទសត្វ ហង្ស ទុង ប្រវឹក
ក្លែកនិក ជាទីដែលពួកទេវតាសមណៈ និងតាបសទាំងឡាយ ស័ក្ដិសិទ្ធនៅ
អាស្រ័យ ជាប្រទេសដែលនៅមាន ទេវតា យក្ស តាកៀនគន្ធ ធំសុះ គន្ធព្វ
និងគន្ធាអាស្រ័យនៅជាច្រើន ។ មានសេចក្ដីដំណាលថា សត្វតាវ៉ៅស
ឈ្មោះបុណ្ណមុខៈនោះឯង មានបក្សីញីចំនួន ៣៥០ ជាគូបម្រើ ។
មានសេចក្ដីដំណាលថា ក្រោកនោះឯង មានបក្សីញីពីរ ពាំចុងឈើ
ដោយមាត់ ហើយឲ្យសត្វតាវ៉ៅស ឈ្មោះបុណ្ណមុខៈនោះទំត្រង់កណ្ដាល
ហើយហើរទៅដោយគិតថា កុំឲ្យមានសេចក្ដីលំបាកក្នុងផ្លូវឆ្ងាយ បំពាល់តា-
វ៉ៅសឈ្មោះបុណ្ណមុខៈនោះឡើយ ។ ពួកបក្សីញីចំនួន ៥០ ក៏ហើរ
ពីខាងក្រោម ។ ដោយគិតថា បើតាវ៉ៅសឈ្មោះបុណ្ណមុខៈនេះ នឹងធ្លាក់
អំពីបន្ទីង ពួកយើងនឹងទទួលតាវ៉ៅសនោះ ដោយស្លាបទាំងឡាយ ។

បញ្ចាសទិជកញ្ញាយោ ឧបរូបរិ ឌេន្តិ មា នំ បុណ្ណមុខំ ផុស្ស-
កោកិលំ អាតបោ បរិឡាហេសីតិ ។ បញ្ចាស បញ្ចាស
ទិជកញ្ញាយោ ឧភតោ បស្សេន ឌេន្តិ មា នំ បុណ្ណមុខំ
ផុស្សកោកិលំ សីតំ វា ឧណ្ហំ វា តិណំ វា រជោ វា វាតោ
វា ឧស្សាវោ វា ឧបប្ផុសីតិ ។ បញ្ចាស ទិជកញ្ញាយោ
បុរតោ បុរតោ ឌេន្តិ មា នំ បុណ្ណមុខំ ផុស្សកោកិលំ
គោបាលកា វា បសុបាលកា វា តិណហារកា វា កដ្ឋ-
ហារកា វា វនកម្មិកា វា កដ្ឋេន វា កឋលាយ វា បាណិនា
វា (ធាសាលេណ្ឌនា) លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា
សក្ខរាហិ វា បហារំ អទំសុ មា យំ បុណ្ណមុខោ ផុស្សកោ-
កិលោ គច្ឆេហិ វា រុក្ខេហិ វា លតាហិ វា សាខាហិ វា
ថម្ភេហិ វា បាសាណេហិ វា ពលវន្តេហិ វា បក្ខីហិ សង្គ-
មេសីតិ ។ បញ្ចាស ទិជកញ្ញាយោ បច្ឆតោ បច្ឆតោ ឌេន្តិ
សណ្ហាហិ សខិលាហិ មញ្ជូហិ មធុរាហិ វាចាហិ សមុ-
ទាចរន្តិយោ មា យំ បុណ្ណមុខោ ផុស្សកោកិលោ អស-
ហេ បរិយុក្កណ្ឋីតិ ។ បញ្ចាស ទិជកញ្ញាយោ ទិសោទិ-
សំ ឌេន្តិ អនេករុក្ខវិវិធវិកតិផលមាហរន្តិយោ មា យំ
បុណ្ណមុខោ ផុស្សកោកិលោ ខុទ្ទាយ បរិកិលមិត្ថាតិ ។



ពួកបក្សីញីចំនួន ៥០ ក៏ហើរមកពីទិសលិច ៗ ដោយគិតថា សូមកុំឲ្យកំ-
ដៅក្តៅដល់ការពើស ឈ្មោះបុណ្ណមុខៈនោះឡើយ ៗ ពួកបក្សីញីចំនួន
៥០ ( ទៀត ) ក៏ហើរមកពីទិសខាងកើត ដោយគិតថា សូមកុំឲ្យ
ត្រជាក់ក្តៅស្មៅធូលី ខ្យល់ ធូលីគលាឡើង ប៉ះពាល់ត្រូវការពើស ឈ្មោះ
បុណ្ណមុខៈនោះឡើយ ៗ ពួកបក្សីញីចំនួន ៥០ ហើរទៅពីទិសខាងមុខ ៗ
ដោយគិតថា សូមកុំឲ្យគង្វាលគោ គង្វាលសត្វចិញ្ចឹម អ្នកនាំស្មៅ អ្នកនាំ
ទឹក អ្នករើសការពើសក្នុងព្រៃ ប្រហារដោយសន្លឹកការពើសឈ្មោះបុណ្ណមុខៈ
នោះ ដោយកំណាត់ឈើ ដោយកម្ទេច ដោយដៃ (ដោយដុំដី) ដោយ
ដុំដី ដោយដំបង ដោយសាស្ត្រា ដោយដុំក្រួសគ្រាប់ខ្សាច់ សូម
កុំឲ្យការពើស ឈ្មោះបុណ្ណមុខៈនេះ ប៉ះទង្គិចនឹងគុម្ពឈើ វល្លិ ដើមឈើ
មែកឈើ សសរ ដុំថ្ម ឬក៏ពួកបក្សីមានកម្លាំងឡើយ ៗ ពួកបក្សីញី
ចំនួន ៥០ ហើរមកពីទិសក្រោយ ៗ និយាយពាក្យទន់ភ្លន់ ដោយពាក្យផ្អែម
ស្រទន់ផ្អែមល្ហែមពីរោះផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យការពើសឈ្មោះ
បុណ្ណមុខៈអផ្សុកក្នុងទីនេះឡើយ ៗ ពួកបក្សីញីចំនួន ៥០ ហើរទៅគ្រប់
ទិស នាំយកផ្លែឈើផ្សេង ៗ ចំពោះគន្លងប្រើប្រាស់ ដោយគិតថា សូមកុំ
ឲ្យការពើសឈ្មោះបុណ្ណមុខៈនេះ លំបាកដោយការស្រេកឃ្លានឡើយ ៗ

អថ ខលុ ភោ តា ទិជកញ្ញាយោ តំ បុណ្ណមុខំ ផុស្សកោកិលំ អាកាសេនេវ អាកាសំ ឧយ្យានេនេវ ឧយ្យានំ នទីតិត្ថេនេវ នទីតិត្ថំ បព្វតសិខរេនេវ បព្វតសិខរំ អម្ពវនេនេវ អម្ពវនំ ជម្ពុវនេនេវ ជម្ពុវនំ លពុជវនេនេវ លពុជវនំ នាឡិកេរសញ្ចារិយេនេវ នាឡិកេរសញ្ចារិយំ ខិប្បមេវ អភិសម្ភោន្តិ រតិត្ថាយ ។ អថ ខលុ ភោ បុណ្ណមុខោ ផុស្សកោកិលោ តាហិ ទិជកញ្ញាហិ ទិវសំ បរិព្យូឡ្ហោ ឯវំ បសំសតិ សាធុ សាធុ ភគិនិយោ ឯតំ ខោ ភគិនិយោ តុម្ហាកំ បតិរូបំ កុលធីតានំ យំ តុម្ហេ ភត្តារំ បរិចរេយ្យាថាតិ ។

(៤៩៨) អថ ខលុ ភោ បុណ្ណមុខោ ផុស្សកោកិលោ យេន កុណាលោ សកុណោ តេនុបសង្កមិ ។ អទ្ទសំសុ ខោ កុណាលស្ស សកុណស្ស បរិចារិកា ទិជកញ្ញាយោ តំ បុណ្ណមុខំ ផុស្សកោកិលំ ទូរតោវ អាគច្ឆន្តំ ទិស្វាន យេន បុណ្ណមុខោ ផុស្សកោកិលោ តេនុបសង្កមឹសុ ឧបសង្កមិត្វា តំ បុណ្ណមុខំ ផុស្សកោកិលំ ឯតទវោចុំ អយំ សម្ម បុណ្ណមុខ កុណាលោ សកុណោ អតិវិយ ផរុសោ អតិវិយ ផរុសវាចោ អប្បេវ នាម តវម្បិ អាគម្ម បិយវាចំ លភេយ្យាមាតិ ។

គ្រានោះ កូនហ្វូងបក្សីកញ្ញាទាំងនោះ ហើរនាំតាវ៉ៅឈ្មោះបុណ្ណមុខៈ អំពីសួនច្បារ ទៅកាន់សួនច្បារ អំពីឧទ្យាន ទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹង ទៅកាន់កំពង់ស្ទឹង អំពីកំពូលភ្នំ ទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយ ទៅកាន់ព្រៃស្វាយ អំពីព្រៃព្រីង ទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្លូ ទៅកាន់ព្រៃខ្នុរសម្លូ អំពីព្រៃដូង ទៅកាន់ព្រៃដូង ដើម្បីសេចក្ដីសប្បាយរីករាយដោយឆាប់ពេក ។ គ្រានោះឯង តាវ៉ៅ ឈ្មោះបុណ្ណមុខៈ ដែលហ្វូងបក្សីកញ្ញាទាំងនោះ ចោមរោមអស់ថ្ងៃមួយ សរសើរយ៉ាងនេះថា ម្នាលនាងទាំងឡាយ ប្រពៃណាស់ ។ នាងទាំងឡាយ បំរើប្ដីដោយហេតុណា ម្នាលនាងទាំងឡាយ ហេតុនោះឯង ជាកិច្ចដ៏សមគួរដល់នាងទាំងឡាយ ជាធីតាកុលត្រកូលហើយ ។

(៤៩៨) គ្រានោះ តាវ៉ៅឈ្មោះបុណ្ណមុខៈ ចូលទៅរកកុណាលសកុណៈ (តាវ៉ៅខ្មៅ) ។ បក្សីកញ្ញាជាអ្នកបំរើកុណាលសកុណៈ បានឃើញតាវ៉ៅឈ្មោះបុណ្ណមុខៈនោះមកពីចម្ងាយ លុះឃើញហើយ នាំចូលទៅរកតាវ៉ៅ ឈ្មោះបុណ្ណមុខៈ លុះចូលទៅដល់ហើយនិយាយពាក្យនេះនឹងតាវ៉ៅ ឈ្មោះបុណ្ណមុខៈនោះថា បពិត្របុណ្ណមុខៈសម្លាញ់ កុណាលសកុណៈនេះ អាក្រក់ក្រៃលែង មានសំដីអាក្រក់ក្រៃលែង គួរយើងសូមពឹងផ្អែកលោក ក្រែងបានពាក្យជាទីស្រឡាញ់ (អំពីកុណាលៈ) ។

អច្ឆេរំ វាម កតិជំ យោតិ វត្វា យេន កុណាលោ សកុណោ តេនុបសង្កមិ ឧបសង្កមិត្វា កុណាលេន សកុណេន សទ្ធឹ បដិសម្មោទិត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បុណ្ណមុខោ បុស្សកោកិលោ តំ កុណាលំ សកុណំ ឯតទវោច កិស្ស ត្វំ សម្ម កុណាល ឥត្ថីនំ សុជាតានំ កុលជាតានំ សម្មាបដិ-បន្នានំ មិច្ឆាបដិបជ្ជោសិ អមនាបភាណីនំបិ កិរ សម្ម កុណាល ឥត្ថីនំ មនាបភាណិនា ភវិតព្វំ កិមង្គំ បន អមនាបភាណីនន្តិ ។ ឯវំ វុត្តេ កុណាលោ សកុណោ តំ បុណ្ណមុខំ បុស្សកោកិលំ ឯវំ អបសាទេសិ ចស្ស ត្វំ សម្ម ជម្ម វសល វិនស្ស ត្វំ សម្ម ជម្ម វសល កោ នុ តយា វិយត្តោ ជាយាជិនេនាតិ ។ ឯវំ អបសាទិតោ ច បន បុណ្ណមុខោ បុស្សកោកិលោ តតោវ បដិនិវត្តិ ។

[៦៤៤] អថ ខលុ ភោ បុណ្ណមុខស្ស បុស្សកោ-កិលស្ស អបរេន សមយេន អចិរស្សេវ អច្ច-យេន ខោ អាពាធោ ឧប្បជ្ជិ ។ លោហិត-បក្ខន្ទិកា ពាឡ្ហា វេទនា វត្តន្តិ មារណន្តិកា ។



ការពើស ទើបខេបង់ ខ្លួនស្រីតាំងឡាយ យ៉ាងនោះឬ ហើយក៏ចូលទៅរកកុណាលសកុណៈ លុះចូលទៅដល់ហើយ ក៏និយាយសំណេះសំណាល ជាមួយនឹងកុណាលសកុណៈ ហើយទុំនៅទីដ៏សមគួរ ។ លុះការពើស ឈ្មោះបុណ្ណមុខៈ ទុំនៅទីដ៏សមគួរហើយ និយាយពាក្យនេះនឹងកុណាលសកុណៈនោះថា នែកុណាលៈសម្លាញ់ ហេតុអ្វី អ្នកប្រតិបត្តិខុសចំពោះនារី ដែលមានជាតិល្អ ជាតិកូនត្រកូល ជាអ្នកប្រតិបត្តិល្អ នែកុណាលៈសម្លាញ់ ឮថា អ្នកគួរនិយាយសំដី ជាទីពេញចិត្ត ទៅកាន់ពួកនារី សូម្បីនិយាយសំដីមិនជាទីគាប់ចិត្ត នឹងគួរនិយាយដល់ពួកនារី ជាសត្វនិយាយសំដីជាទីពេញចិត្ត ។ កាលបើការពើសនិយាយយ៉ាងនេះហើយ កុណាលសកុណៈ ក៏បណ្តេញការពើសឈ្មោះបុណ្ណមុខៈនោះថា នែសំឡាញ់ ជាសត្វអាក្រក់ចង្រៃ អ្នកចូរចៀសចេញ នែសំឡាញ់ជាសត្វអាក្រក់ចង្រៃ អ្នកចូរវិនាសទៅ នរណាឡើយ ជាអ្នកឈ្លាសវៃជាងអ្នក ជាអ្នកចាញ់ស្រី ។ ចំណែកខាងការពើស ឈ្មោះបុណ្ណមុខៈ ត្រូវកុណាលសកុណៈ បណ្តេញយ៉ាងនេះហើយ ក៏ត្រឡប់មកអំពីទីនោះវិញ ។

(៦៤៤) គ្រានោះឯង លុះសម័យតាមក្រោយមក កន្លងទៅមិនយូរប៉ុន្មាន ការពើស ឈ្មោះបុណ្ណមុខៈ មានជម្ងឺ ជាទម្ងន់ ។ ជាលេចធ្លាយយ៉ាងខ្លាំង កើតធ្លាក់ឈាម ទៀបដល់ នូវមរណៈ ។

អថ ខលុ តោ បុណ្ណមុខស្ស បុស្សកោកិលស្ស បាទបរិចារិកា ទិជកញ្ញា ឯកតោ ហោសិ អាពាធិតា ខោ អយំ បុណ្ណមុខោ បុស្សកោកិលោ អប្បេវ នាម ឥមម្ហា អាពាធា វុដ្ឋហេយ្យាតិ ។ តំ ឯកកំ អទុតិយំ ឱហាយ យេន កុណាលោ សកុណោ តេនុបសង្កមិំសុ ។ អទ្ទសា ខោ កុណាលោ សកុណោ តា ទិជកញ្ញាយោ ទូរតោវ អាគច្ឆន្តិយោ ទិស្វាន តា ទិជកញ្ញាយោ ឯតទវោច កហំ បន តុម្ហំ វសលិយោ ភត្តាតិ ។ អាពាធិតោ ខោ សម្ម កុណាល បុណ្ណមុខោ បុស្សកោកិលោ អប្បេវ នាម ឥមម្ហា អាពាធា វុដ្ឋហេយ្យាតិ ។ ឯវំ វុត្តេ កុណាលោ សកុណោ តា ទិជកញ្ញាយោ ឯវំ អបសាទេសិ វិនស្សថ តុម្ហេ វសលិយោ វិនស្សថ តុម្ហេ វសលិយោ ចោរិយោ ធុត្តិយោ អសតិយោ លហុចិត្តាយោ កតស្ស អប្បដិការិកាយោ អនិលោ វិយ យេនកាមង្គមាយោតិ វត្វា យេន បុណ្ណមុខោ បុស្សកោកិលោ តេនុបសង្កមិ ឧបសង្កមិត្វា តំ បុណ្ណមុខំ បុស្សកោកិលំ ឯតទវោច ហំ សម្ម បុណ្ណមុខាតិ ។



គ្រានោះ ពួកបក្សីកញ្ញា ជាអ្នកបម្រើជើងនៃកោកិល ឈ្មោះបុណ្ណមុខៈ មានសេចក្តីត្រិះរិះយ៉ាងនេះថា កោកិល ឈ្មោះបុណ្ណមុខៈនេះ មានជម្ងឺជាទំងន់ ធ្វើដូចម្តេច លោកនឹងបានសះស្បើយ ចាកជម្ងឺនេះ ។ ពួកបក្សីកញ្ញា ក៏បោះបង់កោកិលនោះ ឲ្យនៅតែម្នាក់ឯង មិនឲ្យមានគ្នា ជាគំរប់ពីរ ហើយនាំគ្នាចូលទៅរកកុណាលសកុណៈ ។ កុណាលសកុណៈនោះ បានឃើញពួកបក្សីកញ្ញាទាំងនោះ កំពុងមកពីចម្ងាយ លុះឃើញហើយ និយាយពាក្យនេះ នឹងពួកបក្សីកញ្ញានោះថា នែមេចង្រៃកំផ្លា ចុះប្តីរបស់នាងឯង នៅឯណា ។ ពួកបក្សីកញ្ញាទាំងនោះតបថា បពិត្រកុណាលៈជាម្ចាស់ កោកិលឈ្មោះបុណ្ណមុខៈ មានជម្ងឺជាទំងន់ ធ្វើដូចម្តេច លោកនឹងបានសះស្បើយចាកជម្ងឺនោះ ។ កាលពួកបក្សីកញ្ញាឆ្លើយតបយ៉ាងនេះហើយ កុណាលសកុណៈ តិះដៀលពួកបក្សីកញ្ញាទាំងនោះយ៉ាងនេះថា នែពួកមេចង្រៃ នាងឯងចូរវិនាសចេញទៅ នែមេចង្រៃជាចោរ ជាស្រីអ្នកលេង ពីនះបាប មានចិត្តស្រាល មិនធ្វើតបចំពោះឧបការគុណដែលគេធ្វើហើយ ជាអ្នកទៅតាមក្តីកាម ដូចជាខ្យល់ នាងឯងទាំងឡាយ ចូរវិនាសទៅ លុះពោលដូច្នេះហើយ ក៏ចូលទៅរកកោកិល ឈ្មោះបុណ្ណមុខៈ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះ នឹងកោកិល ឈ្មោះបុណ្ណមុខៈនោះថា នែបុណ្ណមុខៈសំឡាញ់ ម្តេចទៅហើយ

ឃាំ សម្ម កុណាលាតិ ។ អថ ខោ កុណាលោ សកុណោ តំ បុណ្ណមុខំ ផុស្សកោកិលំ បច្ចាហ ច មុខតុណ្ឌកេន ច បរិក្ខិបេត្វា វុដ្ឋាបេត្វា ជាតកេសដ្ឋានំ ជាយាបេសិ ។ អថ ខោ បុណ្ណមុខស្ស ផុស្សកោកិលស្ស សោ អាពាធោ បដិប្បស្សម្ភិ ។

(៣០០) អថ ខោ កុណាលោ សកុណោ តំ បុណ្ណមុខំ ផុស្សកោកិលំ គិលានា វុដ្ឋិតំ អចិរវុដ្ឋិតំ គេលញ្ញា ឯតទវោច ទិដ្ឋា មយា សម្ម បុណ្ណមុខ កណ្ហា ទ្វេបិតិកា បញ្ចបតិកាយ ឆដ្ឋេ បុរិសេ ចិត្តំ បដិពទ្ធន្តិយា យទិទំ គពន្ធេ បីឋសប្បិម្ហិ ។ ភវតិ ច បនុត្តរេត្ថ វាក្យំ

អថជ្ជុនោ នកុលោ ភីមសេនោ
យុធិដ្ឋិលោ សហទេវោ ច រាជា
ឯតេ បតី បញ្ចមតិច្ច នារី
អកាសិ ខុជ្ជវាមនកេន បាបន្តិ ។

ទិដ្ឋា មយា សម្ម បុណ្ណមុខ បញ្ចតបា[១] នាម សមណី

១ ឱ. សព្វតបី នាម ។ ម. សព្វកាមី នាម ។



ការពីសក្ដើយផង កុណាលៈសំឡាញ់ ។ គ្រានោះ កុណាលសកុណៈ ជួយគ្រាប់ការពីស ឈ្មោះបុណ្ណមុខៈនោះ ដោយស្លាបនាំឲ្យយកឯ ដោយចំពុះឯង ឲ្យក្រោកឡើង ហើយឲ្យផឹកថ្នាំវេទ្យ ។ គ្រានោះ ជម្ងឺរបស់ការពីស ឈ្មោះបុណ្ណមុខៈនោះ ក៏ជាសះស្បើយ ។

(៣០០) គ្រានោះ កុណាលសកុណៈ បាននិយាយពាក្យនេះនឹងការពីស ឈ្មោះបុណ្ណមុខៈ ដែលសះស្បើយពាកជម្ងឺ ដែលស្រាកស្រាន្តពាកពាធិខ្លួនជាអកកណី មិនយូរប៉ុន្មានថា ម្នាលបុណ្ណមុខៈសំឡាញ់ កុមារីឈ្មោះនាងកណ្ហា មានបិតាពីរ មានប្តី ៥ នាក់ ជាប់ចិត្តក្នុងបុរសទី ៦ ក្នុងបុរសខ្វិនខម (ដូចត្រឡាចក្នុងកក) គឺខ្ញុំបានឃើញហើយ ។ ពាក្យក្នុងរឿងនោះ មានដូចតទៅនេះ:

ស្ត្រីប្រព្រឹត្តកន្លងប្តីទាំង ៥ នាក់នេះ គឺអជ្ជុនកុមារ ១
នកុលកុមារ ១ ភីមសេនកុមារ ១ យុធិដ្ឋិលកុមារ១
សហទេវកុមារ១ ធ្វើនូវអំពើលាមកនឹង សេពមេថុនធម្ម
ជាមួយបុរសខមតាបតឿ ។

ម្នាលបុណ្ណមុខៈសំឡាញ់ នាងសមណីឈ្មោះបញ្ចតបាវី កាលនៅកណ្ដាលព្រៃ

សុសានមជ្ឈេ វសន្តី ចតុត្ថភត្តំ បរិណាមយមានា សុរ-ធុត្តកេន[១] បាបមកាសិ ។ ទិដ្ឋា មយា សម្ម បុណ្ណមុខ កាកាតី នាម ទេវី សមុទ្ទមជ្ឈេ វសន្តី ភរិយា វេន-តេយ្យស្ស នដកុវេរេន បាបមកាសិ ។ ទិដ្ឋា មយា សម្ម បុណ្ណមុខ កុរុង្គទេវី នាម លោមសុទ្ធរី ឯឡិក-កុមារំ កាមយមានា ឆឡង្គកុមារធនន្តេវាសិនា បាប-មកាសិ ។ ឯវំ ហេតំ មយា ញាតំ ព្រហ្មទត្តស្ស មាតរំ ឱហាយ កោសលរាជំ បញ្ចាលចណ្ឌេន បាបមកាសិ ។

ឯតា ច អញ្ញា ច អកំសុ បាបំ
តស្មាហំ ឥត្ថីនំ ន វិស្សសេ នប្បសំសេ
មហី យថា ជគតិ សមានរត្តា
វសុន្ធរា ឥតរីតរបតិដ្ឋា
សព្វសហា អផន្ទនា អកុប្បា
តថិត្ថិយោ តាយោ ន វិស្សសេ នរោ
សីហោ យថា លោហិតមំសភោជនោ
វាឡមិគោ បញ្ចាវុធោ សុរុទ្ធោ

១ ឧ. សា. គុណាធុត្តកេន ។ ម. សា. សុរាធុត្តកេន ។



ស្មសាន សេពនៈពេលខ្ទុះបាយ ៤ ដង បានធ្វើនូវអំពើលាមកជាមួយនឹងអ្នកលេងសុរា ខ្ញុំបានឃើញហើយ ។ នែបុណ្ណមុខៈសំឡាញ់ នាងទេវីឈ្មោះកាកាតី កាលនៅកណ្ដាលសមុទ្រ ជាភរិយារបស់វេនតេយ្យ បានធ្វើនូវអំពើលាមក ជាមួយនឹងបុរសឈ្មោះនដកុវេរៈ ខ្ញុំក៏បានឃើញហើយ ។ នែបុណ្ណមុខៈសំឡាញ់ ព្រះអគ្គមហេសីមានព្រះលោមល្អ ព្រះនាមកុរុង្គទេវី កាលចង់បានឯឡកកុមារ ធ្វើនូវអំពើលាមកជាមួយនឹងបុរសអ្នកនៅជាមួយទ្រព្យ ( បុរសខ្ញុំគេ ) ឈ្មោះឆឡង្គកុមារ ខ្ញុំក៏បានឃើញហើយ ។ សេចក្ដីនេះ រឿងដូចគ្នានេះ ខ្ញុំដឹងហើយយ៉ាងនេះថា ព្រះមាតារបស់ព្រះបាទព្រហ្មទត្ត លះបង់ព្រះបាទកោសល ទៅធ្វើអំពើលាមកជាមួយនឹងព្រាហ្មណកុមារ ឈ្មោះបញ្ចាលចណ្ឌៈ ។

ពួកស្រីទាំងនុ៎ះក្ដី ពួកស្រីឯទៀតក្ដី បានធ្វើនូវអំពើលាមកព្រោះ
ហេតុនោះ ទើបខ្ញុំមិនទុកចិត្ត មិនសរសើរស្រីទាំងឡាយ ។ ពួក
ស្រីដូចផែនដីជាទីដេកទៅ ជាទីទ្រទ្រង់ មានសេចក្ដីត្រេកអរស្មើជា
ទីតាំងរបស់ទ្រព្យនៃរត្នគ្រប់យ៉ាង អត់ធន់បានគ្រប់អារម្មណ៍ទាំងពួង មិន
ញាប់ញ័រ មិនកម្រើក នរជនមិនគប្បីទុកចិត្តស្រីទាំងនោះទេ
សីហៈជាម្រឹគសាហាវ ជាសត្វស៊ីឈាមនឹងសាច់ មានអាវុធ ៥

បសយ្ហ ទានិ បរិភាសេ ជនោ

ឧជិត្តិយោ តាយោ ច វិស្សជេ ចរេ ។

ឯតា ហិ សម្ម បុណ្ណមុខ ចោរិយោ ចារិយោ កឋិ-
និយោ ចោហតា ពន្ធកិយោ ចាម ទេសិកាយោ ចាម
ឃាតាយោ យតិចំ ចោរិយោ ចារិយោ កឋិនិយោតិ ។
ចោរោ វិយ វញ្ចនិកា មទិរា វិយ វិសទុដ្ឋា កណ្ហាចោ
វិយ វិកត្ថនិយោ ឥស្សសិង្គមិវ បរិវត្តាយោ
ទុរគា ទុជ្ជិវ្ហា យោ សោព្ភមិវ បដិច្ឆន្នា បាតាលមិវ
ទុប្បូរា រក្ខសី វិយ ទុត្តោសា យមោវេកន្តហារិយោ
សិខីរិវ សព្វភក្ខា នទីរិវ សព្វវាហី អនិលោ វិយ
យេនកាមចរា នេរុ វិយ អវិសេសករា វិសរុក្ខោ
វិយ និច្ចផលិតាយោ ។ វុត្តំ ច បនេតំ កិញ្ចិ

យថា ចោរោ យថា ទុដ្ឋោ  កណ្ហាចោវ វិកត្ថនី
ឥស្សសិង្គមិវ បរិវត្តា  ទុជ្ជិវ្ហា ឧរគា យថា ។
សោព្ភមិវ បដិច្ឆន្នា  បាតាលមិវ ទុប្បូរា
រក្ខសី វិយ ទុត្តោសា  យមោវេកន្តហារិយោ ។



សាហាវក្រៃលែង ត្រេកអរត្រឹមការបៀតបៀនសត្វដទៃ ក៏ហៅថា
ស៊ីយ៉ាងណាមិញ ក្អែកស្រីនោះរមែងធ្វើទុក្ខដល់គេ នាងមិន
ត្រូវរកចិត្តឡើយ ។

នែបុណ្ណមុខសំឡាញ់ ស្រីចាំងនឹងឡេះមិនមែនឈ្មោះថា គេសព្វ ជានារី
ជាជាតិកំពក ស្រីចាំងនឹងនុះ មិនមែនត្រាត់តែឈ្មោះថា អ្នកកោសិកាប អ្នក
បរិវុត (នូវបុរស) ទេ ស្រីចាំងនឹងនុះ ក៏ប្រើគេសព្វ នារី ជាទីកំពក ឈ្មោះ
ថា ស្រីសន្ធប់ (ប្តី) ។ ក្អែកស្រីសក្តសក្តាន់ថ្ងន់សក់ ដូចចោរ ដូចគ្រឿង
ស្រវឹងដែលលាយដោយថ្នាំពិស ប៉ិនប៉ាន់ទៅយកបា ដូចតាណាត មាន
អាការប្រែប្រួល ដូចក្អួយមាស មានអណ្តាតពីរដូចពស់ ប៉ិនប៉ាន់ (ខ្លួ
កាយ) ដូចជាតែបិនប៉ាន់ណ្តៅ បំពេញបានដោយក្រដូចសមុទ្រ ត្រេកអរ
បានដោយក្រដូចតាក្សាទឹក នាំទៅដោយជាប់ទាតដូចយមបាល ស៊ីនូវក្តុ
គ្រប់មុខដូចភ្លើង នាំយកនូវក្តុគ្រប់យ៉ាងដូចស្ទឹង ប្រព្រឹត្តរហ័សរហួនដូច
ខ្យល់ ធ្វើនូវក្តុមិនឲ្យប្លែកគ្នាដូចភ្នំមេរុ ថែជានិច្ចដូចឈើមានពិសពុល ។
ពាក្យក្នុងរឿងនេះ មានអាទៅទៀតថា

ក្អែកស្រីមានគល មាយាដូចចោរ មានពិសទាំងដូចស្រាដែលលាយ
ថ្នាំពិស និយាយប៉ិនប៉ាន់តាសដូចតាណាត មានអាការប្រែប្រួលដូច
ក្អួយមាស មានអណ្តាតពីរដូចពស់ ក្អែកស្រីប៉ិនប៉ាន់(នូវកាយ)ដូច
ជាតែប៉ិនប៉ាន់ណ្តៅ បំពេញបានដោយក្រដូចសមុទ្រ ត្រេកអរបាន
ដោយក្រដូចតាក្សាទឹក នាំយកទៅដោយជាប់ទាតដូចយមបាល ។

យថា សាខី ចរី ភីរោ(១) អនិលោ តាយមារកោ
នេវ អភិសេកោ(២) ច វិសុទ្ធោ ធិវុឌ្ឍតី
តាសយន្តិ យមំ កោធំ រេតា ចន្ទការិត្តំ យោតិ ។

(៣០១) ចត្តារិមានិ សម្ម បុណ្ណមុខ ឋានានិ បរកុលេ ន វាសេតព្ពានិ គោណំ ធេនុំ យានំ ភរិយា ចត្តារិ ធនានិ បណ្ឌិតោ ឃរា(៣) យោ ន វិប្បវាសយេ ។

គោណំ ធេនុញ្ច យានញ្ច
ភរិយំ ញាតិកុលេ ន វាសយេ
ភញ្ជន្តិ រថំ អយានកា
អតិវាហេន ហនន្តិ បុង្គវំ
ទោហេន ហនន្តិ វច្ឆកំ
ភរិយា ញាតិកុលេ បទុស្សតីតិ ។

(៣០២) ឆ ឥមានិ សម្ម បុណ្ណមុខ ឋានានិ វត្ថុំ កិច្ចេ ជាតេ អនត្ថចរានិ ភវន្តិ

អគុណំ ធនុ ញាតិកុលេ ច ភរិយា

---

១. ម. ភិតោ ។ ២ ម. នេវ តាវិសមានកា ។ ម. នេវ តាវិសមានកោ ។ ៣ ម. ឯតានិ បណ្ឌិតោ ធនានិ ទំសុន្ធុំ ។



ក្នុងស្រុកដ៏ចាស់ក្ដី នាំយកទៅក្នុងទ្រព្យហើយដល់ស្ម័គ្រ មាននាគការហើយ ពោលពាក្យទាក់ទងខ្សែស់ មិនឲ្យមានប៉ុកដុះចេញបាន ចេះតែជាមិត្ត ដុះលើមានតិះតាល ក្នុងស្រីនេះញ៉ាំងគោ: ក្នុងដូចឡើងនោះ ជ្រើសចន្ទ័ធន្ធកាយខ្លាំងពេកដក់ទៅក្រោយ ។

(៣០១) នែបុណ្ណមុខៈសំឡាញ់ ទ្រព្យណា ដែលបុគ្គល មិនត្រូវឲ្យនៅក្នុងត្រកូលនៃជនដទៃ ទ្រព្យកំនេះ មាន ៤ យ៉ាងគឺ គោឈ្មោល ១ មេគោ ១ យាន ១ ភរិយា ១ បណ្ឌិតមិនត្រូវញ៉ាំងទ្រព្យទាំង ៤ យ៉ាងនេះ ឲ្យនៅប្រាសចាកផ្ទះឡើយ ។

បុគ្គលមិនគប្បីញ៉ាំងគោឈ្មោល ១ មេគោ ១ យាន ១ ភរិយា ១ ឲ្យនៅក្នុងត្រកូលញាតិទេ (ព្រោះថា) ពួកបុគ្គល មិនមានយានៈ រមែងប្រើប្រាស់រទេះ បៀតបៀនគោឈ្មោល ដោយការដឹកនាំហួសកម្លាំង បៀតបៀនមេគោ ដោយការរូតទឹកដោះ ភរិយារមែងប្រព្រឹត្តខូច (ក្បត់ប្ដី) ក្នុងត្រកូលនៃញាតិ ។

(៣០២) នែបុណ្ណមុខៈសំឡាញ់ វត្ថុ ៦ យ៉ាងនេះ រមែងមិនបាន ជាប្រយោជន៍ចំពោះកិច្ចការ ដែលកើតឡើងទេ (វត្ថុ ៦ យ៉ាង) គឺ ធ្នូឥតខ្សែ ១ ភរិយា (ដែលនៅ) ក្នុងត្រកូលញាតិ ១

ឆាវំ រោគំ អក្ខតគត្តញ្ច យោនំ
ទុរេ មិត្តោ ឋាបសហាយកោ ច
កាមេ ជាតេ អនុទ្ទកេ កាមុត្តិតិ។

[១០៣] អដ្ឋហិ ខលុ សម្ម បុណ្ណមុខ ឋានេហិ ឥត្ថី សាមិកំ អវជានាតិ ទលិទ្ទតា អាតុរតា ជិណ្ណកតា សុរាសោណ្ឌតា មុទ្ធតា បមត្តតា សព្វកិច្ចេសុ អនុវត្តនតា សព្វធនអនុប្បទានេន ឥមេហិ ខលុ សម្ម បុណ្ណមុខ អដ្ឋហិ ឋានេហិ ឥត្ថី សាមិកំ អវជានាតិ។ ភវតិ ច បនុត្តរេត្ថ វាក្យំ

ទលិទ្ទំ អាតុរញ្ចាបិ ជិណ្ណកំ សុរសោណ្ឌកំ
បមត្តំ មុទ្ធបត្តញ្ច រត្តំ កិច្ចេសុ ហាបនំ
សព្វកាមប្បទានេន អវជានាតិ សាមិកន្តិ។

[១០៤] នវហិ ខលុ សម្ម បុណ្ណមុខ ឋានេហិ ឥត្ថី បទោសមាហរតិ អារាមគមនសីលា ច ហោតិ ឧយ្យានគមនសីលា ច ហោតិ នទីតិត្ថគមនសីលា ច ហោតិ ញាតិកុលគមនសីលា ច ហោតិ បរកុលគមនសីលា ច ហោតិ អាទាសទុស្សមណ្ឌនានុយោគមនុយុត្តសីលា ច ហោតិ មជ្ជបាយិនី ច ហោតិ



ខ្ញុំការឲ្យនាងស្រីយម្នាក់ ជាមនុស្សកំព្រា មិត្តនៅក្នុងទីឆ្ងាយ សំឡាញ់ ជំលាយក ១ (វាំងនេះ) រមែងមិនមានជាប្រយោជន៍ចំពោះកិច្ចការ ដែលកើតឡើងទេ ។

[១០៣] នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងមើលងាយប្តីដោយហេតុ ៨ យ៉ាងនេះ សេចក្តីកំសត់ក្រ ១ សេចក្តីឈឺចាប់ជាទិច្ច ១ សេចក្តីចាស់គ្រាំគ្រា ១ ភាពជាអ្នកលេងផឹកស្រា ១ ភាពល្ងង់ខ្លៅ ១ សេចក្តីធ្វេសប្រហែស ១ ការមិនប្រព្រឹត្តតាមស្រីរឿយៗ ក្នុងកិច្ចការទាំងពួង ១ ការមិនញ៉ាំងទ្រព្យសម្បត្តិគ្រប់យ៉ាងឲ្យកើតមាន ១ នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងមើលងាយប្តី ដោយហេតុ ៨ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនេះ មានតទៅទៀត

ស្រីមើលងាយប្តី (ដោយហេតុ ៨ យ៉ាង) គឺ ប្តីកំសត់ក្រ ១ ប្តីឈឺជាទិច្ច ប្តីចាស់គ្រាំគ្រា ១ ប្តីជាអ្នកលេងផឹកស្រា ១ ប្តីធ្វេសប្រហែស ១ ប្តីដល់នូវភាពល្ងង់ខ្លៅ ១ ប្តីខ្ជិលច្រអូសក្នុងកិច្ចការ ១ ប្តីញ៉ាំងសេចក្តីត្រូវការក្នុងកិច្ចដែលស្រីត្រូវការគ្រប់យ៉ាងឲ្យវិនាស ១ ។

[១០៤] នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងនាំមកនូវការប្រព្រឹត្តខុស ដោយហេតុ ៩ យ៉ាងគឺ ស្រីទៅកាន់សួនច្បាររឿយៗ ១ ទៅកាន់ឧទ្យានរឿយៗ ១ ទៅកាន់កំពង់ស្ទឹងរឿយៗ ១ ទៅកាន់ត្រកូលញាតិរឿយៗ ១ ទៅកាន់ត្រកូលដទៃរឿយៗ ១ ប្រកបរឿយៗ ក្នុងការស្លៀកពាក់កញ្ចក់ នឹងសំពត់ និងគ្រឿងតែងខ្លួនជាប្រក្រតី ១ ផឹកនូវទឹកស្រវឹងជាប្រក្រតី ១

ធំល្ហោកនសីលា ច ហោតិ បទ្វារដ្ឋាយិនី ច ហោតិ ឥមេហិ ខោ សម្ម បុណ្ណមុខ អដ្ឋហិ ឋានេហិ ឥត្ថិយោ បទោសមាហរន្តីតិ ។ ករិតំ ច បនុត្តរត្ថំ ភាសិ

អាបានគមនសីលា ច ឧយ្យានំ
នទឹ ញាតិបរកុលំ
ទុស្សមណ្ឌនមនុយុត្តា
យា ចិត្តំ មជ្ជបាយិនី
យា ច ធំល្ហោកនសីលា
យា ច បទ្វារដ្ឋាយិនី
ឯតេហិ អដ្ឋហិ ឋានេហិ
បទោសមាហរន្តិ ឥត្ថិយោ ។

[៣០៥] ចត្តាលីសាយ ខលុ សម្ម បុណ្ណមុខ ឋានេហិ ឥត្ថី បុរិសំ អច្ចាវទតិ វិជម្ភតិ វិនមតិ វិលាសតិ វិលជ្ជតិ នខេន នខំ ឃដ្ដេតិ បាទេន បាទំ អក្កមតិ កដ្ឋេន បថវឹ វិលិខតិ ទារកំ ឧល្លង្ឃេតិ ឧល្លង្ឃាបេតិ កីឡតិ កីឡាបេតិ ចុម្ពតិ ចុម្ពាបេតិ ភុញ្ជតិ ភុញ្ជាបេតិ ទទាតិ យាចតិ អាយាចតិ



មានការមើលបុរសមិនដាច់ជាប្រក្រតី ១ ឈរបញ្ចិញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១ នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងនាំមកនូវការខូចខាតដោយហេតុ ៨ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនេះ មានតទៅទៀត

ពួកស្រី ដែលនាំមកនូវការខូច ដោយហេតុ ៨ យ៉ាងគឺ ជាអ្នក
ទៅកាន់ហាងស្រារឿយ ៗ ១ ទៅកាន់ឧទ្យាន ១ ទៅកាន់ស្ទឹង ១
ទៅកាន់ត្រកូលញាតិ ១ ទៅកាន់ត្រកូលដទៃ ១ ប្រកបរឿយ ៗ
ក្នុងការស្លៀកពាក់និងគ្រឿងស្អិតស្អាង ១ ជាស្រីផឹកទឹកស្រវឹង ជា
ប្រក្រតី ១ មានការមើលបុរស មិនដាច់ជាប្រក្រតី ១ ឈរ
បញ្ចិញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១ ។

[៣០៥] នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងដណ្ដើមបុរសដោយហេតុ ៤០ យ៉ាងគឺ កាច់កន ១ បន្ទន់ខ្លួន ១ ដើរក្រាយ ១ ក្រមឹមក្រមៀម ១ យកក្រចកកួចក្រចក ១ យកជើងជាន់ជើង ១ យកកំណាត់ឈើគូសដី ១ លើកកូនក្មេងដោយខ្លួនឯង ១ ឲ្យកូនក្មេងលើកខ្លួនវិញ ១ លេងកូនក្មេងដោយខ្លួនឯង ១ ញ៉ាំងកូនក្មេងឲ្យលេង ១ ថើបកូនក្មេងដោយខ្លួនឯង ១ ញ៉ាំងកូនក្មេងឲ្យថើបវិញ ១ ស៊ីខ្លួនឯង ១ ញ៉ាំងកូនក្មេង ឲ្យស៊ី ១ ឲ្យរបស់ទៅកូនក្មេង ១ សុំវត្ថុនោះរវាមយកមកវិញ ១

តាតមធុត្តកេហិ ឧច្ចំ ភាសតិ នីចំ ភាសតិ អាវិកំ ភាសតិ វិវិកំ ភាសតិ នច្ចេន គីតេន វាទិតេន រោទិតេន វិលាសិតេន វិភូសិតេន ជគ្ឃតិ បេក្ខតិ កដឹ ចាលេតិ គុយ្ហភណ្ឌកំ សញ្ចាលេតិ ឩរុំ វិវរតិ ឩរុំ បិទហតិ ថនំ ទស្សេតិ កច្ឆំ ទស្សេតិ នាភឹ ទស្សេតិ អក្ខឹ និខណតិ ភមុកំ ឧក្ខិបតិ ឱដ្ឋំ បលិខតិ ជិវ្ហំ និល្លាលេតិ ទុស្សំ មុញ្ចតិ ទុស្សំ បដិពន្ធតិ សិរសំ មុញ្ចតិ សិរសំ ពន្ធតិ ឥមេហិ ខលុ សម្ម បុណ្ណមុខ សដ្ឋិយា ឋានេហិ ឥត្ថី បុរិសំ អច្ចាវទតិ ។

(៣០៦) បញ្ចាសាយ ខលុ សម្ម បុណ្ណមុខ ឋានេហិ ឥត្ថី បទុដ្ឋា វេទិតព្វា ភវតិ សាមិកស្ស បវាសំ វណ្ណេតិ បវុត្ថំ ន សរតិ អាគតំ នាភិនន្ទតិ អវណ្ណំ តស្ស ភណតិ វណ្ណំ តស្ស ន ភណតិ អនត្ថំ តស្ស ចរតិ អត្ថំ តស្ស ន ចរតិ អកិច្ចំ តស្ស ករោតិ កិច្ចំ តស្ស ន ករោតិ បរិទហិត្វា សយតិ បរម្មុខី និបជ្ជតិ បរិវត្តកជាតា ខោ បន ហោតិ កុត្តមិយជាតា ទីឃំ អស្សសតិ ទុក្ខំ វេទយតិ ឧច្ចារបស្សាវំ អភិណ្ហំ គច្ឆតិ វិលោមមាចរតិ



ធ្វើត្រាប់តាម (គេ) ដែលកំពុងធ្វើ ១ និយាយខ្លាំង ១ និយាយតិច ១ និយាយបើកចំហមាត់ ១ និយាយលាក់លៀម ១ (ធ្វើខ្លួនមិត្ត) ដោយការរាំច្រៀងប្រគំ យំកប់រៀបចំខ្លួនសម្អិតសម្អាង ១ សើចក្អាកក្អាយ ១ សំឡឹងសំឡក់ ១ ញាក់ចង្កេះ ១ ញាំងគ្រឿងភេទឲ្យកំរើក ១ បើកបង្ហាញភ្លៅ ១ បិទភ្លៅវិញ ១ បង្ហាញដោះ ១ បង្ហាញក្លៀក ១ បង្ហាញផ្ចិត ១ មិចភ្នែក ១ ញាក់ចិញ្ចើម ១ ទំពារបបូរមាត់ ១ លៀនអណ្តាត ១ ឲ្យសំពត់ ១ ស្លៀកសំពត់វិញ ១ ស្រាយសក់ ១ ចងសក់វិញ ១ នែបុណ្ណមុខៈសំឡាញ់ ស្រីមើលងាយប្តីដោយហេតុ ៦០ យ៉ាងនេះឯង ។

(៣០៦) នែបុណ្ណមុខៈសំឡាញ់ ស្រីដែលខូច បណ្ឌិតគប្បីដឹងដោយហេតុ ៤៨ យ៉ាង គឺស្រីសរសើរការទៅឆ្ងាយរបស់ប្តី ១ មិនរឭកប្តីដែលទៅឆ្ងាយ ១ មិនត្រេកអរនឹងប្តី ដែលទើបមកដល់ ១ ពោលទោសប្តីនោះ ១ មិននិយាយសរសើរគុណប្តីនោះ ១ ប្រព្រឹត្តនូវសេចក្តីវិនាសដល់ប្តីនោះ ១ មិនប្រព្រឹត្តសេចក្តីចំរើនដល់ប្តីនោះ ១ ធ្វើនូវអំពើ ដែលមិនគួរធ្វើ ដល់ប្តីនោះ ១ មិនធ្វើអំពើដែលគួរធ្វើដល់ប្តីនោះ ១ ស្លៀកដណ្តប់ហើយដេក ១ ដេកបែរខ្នងឲ្យ ១ ដេកបម្រះខ្លៀល ១ បង្អើតម្នោះ ១ ដកដង្ហើមបញ្ចេញវែង (ដូចជា) រងទុក្ខ ១ ទៅកាន់ទីឧច្ចារៈ បស្សាវៈ រឿយៗ ១ ប្រព្រឹត្តទទឹងទាស់ ១

បរបុរិសសទ្ទំ សុត្វា កណ្ណសោតំ វិធេហតិ[១] សង្ឃាត-
កោ ខោ បន ហោតិ បដិវិស្សកេហិ សទ្ធឹ សន្ថវំ
និត្ថុន្ថកា ខោ បន ហោតិ វិសិខានុចារិនី អតិចារិនី
ខោ បន ហោតិ សាមិកេ អគារវា បទុដ្ឋមនសង្កប្បា
អភិណ្ហំ ទ្វារេ តិដ្ឋតិ កច្ឆានិ អង្គានិ ថនានិ ទស្សេតិ
ទិសោទិសំ គន្ត្វា បេក្ខតិ ឥមេហិ ខោ សម្ម បុណ្ណមុខ
បញ្ចវីសាយ អាការេហិ ឥត្ថី បទុដ្ឋា វេទិតព្វា ភវតិ ។
ភវតិ ច បនុត្តរេត្ថ វាក្យំ

បកសំ តស្ស វណ្ណេតិ
គតំ តស្ស ន សោចតិ
ទិស្វាន បតិមាគតំ
នាភិនន្ទតិ ភត្តារំ
វណ្ណំ ច កទាចិ ភាសតិ
ឯតេ បទុដ្ឋាយ ការេ លក្ខណា ។
អនត្ថំ តស្ស ចរតិ អសញ្ញតា
អត្ថញ្ច ហាបេតិ អកិច្ចការិនី
បរិវត្តិត្វា សយតិ បរម្មុខី

១ ម. វិរោទហតិ ។



ឮសូរប្រុសដទៃទៀត ផ្ទៀងត្រចៀកស្តាប់ ១ ជាស្រីបំផ្លាញទ្រព្យ ១ ធ្វើនូវសេចក្តីស្និទ្ធនឹងប្រុសអ្នកជិតខាង ដែលស្និទ្ធស្នាល ១ ចុះទៅកាន់ផ្លូវដើរ ចេញដើរ ១ ជាស្រីប្រព្រឹត្តដើរលេងនឹងរឿយៗ ក្នុងវេលាយប់ ប្រព្រឹត្តកន្លងចិត្តប្តី ១ មិនគោរពប្តី ១ មានចិត្តគិតតែខូចកាម ១ ឈរទៀបមាត់ទ្វាររឿយៗ ១ បង្ហាញក្លៀក អង្គកាយ ដោះ ដើរទៅកាន់ទិសទាំងពួងហើយក្រឡេកមើល ១ ម្នាលបុណ្ណមុខៈសំឡាញ់ ស្រីដែលខូច បណ្ឌិតគប្បីដឹងដោយហេតុ ២៥ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនុ៎ះ ដូចមានតទៅទៀត

ស្រីសរសើរនូវការនៅឃ្លាតអំពីប្តីនោះ ១ មិននឹកស្រណោះរកប្តីដែលទៅហើយ ១ ឃើញប្តីមកដល់ មិនត្រេកអរ ១ មិនពោលសរសើរគុណប្តី ក្នុងកាលណាមួយ ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីជាអ្នកមិនសង្រួម ប្រព្រឹត្តនូវសេចក្តីវិនាសដល់ប្តីនោះ ១ ញុំាងប្រយោជន៍ឲ្យវិនាស ១ ជាអ្នកធ្វើនូវកិច្ច ដែលមិនគួរធ្វើ ១ ស្បៀតជាប់ចាំមុខនេះ ១ ដេកក្នុងទីកំបាំងមុខ ១

ឯតេ បឋព្យាយ កវត្តិ លក្ខណា ។
បវិត្តជាតា ច កវតិ ក្រុទ្ធមី
តិយញ្ញ អស្សាសតិ ទុក្ខវេតិ
ទុក្ខាវេស្សប្រមេតិណ្ឌ គច្ចតិ
ឯតេ បឋព្យាយ កវត្តិ លក្ខណា ។
វិលោមមាចរតិ អតិច្ចចារិនី
សទ្ទំ និសាមេតិ បស្សេ កាសតោ
និហតកោកា ច តាកេតិ សព្វំ
ឯតេ បឋព្យាយ កវត្តិ លក្ខណា ។
តាវេច្ចន លទ្ធំ កាសិកកតំ ធនំ
វិត្តំ វិហាសេតិ ទុក្ខេន សម្ភតំ ។
បដិវិស្សកេហិ ច តាកេតិ សព្វំ
ឯតេ បឋព្យាយ កវត្តិ លក្ខណា ។
និក្ខិត្តបាតា វិសមាទុតារិនី
និច្ចញ្ច សាមិម្ហិ បទុដ្ឋមានសា
អតិចារិនី ហោតិ អបេតគារវា
ឯតេ បឋព្យាយ កវត្តិ លក្ខណា ។
អភិក្ខណំ តិដ្ឋតិ ទ្វារមូលេ



ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីដែលប្រុសខ្ទមៀល ១ បន្តដង្ហោះ ១ ដកដង្ហើមវែង (ហាក់ដូចជា) ទើបទុក្ខវេទនា ១ ទៅកាន់ទីធ្លារៈរបស់វាសៈហើយ ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីកំណាញ់មិនធ្វើការងារ តែងប្រព្រឹត្តទទឹងទាស់ ១ ស្ដៀងស្ដាប់សម្ដីរបស់បុរសដទៃនិយាយ ១ បំផ្លាញទ្រព្យ ១ ធ្វើសន្ថវៈ (នឹងបុរសដទៃ) ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ បំផ្លាញទ្រព្យសម្បត្តិដែលប្ដីបានមកដោយក្រនាំមកដោយលំបាក បានមកដោយទុក្ខ ១ ធ្វើសន្ថវៈនឹងបុរសអ្នកជិតខាង ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីបានតែការដើរចេញដើរ ១ ដើរលេងរៀប ។ តួនវេលាយប់ ១ មានចិត្តប្រទូស្តចំពោះប្ដីជានិច្ច ១ ប្រព្រឹត្តកន្លងចិត្តប្ដី ១ ប្រាសចាកសេចក្ដីគោរព ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីឈរនៅទៀបមាត់ទ្វារញឹកៗ ១

ធនានិ ធញ្ញានិ ច ឥស្សរិយដ្ឋំ
ទិសេកទិសំ ឋេត្វា ភត្តចិត្តា
បរេ បទុដ្ឋាយ គវេដ្ឋ សត្តុណា ។
សព្វា នទី វង្កគតី[១] សព្វេ កដ្ឋមយា វនា
សព្វិត្ថិយោ ករេ បាបំ លភមានេ និវាតកេ ។
សចេ លភេថ ខណំ វា រហោ វា
និវាតកំ វាបិ លភេថ តាទិសំ
សព្វាវ ឥត្ថី កយិរុំ នុ បាបំ
អញ្ញំ អលទ្ធា បីឋសប្បិនា សទ្ធឹ ។
នរានមារាមករាសុ នារីសុ
អនេកចិត្តាសុ អនិគ្គហាសុ ច
សព្វត្ថ នាភិរមាបិ ចេ សិយា
ន វិស្សសេ តិត្ថសមា ហិ នារិយោ ។
(៣០៧) យញ្ច ទិស្វា កណ្ឌរីកិន្នរានំ
សព្វិត្ថិយោ ន រមន្តិ អគារេ
តំ តាទិសំ មច្ចំ ចជិត្វា ភរិយា
អញ្ញំ ទិស្វា បុរិសំ បីឋសប្បឹ ។
(៣០៨) ពកស្ស ច ពាវរិយស្ស រញ្ញោ

១ ម. វង្កី ។



បង្អិញដោះនឹងក្លៀត ១ មានចិត្តក្តាក់ផ្តើលក្រៀវក្រុតបើលទិសទាំង គូទី ១ ទាំងនេះដោយក្តុណារបស់ស្រីខូច ។ ស្ទឹងទាំងអស់មាន ដំណើរវៀច ព្រៃទាំងអស់សម្រេចអំពីឈើ (យ៉ាងណាមិញ) ពួក ស្រីទាំងអស់ (វៀរលែងតែស្រីដែលមានកិលេសស្តើង) កាល បើមានបុគ្គលអ្នកខ្សឹបខ្សៀវ ក៏គេនឹងធ្វើនូវអំពើលាមកបាន (យ៉ាង នោះដែរ) ។ ពួកស្រី បាននូវឱកាស ឬទីកំបាំង ឬក៏បាននូវ បុគ្គលខ្សឹបខ្សៀវ ប្រាកដដូច្នោះ ពួកស្រីទាំងអស់ មិនបាននូវ បុរសដទៃ ក៏គប្បីធ្វើនូវអំពើលាមក ជាមួយបុរសខ្វិនបាន ។ ពួកបុរស តែងធ្វើនូវអំណាចព្រោះនារីទាំងឡាយ ជាអ្នកធ្វើនូវ សេចក្តីត្រេកអរដល់ពួកបុរស ជាស្រីមានចិត្តច្រើន ដែលគេឃុំ ឃាត់មិនបាន ដោយប្រការទាំងពួង បុគ្គលមិនត្រូវស្និទ្ធស្នាលទេ ព្រោះថា ស្រីទាំងឡាយ ស្មើដោយកំពង់ទឹក ។

(៣០៧) បុគ្គលឃើញ (នូវការគួរនៃសេចក្តីនឿយណាយ) របស់ព្រះកណ្ឌ ព្រះនាមកិន្នរៈនឹងព្រះនាងកិន្នរី (គប្បីដឹងថា) ពួកស្រីទាំងអស់ មិនមែនត្រេកអរ ក្នុងផ្ទះ (របស់ស្វាមីខ្លួន) ដូចជាភរិយា(របស់ ព្រះកណ្ឌរីៈ) លះបង់នូវភត្តា (ស្វាមី) បែបនោះ ព្រោះឃើញ នូវបុរសផ្តេសផ្តាសដទៃជាបុរសខ្វិន ។

(៣០៨) ភរិយា របស់ព្រះបាទពកៈ និងព្រះបាទ ពាវរិយៈ

អច្ចន្តកាមានុគតស្ស ភរិយា
អចាចរី បដ្ឋវសានុគស្ស
កាំ ភ វត្តុំ ឃាតិចរេ កញ្ញំ ។

(៣០៩) បិដ្ឋិយានី សត្តុលោកិស្សរស្ស
រញ្ញោ បិយា ព្រហ្មទត្តស្ស ភរិយា
អចាចរី បដ្ឋវសានុគស្ស
តំ ភិបិ សា ជាជ្ជុកា កាមកាមិនី ។

(៣១០) ទុដ្ឋានំ លហុចិត្តានំ អកតញ្ញូន ទុព្ភិនំ
នាទេវសត្តោ បុរិសោ ថីនំ សទ្ធាតុមរហតិ ។
ន តា បជានន្តិ កតំ ន កិច្ចំ
ន មាតរំ បិតរំ ភាតរំ វា
អនរិយា សមតិក្កន្តធម្មា
សស្សេវ ចិត្តស្ស វសំ វជន្តិ ។
ចិរានុវុដ្ឋំបិ បិយំ មនាបំ
អនុកម្បកំ បាណសមំបិ ភត្តុំ
អាបាសុ កិច្ចេសុ ច នំ ជហន្តិ
តស្មាហំ ឥត្ថីនំ ន វិស្សសាមិ ។



ជាភរិយារបស់អ្នកលោភកាម ដ៏ក្រៃលែង មានប្រព្រឹត្តក្បត់ចំពោះបុរស អ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា ស្រីមិនប្រព្រឹត្តកន្លងហួស នឹងបុរសដទៃនោះ ឯណាកើត ។

(៣០៩) នាងបិង្គិយានី ជាភរិយា ជាទីស្រឡាញ់នៃព្រះបាទព្រហ្មទត្ត ព្រះអង្គជាធំ ក្នុងលោកទាំងមូល មានប្រព្រឹត្តក្បត់ចំពោះបុរស អ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា នាងបិង្គិយានី ជាអ្នកលោភ ក្នុងកាមនោះ មិនបាននូវបុរសក្លឹលសេះនោះផង ( នូវទី អគ្គមហេសីផង ) ។

(៣១០) បុរសដែលមិនមែនខ្មោចចូល មិនគួរជឿពួកស្រីដែលអាក្រក់ មានចិត្តរហ័ស ជាស្រីមិនដឹងគុណ ដែលគេធ្វើដល់ខ្លួន ជាស្រីប្រទូស្ត (ប្ដី) ទេ ។ ពួកស្រីទាំងនោះ មិនដឹងនូវឧបការៈដែលគេធ្វើហើយ ( ដល់ខ្លួន ) មិនដឹងនូវកិច្ចការដែលគួរធ្វើ មិនស្គាល់ម្ដាយ មិនស្គាល់ឪពុក មិនស្គាល់បងប្អូន មិនមានអរិយធម៌ មានការប្រព្រឹត្តកន្លងនូវធម្មតា តែងលុះអំណាចចិត្តរបស់ខ្លួន ។ ពួកស្រីតែងលះបង់ប្ដីជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាអ្នកអនុគ្រោះស្មើដោយជីវិត ដែលគប់ប្រុសគ្នាអស់កាលដ៏យូរ ឬលះបង់នូវប្ដី ក្នុងកិច្ចមានអន្តរាយ ព្រោះហេតុនោះ ខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ ។

ថីនំ ហិ ចិត្តំ យថា វានរស្ស
កន្និប្បកម្ពំ យថា រុក្ខឆាយា
ចលាចលំ ហទយំ ឥត្ថិយានំ
ចក្កស្ស នេមិ វិយ បរិវត្តតិ ។
យទា តា បស្សន្តិ សមេក្ខមានា
អាទេយ្យរូបំ បុរិសស្ស វិត្តំ
សណ្ហាហិ វាចាហិ នយន្តិមេនំ
កម្ពោជកា ជលជេនេវ អស្សំ ។
យទា ន បស្សន្តិ សមេក្ខមានា
អាទេយ្យរូបំ បុរិសស្ស វិត្តំ
សមន្តតោ នំ បរិវជ្ជយន្តិ
តិណ្ណោ នទីបារគតោវ កុល្លំ ។
សិលេសូបមា សិខីរិវ សព្វភក្ខា
តិក្ខមាយា នទីរិវ សីឃសោតា
សេវន្តិ ហេតា បិយមប្បិយញ្ច
នាវា យថា ឱរកូលំ បរញ្ច ។
ន តា ឯកស្ស ន ទ្វិន្នំ អាបណោវ បសារិតា
យោ តា មយ្ហន្តិ មញ្ញេយ្យ វាតំ ជាលេន ពន្ធយេ ។



ព្រោះថាចិត្តរបស់ស្រីដូចស្វាដ៏ចិត្តរារែក ហឫទ័យរបស់ពួកស្រីចុះឡើងញាប់ញ័រដូចម្លប់ឈើ វិលវល់ទៅ ដូចកង់រទេះ ។ ពួកស្រីទាំងនោះ កាលក្រឡេកមើលឃើញទ្រព្យរបស់បុរស ដែលគួរកាន់យកបានកាលណា គំរៀរគេរបុរសនោះ ដោយសំដីដ៏ផ្អែមល្ហែមក្នុងកាលនោះ ដូចពួកជនអ្នកកម្ពុជៈ បញ្ចោតចាប់សេះដោយសា-រាយ ។ ពួកស្រីកាលបើក្រឡេកមើល មិនឃើញទ្រព្យរបស់បុរសដែលគួរកាន់យកបានកាលណា គំរៀរបុរសនោះដោយជុំវិញ ក្នុងកាលណោះ ដូចគេឆ្លងទៅដល់ត្រើយស្ទឹងហើយលះបង់ខ្ទុង ។ ពួកស្រីឧបមាដូចជ័រ (ជាទីជាប់ស្អិតនៃចិត្តបុរស) ដូចភ្លើងស៊ីនូវគ្រឿងគ្រប់យ៉ាង មានមាយាដ៏ហ័ស ដូចស្ទឹងមានខ្សែទឹកដ៏ហ័ស ពួកស្រីទាំងនេះ តែងសេពគប់បុរស ទាំងជាទីស្រឡាញ់ទាំងមិនជាទីស្រឡាញ់ ដូចទូកតែងចូលប្រទះទាំងត្រើយខាងអាយទាំងត្រើយខាងនាយ ។ ពួកស្រីទាំងនោះ មិនមែនជារបស់បុរសម្នាក់ ឬពីរនាក់ទេ ដូចជាហាងផ្សារដែលបើកហើយ បុគ្គលណា សំគាល់នូវពួកស្រីទាំងនោះ ថាជារបស់អញ បុគ្គលនោះ ដូចគេយកសំណាញ់ ខ្ទប់ខ្យល់ ។

យថា នទី ច បន្ថោ ច  បានាគារំ សភា បបា

ឯវំ លោកិត្ថិយោ នាម  វេលា តាសំ ន វិជ្ជតិ ។

ឃតាសនសមា ឯតា  កណ្ហសប្បសិរូបមា

គាវោ ពហិ តិណស្សេវ ឱមសន្តិ វរំ វរំ ។

ឃតាសនំ កុញ្ជរំ កណ្ហសប្បំ

មុទ្ធាភិសិត្តំ បមទា ច សព្វា

ឯតេ នរោ និច្ចយតោ ភជេថ

តេសំ ហវេ ទុព្វិទុ សព្វភាវោ ។

នច្ចន្តវណ្ណា ន ពហូន កន្តា

ន ទក្ខិណា បមទា សេវិតព្វា

ន បរស្ស ភរិយា ន ធនស្ស ហេតុ

ឯតិត្ថិយោ បញ្ច ន សេវិតព្វា ។

(៣០០) អថ ខលុ ភោ អានន្ទោ គិជ្ឈរាជា កុណាលស្ស សកុណស្ស អាទិមជ្ឈកថាបរិយោ-សានំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ



ស្ទឹង ផ្លូវ រោងស្រា រោងសំរាកប្រជុំ រោងអណ្តូងទឹក យ៉ាងណា ធម្មតាពួកស្រីក្នុងលោក ក៏យ៉ាងនោះដែរ វេលា (នៃសេចក្តីស្រើបក្នុងកាម) របស់ពួកស្រីទាំងនោះ មិនមានឈប់ឈរឡើយ ។ ពួកស្រីទាំងនេះ ស្មើដោយអណ្តាតភ្លើង មានឧបមាដូចក្បាលពស់វែក ដូចពួកគោស៊ីស្មៅដ៏ល្អ ៗ ខាងក្រៅ ៗ នរៈគប្បីគប់រកដោយការប្រយ័ត្នខ្ពើមក្នុងវត្ថុទាំងនេះ គឺភ្លើងមួយ ដំរីមួយ ពស់វែកមួយ ព្រះរាជាដែលគេអភិសេកហើយមួយ ពួកស្រីទាំងអស់មួយ ព្រោះភាពទៀងទាត់នៃវត្ថុទាំងនោះដឹងបានដោយក្រណាស់ ។ ពួកស្រីមានពណ៌សម្បុរដ៏ល្អលើសលុបពេក បុគ្គលមិនគួរសេពគប់ ១ ស្រីជាទីស្រឡាញ់ពេញចិត្តរបស់ពួកជនច្រើន បុគ្គលមិនគួរសេពគប់ ១ ស្រីឆ្លៀតឆ្លាសក្នុងការកំនឹងច្រើន បុគ្គលមិនគួរសេពគប់ ១ ប្រពន្ធអ្នកដទៃ បុគ្គលមិនគួរសេពគប់ ១ ស្រី (សេពគប់) ព្រោះហេតុនៃទ្រព្យ បុគ្គលក៏មិនគួរសេពគប់ ១ ស្រី ៥ ពួកនេះ បុគ្គលមិនគួរសេពគប់ទេ ។

(៣០១) លំដាប់នោះ ស្តេចត្មាតឈ្មោះអានន្ទ បានដឹងនូវគាថាជាខាងដើម កណ្តាល និងខាងចុង របស់កុណាលសកុណៈ ហើយបានពោលគាថាទាំងនេះ ក្នុងវេលានោះថា

បុណ្ណម្បិ ចេមំ បឋវឹ ធនេន
ទជ្ជិត្ថិយា បុរិសោ សម្មតាយ
លទ្ធា ខណំ អតិមញ្ញេយ្យ តម្បិ
តាសំ វសំ អសតីនំ ន គច្ឆេ ។
ឧដ្ឋាហកញ្ចេបិ អលីនវុត្តឹ
កោមារភត្តារំ បិយំ មនាបំ
អាបាសុ កិច្ចេសុ ច នំ ជហន្តិ
តស្មាហំ ឥត្ថីនំ ន វិស្សសាមិ ។
ន វិស្សសេ ឥច្ឆតិ មន្តិ បោសោ
ន វិស្សសេ រោទតិ មេ សកាសេ
សេវន្តិ ហេតា បិយមប្បិយញ្ច
នាវា យថា ឱរកុលំ បរញ្ច ។
ន វិស្សសេ សាខបុរាណសន្ថតំ
ន វិស្សសេ មិត្តបុរាណចោរំ
ន វិស្សសេ រាជា សខា មមន្តិ
ន វិស្សសេ ឥត្ថី ទសន្ន មាតរំ ។
ន វិស្សសេ រាមករាសុ នារិសុ
អច្ចន្តសីលាសុ អសញ្ញតាសុ

បុរសគប្បីឲ្យផែនដី ដែលពេញដោយទ្រព្យ ដល់ស្ត្រីដែលសន្មតហើយ ស្រីនោះលុះបានឱកាស រមែងមើលងាយបុរសនោះវិញ (ព្រោះហេតុនោះ) បុរសមិនត្រូវលុះអំណាចនៃស្រីទាំងនោះឡើយ ។ ពួកស្រីរមែងលះបង់នូវប្តីក្តី ដែលជាអ្នកមានព្យាយាម ព្រោះឡើងមានការប្រព្រឹត្តមិនរួញរា ស្វាមីជាទីស្រឡាញ់ពេញចិត្តផង លះបង់នូវប្តីនោះ ព្រោះកិច្ចដែលមានអន្តរាយផង ព្រោះហេតុនោះ ខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ ។ បុរសមិនត្រូវទុកចិត្តស្រីដោយគិតថា ស្រីនោះចង់បានអញ មិនត្រូវទុកចិត្តស្រីដោយគិតថា ស្រីនោះយំនៅចំពោះអញ (ដូច្នេះ) ព្រោះថា ស្រីទាំងនោះរមែងគប់រកនូវបុរស ទាំងជាទីស្រឡាញ់ ទាំងមិនជាទីស្រឡាញ់ ដូចទូកឆ្លងប្រែះ ទាំងត្រើយខាងអាយទាំងត្រើយខាងនាយ ។ បុគ្គលមិនត្រូវទុកចិត្តមែកឈើចាស់ ដែលគេក្រាលទុកទេ មិនត្រូវទុកចិត្តចោរដែលចាស់ជាមិត្តទេ មិនត្រូវទុកចិត្តថា ព្រះរាជា ជាសំឡាញ់របស់អញដូច្នេះទេ មិនត្រូវទុកចិត្តស្រីជាមាតារបស់បុត្ត ១០ នាក់ (យាយចាស់) ទេ ។ បុគ្គលមិនត្រូវទុកចិត្ត ចំពោះពួកនារីអ្នកធ្វើនូវសេចក្តីត្រេកអរ អ្នកកន្លងសីលធម៌ មិនសង្រួមទេ

អប្ពុត្តេមាតុគាមស្ស ការិយោ
ន វិស្សសេ តិត្ថសមា ហិ តាយោ ។
ហារេយ្យុំ ឆិន្ទេយ្យុំ ឆេទាបេយ្យុំ
កណ្ឋំបិ ឆេត្វា រុធិរំ បិវេយ្យុំ
មា ទីនកាមាសុ អសញ្ញតាសុ
ភាវំ ករេ គង្គតិត្ថូបមាសុ ។

មុសា តាសំ យថា សច្ចំ សច្ចំ តាសំ យថា មុសា
គាវោ ពហិំ តិណស្សេវ ឱមសន្តិ វរំ វរំ ។
គតេន តា បលោភេន្តិ បេក្ខិតេន ម្ហិតេន ច
អថោបិ ទុន្និវត្ថេន មញ្ជុនា ភណិតេន ច ។
ចោរិយោ កឋិនា ហេតា វាឡា ច លបសក្ខរា
ន តា កិញ្ចិ ន ជានន្តិ យំ មនុស្សេសុ វញ្ចនំ ។
អសា លោកិត្ថិយោ នាម វេលា តាសំ ន វិជ្ជតិ
សារត្តា ច បគព្ភា ច សិខី សព្វឃសោ យថា ។





មិនត្រូវទុកចិត្តករិយា ដែលមានសេចក្តីស្រឡាញ់ក្រៃពេក ព្រោះថា នារីទាំងឡាយទុកស្មើកំពង់ទឹក ។ ពួកស្រី រមែងសម្លាប់ ( ប្រុស ) ខ្លះ កាត់ ( កប្រុស ) ខ្លួនឯងខ្លះ ប្រើគេឲ្យកាត់ខ្លះ កាត់កហើយ ផឹកឈាមខ្លះ បុគ្គលកុំធ្វើសេចក្តីស្នេហាចំពោះពួកស្រី ដែលមាន សេចក្តីប្រាថ្នាថោកទាប ជាអ្នកមិនសង្រួម មានចិត្តដូចកំពង់ទឹក ។ ពាក្យកុហក របស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យពិត ឯពាក្យ ពិត របស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យកុហក ( ពួកស្រី ) ដូចគោ ស៊ីចំបើតែស្មៅល្អ ៗ ទាន់ស្រស់ ៗ ពួកស្រីទាំងនោះ តែងប្រលោម ( ប្រុស ) ដោយដំណើរផង ដោយការដែល ក្រឡេកមើលផង ដោយសំណើចផង ម្យ៉ាងដោយសំពត់ដែលស្លៀក អាក្រក់ផង ដោយពាក្យពីរោះផង ។ ពិតណាស់ ស្រីទាំងនេះដូច ចោរ មានចិត្តរឹងត្អឹង ខូចកាច តែមានសំដីផ្អែមដូចស្ករ ការ បញ្ឆោតណាក្នុងពួកមនុស្ស ពួកស្រីទាំងនោះ មិនមែនជាមិនដឹងការ បញ្ឆោតណាមួយ(នោះ)ទេ ។ ឈ្មោះ ពួកស្រីក្នុងលោក (ច្រើនតែ) លាមក វេលារបស់ពួកស្រីទាំងនោះ មិនមានទេ ពួកស្រីជាអ្នក ស្រើបស្រាលផង ល្មើសល្មមផង ដូចភ្លើងស៊ីគ្រប់យ៉ាង ។

នត្ថិត្ថីនំ បិយោ នាម    អប្បិយោបិ ន វិជ្ជតិ
សេវន្តិ ហេតា បិយមប្បិយញ្ច
នាវា យថា ឱរកូលំ បរញ្ច ។
នត្ថិត្ថីនំ បិយោ នាម    អប្បិយោបិ ន វិជ្ជតិ
ធនត្តា បដិវល្លន្តិ    លតាវ ទុមនិស្សិតា ។
ហត្ថិពន្ធំ អស្សពន្ធំ    គោបុរិសញ្ច ចណ្ឌាលំ
ឆវឌាហកំ បុប្ផឆឌ្ឌកំ    សធនំ អនុបតន្តិ នារិយោ ។
កុលបុត្តំបិ ជហន្តិ    អកិញ្ចនំ ឆវកសមំ
សទិសំ អនុបតន្តិ    ធនហេតុ ច នារិយោតិ ។

[៣១៦] អថ ទ្វិជោ នារទោ ទេវព្រាហ្មណោ អានន្ទស្ស គិជ្ឈរាជស្ស គាថាបរិយោសានំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

ចត្តារោមេ ន បូរេន្តិ    តេ មេ សុណាថ ភាសតោ
សមុទ្ទោ ព្រាហ្មណោ រាជា    ឥត្ថី ចាបិ ទិជម្បតិ ។
សរិតា សាគរំ យន្តិ    យា កាចិ បថវិស្សិតា
តា សមុទ្ទំ ន បូរេន្តិ    ឩនត្តា ហិ ន បូរតិ ។





បុរសឈ្មោះថាជាទីស្រឡាញ់ របស់ពួកស្រី មិនមាន ទាំងមិនជាទីស្រឡាញ់ក៏មិនមាន ព្រោះថាពួកស្រីទាំងនេះ តែងគប់រកបុរសជាទីស្រឡាញ់ទាំងមិនស្រឡាញ់ ដូចទូក តែងចូលប្រទះទាំងត្រើយខាងអាយនិងត្រើយខាងនាយ ។ បុរសឈ្មោះថាជាទីស្រឡាញ់របស់ពួកស្រីមិនមាន ទាំងមិនជាទីស្រឡាញ់ក៏មិនមាន ពួកស្រីតែងរួបរឹត (បុរស) ដើម្បីទ្រព្យសម្បត្តិ ដូចវល្លិ៍ពាក់ព័នដើមឈើ ។ ស្រីទាំងឡាយ តែងតែតាមបុរសឃ្វាលដំរី ឃ្វាលសេះ ឃ្វាលគោ បុរសចណ្ឌាល អ្នកដុតខ្មោច និងអ្នកបោចសម្រាម ដែលមានទ្រព្យ ។ ស្រីទាំងឡាយតែងលះបង់នូវកូនអ្នកមានត្រកូល ដែលមិនមានទ្រព្យតិចតួច ទុកស្មើសាកសព នារីទាំងឡាយ (ហ្មឺនតែ) គប់រកបុរស ព្រោះហេតុតែទ្រព្យ ។

[៣១៦] សេចក្ដីដំណាលថា គ្រានោះ ទេវព្រាហ្មណ៍ ឈ្មោះនារទៈ បានដឹងនូវគាថាជាខាងដើម កណ្ដាល និងទីបំផុត របស់ស្ដេចត្មាតឈ្មោះអានន្ទហើយ ក៏ពោលគាថាទាំងឡាយនេះ ក្នុងវេលានោះថា

បពិត្រលោកជាម្ចាស់នៃបក្សី សូមលោកស្ដាប់ពាក្យ ដែលខ្ញុំនឹងនិយាយដូចតទៅនេះ ជន ៤ ពួកនេះ សមុទ្រ ១ ព្រាហ្មណ៍ ១ ព្រះរាជា ១ ស្រី ១ រមែងមិនពេញ ។ ស្ទឹងណាមួយដែលអាស្រ័យនូវប្រថពីដែលហូរទៅកាន់សាគរ ស្ទឹងទាំងនោះ ក៏ញ៉ាំងសមុទ្រឲ្យពេញមិនបាន ព្រោះថា សមុទ្ររមែងមិនពេញ ទៅតែនៅខ្វះរាក ។

ព្រាហ្មណោ ច អជិយោន វេតមក្ខានបតុំ
កិំ យេ្យាបិ សុតមិច្ឆេយ្យ ទិដ្ឋា ហិ ន ឰរតិ ។
ពជា ច បវី សត្តំ សសមុទ្ទំ សបព្វតំ
អជ្ឈាវសំ វិជិតា អនន្តគោចរិ
ចារំ សមុទ្ទំ បត្ថេតិ ទិដ្ឋា ហិ ន ឰរតិ ។
ឯកោមេកាយ ឥត្ថិយា អដ្ឋដ្ឋ បតិយោ សិយុំ
សុរា ច ពលវន្តោ ច សព្វកាមរសាហរា
ការេយ្យ នវមេ ឆន្ទំ ទិដ្ឋា ហិ ន ឰរតិ ។
សព្វិត្ថិយោ សិខីរិវ សព្វភក្ខា
សព្វិត្ថិយោ នទីរិវ សព្វវហិនី
សព្វិត្ថិយោ កណ្ដកានំវ សាខា
សព្វិត្ថិយោ ធនហេតុ វជន្តិ ។
វាតញ្ច ជាលេន នរោ បរាមសេ
ឱសិញ្ចយេ សាគរមេកបាណិនា
សកេន ហត្ថេន ករេយ្យ ឃោសំ
យោ សព្វភាវំ បមទាសុ ឱស្សជេ ។
ចោរីនំ ពហុពុទ្ធីនំ យាសុ សច្ចំ សុទុល្លភំ



ព្រាហ្មណ៍រៀនចប់ហើយមានគម្ពីរឈ្មោះវេទហោសៈ ជាតំរប់ ៤ ហើយ តែងប្រាថ្នាទៅការពារជើងទៀតលែង ព្រោះថា ព្រាហ្មណ៍នោះ រមែងមិនពេញ ចេះតែឃ្លានអាត ។ ទីណាព្រះរាជាឈ្មោះគ្រប់គ្រង ផែនដីទាំងអស់ ព្រមទាំងសមុទ្រនិងភ្នំហើយ តែងប្រាថ្នាគេត្រាន់ សមុទ្រ និងផ្សេងសមុទ្រ ដែលសម្បូរដោយរតនៈ មិនទាន់ចំបំពុត ព្រោះថាព្រះរាជានោះ រមែងមិនគ្រប់គ្រាន់ ចេះតែឃ្លានអាត ។ ស្រីម្នាក់ ៗ មានប្តីប្រាំបី ៗ ហើយប្តីនោះ ជាអ្នកក្លៀវក្លាផង មានកម្លាំងផង នាំមកនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង គិតនឹងធ្វើនូវសេចក្តីប្រាថ្នានឹងប្តីទី ៩ ទៀត ព្រោះថា ស្រីនោះ រមែងមិនគ្រប់គ្រាន់ ចេះតែឃ្លានអាត ។ ពួកស្រីទាំងអស់ ដូចក្អែកស៊ីនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូចស្ទឹងនាំទៅនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូចមែកឈើមានបន្លា ពួកស្រីទាំងអស់ គប់គេ (ប្តី) ព្រោះហេតុតែទ្រព្យ ។ នរជនណា ផុតផ្ទាក់នូវគាល គឺការរើរ ចាំចិត្តរបស់ពួកស្រី នរជននោះ ទុកដូចគេយកសំណាញ់ចាប់ខ្យល់ ឬដូចគេបាចទឹកសមុទ្រ ដោយដៃម្ខាង ក៏ដូចនោះ ឬដូចគេយកដៃមួយ ទះឲ្យឮសូរគឹកកង ។ ពួកស្រីដែលដូចជាចោរ មានពុទ្ធិច្រើន មានពាក្យសច្ចៈ គេរកបានដោយកម្រណាស់

ថីនំ ភាវោ ទុរាជានោ មច្ឆស្សេវោទកេ គតំ ។
អនលា មុទុសម្ភាសា ទុប្បូរា តា នទីសមា
សីទន្តិ នំ វិទិត្វាន អារកា បរិវជ្ជយេ ។
អាវដ្ដនី មហាមាយា ព្រហ្មចរិយវិកោបនា
សីទន្តិ នំ វិទិត្វាន អារកា បរិវជ្ជយេ ។
យញ្ចេតា ឧបសេវន្តិ ឆន្ទសា វា ធនេន វា
ជាតវេទោវ សណ្ឋានំ ខិប្បំ អនុទហន្តិ នំ ។

(៣១៣) អថ ខលុ ភោ កុណាលោ សកុណោ នារទស្ស ទេវព្រាហ្មណស្ស អាទិមជ្ឈគាថាបរិយោសានំ វិទិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

សល្លបេ និសិតខគ្គបាណិនា
បណ្ឌិតោ អបិ បិសាចទោសិនា
ឧគ្គតេជំ ឧរគម្បិ អាសីទេ
ឯកោ ឯកាយ បមទាយ នាលបេ ។
លោកចិត្តមថនា ហិ នារិយោ



ភាពនៃស្រីទាំងឡាយ គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ។ ពួកស្រីទាំងនោះ មានមារយាទបញ្ចេញបុញ្ញ មានសំដីទន់ ទុកស្មើដោយស្ទឹង បំពេញបានដោយក្រ តែងលិចចុះ (ក្នុងអបាយ ព្រោះហេតុនៃកាម) បុគ្គលដឹងច្បាស់នូវដំណើរនោះហើយ គប្បីវៀរឲ្យឆ្ងាយចេញ ។ ពួកស្រីជាអ្នកញុំាងចិត្តប្រុសឲ្យត្រឡប់ត្រឡិន មានមាយាច្រើន ញុំាងព្រហ្មចរិយធម៌ ឲ្យកម្រើក តែងលិចចុះ (ក្នុងអបាយ) បុគ្គលដឹងច្បាស់នូវដំណើរនោះហើយ គប្បីចៀសឲ្យឆ្ងាយចេញ ។ ពួកស្រីទាំងនោះ ចូលទៅគប់រកប្រុសណា ដោយសេចក្ដីប្រាថ្នា ឬដោយទ្រព្យសម្បត្តិ រមែងដុតកំដៅប្រុសនោះដោយឆាប់រហ័ស ដូចភ្លើងឆេះនូវទីរបស់ខ្លួន ។

(៣១៣) សេចក្ដីដំណាលថា គ្រានោះ កុណាលសកុណៈ ដឹងនូវគាថាជាខាងដើម កណ្ដាល និងទីបំផុត នៃទេវព្រាហ្មណ៍ឈ្មោះនារទៈ ហើយក៏ពោលគាថាទាំងនេះ ក្នុងវេលានោះថា

បណ្ឌិតៈ គប្បីចរចា (ជាមួយ) នឹងបុគ្គលមានដៃកាន់ដាវ
សម្លៀងហើយ (ជាមួយ) នឹងបុគ្គលប្រទូស្តដូចជាបិសាច
ឬក៏ចូលទៅកៀកពស់ ដែលមានពិសដ៏ពន្លឹក (ប្រសើរជាង)
ប្រុសម្នាក់ឯង មិនគួរនិយាយចរចា ចំពោះស្រីម្នាក់ឯងទេ ។
ព្រោះថា នារីទាំងឡាយ ជាអ្នកញាំញីនូវចិត្តនៃមនុស្សលោក

ឆន្ទគីតគណិតម្ហិតាវុធា
តានយន្តិ អនុបន្ធិតស្សតិ
ទីបេ រក្ខសិគណាវ វាណិជេ ។
នត្ថិ តាសំ វិនយោ ន សំវរោ
មជ្ជមំសនិរតា អសញ្ញតា
តា គិលន្តិ បុរិសស្ស បាភតំ
សាគរេវ មករំ តិមិង្គលោ ។
បញ្ចកាមគុណសាតគោចរា
ឧទ្ធតា អនិយតា អសញ្ញតា
ឱសរន្តិ បមទា បមាទិនំ
លោណតោយវតិយំវ អាបគា ។
យំ នរំ ឧបលបេន្តិ នារិយោ
ឆន្ទសា វា រតិយា វា ធនេន វា
ជាតវេទសទិសំបិ តាទិសំ
រាគទោសវធិយោ ទហន្តិ នំ ។
អឌ្ឍំ ញត្វា បុរិសំ មហទ្ធនំ
ឱសរន្តិ សធនំ សហត្តនា



ជាអ្នកមានការរាំ ច្រៀង និយាយ សើច ញញឹម ជាគ្រឿង តែង បៀតបៀនខ្លួនប្រុសដែលមិនបានតម្កល់ស្មារតី ដូចពួកស្រីអារក្សទឹក ក្នុងកោះបៀតបៀនពួកពាណិជ ។ ពួកស្រីទាំងនោះមិនមានវិន័យ មិនមានសំវរៈ ពួកស្រីទាំងនោះជាអ្នកត្រេកអរក្នុងទឹកស្រវឹង និងសាច់ ជាអ្នកមិនសង្រួម តែងលេបទ្រព្យសម្បត្តិរបស់បុរស ដូចត្រីធំឈ្មោះតិមិង្គិល លេបខ្លួនមករក្នុងសាគរ ។ ពួកស្រីមានសេចក្ដីត្រេកអរក្នុងបញ្ចកាមគុណជាអារម្មណ៍ មានការភ្លើនភ្លៃ មិនទៀង មិនសង្រួម ហ៊ាំ ទៅរកបុរសអ្នកប្រមាទ ដូចទឹកស្ទឹង តែងហូរចុះទៅរកទីមានទឹកប្រៃ (សមុទ្រ) ។ នារីទាំងឡាយ តែងនិយាយស្រស់ស្រាយរកជនណា ដោយសេចក្ដីស្រឡាញ់ ឬដោយតម្រេក ឬក៏ដោយទ្រព្យ ពួកស្រីសម្លាប់ប្រុសដោយរាគៈនិងទោសៈ តែងដុតកម្ដៅនរជននោះស្មើ ប្រុសនោះរឿងដូចភ្លើងជាអ្នកដឹងនូវ ។ ពួកស្រីដឹងថាបុរសអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន តែងត្រឡែតរកប្រុសដែលមានទ្រព្យ ដោយខ្លួនឯង

រត្តចិត្តំ អតិវេឋយន្តិ នំ
សាខំ មាលុវលតាវ កាននេ ។
តា ឧបេន្តិ វិរេន ឧន្នសា
ចិត្រកិម្ពរុចិយោ អលង្កតា
ឱហសន្តិ បហសន្តិ នារិយោ
សំវរ សគមាយកោវិទា ។
ជាតរូបមណិមុត្តភូសិតា
សក្កតា បតិកុលេសុ នារិយោ
រក្ខិតា អតិចរន្តិ សាមិកំ
ទានវំ ហទយន្តរនិស្សិតា ។
អេដកបិ ហំ ឥកោ វិចក្ខណោ
សក្កតោ ពហុជនស្ស បូជិតោ
នារីនំ វសង្គតោ ន ភាសតិ
រាហុនា ឧបហតោវ ចន្ទិមា ។
យំ ករេយ្យ កុបិតោ ទិសោ ទិសំ
ទុដ្ឋចិត្តោវ សមាគតំ អរិំ



រួបរឹតបុរសដែលមានចិត្តត្រេកអរ ដូចវល្លិ៍ក្នុងព្រៃរួបរឹតដើមឈើ ។ នារីទាំងឡាយនោះ មានខ្លួនតុបតែងដោយគ្រឿងតាក់តែងហើយ ក្តាប់ខ្ញុំ ( បុរស ) ដោយសេចក្តីប្រាថ្នាផ្សេង ៗ ជាអ្នកយល់កលមាយាទាំងឡាយ តែងសើច តែងញញឹម តែងហាក់ដូចជាសម្រិម ៗ នារីទាំងឡាយ ស្អិតស្អាងខ្លួនដោយមាស កែវមណី និងកែវមុក្តា ដែលគេធ្វើសក្ការៈ ក្នុងត្រកូលរបស់ប្តី ដែលគេរក្សាហើយ ក៏នៅតែប្រព្រឹត្តកន្លងស្វាមីបាន ដូចជាប្រុសទានវដែលការពារនៅក្នុងចន្លោះហឫទ័យ ប្រព្រឹត្តកន្លងអសុរកញ្ញាបាន ។ ទោះបី សូម្បីមានតេជះ មានប្រាជ្ញាវាងវៃ ដែលអ្នកផងច្រើនគ្នាធ្វើសក្ការបូជា លុះក្នុងអំណាចនៃស្រីទាំងឡាយហើយ តែងមិនរុងរឿង ដូចព្រះចន្ទ្រដែលត្រូវរាហូចាប់ ។ ពោរអ្នកក្រោធមានចិត្តកាចក្រក់ (ឃើញ) ពោរជាសត្រូវ (នឹងខ្លួន) មកប្រទះគ្នាហើយ ធ្វើនូវសេចក្តីវិនាសណា

នេន កិរិយា ព្យសនំ និគច្ឆតិ

ជាតិំ វសន្តោ អបេក្ខោ ។

កោសល្លុ ពពទធិន្នតង្ហិតា

មាធមាណិតសធណ្ហាតង្ហិតា

ហើងទៅបតតា ហិ ជាតិយោ

តា រមន្តិ ត្ថុណាបេវ មត្ថិកោ ។

តា កាមលេសុ វិសិទន្តេសុ ភ

កដជាចីសុ មិតមេសុ ភ បច

ទិដ្ឋិតំ នមុចិជាសភត្ថុ

ចក្ខុមា បរិវជ្ជេយ្យ សុខត្ថិកោ ។

ទិស្សធិត្វា កុសលំ តតោគុណំ

យោ អនរិយចរិតានិ មា ចរិ

គេវតាហិ ធរិយំ ធម្មិស្សតិ

ជេនកាមិមណិយំ ភណិកោ ។

សោ វង តរហិតោ ឋាត្ថុ ឧ

ធុម្មកំ ឧបបាតោ សកម្មុនា

តដ្ឋតិ អដិយតោ តណ្ហាតលំ



បុគ្គលអ្នកមានតណ្ហា ស្រុកនិគមជាប ស្រីទាំងឡាយ រមែង ដល់នូវសេចក្តីវិនាសព្រោះស្រីនោះ ដាក់សេចក្តីវិនាសនោះទៅទៀត ។ ជាតិស្រីទាំងឡាយ ដែលមានសក់ខ្មៅ មានស្នាមដាំដោយក្រចក ដែលក្រៅ គេក៏យ នេះជាក់ ដោយជើង ដៃ ចិញ្ចឹមបីបាច់ ក៏នៅតែ ចូលទៅរកឯការដោតភាពវិញ នៅតែត្រេកអរ (ក្នុងកាមទៀត) ដូចព្រាយត្រេកអរនឹងសាកសព ។ បុរសអ្នកមានបញ្ញាចក្ខុ ត្រូវការ ដោយសេចក្តីសុខ គប្បីវៀរស្រីទាំងឡាយនោះ (ដែលនៅ) ក្នុង ត្រកូលទាំងឡាយក្តី ក្នុងបន្ទាយក្រុងក្តី ក្នុងជនបទក្តី ក្នុងនិគមក្តី ឬក៏វៀរនូវការធ្លាក់ដូចជាអន្ទាក់នៃបក្សីរបស់មារ ដែលកិលេស-មារដាក់ហើយក្តី ។ បុគ្គលណា លះបង់នូវតបោគុណ (គុណនៃ សេចក្តីព្យាយាម) ជាកុសលហើយ ប្រព្រឹត្តនូវបាបមិនប្រសើរ បុគ្គលនោះ (លុះបរ) ចាកទៅហើយ នឹងមកកាន់នរកវិញ ដូចភាពដើម (មានខ្សែប្រើនដែរ) ក្នុងកិរិយា ។ ប្រុស (ដែលលុះក្នុងអំណាចស្រី) នោះ ត្រូវគេតិះដៀលក្នុងលោកនេះផង ក្នុងលោកខាងមុខផង ជាមនុស្សមានគំនិតអាក្រក់ ត្រូវកម្មរបស់ ខ្លួនបៀតបៀន ជាបុគ្គលមិនទៀង តែងធ្លាក់ទៅកាន់អបាយភូមិ

ផុដ្ឋគព្ភគហេជាវ ខុប្បុរេជ ។
សោ ឧបេតិ និរយំ បតាបនំ
សត្តិសូលនិវេកញ្ច អាយសំ
អាវសិត្វាន តិរច្ឆានយោនិយំ
បេតាសុរវិសយំ ន មុញ្ចតិ ។
ទិព្យា ចិត្តា រតិយោ ច នន្ទនេ
ចក្កវត្តិចរិតញ្ច មានុសេ
នាសយន្តិ បមុទា បមាទិនំ
ទុគ្គតិញ្ច បដិបាទយន្តិ នំ ។
ទិព្យា ចិត្តា រតិយោ ច ទុល្លភា
ចក្កវត្តិចរិតញ្ច មានុសេ
សោវណ្ណព្យម្ហនិលយា ច អច្ឆរា
យេ ចរន្តិ បមុជាហនក្ខិកា ។
កាមធាតុសមតិក្កមា គតិ
រូបធាតុសម្ភវេ ច ទុល្លភា
វីតកាមសំយុបបត្តិ យា
យេ ចរន្តិ បមុជាហនក្ខិកា ។



ដូចបេដែលរីមលាសាច ដើរទៅក្នុងទីទុរស្ថ ។ បុរសនោះរមែង ចូលទៅកាន់នរក ជាទីញុំាងសត្វឲ្យក្តៅ ទៅកាន់ស្រ័យដ៏ទីព្រោក មានបន្លាដូចលំពែងធ្វើអំពីដែកផង កំណើតតិរច្ឆានផង វិស័យនៃប្រេត និងអសុរកាយផង រមែងមិនរួចផុតបានទេ ។ ស្រីទាំងឡាយ រមែងញុំាងល្បែងជាទិព្វ ម្យ៉ាងនិងតម្រេក ក្នុងទីជាទីរីករាយ ម្យ៉ាងនិងសម្បត្តិចក្រពត្តិ ក្នុងទីជាលំនៅមនុស្សនៃបុគ្គលអ្នកប្រមាទ ឲ្យវិនាស ពួកស្រីរមែងញុំាងបុរសនោះ ឲ្យដល់នូវទុគ្គតិ ។ ល្បែងជាតម្រេកទិព្វ សម្បត្តិស្តេចចក្រពត្តិ ក្នុងទីជាលំនៅរបស់មនុស្ស និងពួកស្រីអប្សរមានពិមានមាសជាលំនៅ ជាសម្បត្តិដែលបុគ្គលមិនត្រេកអរដោយពួកស្រី ហើយប្រព្រឹត្ត (ព្រហ្មចរិយធម៌) មិនមែនបានដោយក្រទេ ។ គតិជាទីកន្លងផុតចាកកាមធាតុ គឺការកើតក្នុងរូបធាតុ និងការកើតក្នុងសុទ្ធាវាស ជាវិស័យរបស់អ្នកប្រាសចាកកាមៈ ជាសម្បត្តិដែលបុគ្គលមិនត្រេកអរ ដោយពួកស្រី ហើយប្រព្រឹត្ត (ព្រហ្មចរិយធម៌) មិនមែនបានដោយក្រទេ ។

សព្វុត្តុសមតិក្កម្ម សរិ
អច្ចន្តំ អចលិតំ អសន្ធិតំ
ចិត្តេហិ សុចិហិ ច តុល្យំ
យេ ចរន្តិ បមុញ្ចាហង្ការតិ ។

(៣១៦) កុណាលោហំ តទា អាសឹ ឧទាយី បុស្សកោកិលោ
អានន្ទោ គិជ្ឈរាជាសិ សារីបុត្តោ ច នារទោ
បរិសា ពុទ្ធបរិសា ឯវំ ធារេថ ជាតកន្តិ ។

កុណាលជាតកំ ចតុត្ថំ ។

# មហាសុតសោមជាតកំ

(៣១៧) កស្មា តុវំ រសក បដិសាសិ
ករោសិ កម្មានិ សុទារុណានិ
ហនាសិ ឥត្ថី បុរិសេ ច មូឡ្ហោ
មំសស្ស ហេតុ អទុ ធនស្ស ការណា ។



គុណជាតិដ៏ក្សេមក្សាន្ត គឺព្រះនិព្វាន ជាទីកន្លែងផុតចាកនូវទុក្ខទាំងពួង ជាអច្ចន្តសុខ មិនកម្រើក មិនមានបច្ច័យតាក់តែង បុគ្គលមិនត្រេកអរជាមួយស្រី ហើយប្រព្រឹត្ត ( ព្រហ្មចរិយធម៌ ) ជាអ្នកស្អាត មានកិលេសរលត់ មិនមែនបានដោយក្រោធ ។

(៣១៦) ( ព្រះសាស្តា ទ្រង់ប្រជុំជាតកនេះថា ) ក្នុងកាលនោះ កុណាលបក្សី បានមកជាតថាគត បុស្សកោកិលបក្សី បានមកជាឧទាយីភិក្ខុ ស្តេចត្មាត បានមកជាអានន្ទ នារទព្រាហ្មណ៍ បានមកជាសារីបុត្ត ពួកបរិស័ទបានមកជាពុទ្ធបរិស័ទ អ្នកទាំងឡាយចូរចាំទុកជាតកយ៉ាងនេះ ។

ចប់ កុណាលជាតក ទី ៤ ។

# មហាសុតសោមជាតក

(៣១៧) ( សេនាបតី សួរថា ) ម្នាលរសកៈ ( តាយពិសេស ) ព្រោះហេតុអ្វី អ្នកធ្វើនូវអំពើដ៏លាមកក្រៃលែង ព្រោកផ្សាខ្លះ អ្នកជាបុគ្គលវង្វេង សម្លាប់ពួកស្រីនិងប្រុស ព្រោះហេតុសាច់ ឬព្រោះហេតុទ្រព្យ ។

(៣១៦) ន អត្តហេតុ ន ធនស្ស ការណា
ន បុត្តទារស្ស សហាយញាតិនំ
ភត្តា ច មេ ភគវា ភូមិបាលោ
សោ ភុញ្ជតិ មំសំ ភទន្តេ បណីតំ ។

(៣១៧) សចេ តុវំ ភត្តុហេតុ បយុត្តោ
ករោសិ កម្មានិ សុទារុណានិ
បាតោ អន្តេបុរំ បាបុណិត្វា
លបេយ្យាសិ មេ រាជិនោ សម្មុខេ តំ ។

(៣១៨) តថា ករិស្សាមិ អហំ ភទន្តេ
យថា តុវំ ភាសសិ កាឡហត្ថិ
បាតោ អន្តេបុរំ បាបុណិត្វា
វក្ខាមិ តេ រាជិនោ សម្មុខេ តំ ។

(៣១៩) តតោ រត្យា វិវសានេ សុរិយស្សុគ្គមនំ បតិ
កាឡោ រសកមាទាយ រាជានំ ឧបសង្កមិ
ឧបសង្កមិត្វា រាជានំ ឥទំ វចនមព្រវិ ។
សច្ចំ កិរ មហារាជ រសកោ បេសិតោ តយា
ហនតិ ឥត្ថីបុរិសេ តុវំ មំសានិ ខាទសិ ។



(៣១៦) (នាយពិសេស ជំរាបថា) ខ្ញុំសម្លាប់ មិនមែនព្រោះហេតុខ្លួនឯង មិនមែនព្រោះហេតុទ្រព្យ មិនមែនព្រោះហេតុកូនប្រពន្ធ ឬសំឡាញ់និងញាតិទេ បពិត្រលោកដ៏ចំរើន ព្រោះថាព្រះភូមិបាលអ្នកមានបុណ្យ ជាម្ចាស់នៃខ្ញុំ ទ្រង់សោយនូវសាច់ប្រាកដដូច្នេះ ។

(៣១៧) (សេនាបតី...) បើអ្នកឯងខ្វល់ខ្វាយ ក្នុងកិច្ចរបស់ព្រះរាជាជាម្ចាស់ ហើយធ្វើនូវអំពើដ៏សាហាវក្រៃលែង អ្នកឯង លុះព្រឹកឡើង ចូលទៅកាន់ក្នុងព្រះរាជវាំងហើយ គប្បីនិយាយនូវដំណើរនោះប្រាប់ខ្ញុំ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ។

(៣១៨) (នាយពិសេស...) បពិត្រសេនាបតីឈ្មោះកាឡហត្ថីដ៏ចំរើន លោកនិយាយយ៉ាងណា ខ្ញុំនឹងធ្វើយ៉ាងនោះ ព្រឹកឡើងខ្ញុំនឹងចូលទៅកាន់ក្នុងព្រះរាជវាំង ហើយថ្លែងសេចក្តីនោះ ដល់លោក ក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ។

(៣១៩) (អភិសម្ពុទ្ធគាថា) គ្រានោះ កាលដែលរាត្រីភ្លឺច្បាស់ ព្រះអាទិត្យរះឡើងប្រាកដ សេនាបតីឈ្មោះកាឡហត្ថី ក៏នាំរសកៈចូលទៅគាល់ព្រះរាជា លុះចូលទៅដល់ហើយ ក៏ក្រាបទូលពាក្យនេះ ចំពោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គប្រើរសកៈឲ្យទៅសម្លាប់ស្រីប្រុស ព្រះអង្គទ្រង់សោយសាច់មនុស្ស ។

(៣៦០) ឯវមេវ តុវំ កាឡ  រសគេធោ ហេសិតោ មយា

មម អត្ថំ ការេន្តស្ស  ហាមេតំ បរិកាសសិ ។

(៣៦១) អាឆេត្វា សព្ទមញ្ញានំ  ទាធិត្វា សេតធ្ទិមា

បរិត្តមាយ បរិសាយ  អត្តាចំ ទាធិយា មតោ ។

ឯវំ បមត្តោ សេតាកោ រតោ

តាកោ យតី ភាយេតិ តាវទុជ្ជ្យសិ[១]

វិគម្ម បុត្តេ ចជិ[២] ញាតកេ ច

បរិត្តិយ អត្តានញ្ញេវ ទាធតិ ។

តំ តេ សុត្វាន វិគតុ ឆន្ទោ

មា ភក្ខយិ រាជ មនុស្សមំសំ

មា ត្វំ ឥមំ កេវលំ វារិជោវ

ទ្វិបទាធិប សុញ្ញមកាសិ រដ្ឋំ ។

(៣៦២) សុជាតោ នាម នាមេន  ទិរសោ តស្ស អត្រជោ

ជម្ពុបេសឹ អលទ្ធាន  មតោ សោ តស្ស សង្ខ័យេ

ឯវមេវ អហំ កាឡ  ភុត្វា ភក្ខំ រសុត្តមំ

អលទ្ធា មានុសំ មំសំ  មញ្ញេ ហេស្សាមិ ជីវិតំ ។

---

១ ម. តាវទុជ្ជ្យតិ ។ ម. ភាយតិ តាវទុជ្ជ្យតិ ។ ២ ម. ចជិត្វា ។



(៣៦០) (ព្រះរាជា...) ម្នាលកាឡហត្ថិ ខ្ញុំបានប្រើសេកៈដ៏ញោះមួយ ហេតុអ្វីអ្នកនេះប្រហែលសេកប្រុសៈ ដែលធ្វើប្រយោជន៍ឲ្យខ្ញុំនុ៎ះ ។

(៣៦១) (កាឡហត្ថិ...) ក្រពើឈ្មោះអាខុ ជាប់ចិត្តនឹងរស ស៊ីខ្លាញ់ពួកក្រពើតិចតួច កាលបើក្រពើជាប់រាំងអស់ហើយ ក៏ទៅស៊ីកន្ទុយខ្លួនឯងស្លាប់ទៅ ។ ព្រះអង្គជាអ្នកប្រមាទ ត្រេកអរក្នុងរសដែលគួរគោរព បើព្រះអង្គនៅជាបុថុជ្ជនពាល មិនយល់ហេតុអ្វីតទៅយ៉ាងនេះទេ ព្រះអង្គនឹងលះបង់ចោលប្រពន្ធកូនទាំងឡាយផង នូវពួកញាតិផង ដូចក្រពើឈ្មោះអាខុក្រឡប់ស៊ីខ្លួនឯង ។ បពិត្រព្រះរាជា សូមសេចក្ដីប្រាថ្នារបស់ព្រះអង្គប្រាសចេញទៅ ព្រោះបានស្ដាប់ព្រះសណ្ដាប់នូវពាក្យនេះ សូមព្រះអង្គកុំសោយសាច់មនុស្ស បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ សូមព្រះអង្គកុំធ្វើដែននេះឲ្យសោះសូន្យ ដូចក្រពើឈ្មោះអាខុ ធ្វើមហាសមុទ្រទាំងមូលនេះឲ្យសូន្យ (ពីត្រី) ។

(៣៦២) (ព្រះរាជា..) កូនបង្កើតរបស់សុជាតកុដុម្ពីនោះ ឈ្មោះសុជាតៈតាមឈ្មោះ មិនបានស៊ីផ្លែព្រីងហើយស្លាប់ទៅ ព្រោះអស់ផ្លែព្រីងនោះ (យ៉ាងណា) ម្នាលកាឡហត្ថិ ខ្ញុំបរិភោគនូវអាហារមានរសដ៏ឧត្តម បើមិនបានសាច់មនុស្សទេ ប្រហែលជានឹងលះបង់នូវជីវិត ក៏យ៉ាងនោះដែរ ។

(៣៦៣) មាណវ អភិរូបោសិ កុលេ ជាតោសិ សោត្ថិយេ
ន ត្វំ អរហសិ តាត អភក្ខំ ភក្ខយេតវេ ។

(៣៦៤) រសានញ្ញតរំ ឯតំ កស្មា មំ ត្វំ និវារយេ
សោហំ តត្ថ គមិស្សាមិ យត្ថ លច្ឆាមិ ឯទិសំ ។
សោហំ និប្បតិស្សាមិ ន តេ វច្ឆាមិ សន្តិកេ
យស្ស មេ ទស្សនេន ត្វំ នាភិនន្ទសិ ព្រាហ្មណ ។

(៣៦៥) អទ្ធា អញ្ញេបិ ទាយាទេ បុត្តេ លច្ឆាម មាណវ
ត្វញ្ច ជម្ម វិនស្សស្សុ យត្ថ បត្តំ ន តំ សុណេ ។

(៣៦៦) ឯវមេវ តុវំ ព្រហ្មេ និបទិន្ន[១] សុណោហិ មេ
បព្វាជិស្សន្តិ តំ រដ្ឋា សោណ្ឌំ មាណវកំ យថា ។

(៣៦៧) សុជាតោ នាម នាមេន ភាវិតត្តាន សាវកោ
អច្ឆរំ កាមយន្តោវ ន សោ ភុញ្ជិ ន សោ បិវិ ។

១ ម. រូបទិន្ន ។



(៣៦៣) (កាឡហត្ថីនាំរឿងព្រាហ្មណ៍ថា) ម្នាលមាណពកូន អ្នកមានរូបស្រស់បស់ កើតក្នុងត្រកូលសោត្ថិយៈ ម្នាលកូន អ្នកមិនគួរស៊ីនូវភោជន ដែលមិនគួរស៊ីទេ ។

(៣៦៤) (មាណព...) បណ្តារសជាតិទាំងឡាយ ទឹកសុរានេះ រសជាជា ទឹកមានរសមួយដែរ ព្រោះហេតុអ្វី ទើបលោកឪពុកឃាត់ខ្ញុំ ខ្ញុំបាននូវទឹកសុរានេះក្នុងទីណា ខ្ញុំនឹងទៅក្នុងទីនោះ ។ បពិត្រព្រាហ្មណ៍ឪពុក បើលោកឪពុកមិនត្រេកអរនឹងការឃើញខ្ញុំណា ខ្ញុំនោះនឹងចេញទៅ (អំពីស្រុក) ខ្ញុំមិននៅក្នុងសំណាក់លោកឪពុកទេ ។

(៣៦៥) (ព្រាហ្មណ៍...) នែមាណពកូន យើងនឹងបាននូវកូនទាំងឡាយឯទៀត ទទួលមត៌កដោយពិត នែកូនថោកទាប ឯងចូរវិនាសចុះ លំនៅដែលកូនទៅដល់ក្នុងទីណា សូមកុំឲ្យអញឮនូវទីនោះ ។

(៣៦៦) (កាឡហត្ថី...) បពិត្រព្រះមហាក្សត្រិយ៍ ជាធំជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំ ពួកប្រជាជន នឹងបណ្តេញព្រះអង្គចាកដែន ដូចមាណពអ្នកលេងស៊ីផឹកដូច្នោះ ។

(៣៦៧) (ព្រះពុទ្ធ...) សាវក របស់ពួកឥសី អ្នកមានខ្លួនអប់រំហើយ ជាសាវកឈ្មោះសុជាតៈ ប្រាថ្នានូវស្រីអប្សរ ទើបសាវកនោះ មិនស៊ី មិនផឹកទេ ។

កុសគ្គេនុទកមាទាយ   សមុទ្ទេ ឧទកំ មិនេ

ឯវំ មានុសកា កាមា   ទិព្វកាមាន សន្តិកេ ។

ឯវមេវ អហំ កាឡ   ភុត្វា ភត្តំ រសុត្តមំ

អលទ្ធា មានុសំ មំសំ   មញ្ញេ ហេស្សាមិ ជីវិតំ ។

(៣៦៨) យថាបិ តេ ធតរដ្ឋា   ហំសា វេហាយសង្គមា

អយុត្តបរិភោគេន   សព្វេ អព្ភត្ថំ គតា ។

ឯវមេវ តុវំ រាជ   ទិបទិន្ទ សុណោហិ មេ (១)

អភក្ខំ រាជ ភក្ខេសិ   តស្មា បព្វាជិស្សន្តិ តំ ។

(៣៦៩) តិដ្ឋាហីតិ មយា វុត្តោ   សោ ត្វំ គច្ឆសិ បម្មុខោ

អដ្ឋិតោ ត្វំ ឋិតោម្ហីតិ   លបសិ ព្រហ្មចារិនិ

ឥទំ តេ សមណាយុត្តំ   អសិញ្ច មេ មញ្ញសិ កង្ខបត្តំ

១ ម. បព្វាជេន្តិ ។



បុគ្គលយកទឹកដោយចុងស្បូវមកប្រៀបធៀបនឹងទឹកក្នុងសមុទ្រ យ៉ាងណា កាមទាំងឡាយជារបស់មនុស្ស (ប្រៀបធៀប) ក្នុងសំណាក់នៃកាមជាទិព្វក៏យ៉ាងនោះដែរ ។ ម្នាលកាឡហត្ថី ខ្ញុំបរិភោគនូវអាហារមានរសដ៏ឧត្តម បើមិនបានសាច់មនុស្សទេ ប្រហែលជាលះបង់ជីវិត យ៉ាងនោះឯង ។

(៣៦៨) (កាឡហត្ថី...) ដូចយ៉ាងពួកបក្សីហង្សឈ្មោះធតរដ្ឋៈទាំងនោះ ជាសត្វហើរទៅកាន់អាកាស ដល់នូវសេចក្តីវិនាសទាំងអស់គ្នា ព្រោះស៊ីនូវចំណីមិនគួរ ។ បពិត្រព្រះរាជាជាធំជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំ បពិត្រព្រះរាជា ព្រះអង្គក៏សោយអាហារ ដែលមិនគួរសោយ ក៏យ៉ាងនោះឯង ពួកប្រជាជននឹងបណ្តេញព្រះអង្គ (ចាកដែន) ក៏យ៉ាងនោះដែរ ។

(៣៦៩) (ព្រះរាជា...) អ្នកកាលដែលខ្ញុំនិយាយថា អ្នកឈប់សិន ហើយបែរជាដើរទៅមុខ ម្នាលអ្នកជាព្រហ្មចារី អ្នកមិនឈប់តែនិយាយថា ខ្ញុំឈប់ហើយ ពាក្យនេះមិនគួរដល់អ្នកជាសមណៈទេ អ្នកសំគាល់នូវដាវរបស់ខ្ញុំ គួរដល់សេចក្តីសង្ស័យដែរឬ ។

(៣៣០) បិតោ ហាមស្មិ សទ្ធម្មេសុ កថំ

ន ធាមកោត្តំ បរិវត្តយាមិ

ហោរញ្ញ លោកេ អបិតំ វជេដ្ឋំ

មាតាបិតំ ទេវបិតំ នរោ ចុតំ ។

សចេ តុវំ សត្តុហរំ កថំ សុតំ គណ្ហាហិ ខត្តិយំ

តេន យញ្ញំ យជិត្វាន ឯវំ សគ្គំ គមិស្សសិ ។

(៣៣១) កិស្មឹ នុ រដ្ឋេ តវ ជាតិភូមិ

អថ កេន អត្ថេន ឥធានុបត្តោ

អក្ខាហិ មេ ព្រាហ្មណ ឯតមត្ថំ

កិមិច្ឆសិ ទេមិ តយជ្ជ បត្ថិតំ ។

(៣៣២) គាថា ចតស្សោ ធរណីមហិស្សរ

សុគម្ភីរត្ថា វរសាគរូបមា

តវេវ អត្ថាយ ឥធាគតោស្មិ

សុណោហិ គាថា បរមត្ថសញ្ហិតា ។



(៣៣០) (ចរតា...) បពិត្រព្រះរាជា សត្វជាអ្នកឈប់ ក្នុងព្រះសទ្ធម្មទាំងឡាយ មិនត្រូវប៉ះប្រទាមនឹងកោត្រទេ អ្នកប្រាជ្ញទាំងឡាយ តែងក្រោលឡើងទៅជាមិនឈប់ក្នុងលោក ដែលឡើកស៊ីតលោកនេះទៅជាអ្នកទៅកាន់អបាយ កាន់នរក ។ បពិត្រព្រះរាជា បើព្រះអង្គជឿ ចូរព្រះអង្គចាប់សុតសោមជាក្សត្រិយ៍មកបូជាយញ្ញ ព្រះអង្គនឹងទៅកាន់ឋានសួគ៌ ដោយការបូជានោះ ។

(៣៣១) (ព្រះរាជាសុតសោម...) ជាតិភូមិរបស់អ្នក ក្នុងដែនណាមួយទៀត អ្នកមកដល់ក្នុងទីនេះ ដោយប្រយោជន៍ ដូចម្តេច ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុះដល់ខ្ញុំ អ្នកប្រាថ្នារបស់អ្វី ខ្ញុំនឹងឲ្យនូវរបស់នោះ តាមដែលអ្នកប្រាថ្នា ក្នុងថ្ងៃនេះ ។

(៣៣២) (ខ្ញុំព្រាហ្មណ៍...) បពិត្រព្រះអង្គជាមហិស្សរៈលើដែនដី គាថាទាំងឡាយ ៤ បទ មានអត្ថដ៏ជ្រៅ ប្រសើរក្រៃលែង ប្រៀបដូចជាសាគរ ខ្ញុំមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ព្រះអង្គតែម្យ៉ាង សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវគាថា ដែលប្រកបដោយប្រយោជន៍ដ៏ប្រសើរ ។

(៣៣៣) ន វេ នុតប្បន្តិ មតិមន្តោ សបញ្ញា
ពហុស្សុតា យេ ពហុឋានចិន្តិនោ
ទីបំ ហិ ឯតំ បរមំ នរានំ
យំ បណ្ឌិតា សោកនុទា ភវន្តិ ។
អត្តាន ញាតី ឧទាហុ បុត្តទារំ
ធញ្ញំ ធនំ រជតំ ជាតរូបំ
កិមេវ ត្វំ សុតសោមានុតប្បេ
កោរព្យ សេដ្ឋ វចនំ សុណោម តេ ។

(៣៣៤) ន ចាហមត្តានមនុត្ថុនាមិ[1]
ន បុត្តទារំ ន ធនំ ន រដ្ឋំ
សតញ្ច ធម្មោ ចរិតោ បុរាណោ
តំ សង្គរំ ព្រាហ្មណស្សានុតប្បេ ។
កតោ មយា សង្គរោ ព្រាហ្មណេន
រដ្ឋេ សកេ ឥស្សរិយេ ឋិតេន
តំ សង្គរំ ព្រាហ្មណសប្បទាយ
សច្ចានុរក្ខី បុនរាវជិស្សំ ។

[1] ម. នេវាហមត្តានមនុត្ថុនាមិ ។



(៣៣៣) (ព្រះបាទកោរព្យ...) បណ្ឌិតទាំងឡាយណា ជាអ្នកមានយោបល់ ប្រកបដោយបញ្ញា ជាពហុស្សូត្រ គិតនូវហេតុបានច្រើនយ៉ាង រមែងមិនយំទេ បណ្ឌិតទាំងឡាយនោះ ជាអ្នកបន្ទោបង់នូវសេចក្ដីសោក ដោយហេតុណាពិត ហេតុនុ៎ះជាទីពឹងដ៏ប្រសើរ របស់ជនទាំងឡាយ ។ បពិត្រព្រះបាទសុតសោម ព្រះអង្គសោកស្ដាយចំពោះខ្លួន ញាតិ ឬកូនប្រពន្ធ ស្រូវ ទ្រព្យ ប្រាក់ មាស ឬអ្វី បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ យើងនឹងស្ដាប់ពាក្យរបស់លោក ។

(៣៣៤) (ព្រះបាទសុតសោម...) ខ្ញុំមិនសោកស្ដាយចំពោះខ្លួន មិនសោកស្ដាយចំពោះកូនប្រពន្ធ មិនសោកស្ដាយចំពោះទ្រព្យ មិនសោកស្ដាយចំពោះផែនដី (មាន) បុរាណធម៌ ជាចរិតរបស់សប្បុរសទាំងឡាយ ខ្ញុំសោកស្ដាយនឹងការបដិញ្ញានោះ ចំពោះព្រាហ្មណ៍ ។ ការបដិញ្ញានឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរិយភាពក្នុងដែនរបស់ខ្លួន បានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ នឹងដោះនូវការបដិញ្ញានោះ របស់ព្រាហ្មណ៍ ហើយនឹងត្រឡប់មកវិញ ។

[៣៣៥] ន ភាយាមេតំ អតិសទ្ទហាមិ

សុខី នរោ បច្ចុមុខា បមុត្តោ

អមិត្តហត្ថំ បុនរាវជេយ្យ

កោរព្យ សេដ្ឋ ន ហិ មំ ឧបេតិ ។

មុត្តោ តុវំ បោរិសាទស្ស ហត្ថា

គន្ត្វា សកំ មន្ទិរំ កាមកាមី

មធុរំ បិយំ ជីវិតំ លទ្ធ រាជ

កុតោ តុវំ ឯហិសិ មេ សកាសំ ។

[៣៣៦] មតំ វរេយ្យ បរិសុទ្ធសីលោ

ន ជីវិតំ គរហិតោ បាបធម្មោ

ន ហិ តំ នរំ តាយតេ ទុគ្គតីហិ

យស្សាបិ ហេតុ អលិកំ ភណេយ្យ ។

សចេបិ វាតោ គិរិមាវហេយ្យ

ចន្ទោ ច សុរិយោ ច ឆមា បតេយ្យុំ

សព្វា ច នជ្ជោ បដិសោតំ វជេយ្យុំ

ន ត្វេវហំ រាជ មុសា ភណេយ្យំ ។



(៣៣៥) (ព្រះបាទបោរិសាទ...) ខ្ញុំមិនជឿនូវពាក្យនុ៎ះជាដ៏ មានសេចក្ដីសុខ បានរួចអំពីមាត់នៃមច្ចុហើយ ត្រឡប់មកកាន់ដៃនៃសត្រូវវិញដូច្នេះទេ បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ ព្រះអង្គនឹងមិនមកកាន់ខ្ញុំទេ ។ បពិត្រព្រះរាជា ព្រះអង្គបានរួចអំពីដៃនៃព្រះបាទបោរិសាទហើយ មានប្រាថ្នា ទៅកាន់មន្ទីររបស់ខ្លួន ហើយបាននូវជីវិត ជាទីស្រឡាញ់ពេញចិត្ត ការណា ព្រះអង្គនឹងមកកាន់សំណាក់របស់ខ្ញុំវិញ ។

[៣៣៦] (ព្រះបាទសុតសោម...) បុគ្គលអ្នកមានសីលបរិសុទ្ធ គប្បីប្រាថ្នានូវសេចក្ដីស្លាប់ ឯបុគ្គលអ្នកមានធម៌ដ៏លាមក ដែលពួកអ្នកផងតិះដៀល មិនគួរចង់រស់ឡើយ បុគ្គលក្រសួងសីល ពោលនូវពាក្យមិនពិត ព្រោះហេតុខ្លួនណា ខ្លួននោះ គប្បីមិនការពារនូវជននោះចាកទុគ្គតិបានឡើយ ។ បើទុកជាខ្យល់បក់នាំភ្នំបានក្ដី ព្រះចន្ទ្រនិងព្រះអាទិត្យ ធ្លាក់មកលើផែនដីក្ដី ទឹកស្ទឹងទាំងអស់ ហូរច្រាសខ្សែទឹកក្ដី បពិត្រព្រះរាជា ខ្ញុំក៏មិនពោលពាក្យកុហកទេ ។

(៣៣៧) នភំ ផលេយ្យ ឧទធិ វិសុស្សេ
សំវដ្ដេយ្យ ភូតធរា វសុន្ធរា
សិលុច្ចយោ មេរុ សមូលមុប្បតេយ្យ
ន ត្វេវហំ រាជ មុសា ភណេយ្យំ ។

(៣៣៨) អសិញ្ច សត្តិញ្ច បរាមសាមិ
សបថំបិ តេ សម្ម អហំ ករោមិ
តយា បមុត្តោ អននោ ភវិត្វា
សច្ចានុរក្ខី បុនរាវជិស្សំ ។

(៣៣៩) យោ តេ កតោ សង្គរោ ព្រាហ្មណេន
រដ្ឋេ សកេ ឥស្សរិយេ ឋិតេន
តំ សង្គរំ ព្រាហ្មណសប្បទាយ
សច្ចានុរក្ខី បុនរាវជស្សុ ។

(៣៤០) យោ មេ កតោ សង្គរោ ព្រាហ្មណេន
រដ្ឋេ សកេ ឥស្សរិយេ ឋិតេន
តំ សង្គរំ ព្រាហ្មណសប្បទាយ
សច្ចានុរក្ខី បុនរាវជិស្សំ ។

(៣៤១) មុត្តោ ច សោ បោរិសាទស្ស ហត្ថា
គន្ត្វាន តំ ព្រាហ្មណំ ឯតទវោច



(៣៣៧) មេឃបែកធ្លាយ ទឹកសមុទ្រនឹងស្ងួត ឬផែនដីជាទីទ្រទ្រង់នូវសត្វប្រែត្រឡប់ ឬភ្នំឈ្មោះមេរុលើនឹងឥតឫស ខ្ញុំក៏មិនពោលពាក្យកុហកទេ ។

(៣៣៨) ខ្ញុំចាប់ដាវនិងលំពែង បពិត្រទ្រង់ជាសំឡាញ់ ខ្ញុំនឹងធ្វើនូវសម្បថចំពោះទ្រង់ ខ្ញុំរួចចេញអំពីទ្រង់ ជាអ្នកមិនមានបំណុល រក្សានូវសច្ចៈ នឹងត្រឡប់មកវិញ ។

(៣៣៩) (ព្រះបាទបោរិសាទ...) ការប្តេជ្ញាណា ជាមួយនឹងព្រាហ្មណ៍ ដែលព្រះអង្គឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួន បានធ្វើហើយ សូមព្រះអង្គជាអ្នករក្សានូវសច្ចៈ រំដោះនូវការប្តេជ្ញានោះនឹងព្រាហ្មណ៍ហើយ ចូរត្រឡប់មកវិញ ។

(៣៤០) (ព្រះបាទសុតសោម...) ការប្តេជ្ញាណា ជាមួយនឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅ ក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួន បានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ នឹងរំដោះនូវការប្តេជ្ញានោះនឹងព្រាហ្មណ៍ហើយ នឹងត្រឡប់មកវិញ ។

(៣៤១) (គាថាសម្ពន្ធ) ព្រះបាទសុតសោមនោះ រួចពីព្រះហស្តនៃព្រះបាទបោរិសាទ ហើយទៅ បានពោលពាក្យនេះនឹងព្រាហ្មណ៍នោះថា

សុណោមិ គាថាយោ សតារហាយោ
យា មេ សុតា អស្សុ ហិតាយ ព្រហ្មេ ។

[៣៦២] សកិទេវ សុតសោម សព្ភិ ហោតិ សមាគមោ
សា នំ សង្គតិ បាលេតិ នាសព្ភិ ពហុសង្គមោ ។
សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ។

ជីរន្តិ វេ រាជរថា សុចិត្តា
អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តិ ។

នភញ្ច ទូរេ បឋវី ច ទូរេ
បារំ សមុទ្ទស្ស តទាហុ ទូរេ
តតោ ហវេ ទូរតរំ វទន្តិ
សតញ្ច ធម្មោ អសតញ្ច រាជ ។



ម្នាលព្រាហ្មណ៍ ខ្ញុំសូមស្តាប់នូវគាថាទាំងឡាយ ដែលគួរដល់ថ្លៃ ១០០ កហាបណៈ ជាគាថាដែលខ្ញុំស្តាប់ហើយមានប្រយោជន៍ ។

[៣៦២] (ព្រាហ្មណ៍...) បពិត្រព្រះសុតសោម ការជួបប្រទះដោយសប្បុរសទាំងឡាយ អស់វារៈតែម្តង ការជួបប្រទះនោះ រមែងរក្សានូវបុគ្គលនោះបាន ឯការជួបជុំដោយពួកអសប្បុរសជាច្រើនដង រមែងមិនរក្សានូវបុគ្គលនោះបានទេ ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាល នឹងពួកសប្បុរស គុណធម៌ដ៏ប្រសើរ រមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្ម របស់ពួកសប្បុរស មិនមែនជាគុណធម៌លាមកឡើយ ។ រាជរថទាំងឡាយ ដែលគេចេនាល្អហើយ រមែងគ្រាំគ្រាទៅវិញ សូម្បីសរីរៈ (នៃពួកសត្វ) ក៏រមែងដល់នូវសេចក្តីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរសទាំងឡាយ រមែងមិនដល់នូវសេចក្តីគ្រាំគ្រាទេ ពួកសប្បុរស រមែងចរចាដោយពួកសប្បុរស ។ អាកាសនិងផែនដី ឋិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយ ពោលនូវត្រើយសមុទ្រថាឆ្ងាយ បពិត្រព្រះរាជា អ្នកប្រាជ្ញទាំងឡាយ ពោលនូវធម៌ របស់ពួកសប្បុរស នឹងពួកអសប្បុរសថា ឆ្ងាយជាងនោះទៅទៀត ។

(៣៤៣) សាហស្សិយោ ឥមា គាថា នយិមា គាថា សតារហា
ចត្តារិ ត្វំ សហស្សានិ ខិប្បំ គណ្ហាហិ ព្រាហ្មណ ។

(៣៤៤) អាសីតិយា នាវុតិយា ច គាថា
សតារហា ចាបិ ភវេយ្យ គាថា
បច្ចត្តមេវ សុតសោម ជានាហិ
សាហស្សិយា នាម កា អត្ថិ គាថា ។

(៣៤៥) ឥច្ឆាមិ វោហំ សុតវុទ្ធិមត្តនោ
សន្តោតិ មំ សប្បុរិសា ភជេយ្យុំ
អហំ សវន្តីហិ មហោទធីវ
ន ហិ តាត តប្បាមិ សុភាសិតេន ។
អគ្គិ យថា តិណកដ្ឋំ ទហន្តោ
ន តប្បតិ សាគរោវ នទីហិ
ឯវម្បិ តេ បណ្ឌិតា រាជសេដ្ឋ
សុត្វា ន តប្បន្តិ សុភាសិតេន ។



(៣៤៣) (ព្រះបាទសុតសោម...) គាថាទាំងនេះ គួរដល់ថ្លៃ ១ ពាន់កហាបណៈ គាថាទាំងនេះ មិនគួរដល់ថ្លៃត្រឹម ១០០ កហាបណៈទេ ម្នាលព្រាហ្មណ៍ លោកចូរទទួលយកកហាបណៈ ៤ ពាន់ ជាប្រញាប់ចុះ ។

(៣៤៤) (ព្រះបិតា...) គាថាមានថ្លៃ ៨០ កហាបណៈ ៩០ កហាបណៈ នឹងគាថាគួរដល់ថ្លៃ ១០០ កហាបណៈ ម្នាលសុតសោម អ្នកចូរដឹងដោយខ្លួនឯងចុះ គាថាដូចម្តេចដែលឈ្មោះថាគួរដល់ថ្លៃ ១ ពាន់កហាបណៈ ។

(៣៤៥) (ព្រះបាទសុតសោម...) ខ្ញុំព្រះអង្គប្រាថ្នានូវសេចក្តីចំរើនដោយសុតៈគឺការចេះដឹង ដើម្បីខ្លួន សប្បុរសទាំងឡាយ អ្នកមានចិត្តស្ងប់ គប្បីគប់រកខ្ញុំព្រះអង្គ បពិត្រព្រះបិតា ខ្ញុំព្រះអង្គ មិនឆ្អែតដោយសុភាសិត ដូចជាមហាសមុទ្រមិនឆ្អែតដោយទឹកស្ទឹងដែលហូរចូលទៅ ។ ភ្លើងកាលឆេះស្មៅនឹងឈើ រមែងមិនឆ្អែត សាគរមែងមិនឆ្អែតដោយទឹកស្ទឹងទាំងឡាយ បពិត្រព្រះរាជាដ៏ប្រសើរ បណ្ឌិតទាំងឡាយនោះ បានស្តាប់ហើយ ក៏មិនឆ្អែតដោយសុភាសិតក៏យ៉ាងនោះដែរ ។

សរាសស្ស ពាសស្ស យថា សុណោមិ
កថំ អហំ អត្ថនិ ជនិន្ទ
ឥមេវ សត្តុ ពិសាមយាមិ
ន ហិ តាត ធម្មេសុ មមត្ថិ តិត្តិ ។

(៣៦៦) ឥទញ្ច រដ្ឋំ សធនំ សយោគ្គំ
សកាយុរំ សព្វកាមូបបន្នំ
កិំ កាមហេតុ បរិភាសសេ មំ
គច្ឆាមហំ ពោរិសាទស្ស ញត្តេ[១] ។

(៣៦៧) អត្តានុរក្ខាយ ភវន្តិ ហេតេ
ហត្ថារោហា រថិកា បត្តិកា ច
អស្សារោហា យេ ច ធនុគ្គហាសេ
សេនំ បយុញ្ជាម ហនាម សត្តុំ ។

(៣៦៨) សុទុក្ករំ ពោរិសាទោ អកាសិ
ជីវំ គហេត្វាន អវស្សជី មំ
តំ តាទិសំ បុព្វកិច្ចំ សរន្តោ
ទុព្ភេ អហំ តស្ស កថំ ជនិន្ទ ។

១ ម. ពោរិសាទស្ស បន្តេ ។



បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គស្តាប់នូវគាថា ដែលមានប្រយោជន៍របស់តាបសនៃខ្លួន គ្រប់កាលណា គ្រប់កាលណា ខ្ញុំព្រះអង្គតែងជឿស្តាប់នូវគាថានោះឯងដោយគោរព បពិត្រព្រះបិតា ខ្ញុំព្រះអង្គមិនមានសេចក្តីឆ្អែត ក្នុងធម៌ទាំងឡាយទេ ។

(៣៦៦) ដែនរបស់ព្រះអង្គនេះ ព្រមទាំងទ្រព្យ ព្រមទាំងយាន ព្រមទាំងគ្រឿងប្រដាប់កាយ បរិបូណ៌ដោយកាម គួរព្រះទ្រង់គ្រប់យ៉ាង ព្រះអង្គនៅប្រទេចខ្ញុំព្រះអង្គ ព្រោះហេតុនៃសេចក្តីប្រាថ្នាដូចម្តេច ខ្ញុំព្រះអង្គនឹងទៅកាន់សំណាក់នៃព្រះបាទពោរិសាទ ។

(៣៦៧) (ព្រះបិតា...) ដើម្បីរក្សាពលទាំងនុ៎ះ គឺពលដំរី ពលរថ ពលថ្មើរជើង ពលសេះ និងនាយខ្មាន់ធ្នូ ក៏មានសម្រាប់រក្សាខ្លួន យើងនឹងលើកពលសេនាទៅសម្លាប់សត្រូវ ។

(៣៦៨) (ព្រះបាទសុតសោម...) ព្រះបាទពោរិសាទ បានធ្វើនូវអំពើដ៏កម្រក្រៃលែង ចាប់ខ្ញុំព្រះអង្គទាំងរស់ ហើយលែងវិញ បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គ រឭកឃើញនូវឧបការគុណក្នុងកាលមុនប្រាកដដូច្នោះ ខ្ញុំនឹងប្រទូស្តចំពោះស្តេចពោរិសាទនោះដូចម្តេចកើត ។

(៣៧៩) វន្ទិត្វា សោ បិតរំ មាតរញ្ច
អនុសាសេត្វា នេគមញ្ច ពលញ្ច
សច្ចវាទី សច្ចានុរក្ខមានោ
អគមាសិ សោ យត្ថ បោរិសាទោ ។

(៣៨០) កតោ មយា សង្គរោ ព្រាហ្មណេន
រដ្ឋេ សកេ ឥស្សរិយេ ឋិតេន
តំ សង្គរំ ព្រាហ្មណស្សប្បទាយ
សច្ចានុរក្ខី បុនរាវជិស្សំ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។

(៣៨១) ន ហាយតេ ខាទិតុំ មយ្ហំ បច្ឆា
ចិតកា អយំ តាវ សធូមិកា ច
និទ្ធូមកេ បចិតំ សាធុ បក្កំ
សុណោម តាវ គាថាយោ សុភាសិតាយោ ។

(៣៨២) អធម្មិកោ ត្វំ បោរិសាទកាសិ
រដ្ឋា ច ភដ្ឋោ ឧទរស្ស ហេតុ
ធម្មញ្ចិមា អភិវទន្តិ គាថា
ធម្មោ អធម្មោ ច កុហិំ សមេតិ ។



(៣៧៩) (អភិសម្ពុទ្ធគាថា) ព្រះបាទសុតសោម ក្រាបថ្វាយបង្គំលាព្រះបិតាមាតា ប្រៀនប្រដៅអ្នកនិគមនិងពលសេនា ព្រះអង្គពោលនូវពាក្យសច្ចៈ រក្សានូវពាក្យសច្ចៈ ហើយក៏ទៅកាន់សំណាក់នៃព្រះបាទបោរិសាទ ។

(៣៨០) (ព្រះបាទសុតសោម...) ការប្ដេជ្ញានឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួនបានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ ដោះប្ដេជ្ញានឹងព្រាហ្មណ៍ហើយត្រឡប់មកវិញ បពិត្រព្រះបាទបោរិសាទ ចូរព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយនូវខ្ញុំចុះ ។

(៣៨១) (ព្រះបាទបោរិសាទ...) ខ្ញុំមិនបាត់ទេ ចាំខ្ញុំស៊ីជាការក្រោយចុះ ព្រោះរងើកភ្លើងនេះ ប្រកបដោយផ្សែងនៅឡើយ សាច់ដែលចំអិន លើរងើកឥតផ្សែង ជាសាច់ឆ្អិនល្អ យើងនឹងស្ដាប់នូវគាថារបស់ទ្រង់ ដែលគួរថ្លៃ ១០០ កហាបណៈ សិន ។

(៣៨២) (ព្រះបាទសុតសោម...) ព្រះអង្គជាអធម្មិករាជ ជាអ្នកស៊ីនូវបុរស ត្រាត់ក្រាត់អំពីដែន ព្រោះហេតុតែពោះ គាថាទាំងឡាយនេះ រមែងប្រកាសសុចរិតធម៌ ចំណែកធម៌និងអធម៌ ស្របគ្នាក្នុងទីណាកើត ។

អធម្មិកស្ស លុទ្ទស្ស និច្ចំ លោហិតបាណិនោ
នត្ថិ សច្ចំ កុតោ ធម្មោ តំ សុតេន ករិស្សសិ ។

(៣៩៣) យោ មំសហេតុ មិគវំ ចរេយ្យ[១]
យោ វា ហនេ[២] បុរិសមត្តហេតុ
ឧភោបិ តេ បេច្ច សមា ភវន្តិ
កស្មា នោ អធម្មិកំ ព្រូសិ មំ ត្វំ ។

(៣៩៤) បញ្ច បញ្ចនខា ភក្ខា ខត្តិយេន បជានតា
អភក្ខំ រាជ ភក្ខេសិ តស្មា អធម្មិកោ តុវំ ។

(៣៩៥) មុត្តោ តុវំ បោរិសាទស្ស ហត្ថា
គន្ត្វា សកំ មន្ទិរំ កាមកាមី
អមិត្តហត្ថំ បុនរាគតោសិ
ន ខត្តធម្មេ កុសលោសិ រាជ ។

(៣៩៦) យេ ខត្តធម្មេ កុសលា ភវន្តិ
បាយេន តេ នេរយិកា ភវន្តិ

១–២ ចរេយ្យ ។ ហន្តិ ។



ព្រះអង្គជាអធម្មិកជន ព្រះហស្តប្រឡាក់ឈាមជានិច្ច មិនមានសច្ចៈ ធម៌នឹងមានមកអំពីណា ព្រះអង្គនឹងធ្វើអ្វីដោយការស្ដាប់ ។

(៣៩៣) (ព្រះបាទបោរិសាទ...) បុគ្គលណាត្រាច់ទៅកាន់ព្រៃសម្លាប់ម្រឹគព្រោះហេតុតែសាច់ ឬសម្លាប់បុរសព្រោះហេតុតែខ្លួន បុគ្គលទាំងពីរនោះ ស្មើគ្នាក្នុងលោកខាងមុខ ហេតុអ្វីព្រះអង្គហៅខ្ញុំថាជាអធម្មិកជន ។

(៣៩៤) (ព្រះបាទសុតសោម...) ក្សត្រិយ៍ជាអ្នកចេះដឹង មិនគួរសោយនូវពួកសត្វ ៥ មិន ៥ ទេ បពិត្រព្រះរាជា ព្រះអង្គសោយនូវសាច់ដែលមិនគួរសោយ ព្រោះហេតុនោះ ទើបព្រះអង្គឈ្មោះថាជាអធម្មិកជន ។

(៣៩៥) (ព្រះបាទបោរិសាទ...) លោកបានរួចអំពីដៃបោរិសាទហើយ ទៅកាន់មន្ទីររបស់ខ្លួនតាមសេចក្ដីប្រាថ្នា ហើយត្រឡប់មកកាន់ដៃរបស់សត្រូវវិញ បពិត្រព្រះរាជា ព្រះអង្គជាបុគ្គលមិនឈ្លាសក្នុងខត្តិយធម៌ទេ ។

(៣៩៦) (ព្រះបាទសុតសោម...) ពួកបុគ្គលណា ជាអ្នកឈ្លាសក្នុងខត្តិយធម៌ ពួកបុគ្គលនោះ ច្រើនតែធ្លាក់ទៅក្នុងនរក

តស្មា អហំ ទឡ្ហធម្មំ បហាយ
សច្ចានុរក្ខី បុនរាគតោស្មិ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។

(៣៨៧) បាសាទវាសា បឋវីគវស្សា
កាមិត្ថិយោ កាសិកចន្ទនញ្ច
សព្វំ តហឹ លភសិ សាមិតាយ
សច្ចេន កឹ បស្សសិ អានិសំសំ ។

(៣៨៨) យេ កេចិមេ អត្ថិ រសា បឋព្យា
សច្ចំ តេសំ សាធុតរំ រសានំ
សច្ចេ ឋិតា សមណព្រាហ្មណា ច
តរន្តិ ជាតិមរណស្ស បារំ ។

(៣៨៩) មុត្តោ តុវំ បោរិសាទស្ស ហត្ថា
គន្ត្វា សកំ មន្ទិរំ កាមកាមី
អមិត្តហត្ថំ បុនរាគតោសិ
ន ហិ នូន តេ មរណភយំ ជនិន្ទ
អលីនចិត្តោ ចសិ សច្ចវាទី ។



ព្រោះហេតុនោះ បានលះបង់នូវទឡ្ហធម៌ ជាអ្នករក្សានូវសច្ចៈ ត្រឡប់មកវិញ មកក្រែព្រះបាទពោរិសាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយនូវខ្ញុំចុះ ។

(៣៨៧) (ព្រះបាទពោរិសាទ...) ប្រាសាទជាទីនៅលើផែនដី គោនិងសេះ ស្ត្រីដែលគួរប្រាថ្នា និងខ្លឹមចន្ទន៍ក្នុងដែនកាសី ទ្រង់បាននូវវត្ថុទាំងអស់ ក្នុងទីនោះ ដោយភាពជាម្ចាស់ ចុះទ្រង់ឃើញនូវអានិសង្សនៃពាក្យសច្ចៈ ដូចម្តេច ។

(៣៨៨) (ព្រះបាទសុតសោម...) រសណាមួយ មាននៅលើផែនដី សច្ចៈ ជារសល្អក្រៃលែងជាងរសទាំងឡាយនោះ ពួកសមណៈនិងព្រាហ្មណ៍ ដែលតាំងនៅក្នុងសច្ចៈ រមែងឆ្លងទៅកាន់ត្រើយនៃជាតិនិងមរណៈបាន ។

(៣៨៩) (ព្រះបាទពោរិសាទ...) ទ្រង់បានរួចអំពីដៃពោរិសាទ ហើយ បានទៅកាន់មន្ទីរ របស់ខ្លួនវិញ តាមសេចក្ដីប្រាថ្នា ត្រឡប់មកកាន់ដៃសត្រូវវិញ មកក្រែទ្រង់ជាធំជាងជន ភ័យអំពីសេចក្ដីស្លាប់ មិនមានដល់ទ្រង់ដោយពិត ទ្រង់ជាអ្នកពោលនូវពាក្យសច្ចៈ ទាំងមានចិត្តក៏មិនរួញរា ។

[៣៦០] កតា មេ កល្យាណា អនេករូបា
យញ្ញា យិដ្ឋា យេ វិបុលា បសត្ថា
វិសោធិតោ បរលោកស្ស មគ្គោ
ធម្មេ ឋិតោ កោ មរណស្ស ភាយេ ។
កតា មេ កល្យាណា អនេករូបា
យញ្ញា យិដ្ឋា យេ វិបុលា បសត្ថា
អនានុតប្បំ បរលោកំ គមិស្សំ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។
បិតា ច មាតា ច ឧបដ្ឋិតា មេ
ធម្មេន មេ ឥស្សរិយំ បសត្ថំ
វិសោធិតោ បរលោកស្ស មគ្គោ
ធម្មេ ឋិតោ កោ មរណស្ស ភាយេ ។
បិតា ច មាតា ច ឧបដ្ឋិតា មេ
ធម្មេន មេ ឥស្សរិយំ បសត្ថំ
អនានុតប្បំ បរលោកំ គមិស្សំ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។
ញាតីសុ មិត្តេសុ កតូបការោ



(៣៦០) (ព្រះបាទសុតសោម...) យ័ញ្ញ (ការបូជា) មានច្រើនប្រការ ជាកល្យាណធម៌ ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយ ដែលអ្នកប្រាជ្ញ តែងសរសើរ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅ ក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់ ។ យ័ញ្ញមានច្រើនប្រការ ជាកល្យាណធម៌ ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយ ដែលអ្នកប្រាជ្ញតែងសរសើរ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទពោរិសាទ សូមព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ មាតានឹងបិតា ខ្ញុំបានបំរើហើយ ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅ ក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់ ។ បិតានឹងមាតា ខ្ញុំក៏បានបម្រើហើយ ឥស្សរភាពខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្តៅក្រហាយនឹងទៅបរលោកទេ បពិត្រព្រះបាទពោរិសាទ សូមព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ ខ្ញុំបានធ្វើឧបការៈចំពោះពួកញាតិនឹងមិត្តហើយ

ធម្មេន មេ ឥស្សរិយំ បសត្ថំ
វិសោធិតោ បរលោកស្ស មគ្គោ
ធម្មេ ឋិតោ កោ មរណស្ស ភាយេ ។
ញាតីសុ មិត្តេសុ កតូបការោ
ធម្មេន មេ ឥស្សរិយំ បសត្ថំ
អនានុតប្បំ បរលោកំ គមិស្សំ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។
ទិន្នំ មេ ទានំ ពហុធា ពហុន្នំ
សន្តប្បិតា សមណព្រាហ្មណា ច
វិសោធិតោ បរលោកស្ស មគ្គោ
ធម្មេ ឋិតោ កោ មរណស្ស ភាយេ ។
ទិន្នំ មេ ទានំ ពហុធា ពហុន្នំ
សន្តប្បិតា សមណព្រាហ្មណា ច
អនានុតប្បំ បរលោកំ គមិស្សំ
យជស្សុ យញ្ញំ ខាទ មំ បោរិសាទ ។



ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់ ។ ខ្ញុំបានធ្វើឧបការគុណ ចំពោះពួកញាតិនឹងមិត្តហើយ ឥស្សរភាពខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គស៊ីខ្ញុំចុះ ។ ការឲ្យទានដល់ពួកជនជាច្រើន ដោយអាការច្រើនយ៉ាង ខ្ញុំក៏បានឲ្យហើយ ទាំងពួកសមណព្រាហ្មណ៍ ខ្ញុំក៏បានផ្គាប់ផ្គុនហើយ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់ ។ ការឲ្យទានដល់ពួកជនជាច្រើន ដោយអាការច្រើនយ៉ាង ខ្ញុំក៏បានឲ្យហើយ ទាំងសមណព្រាហ្មណ៍ ខ្ញុំក៏បានផ្គាប់ផ្គុនហើយ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមទ្រង់បូជាយញ្ញ សូមទ្រង់ស៊ីខ្ញុំចុះ ។

(៣៦១) វិសំ បជានំ បុរិសោ អទេយ្យ
អាសីវិសំ ជលិតំ ឧគ្គតេជំ
មុទ្ធាបិ តស្ស វិផលេយ្យ សត្តធា
យោ តាទិសំ សច្ចមហំ ជហេយ្យ ។

(៣៦២) សុត្វា ធម្មំ វិជានន្តិ នរា កល្យាណបាបកំ
អបិ គាថា សុណិត្វាន ធម្មេ មេ រមតេ មនោ ។

(៣៦៣) សកិទេវ មហារាជ សព្ភិ ហោតិ សមាគមោ
សា នំ សង្គតិ បាលេតិ នាសព្ភិ ពហុសង្គមោ ។
សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ ។
ជីរន្តិ វេ រាជរថា សុចិត្តា
អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តិ ។



(៣៦១) (ព្រះបាទបោរិសាទ...) បុគ្គលណា លះបង់នូវការពោល ពាក្យសច្ចៈប្រាកដដូច្នោះ ក្បាលរបស់បុគ្គលនោះ នឹងបែក ជា ៧ ភាគ ដូចបុរសស្គាល់នូវថ្នាំពិស ហើយស៊ីនូវថ្នាំពិស (ឬ ដូចគេចាប់) នូវអាសិរពិសដែលមានពិសកាចមានតេជៈខ្លាំង ។

(៣៦២) ជនទាំងឡាយ បានស្តាប់ធម៌ហើយ រមែងដឹងច្បាស់នូវ បុណ្យនិងបាប ម្យ៉ាងទៀតចិត្តរបស់ខ្ញុំ តែងត្រេកអរក្នុងធម៌ ព្រោះ បានស្តាប់នូវគាថាទាំងឡាយ ។

(៣៦៣) (ព្រះបាទសុតសោម...) បពិត្រមហារាជ ការជួបប្រទះ ដោយសប្បុរសទាំងឡាយអស់វារៈតែម្តង ការជួបប្រទះនោះរមែង រក្សានូវបុគ្គលនោះបាន ការជួបជុំដោយពួកអសប្បុរស ច្រើនដង រមែងមិនរក្សាបុគ្គលបានទេ ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណធម៌ដ៏ប្រសើររមែង កើតមាន ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនជា ទោសដ៏លាមកទេ ។ រាជរថទាំងឡាយ ដែលគេតាក់តែងល្អហើយ រមែងគ្រាំគ្រា សូម្បីសរីរៈ (របស់ពួកសត្វ) ក៏រមែងដល់នូវសេចក្តី គ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរស មិនដល់នូវសេចក្តីគ្រាំគ្រា ទេ សប្បុរសទាំងឡាយ រមែងដឹងគ្នាដោយពួកសប្បុរសបាន ។

នភញ្ច ទូរេ បថវី ច ទូរេ
បារំ សមុទ្ទស្ស តទាហុ ទូរេ
តតោ ហវេ ទូរតរំ វទន្តិ
សតញ្ច ធម្មោ អសតញ្ច រាជ ។

(៣៦៤) គាថា ឥមា អត្ថវតី សុព្យញ្ជនា
សុភាសិតា តុយ្ហ ជនិន្ទ សុត្វា
អានន្ទិ វិត្តោ សុមនោ បតីតោ
ចត្តារិ តេ សម្ម វរេ ទទាមិ ។

(៣៦៥) យោ នត្តនោ មរណំ ពុជ្ឈសេ[១] តុវំ
ហិតាហិតំ វិនិបាតញ្ច សគ្គំ
គិទ្ធោ រសេ ទុច្ចរិតេ និវិដ្ឋោ
កឹ ត្វំ វរេ ទស្សសិ បាបធម្ម ។
អហញ្ច តំ ទេហិ វរន្តិ វជ្ជំ
ត្វញ្ចាបិ ទត្វាន អវាករេយ្យ
សន្ទិដ្ឋិកំ កលហមិមំ វិវាទំ
កោ បណ្ឌិតោ ជានមុបព្វជេយ្យ ។

(៣៦៦) ន តំ វរំ អរហតិ ជន្តុ ទាតុំ
យំ វាបិ ទត្វា អវាករេយ្យ

១ ម. ពុជ្ឈសិ ។



អាកាសនិងផែនដី ឋិតនៅ ក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយបានពោលនូវត្រើយសមុទ្រនោះថាឆ្ងាយ បពិត្រព្រះរាជា បណ្ឌិតទាំងឡាយ រមែងពោលថា ធម៌របស់ពួកសប្បុរស និងពួកអសប្បុរស ឆ្ងាយជាងនោះទៅទៀត ។

(៣៦៤) (ព្រះបាទបោរិសាទ...) បពិត្រទ្រង់ជាធំជាងជន គាថាទាំងឡាយនេះមានអត្ថ មានព្យញ្ជនៈពីរោះ ទ្រង់សំដែងពីរោះណាស់ ខ្ញុំបានស្តាប់ហើយ ក៏ត្រេកអរ រីករាយ មានចិត្តល្អជ្រះថ្លា បពិត្រទ្រង់ជាសំឡាញ់ ខ្ញុំសូមឲ្យពរ ៤ ប្រការដល់ទ្រង់ ។

(៣៦៥) (ព្រះបាទសុតសោម...) ទ្រង់មិនដឹងនូវសេចក្តីស្លាប់របស់ខ្លួន ទាំងអំពើមានប្រយោជន៍និងឥតប្រយោជន៍ ទាំងនរកនិងឋានសួគ៌ទេ បពិត្រព្រះអង្គមានធម៌ដ៏លាមក ព្រះអង្គជាប់ចំពាក់ក្នុងរស (នៃសាច់មនុស្ស) តាំងនៅស៊ប់ក្នុងទុច្ចរិតធម៌ តើម្តេចនឹងឲ្យពរកើត ។ បើខ្ញុំពោលថា សូមព្រះអង្គប្រទានពរនោះ ព្រះអង្គប្រទានហើយត្រឡប់ជាមិនប្រទានវិញ តើបណ្ឌិតណាកាលដឹង នឹងហ៊ានចូលទៅកាន់ជម្លោះ និងវិវាទដ៏ជាក់ស្តែងនេះ ។

(៣៦៦) (ព្រះបាទបោរិសាទ...) ជនឲ្យនូវពរណា ហើយត្រឡប់ជាមិនឲ្យវិញ មិនគួរឲ្យពរនោះទេ បពិត្រទ្រង់ជាសំឡាញ់

វិស្សុំ សទ្ទំ អភិកាមយមានោ
ចាណំ ចជិត្វាចបំ ធនុយេវ ។

(៣៦៧) អរិយស្ស អរិយេន សមេតិ សក្ខិ[១]
បញ្ញស្ស បញ្ញាណវតា សមេតិ
បស្សេយ្យ តំ វស្សសតំ អរោគំ
ឯតំ វរំ បឋមំ វរាមិ ។

(៣៦៨) អរិយស្ស អរិយេន សមេតិ សក្ខិ
បញ្ញស្ស បញ្ញាណវតា សមេតិ
បស្សេសិ មំ វស្សសតំ អរោគំ
ឯតំ វរំ បឋមំ ទទាមិ ។

(៣៦៩) យេ ខត្តិយាសេ ឥធ ភូមិបាលា
មុទ្ធាភិសិត្តា កតនាមធេយ្យា
ន តាទិសេ ភូមិបតី អទេសិ
ឯតំ វរំ ទុតិយំ វរាមិ ។

(៣៧០) យេ ខត្តិយាសេ ឥធ ភូមិបាលា
មុទ្ធាភិសិត្តា កតនាមធេយ្យា
ន តាទិសេ ភូមិបតី អទេមិ
ឯតំ វរំ ទុតិយំ ទទាមិ ។

---
១ ម. សខ្យំ ។



សូមទ្រង់កុំញាប់ញ័រ សូមទ្រង់ទូល (ករ) ចុះ ខ្ញុំសូមបោះបង់ជីវិត ក៏ នៅតែថ្វាយទ្រង់ ។

(៣៦៧) (ព្រះបាទសុតសោម...) ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ តែងស្រួលគ្នានឹងអរិយៈ របស់បុគ្គលមានប្រាជ្ញា តែងស្រួលគ្នានឹងបុគ្គលមានប្រាជ្ញា ខ្ញុំសូមឃើញព្រះអង្គមានជន្មាយុ ១០០ ឆ្នាំ ឥតមានរោគ បណ្ដាពរទាំងឡាយ ខ្ញុំប្រាថ្នានូវពរទី ១ នុ៎ះ ។

(៣៦៨) (ព្រះបាទពោរិសាទ...) ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ តែងស្រួលគ្នានឹងអរិយៈ របស់បុគ្គលមានប្រាជ្ញា តែងស្រួលគ្នានឹងបុគ្គលមានប្រាជ្ញា ទ្រង់នឹងសូមឃើញខ្ញុំមានអាយុ ១០០ ឆ្នាំ ឥតមានរោគ បណ្ដាពរទាំងឡាយ ខ្ញុំនឹងថ្វាយពរទី ១ នេះ ។

(៣៦៩) (ព្រះបាទសុតសោម...) ពួកក្សត្រិយ៍ណា ក្នុងផែនដី ក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ មានព្រះនាមសម្រេចហើយ ព្រះអង្គជាម្ចាស់ផែនដី កុំសោយនូវពួកក្សត្រិយ៍ទាំងនោះឡើយ បណ្ដាពរទាំងឡាយ ខ្ញុំប្រាថ្នានូវពរទី ២ នេះ ។

(៣៧០) (ព្រះបាទពោរិសាទ...) ពួកក្សត្រិយ៍ណា ក្នុងផែនដីក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ មានព្រះនាមសម្រេចហើយ ខ្ញុំជាម្ចាស់ផែនដី ក៏មិនស៊ីនូវពួកក្សត្រិយ៍ទាំងនោះទេ បណ្ដាពរទាំងឡាយ ខ្ញុំនឹងថ្វាយនូវពរទី ២ នេះ ។

(៣៩១) បកោសតំ ខត្តិយា តេ កហិតា
គណ្ហាតុ អស្សមុខា រុធន្តា
សកេ តេ រដ្ឋេ បដិបាទយាហិ
ឯតំ វរំ តតិយំ វរាមិ ។

(៣៩២) បកោសតំ ខត្តិយា មេ កហិតា
គណ្ហាតុ អស្សមុខា រុធន្តា
សកេ តេ រដ្ឋេ បដិបាទយាមិ
ឯតំ វរំ តតិយំ ទទាមិ ។

(៣៩៣) ឆិទ្ទំ តេ រដ្ឋំ ព្យថិតា ភយា ហិ
បុថូ នរា លេណមនុប្បវិដ្ឋា
មនុស្សមំសំ វិរមាហិ រាជ
ឯតំ វរំ ចតុត្ថំ វរាមិ ។

(៣៩៤) អទ្ធា ហិ សោ ភក្ខោ មម មនាបោ
ឯតស្ស ហេតុម្ហិ វនំ បវិដ្ឋោ
សោហំ កថំ ឯត្តោ ឧបារមេយ្យំ
អញ្ញំ វរំ ចតុត្ថំ វរស្សុ ។



(៣៩១) (ព្រះបាទសុតសោម...) ពួកក្សត្រិយ៍ជាច្រើននាក់ ដែលព្រះអង្គចាប់ដោតបាតដៃ មានមុខជោគដោយទឹកភ្នែក កំពុងយំ សូមព្រះអង្គឲ្យក្សត្រិយ៍ទាំងនោះ ត្រឡប់ទៅកាន់ដែនរបស់ខ្លួនវិញ បណ្ដាពរទាំងឡាយ ខ្ញុំប្រាថ្នាពរទី ៣ នេះ ។

(៣៩២) (ព្រះបាទបោរិសាទ...) ពួកក្សត្រិយ៍ជាច្រើននាក់ ដែលខ្ញុំចាប់ដោតបាតដៃ មានមុខជោគដោយទឹកភ្នែក កំពុងយំ ខ្ញុំនឹងឲ្យពួកក្សត្រិយ៍ទាំងនោះ ត្រឡប់ទៅកាន់ដែន របស់ខ្លួនវិញ បណ្ដាពរទាំងឡាយ ខ្ញុំនឹងឲ្យពរទី ៣ នេះ ។

(៣៩៣) (ព្រះបាទសុតសោម...) ដែនរបស់ព្រះអង្គ ជាដែនប្រហោង (មិនសូវមានប្រជាជន) ព្រោះពួកប្រជាជន ជាច្រើនញាប់ញ័រហើយ ព្រោះភ័យគ្រប់សព្វ ហើយក៏ចូលទៅកាន់ទីពួន បពិត្រព្រះរាជា សូមព្រះអង្គវៀរសាច់មនុស្សទៅ បណ្ដាពរទាំងឡាយ ខ្ញុំប្រាថ្នាពរទី ៤ នេះ ។

(៣៩៤) (ព្រះបាទបោរិសាទ...) អាហារនោះ ជាទីពេញចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលព្រៃ ព្រោះហេតុតែសាច់មនុស្សនុ៎ះឯង នឹងវៀរចាកសាច់មនុស្សនុ៎ះ ដូចម្ដេចបាន បណ្ដាពរទាំងឡាយ សូមទ្រង់ប្រាថ្នានូវពរទី ៤ ដទៃវិញ ។

(៣៧៥) ន វេ បិយំ មេតិ ជនិន្ទ តាទិសោ
អត្តំ និរង្កត្វា បិយានិ សេវតិ
អត្តាវ សេយ្យោ បរមា ច សេយ្យោ
លព្ភា បិយា ឱចិតត្ថេន បច្ឆា ។

(៣៧៦) បិយំ មេ មានុសំ មំសំ សុតសោម វិជានហិ
នម្ហិ សក្កា និវារេតុំ អញ្ញំ តុំ សម្ម វិវរស្សុ ។

(៣៧៧) យោ វេ បិយំ មេតិ បិយានុរក្ខី
អត្តំ និរង្កត្វា បិយានិ សេវតិ
សោណ្ឌោវ បិត្វា វិសមិស្សបានំ
តេនេវ សោ ហោតិ ទុក្ខី បរត្ថ ។
យោ ចីធ សង្ខាយ បិយានិ ហិត្វា
កិច្ឆេនបិ សេវតិ អរិយធម្មេ
ទុក្ខិតោវ បិត្វាន យថោសធានិ
តេនេវ សោ ហោតិ សុខី បរត្ថ ។





(៣៧៥) (ព្រះបាទសុតសោម...) បពិត្រព្រះអង្គ ជាធំជាងជន បុគ្គលប្រហែលដូចព្រះអង្គ លះបង់នូវខ្លួនចោលដោយគិតថា នេះជាទីស្រឡាញ់របស់អញដូច្នេះ រមែងមិនបានសេពគប់នូវវត្ថុជាទីស្រឡាញ់ទេ ខ្លួនហ្នឹងហើយ ជាសភាវៈប្រសើរ ឈ្មោះថាប្រសើរក្រៃលែង បុគ្គលអ្នកមានចិត្តសន្សំហើយ គប្បីបាននូវគុណជាទីស្រឡាញ់ ក្នុងកាលជាខាងក្រោយ ។

(៣៧៦) (ព្រះបាទពោរិសាទ...) បពិត្រព្រះបាទសុតសោម សូមទ្រង់ជ្រាបនូវសាច់មនុស្សថាជាទីស្រឡាញ់របស់ខ្ញុំ ទ្រង់មិនអាចឃាត់ខ្ញុំបានទេ បពិត្រទ្រង់ជាសំឡាញ់ សូមទ្រង់ត្រឡប់ទៅវិញ ។

(៣៧៧) (ព្រះបាទសុតសោម...) បុគ្គលណាជាអ្នករក្សានូវវត្ថុជាទីស្រឡាញ់ ដោយគិតថា វត្ថុនេះជាទីស្រឡាញ់របស់អញដូច្នេះ លះបង់ខ្លួន ហើយទៅសេពគប់វត្ថុ ជាទីស្រឡាញ់ បុគ្គលនោះរមែងជាទុក្ខក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូចជាអ្នកលេងសុរា ផឹកទឹកសុរាដែលលាយដោយថ្នាំពិស ។ ចំណែកខាងបុគ្គលណា ក្នុងលោកនេះ បានពិចារណា លះបង់នូវវត្ថុជាទីស្រឡាញ់ ហើយបែរមកសេពគប់នូវអរិយធម៌ សូម្បីដោយលំបាក បុគ្គលនោះ រមែងបានសុខ ក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូចបុគ្គលដល់នូវសេចក្ដីទុក្ខ ព្រោះផឹកនូវឱសថ ។

(៣៧៨) ហិត្វាយហំ បិតរំ មាតរញ្ច
មនាបិយេ កាមគុណេ ច បញ្ច
ឯតស្ស ហេតុម្ហិ វនំ បវិដ្ឋោ
តន្តេ វរំ កិន្តិមហំ ទទាមិ ។

(៣៧៩) ន បណ្ឌិតា ទិគុណមាហុ វាក្យំ
សច្ចប្បដិញ្ញាវ ភវន្តិ សន្តោ
វរស្សុ សម្ម ឥតិ មំ អវោច
ឥច្ចព្រវី ត្វំ ន ហិ តេ សមេតិ ។

(៣៨០) អបុញ្ញលាភំ អយសំ អកិត្តឹ
បាបំ ពហុំ ទុច្ចរិតំ កិលេសំ
មនុស្សមំសស្ស កតេ ឧបាគា
តន្តេ វរំ កិន្តិមហំ ទទេយ្យំ ។

(៣៨១) ន តំ វរំ អរហតិ ជន្តុ យាចិតុំ
យំ ចាបិ ទត្វា ន អវាករេយ្យ
វរស្សុ សម្ម អវិកម្បមានោ
បាណំ ចជិត្វាន ទស្សយេតំ ។



(៣៧៨) (ព្រះបាទបោរិសាទ...) ខ្ញុំលះបង់បិតាមាតា និងបញ្ចកាម-គុណ ជាទីពេញចិត្ត ហើយចូលព្រៃ ព្រោះហេតុតែសាច់មនុស្ស នោះ ខ្ញុំនឹងថ្វាយពរនោះ ដល់ទ្រង់ ដូចម្តេចបាន ។

(៣៧៩) (ព្រះបាទសុតសោម...) បណ្ឌិតទាំងឡាយជាសប្បុរស ជាអ្នកប្តេជ្ញា ដោយពាក្យសច្ចៈ មិនពោលនូវពាក្យពីរជាន់ទេ ព្រះអង្គបានពោលនឹងខ្ញុំថា បពិត្រទ្រង់ជាសំឡាញ់ សូមទ្រង់ទទួលពរចុះ ព្រះអង្គបានពោលដូច្នេះហើយ (តែពាក្យនោះ) របស់ព្រះអង្គ មិនស្របគ្នាទេ ។

(៣៨០) (ព្រះបាទបោរិសាទ...) ខ្ញុំដល់នូវភាពជាអ្នកមិនមានបុណ្យ មិនមានយស មិនមានកេរ្តិ៍ឈ្មោះ មានបាប មានទុច្ចរិត សៅ-ហ្មងជាច្រើន ក៏ព្រោះហេតុតែសាច់មនុស្ស ខ្ញុំនឹងថ្វាយពរនោះ ដល់ទ្រង់ ដូចម្តេចកើត ។

(៣៨១) (ព្រះបាទសុតសោម...) (ទ្រង់មានបន្ទូលហើយថា) ជនឲ្យនូវពរណា ហើយត្រឡប់ជាមិនឲ្យវិញ មិនគួរឲ្យពរនោះទេ បពិត្រទ្រង់ជាសំឡាញ់ សូមទ្រង់កុំញញើតញ័រ សូមទទួលយក (ពរ) ចុះ ខ្ញុំសូមស្លាប់បង់ជីវិត ក៏នៅតែថ្វាយទ្រង់ដែរ ។

(៣៨២) ធាណាំ ចជន្តិ សតាធេសា ឧទេន្នោ
សច្ចប្បដិញ្ញាវ អវត្តិ សន្តោ
ឧត្តា វរំ ទិព្វមភិត្ថរេហិ
ឯតេន សម្បន្នកុ ភជស្សេ ។
ចជេ ធនំ អង្គវរស្ស ហេតុ
អង្គំ ចជេ ជីវិតំ រក្ខមានោ
អង្គំ ធនំ ជីវិតញ្ចាបិ សព្វំ
ចជេ នរោ ធម្មមនុស្សរន្តោ ។

(៣៨៣) យស្មា ហិ ធម្មំ បុរិសោ វិជញ្ញា
យេ ចស្ស កង្ខំ វិនយន្តិ សន្តោ
តញ្ហិស្ស ទីបញ្ច បរាយណញ្ច
ន តេន មេត្តិំ ជិរយេថ បញ្ញោ ។

(៣៨៤) អទ្ធា ហិ សោ ភក្ខោ មម មនាបោ
ឯតស្ស ហេតុម្ហិ វយំ បវិដ្ឋា
សចេ ច មំ យាចសិ ឯតមត្ថំ
ឯតំបិ តេ សម្ម វរំ ទទាមិ ។

---

១ ម. សព្ពោ តបិ ធម្មំ ។



(៣៨២) ទុះតែធម៌ របស់ពួកសប្បុរស ធម្មតាពួកសប្បុរស នាំអ្នកឆ្លងដោយពាក្យសច្ចៈ តែងលះបង់នូវជីវិត ព្រោះអន្តរាយ ហើយ ទុះឲ្យហើស បពិត្រព្រះរាជដ៏ប្រសើរ សូមព្រះអង្គសម្រេចដោយធម៌នឹងពាក្យសច្ចៈនុ៎ះ ។ ជនគប្បីលះបង់នូវទ្រព្យ ព្រោះហេតុតែអវយវៈដ៏ប្រសើរ កាលបើរក្សានូវជីវិត ក៏គប្បីលះបង់នូវអវយវៈ កាលបើរឭកឃើញនូវធម៌ គប្បីលះបង់ទាំងអវយវៈទ្រព្យនឹងជីវិតទាំងអស់ ។

(៣៨៣) បុរសដឹងនូវធម៌អំពីបុគ្គលណា ឬពួកសប្បុរសណា បន្ទោបង់នូវសេចក្ដីសង្ស័យ របស់បុគ្គលនោះបាន ដំណើរនោះ ឈ្មោះថាជាទីពឹង ជាទីតាំង របស់បុគ្គលនោះ បុគ្គលអ្នកមានប្រាជ្ញា មិនគប្បីបំផ្លាញមេត្រីចិត្តអំពីបុគ្គលនោះទេ ។

(៣៨៤) (ព្រះបាទបោរិសាទ...) តបថា អាហារនោះ ជាទីគាប់ចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលទៅព្រៃ ព្រោះហេតុតែសាច់មនុស្សនុ៎ះ បើទ្រង់ទទួចសូមសេចក្ដីនុ៎ះនឹងខ្ញុំ បពិត្រទ្រង់ជាសំឡាញ់ ខ្ញុំក៏ឲ្យពរនោះ ដល់ទ្រង់ ។

(៣៨៥) សខា ច មេ ហោសិ សហា ច មេសិ
វចនំបិ តេ សម្ម អហំ អកាសឹ
តុវំបិ មេ សម្ម ករោហិ វាក្យំ
ឧភោបិ គន្ត្វាន បមោចយាម ។

(៣៨៦) សខា ច តេ ហោមិ សហា ច ត្យម្ហិ
វចនំបិ មេ សម្ម តុវំ អកាសិ
អហំបិ តេ សម្ម ករោមិ វាក្យំ
ឧភោបិ គន្ត្វាន បមោចយាម ។

(៣៨៧) កម្មាសបាទេន វិហេឋិតត្ថ
តលាវុតា អស្សុមុខា រុទន្តា
ន ជាតុ ទុព្ភេថ ឥមស្ស រញ្ញោ
សច្ចប្បដិញ្ញំ មេ បដិស្សុណាថ ។

(៣៨៨) កម្មាសបាទេន វិហេឋិតម្ហា
តលាវុតា អស្សុមុខា រុទន្តា
ន ជាតុ ទុព្ភេម ឥមស្ស រញ្ញោ
សច្ចប្បដិញ្ញំ តេ បដិស្សុណាម ។



(៣៨៥) ព្រះអង្គជាសហាយ របស់ខ្ញុំផង ជាសំឡាញ់ របស់ខ្ញុំផង បពិត្រព្រះអង្គជាសំឡាញ់ ខ្ញុំបានធ្វើតាមព្រះវាចា របស់ព្រះអង្គ ព្រះអង្គគួរធ្វើតាមពាក្យរបស់ខ្ញុំដែរ យើងទាំងពីរនាក់ ទៅដោះលែង (ពួកក្សត្រិយ៍ទាំងនោះជាមួយគ្នា) ។

(៣៨៦) (ព្រះបាទសុតសោម...) ខ្ញុំជាសហាយរបស់ព្រះអង្គផង ជាសំឡាញ់របស់ព្រះអង្គផង បពិត្រព្រះអង្គជាសំឡាញ់ បើព្រះអង្គធ្វើតាមពាក្យខ្ញុំ ទាំងខ្ញុំក៏ធ្វើតាមពាក្យព្រះអង្គដែរ យើងទាំងពីរនាក់ទៅដោះលែង (ពួកក្សត្រិយ៍ទាំងនោះជាមួយគ្នា) ។

(៣៨៧) ពួកយើងដែលត្រូវព្រះរាជាជើងពពាល បៀតបៀនដោតបាតដៃ មានមុខជោគជាំដោយទឹកភ្នែក ស្រែកយំ (ឥឡូវនេះ) អ្នកទាំងឡាយ លែងប្រទូស្តនឹងព្រះរាជានេះចុះ អ្នកទាំងឡាយ ចូរទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងត្រង់ របស់ខ្ញុំចុះ ។

(៣៨៨) (ពួកក្សត្រិយ៍...) ពួកយើងដែលត្រូវព្រះរាជាជើងពពាល បៀតបៀនដោតបាតដៃ មានមុខជោគជាំដោយទឹកភ្នែក ស្រែកយំ (ឥឡូវនេះ) ពួកយើងមិនប្រទូស្ត ចំពោះព្រះរាជានេះទេ ពួកយើងនឹងទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងត្រង់ របស់ព្រះអង្គ ។

(៣៨៩) យថា បិតា ច អថបិ មាតា
អនុកម្បកា អត្ថកាមា បជានំ
ឯវម្បិ ភោ ហោតុ អយញ្ច រាជា
តុម្ហេ ច ភោ ហោថ យថេវ បុត្តា ។

(៣៩០) យថា បិតា ច អថបិ មាតា
អនុកម្បកា អត្ថកាមា បជានំ
ឯវម្បិ នោ ហោតុ អយញ្ច រាជា
មយម្បិ ហេស្សាម យថេវ បុត្តា ។

(៣៩១) ចតុប្បទំ សកុណញ្ចាបិ មំសំ
សូទេហិ រន្ធំ សុកតំ សុនិដ្ឋិតំ
សុធំ វ ឥន្ទោ បរិភុញ្ជិយាន
ហិត្វា គតោ រមសី អរញ្ញេ ។
តា ខត្តិយា វេល្លិវិលាកមជ្ឈា
អលង្កតា សម្បរិវារយិត្វា
ឥន្ទំវ ទេវេសុ បមោទយឹសុ
ហិត្វា គតោ រមសី អរញ្ញេ ។



(៣៨៩) (ព្រះបាទសុតសោម...) បិតា ឬមាតា ជាអ្នកអនុគ្រោះ ប្រាថ្នានូវសេចក្តីចំរើន ដល់បុត្រទាំងឡាយ យ៉ាងណាមិញ ចំណែកព្រះរាជានេះ ចូរមានដល់លោកទាំងឡាយ ក៏យ៉ាងនោះដែរ ទាំងលោកទាំងឡាយ ក៏ចូរដូចជាបុត្រ ។

(៣៩០) (ពួកក្សត្រិយ៍...) បិតា ឬមាតា ជាអ្នកអនុគ្រោះ ប្រាថ្នានូវសេចក្តីចំរើន ដល់បុត្រទាំងឡាយ យ៉ាងណាមិញ ចំណែកព្រះរាជានេះ ចូរមានដល់យើងទាំងឡាយ យ៉ាងនោះដែរ ទាំងពួកយើងក៏ដូចបុត្រដែរ ។

(៣៩១) (ព្រះបាទសុតសោម...) ព្រះអង្គធ្លាប់សោយនូវសាច់នៃសត្វជើង ៤ ឬសត្វបក្សី ដែលពួកនាយពិសេសតាក់តែងល្អ សម្រេចហើយល្អ ជាវិសេសគួរ ដូចព្រះឥន្ទ្រ សោយនូវសុធាភោជន ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃតែម្នាក់ឯង ដូចម្តេចកើត ។ ពួកនាងខត្តិយានីទាំងនោះ មានគ្រឿងប្រដាប់ ក្តុំផ្ទុក និងមានចង្កេះដ៏រៀវ តាក់តែងខ្លួនគាល់ស្រៀវស្រា ញ៉ាំងព្រះអង្គឲ្យត្រេកអរ ដូចជាស្រីទេពអប្សរ ញ៉ាំងព្រះឥន្ទ្រក្នុងទេវលោក ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្តេចកើត ។

តម្ពូបធានេ ឥធ គោណកម្ហិ
សុភម្ហិ សព្វស្សយនម្ហិលង្កតេ(១)
សយនស្ស មជ្ឈម្ហិ សុខំ សយិត្វា
ហិត្វា កថេកោ រមសី អរញ្ញេ ។
ពាណិស្សរំ កុម្ភថូណំ និសីថេ
អថោបិ វេ និប្បុរិសំបិ តូរិយំ
ពហុំ សុគីតញ្ច សុវាទិតញ្ច
ហិត្វា កថេកោ រមសី អរញ្ញេ ។
ឧយ្យានសម្បន្នបហូតមាល្យំ
មិគាជិនូបេតបុរំ សុរម្មំ
ហយេហិ នាគេហិ រថេហុបេតំ
ហិត្វា កថេកោ រមសី អរញ្ញេ ។

(៣៩២) កាឡបក្ខេ យថា ចន្ទោ ហាយតេវ សុវេ សុវេ
កាឡបក្ខូបមោ រាជ អសតំ ហោតិ សមាគមោ ។
យថាហំ រសកមាគម្ម សូទំ កាបុរិសាធមំ
អកាសឹ បាបកំ កម្មំ(២) យេន គច្ឆាមិ ទុគ្គតឹ ។

១ ម. សព្វស្សយនម្ហិលង្កតេ ។ ២ ម. បាបកំ កម្មំ ។



ព្រះអង្គផ្ទំលើព្រះយន្ទំ មានខ្នើយពណ៌ក្រហម មានព្រំមានរោម ច្រើន ដែលគេរៀបចំទុកទីព្រះយន្ទំទាំងអស់ ដ៏ល្អជាសុខសប្បាយ ត្រង់ចំកណ្តាលនៃព្រះយន្ទំ ហើយលះបង់ចោល ត្រេកអរក្នុង ព្រៃម្នាក់ឯង ដូចម្តេចកើត ។ ក្នុងវេលាយប់ មានស្គរសំភោរខ្សែ គន្ធ័នឹងស្គរ ទាំងតូរ្យតន្ត្រី ឥតមានបុរសលេងលាយ មានចាំង ចម្រៀងដ៏ពីរោះ នឹងប្រគំតន្ត្រីពិរោះជាច្រើនយ៉ាង ព្រះអង្គលះបង់ ចោល ហើយព្រះអង្គនៅក្នុងព្រៃម្នាក់ឯង ដូចម្តេចកើត ។ ឧទ្យាន (ឈ្មោះមិគាជិន) ក៏មានផ្កាច្រើនបរិបូណ៌ បុរីប្រកបដោយ ឈ្មោះគោមមុខឧទ្យានមិគាជិន ជាបុរីគួរជាទីសប្បាយនៃព្រះនគរ សម្បូរ ដោយដំរី សេះ រថ ព្រះអង្គលះបង់ចោល ហើយ ព្រះអង្គនៅក្នុងព្រៃតែម្នាក់ឯង ដូចម្តេចកើត ។

[៣៩២] (ព្រះបាទពោរិសាទ...) ព្រះចន្ទក្នុងកាឡបក្ខ (រនោច) រមែងសាបសូន្យទៅរាល់ៗថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការ សមាគមនឹងពួកអសប្បុរស រមែងវិនាសទៅដូចព្រះចន្ទ្រ ក្នុងកាឡបក្ខ ។ ដូចជាខ្ញុំ ព្រោះអាស្រ័យរសកៈអ្នកស្ងោរដណ្តាំ ជាបុរសអាក្រក់ លាមក ហើយបានធ្វើនូវបាបកម្មអាក្រក់ ជាហេតុទៅកាន់ទុគ្គតិ ។

សុក្កបក្ខេ យថា ចន្ទោ វឌ្ឍតេវ សុវេ សុវេ
សុក្កបក្ខូបមោ រាជ សតំ ហោតិ សមាគមោ ។
យថាហំ តុម្ហមាគម្ម សុតសោម វិជានហិ
ករោមិ កុសលំ កម្មំ យេន គច្ឆាមិ សុគ្គតឹ ។

ថលេ យថា វារិ ជនិន្ទ វុដ្ឋំ
អនទ្ធនេយ្យំ ន ចិរដ្ឋិតីកំ
ឯវម្បិ មេ ហោតិ អសតំ សមាគមោ
អនទ្ធនេយ្យោ ឧទកំ ថលេវ ។
សរេ យថា វារិ ជនិន្ទ វុដ្ឋំ
ចិរដ្ឋិតីកំ នរវីរសេដ្ឋ
ឯវម្បិ មេ ហោតិ សតំ សមាគមោ
ចិរដ្ឋិតីកោ ឧទកំ សរេវ ។
អព្យាយិកោ ហោតិ សតំ សមាគមោ
យាវម្បិ តិដ្ឋេយ្យ តថេវ ហោតិ
ខិប្បំ ហិ វេតិ អសតំ សមាគមោ
តស្មា សតំ ធម្មោ អសព្ភិ អារកា ។



ព្រះចន្ទ្រក្នុងសុក្កបក្ខ រមែងចំរើនរៀងរាល់ៗថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការជួបប្រទះនឹងពួកសប្បុរស ទុកមាដូចជាព្រះចន្ទ្រក្នុងសុក្កបក្ខ ។ បពិត្រព្រះបាទសុតសោម សូមព្រះអង្គជ្រាបចុះ ដូចយ៉ាងខ្ញុំ អាស្រ័យព្រះអង្គ ហើយធ្វើការកុសល ជាហេតុទៅកាន់សុគតិ ។

បពិត្រព្រះអង្គជាធំជាងជន ទឹកដែលបង្អុរចុះលើទីទួល មិនស្ថិតនៅ មិនឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកអសប្បុរសរបស់ខ្ញុំ មិនតាំងនៅអស់កាលយូរ ដូចទឹកលើទីទួលយ៉ាងនោះដែរ ។ បពិត្រព្រះអង្គជាធំជាងជន ជាអ្នកក្លាហានប្រសើរជាងជន ទឹកដែលបង្អុរចុះក្នុងស្រះ ឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកសប្បុរសរបស់ខ្ញុំ ឋិតនៅអស់កាលយូរ ដូចទឹកក្នុងស្រះ យ៉ាងនោះដែរ ។ សមាគមនឹងពួកសប្បុរស រមែងមិនឃ្លាតចេញទេ គប្បីឋិតនៅដរាបអស់ជីវិត ការសមាគមនឹងពួកអសប្បុរស រមែងវិនាសទៅឆាប់ ដោយប្រការដូច្នេះឯង ព្រោះហេតុនោះ ធម៌របស់ពួកសប្បុរស រមែងឆ្ងាយអំពីពួកអសប្បុរស ។

(៣៨៣) ន សោ រាជា យោ អជេយ្យំ ជិនាតិ
ន សោ សខា យោ សខារំ ជិនាតិ
ន សា ភរិយា យា បតិនោ ន វិភេតិ
ន តេ បុត្តា យេ ន ភរន្តិ ជិណ្ណំ ។
ន សា សភា យត្ថ ន សន្តិ សន្តោ
ន តេ សន្តោ យេ ន ភណន្តិ ធម្មំ
រាគញ្ច ទោសញ្ច បហាយ មោហំ
ធម្មំ ភណន្តាវ ភវន្តិ សន្តោ ។
នាភាសមានំ ជានន្តិ មិស្សំ ពាលេហិ បណ្ឌិតំ
ភាសមានញ្ច ជានន្តិ ទេសេន្តំ អមតំ បទំ ។
ភាសយេ ជោតយេ ធម្មំ បគ្គណ្ហេ ឥសិនំ ធជំ
សុភាសិតទ្ធជា ឥសយោ ធម្មោ ហិ ឥសិនំ ធជោ ។

សុតសោមជាតកំ បញ្ចមំ ។



(៣៨៣) (ព្រះបាទសុតសោម...) ព្រះរាជាណា ផ្ចាញ់នូវបុគ្គលមិនគួរផ្ចាញ់ (មាតាបិតា) ព្រះរាជានោះ មិនមែនជាព្រះរាជាទេ សំឡាញ់ណា ផ្ចាញ់នូវសំឡាញ់ សំឡាញ់នោះ មិនមែនជាសំឡាញ់ទេ ភរិយាណា មិនខ្លាចប្តី ភរិយានោះមិនមែនជាភរិយាទេ ពួកបុត្រណា មិនចិញ្ចឹមមាតាបិតា ជាបុគ្គលចាស់ទុំ ពួកបុត្រនោះ មិនមែនជាកូនទេ ។ ពួកសប្បុរសមិនមានក្នុងទីប្រជុំណា ទីនោះ មិនមែនទីប្រជុំទេ ពួកជនណា មិនពោលនូវធម៌ ពួកជននោះ មិនមែនជាសប្បុរសទេ លុះតែពួកជន លះបង់នូវរាគៈ ទោសៈ និងមោហៈ ហើយពោលនូវធម៌ ទើបឈ្មោះថា សប្បុរស ។

បណ្ឌិតកាលបើមិនពោល (នូវធម៌) ជាអ្នកច្រឡូកច្រឡំ ដោយពួកជនពាល ពួកអ្នកដទៃរមែងស្គាល់មិនបាន លុះតែពោលសំដែងនូវអមតបទ ទើបពួកអ្នកដទៃស្គាល់បាន ។ បណ្ឌិតគប្បីពោលបំភ្លឺនូវធម៌ ផ្គងឡើងនូវធម៌ ជាទង់ជ័យនៃពួកឥសី ពួកឥសីមានសុភាសិតជាទង់ជ័យ ព្រោះថាធម៌ទុកដូចជាទង់ជ័យនៃពួកឥសី ។

ចប់ សុតសោមជាតក ទី ៥ ។

## តស្សុទ្ទានំ

សុមុខោ បន ហំសវរោ ច មហា
សុធភោជនិកោ ច បរោ បវរោ
សកុណាលទិជាធិបតិវ្ហយនោ
សុតសោមវរុត្តមសវ្ហយនោ ។

អសីតិនិបាតំ និដ្ឋិតំ ។



## ឧទ្ទាននៃជាតកនោះគឺ

ចុល្លហង្សឈ្មោះសុមុខៈ ១ មហាហង្សដ៏ប្រសើរ ១ តាបសឲ្យនូវសុធាភោជនដ៏ប្រសើរដទៃ ១ ស្តេចបក្សីឈ្មោះកុណាល ១ ព្រះរាជាដ៏ប្រសើរព្រះនាមសុតសោម ១ ។

ចប់ អសីតិនិបាត ។